សាកលវិទ្យាល័យភូមិន្ទកសិកម្ម
មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ

# ការគ្រប់គ្រងធនាគារ និង ស្ថាប័នហិរញ្ញវត្ថុ

# Bank Management and Financial Institution

សាស្ត្រាចារ្យរង បណ្ឌិត ឆាយ គន្ធា
ជា សុភៈមករា

ឧបត្ថម្ភដោយ

២០២១

សាកលវិទ្យាល័យភូមិន្ទកសិកម្ម
មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ

# ការគ្រប់គ្រងធនាគារ និង ស្ថាប័នហិរញ្ញវត្ថុ
## Bank Management and Financial Institution

សាស្ត្រាចារ្យរង បណ្ឌិត ឆាយ គន្ធា
ជា សុភ:មករា

២០២១

# រក្សាសិទ្ធ

© ឆ្នាំ២០២១

**រក្សាសិទ្ធគ្រប់យ៉ាង**

គ្មានផ្នែកណាមួយនៃសៀវភៅនេះ អាចត្រូវបានថតចម្លង និងផលិតឡើងវិញ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នកនិពន្ធ និងសាកលវិទ្យាល័យភូមិន្ទកសិកម្មឡើយ។

បោះពុម្ពលើកទី១ ដោយមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍( ស.គ.ន )នៃក្រសួងអប់រំ យុវជន និងកីឡា នៅព្រះរាជាណាចក្រកម្ពុជា។

**ទំនាក់ទំនងព័ត៌មាន:**

អ្នកនិពន្ធ៖ សាស្ត្រាចារ្យរង បណ្ឌិត **ឆាយ គង្គា** និង **ជា សុភ:មករា**

ទូរស័ព្ទ៖ (+៨៥៥) ១២ ៦៨៤ ៨២៨ / ៩៨ ៦៨៤ ៨២៨

អ៊ីមែល៖ chhaykongkea@gmail.com

© 2021 by Assoc. Prof. CHHAY Kongkea, Ph.D. and Chea Sopheakmakara, All rights reserved. No part of this publication may be reproduced, stored in a retrieval system, or transmitted by any process without the prior written permission from the author and the Royal University of Agriculture.

First Edition

Printed by the Research Creativity and Innovation Fund (RCI Fund) of Ministry of Education, Youth and Sports, Kingdom of Cambodia

Enquiries about the book:
Author: Assoc. Prof. CHHAY Kongkea, Ph.D.  and Chea Sopheakmakara
Mobile phone: (+855) 12 684 828 / 98 684 828
Email: chhaykongkea@gmail.com

# បុព្វកថា

ដំណើរអភិវឌ្ឍនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងយុគសម័យទំនើបនេះ ជាមេរៀនដ៏ជោគជ័យបំផុតមួយ ដែលចាប់ឫសគល់ចេញពីការបញ្ចប់របបប្រល័យពូជសាសន៍ ការបញ្ចប់សង្គ្រាម ការផ្សះផ្សាជាតិ ការកសាងមូលដ្ឋានរឹងមាំនៃសន្តិភាពនិងស្ថេរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច។ នៅក្រោយពេលដែលសន្តិភាពត្រូវបានកើតឡើងដោយបរិបូរណ៍នៅឆ្នាំ១៩៩៨ កម្ពុជាទទួលកំណើនសេដ្ឋកិច្ចខ្ពស់ គឺប្រមាណ៨% ក្នុងមួយឆ្នាំ។ លើសពីនេះទៀត អត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយពីប្រមាណ៥៣% នៅឆ្នាំ២០០៤ មកនៅទាបជាង១០% នៅឆ្នាំ២០១៩។ ដំណើរនៃការអភិវឌ្ឍជាតិជាសកម្មភាពដែលបន្តទៅមុខជាប់ជានិច្ច ហើយគោលនយោបាយថ្មីៗដែលមានលក្ខណៈអន្តរវិស័យគ្របដណ្តប់ក៏កំពុងលេចរូបរាងឡើងដើម្បីតម្រង់ទិសកម្ពុជាឆ្ពោះទៅកាន់ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឈានឡើងជាប្រទេសមានប្រាក់ចំណូលខ្ពស់ នៅឆ្នាំ២០៥០។ ការប្រែប្រួលឆាប់រហ័សនៃនិម្មាបនកម្មពិភពលោកនិងតំបន់ រួមទាំងទំនាក់ទំនងភូមិសាស្ត្រនយោបាយ បានផ្តល់កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា ដែលត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងបន្តពង្រឹងនិងអភិវឌ្ឍវិស័យអប់រំឆ្ពោះទៅរកការស្រាវជ្រាវនិងនវានុវត្តន៍ ដើម្បីពង្រឹងសមត្ថភាពនិងជំនាញរបស់ធនធានមនុស្សនៅកម្ពុជា ឱ្យស្របទៅនឹងបរិបទថ្មីនៃការអភិវឌ្ឍ ជាពិសេសការពង្រឹងសហគ្រិនភាពក្នុងការរៀបចំម៉ូដែលធុរកិច្ចថ្មីៗ។ ដើម្បីចាប់យកកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្មទី៤ និងសេដ្ឋកិច្ចឌីជីថលដែលកំពុងផុសផុលឡើង ប្រព័ន្ធអេកូឡូហ្ស៊ីដែលបង្កលក្ខណៈអំណោយផលដល់ការបង្កើតថ្មី នវានុវត្តន៍ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ត្រូវតែមានការកែលម្អ។

បណ្តាប្រទេសនៅទ្វីបអាស៊ីកំពុងនាំមុខក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ដោយមានភាគហ៊ុនប្រមាណ៤៤% នៃការវិនិយោគទាំងមូលរបស់ពិភពលោក។ ប្រទេសចិនកំពុងបន្តកសាងហេដ្ឋារចនាសម្ព័ន្ធនៃការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ក៏ដូចជាសមត្ថភាពមនុស្ស។ ផ្ទុយទៅវិញ ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក កំពុងស្ថិតនៅឆ្ងាយពីការវិនិយោគនេះ ហើយជាលទ្ធផលប្រទេសទាំងនោះក៏ពុំមានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ដែរ។ ទុនវិនិយោគសរុបលើការស្រាវជ្រាវនិងអភិវឌ្ឍរបស់ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក មានប្រមាណ៥%នៃការវិនិយោគទាំងមូលរបស់ពិភពលោក ក្នុងពេលដែលតំបន់ទាំង២នេះមានប្រជាជនប្រមាណ២០%នៃប្រជាជនពិភពលោក។ ប្រទេសចំនួន៦ដែលមានលំដាប់ខ្ពស់ជាងគេនៅក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ រួមមាន សហរដ្ឋអាមេរិក ចិន ជប៉ុន អាល្លឺម៉ង់ ឥណ្ឌា និងកូរ៉េខាងត្បូង ដែលស្មើនឹងប្រមាណ៧០%នៃទុនវិនិយោគសរុបរបស់ពិភពលោក។

តើចំណេះដឹង ផលិតផល និងសេវាកម្មថ្មីទាំងនេះកើតឡើងពីអ្វី? ហើយកើតឡើងដោយរបៀបណា? ព្រះរាជាណាចក្រកម្ពុជាកំពុងតែកសាងមូលដ្ឋានសម្រាប់ការត្រៀមខ្លួនទទួល និងប្រកួតប្រជែងក្នុងយុគសម័យបដិវត្តឧស្សាហកម្មទី៤ នៅក្នុងសេដ្ឋកិច្ចដែលផ្អែកលើពុទ្ធិ ហើយដែលប្រការនេះ

ចាំបាច់តម្រូវឱ្យពលរដ្ឋកម្ពុជា ត្រូវក្លាយខ្លួនជាពលរដ្ឋឌីជីថល ពលរដ្ឋសកល និងពលរដ្ឋដែលប្រកបដោយការទទួលខុសត្រូវ ដែលមានសមត្ថភាពក្នុងការផលិត ចែកចាយ និងប្រើប្រាស់ពុទ្ធិដើម្បីទទួលមនុញ្ញផល និងរួមចំណែកក្នុងកំណើន។ ធនាគារពិភពលោកបានធ្វើការកត់សម្គាល់តាំងពីឆ្នាំ ២០០២នូវបម្លាស់ប្តូរនៃមូលដ្ឋានសេដ្ឋកិច្ច ពីសេដ្ឋកិច្ចដែលពឹងផ្អែកលើកម្លាំងពលកម្ម និងធនធានអតិកម្ម (Labour and Resource Based Economy) ទៅកាន់សេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិ (Knowledge Based-Economy) ដែលក្នុងន័យនេះ ពុទ្ធិគឺជាគន្លឹះនៃការអភិវឌ្ឍ។ អាស្រ័យហេតុនេះ នៅលើគន្លងដែលកម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅកាន់សេដ្ឋកិច្ចឌីជីថល សង្គមកម្ពុជាត្រូវតែមានសមត្ថភាពក្នុងការផលិត ជ្រើសរើស បន្សាំ បង្កើតមុខរបរ និងប្រើប្រាស់ពុទ្ធិ ដើម្បីរក្សានិរន្តរភាពនៃកំណើន និងកែលម្អជីវភាពរស់នៅ។ សមត្ថភាពទាំងនេះ អាចកើតឡើងនៅពេលពលរដ្ឋកម្ពុជាមានឱកាសក្នុងការទទួលបានបទពិសោធន៍ពីការស្រាវជ្រាវ ការបណ្តុះគំនិតច្នៃប្រឌិត និងការស្វែងរកនវានុវត្តន៍។

កំណែទម្រង់វិស័យអប់រំ គឺជាការត្រួសត្រាយមាគ៌ាសម្រាប់ដំណើរឆ្ពោះទៅកាន់សង្គមប្រកបដោយពុទ្ធិ និងប្រជាពលរដ្ឋប្រកបដោយភាពរស់រវើក។ តាមរយៈមូលដ្ឋានអប់រំ សង្គមប្រកបដោយពុទ្ធិនឹងប្រមូលផ្តុំ បង្កើត និងចែករំលែក ទៅកាន់សមាជិកក្នុងសង្គមនូវសម្បទាអប់រំ ពិសេសគឺពុទ្ធិសម្បទាក្នុងបុព្វហេតុនៃមនុស្សជាតិនិងឧត្តមប្រយោជន៍នៃប្រទេស។ សង្គមប្រកបដោយពុទ្ធិ គឺពុំគ្រាន់តែជាសង្គមដែលសម្បូរព័ត៌មានប៉ុណ្ណោះទេ តែជាសង្គមដែលប្រជាពលរដ្ឋអាចធ្វើបរិវត្តកម្មពីព័ត៌មានទៅជាមូលធនប្រកបដោយប្រសិទ្ធភាព។ ការរីកចម្រើនទៅមុខជាលំដាប់នៃបច្ចេកវិទ្យានិងតំណភ្ជាប់ បានពង្រីកព្រំដែននៃការចូលទៅកាន់ និងការទទួលបានព័ត៌មានជាសកល ហើយដែលក្នុងន័យនេះ ការអប់រំនឹងបន្តវិវត្តទៅមុខនិងមានការផ្លាស់ប្តូរ។ សង្គមមួយដែលមានអំណាន និងរបាប់ជាបុរេលក្ខខណ្ឌនៃជីវភាពប្រចាំថ្ងៃនៃប្រជាពលរដ្ឋ ពេលនោះបំណិននៃអំណាន និពន្ធ និងការគណនាលេខនព្វន្ត គឺជាចលករនៃការរៀនរបស់សិស្ស។ ធាតុដ៏ចម្បងមួយដែលស្ថិតនៅក្នុងការកសាងសង្គមដែលប្រកបដោយពុទ្ធិគឺសៀវភៅសិក្សា ហើយការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សាជាប្រចាំ គឺជានវានុវត្តន៍នៃវិស័យអប់រំដែលនាំទៅរកការសិក្សាពេញមួយជីវិត ការអភិវឌ្ឍសម្បទាអប់រំ និងការចែករំលែកចំណេះដឹង។ មូលដ្ឋានអប់រំ ជាពិសេសគឺគ្រឹះស្ថានឧត្តមសិក្សាត្រូវមានតួនាទីដែលប្រកបដោយការឆ្លើយតប ចំពោះតម្រូវការខាងលើនេះ។ សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំត្រូវបន្តសិក្សាជាប់ជានិច្ច តាមរយៈការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ហើយដែលសៀវភៅសិក្សាទាំងនេះនឹងក្លាយជាស្ពាននៃទំនាក់ទំនងរវាងនវានុវត្តន៍នៃបច្ចេកវិទ្យា និងការរៀននិងបង្រៀននៅក្នុងថ្នាក់រៀន។

សង្គមដែលប្រកបពុទ្ធិ ក៏ជាសង្គមដែលបណ្តុះឱ្យមានរចនាសម្ព័ន្ធទន់នៃសេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិដែរ។ ឧទាហរណ៍ជាក់ស្តែងនៃបែបផែននេះរួមមាន Silicon Valley នៃសហរដ្ឋអាមេរិក សួនឧស្សាហកម្មវិស្វកម្មអាកាសយានយន្តនិងយានយន្តនៅទីក្រុង Munich ប្រទេសអាល្លឺម៉ង់ តំបន់ជីវបច្ចេកវិទ្យានៅក្រុង Hyderabad ប្រទេសឥណ្ឌា តំបន់ផលិតគ្រឿងអេឡិចត្រូនិកនិងសារគមនាគមន៍ឌីជីថលនៅទីក្រុង Seoul ប្រទេសកូរេខាងត្បូង ក៏ដូចជាសួនឧស្សាហកម្មថាមពល និងឥន្ទនគីមីសាស្ត្រនៃប្រទេសប្រេស៊ីល ហើយក៏នៅមានទីក្រុងនៃប្រទេសជាច្រើនទៀតនៅលើពិភពលោក។ លក្ខណៈសម្បត្តិ

នៃទីក្រុងទាំងនេះគឺការប្រើប្រាស់និន្នាការនៃការអភិវឌ្ឍដែលជំរុញ និងតម្រង់ទិសដោយចំណេះដឹង ហើយដែលចំណេះដឹងទាំងនោះកើតចេញជាដំបូងពីការវិនិយោគទៅលើគ្រឹះស្ថានឧត្តមសិក្សា ស្ថាប័នស្រាវជ្រាវ មជ្ឈមណ្ឌលឧត្តមភាពនៃជំនាញជាន់ខ្ពស់ ការប្រកួតប្រជែងដោយគុណាធិបតេយ្យ និងជាពិសេសគឺការបណ្តុះវប្បធម៌អំណាននិងនិពន្ធសៀវភៅ។ ល្បឿននៃការរីកចម្រើនផ្នែកពុទ្ធិ និងបច្ចេកវិទ្យាកំពុងមានសន្ទុះលឿនជាងអ្វីដែលសិស្ស និងនិស្សិតអាចទទួលបានពីគ្រូនៅគ្រឹះស្ថានសិក្សា ដែលធ្វើឱ្យគោលដៅនៃការអប់រំនៅពេលបច្ចុប្បន្ននេះ មានការប្រឈមខ្លាំងជាងពេលណាទាំងអស់។ ឧទាហរណ៍ក្នុងមួយឆ្នាំ មានសៀវភៅជាង២,២លានចំណងជើង ត្រូវបានសរសេរនិងបោះពុម្ព ដែលក្នុងនោះប្រទេសចិនមាន៤៤០ពាន់ ចំណែកឯសហរដ្ឋអាមេរិកមាន៣០៥ពាន់ និងប្រទេសរុស្ស៊ីមាន១២០ពាន់ចំណងជើង។

ខណៈពេលដែលបច្ចេកវិទ្យាកំពុងរីកចម្រើនជារៀងរាល់ថ្ងៃ មធ្យោបាយសម្រាប់អំណានក៏មានច្រើនជម្រើសសម្រាប់សិស្ស-និស្សិត និងសាធារណៈជន រួមមានការអានសៀវភៅ ការអានលើឧបករណ៍អេឡិចត្រូនិក ការអានដោយប្រើទូរសព្ទវៃឆ្លាត និងការអានលើកុំព្យូទ័រ ដែលសុទ្ធសឹងជាមធ្យោបាយសំខាន់ៗដែលនាំអ្នកអានទាំងឡាយឱ្យសម្រេចគោលបំណងអានរបស់ខ្លួន។ ម្យ៉ាងវិញទៀត អំណានដោយប្រើមធ្យោបាយបច្ចេកវិទ្យាទំនើប ចំណាយពេលតិច ងាយស្រួលអាន និងជួយដល់បរិស្ថានមួយកម្រិតទៀត។ នាពេលបច្ចុប្បន្ន សិស្ស-និស្សិត និងសាធារណៈជនកម្ពុជាដែលស្រឡាញ់អំណានកំពុងតែប្រើប្រាស់មធ្យោបាយអំណានទាំងនេះ។ បើយើងក្រឡេកមើលទៅប្រទេសជឿនលឿន ទោះបីជាបច្ចេកវិទ្យារីកចម្រើនខ្លាំងយ៉ាងណា អំណានតាមរយៈសៀវភៅនៅតែមានសន្ទុះដដែល។ ម្យ៉ាងវិញទៀតបច្ចេកវិទ្យាអានបែបទំនើបតាមរយៈឧបករណ៍ទំនើប អាស្រ័យលើលទ្ធភាពនៃធនធានអប់រំឌីជីថល និងមាតិកាឌីជីថលគ្រប់គ្រាន់ដែលបានផលិត និងបង្ហោះចែកចាយសម្រាប់អំណាន។

ក្នុងបរិបទកម្ពុជា ជាពិសេសក្នុងបរិការណ៍នៃការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឱ្យមានបរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្តែមនៃការអប់រំ ជាពិសេសការអប់រំតាមប្រព័ន្ធអេឡិចត្រូនិកនិងការអប់រំពីចម្ងាយ ដើម្បីលើកកម្ពស់អំណាន តាមរយៈការផលិតមាតិកាឌីជីថលដែលមានភាពចំរុះ ការកសាងសមត្ថភាពផ្នែកតំណភ្ជាប់និងវេទិកាឌីជីថល ការពង្រីកវិសាលភាពនៃមជ្ឈមណ្ឌលទិន្នន័យ និងការលើកកម្ពស់គុណភាពនៃការផលិតធនធានអប់រំឌីជីថល គួបផ្សំជាមួយការចែកសន្លឹកកិច្ចការឱ្យសិស្សយកទៅរៀននៅផ្ទះ និងការចុះទៅជួបជាមួយសិស្សជាបណ្តុំនៅតាមសហគមន៍។ ក្នុងន័យលើកកម្ពស់អំណាន និងភាពសម្បូរបែបនៃធនធានសៀវភៅសិក្សា ឱ្យកាន់តែមានប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិ និងផ្តល់ឱកាសអំណានកាន់តែច្រើនថែមទៀតដល់សិស្សានុសិស្ស និស្សិត និងសាធារណៈជន ក្រសួងអប់រំ យុវជន និងកីឡាលើកទឹកចិត្តនូវចំណុចមួយចំនួនដូចខាងក្រោម៖

១. សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំ សូមបន្តនិងបង្កើនការបោះពុម្ពស្នាដៃបន្ថែមទៀត ដើម្បីធ្វើឱ្យធនធានសម្រាប់អំណានកាន់តែសម្បូរបែប ជាពិសេសធនធានអំណានជាខេមរភាសា

២. គ្រឹះស្ថានឧត្តមសិក្សា សូមផ្ដល់លទ្ធភាពគ្រប់បែបយ៉ាង ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និងនិស្សិតគ្រប់កម្រិតសិក្សាអាចចូលរួមអាន និងសិក្សាស្រាវជ្រាវតាមគ្រប់លទ្ធភាពជាមួយធនធានអំណាន ជាពិសេសការរៀបចំឱ្យមានពេលវេលាសម្រាប់សហសិក្សា និងអំណានក្នុងបណ្ណាល័យ

៣. សាស្ត្រាចារ្យតាមមុខវិជ្ជា និងអ្នកស្រាវជ្រាវតាមជំនាញឬវិស័យ ត្រូវរៀបចំដំណើរការរៀនបង្រៀន និងស្រាវជ្រាវដែលមានដាក់បញ្ចូលកិច្ចការស្វ័យសិក្សា សហសិក្សា ឬការស្រាវជ្រាវបណ្ណាល័យដែលតម្រូវឱ្យនិស្សិត ត្រូវអាននិងស្រាវជ្រាវជាមួយធនធានអំណាន

៤. គ្រឹះស្ថានឧត្តមសិក្សា និងមជ្ឈមណ្ឌលស្រាវជ្រាវ ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបង្កើតបណ្ណាល័យ មជ្ឈមណ្ឌលរក្សាឯកសារ ឬមជ្ឈមណ្ឌលអប់រំឌីជីថលជាដើម ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់និងនិស្សិតគ្រប់កម្រិតសិក្សាអាចទទួលបាន និងស្វែងរកប្រភពសម្រាប់អំណានកាន់តែសម្បូរបែប និងមានភាពបត់បែន ឆ្លើយតបតាមតម្រូវការអ្នកអាន

៥. និស្សិតគ្រប់កម្រិតសិក្សាត្រូវខិតខំនិងចំណាយពេលវេលាដើម្បីអាន និងចាត់ទុកវប្បធម៌និងអកប្បកិរិយាអំណានជាផ្នែកមួយ នៃពេលវេលានិងភាពស៊ីវិល័យនៃជីវិតប្រចាំថ្ងៃ

៦. បងប្អូនជនរួមជាតិ ដែលជាមាតាបិតា ឬអ្នកអាណាព្យាបាល សូមជួយជំរុញនិងបង្កលក្ខណៈកាន់តែច្រើនថែមទៀត ជាពិសេសការលែលកចំណាយនៅក្នុងគ្រួសារសម្រាប់ការទិញសម្ភារៈសិក្សា សៀវភៅអាន និងឧបករណ៍សម្រាប់អំណានដល់កូនៗ ដែលចាត់ទុកជាការវិនិយោគមួយដ៏សំខាន់ សម្រាប់ បង្កើនចំណេះដឹង និងអនាគតរបស់ពួកគេ។

ដោយមានការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលហៅកាត់ថា "មូលនិធិ ស.គ.ន." និងហៅជាភាសាអង់គ្លេសថា The Research Creativity and Innovation Fund ដែលហៅកាត់ជាភាសាអង់គ្លេសថា "RCI Fund"។ គោលដៅចម្បងនៃមូលនិធិនេះ គឺរួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងសាកលភាវូបនីយកម្ម។ មូលនិធិ ស.គ.ន. បានសម្រេចកំណត់ប្រធានបទ ជាអាទិភាពសម្រាប់ការគាំទ្រដោយមូលនិធិចំនួន៣ រួមមានឌីជីថលនីយកម្មសម្រាប់បដិវត្តឧស្សាហកម្ម៤.០ (Digitalization for IR.4.0) ការស្រាវជ្រាវអនុវត្តលើវិស័យកសិកម្ម (Applied Agricultural Research) និងការស្រាវជ្រាវគរុកោសល្យសតវត្សទី២១ (21st Century Pedagogy Research)។

ដោយមានការធ្វើអាទិភាពវូបនីយកម្មទៅលើទិសដៅ នៃការប្រើប្រាស់ថវិកាមូលនិធិសម្រាប់ឆ្នាំ ២០២០ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ការគាំទ្រដល់ការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សា (Text book) ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។ គោលបំណងនៃការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា គឺដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូនដល់និស្សិត

ដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ លើសពីនេះទៀត ការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា មានគោលដៅដូចខាងក្រោម ៖

១. ឆ្លើយតបជាបន្ទាន់ចំពោះការខ្វះខាតធនធានសិក្សា ដែលជាតម្រូវការសិក្សារបស់និស្សិតនៅកម្រិតឧត្តមសិក្សា

២. លើកកម្ពស់ទំនើបភាវូបនីយកម្ម និងឧត្តមានុវត្តន៍នៃការរៀននិងបង្រៀន និងការស្រាវជ្រាវនៅលើមុខវិជ្ជា កម្មវិធីសិក្សា ឬមុខជំនាញជាក់លាក់

៣. បង្កើនភាពស៊ីជម្រៅក្នុងការកសាងវិជ្ជាជីវៈនិងបទពិសោធន៍សម្រាប់បាឋកថិកា/សាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ

៤. រួមចំណែកដល់ការកសាងភាពជាសហគមន៍វិជ្ជាជីវៈ ការចែករំលែកបទពិសោធន៍ និងវប្បធម៌នៃការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា បានវាយតម្លៃខ្ពស់ចំពោះការបោះជំហានប្រកបដោយមនសិការវិជ្ជាជីវៈនៃគ្រឹះស្ថានឧត្តមសិក្សា និងបុគ្គលិកអប់រំទាំងអស់ ក្នុងការរៀបចំ រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រឹងសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូននិស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សាជាផ្នែកមួយនៃការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានឧត្តមសិក្សា និងជាធនធានសិក្សាដែលជាមូលដ្ឋានមួយដ៏សំខាន់ ក្នុងការគាំទ្រដល់ការបង្រៀន និងរៀន ហើយត្រូវមានបរិមាណគ្រប់គ្រាន់ ឆ្លើយតបទៅនឹងកម្មវិធីអប់រំ និងតម្រូវការសិក្សាស្រាវជ្រាវ។ ជាគោលការណ៍ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ត្រូវមានសៀវភៅសិក្សាដែលប្រើជាគោលសម្រាប់មុខវិជ្ជានីមួយៗ។ ចំនួនសៀវភៅសិក្សាដែលគ្រប់គ្រាន់សម្រាប់ការស្រាវជ្រាវ និងការសិក្សារបស់និស្សិត ត្រូវមានយ៉ាងតិចមួយចំណងជើងក្នុងមួយមុខវិជ្ជា ហើយត្រូវតម្កល់យ៉ាងតិច២ច្បាប់នៅក្នុងបណ្ណាល័យ ឬអាចរកបានតាមប្រព័ន្ធអេឡិចត្រូនិក។ ក្រសួងអប់រំ យុវជន និងកីឡា លើកទឹកចិត្តបន្ថែមទៀតជូនដល់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលបានស្នើសុំថវិកាមូលនិធិ ស.គ.ន រួច សូមចូលរួមបន្ថែមទៀតដើម្បីបង្កើនចំនួនចំណងជើងសៀវភៅ។ ចំណែកគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលពុំទាន់បានដាក់ពាក្យស្នើសុំថវិកាមូលនិធិ ដើម្បីរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា សូមរួសរាន់ចូលរួមដើម្បីជាគុណប្រយោជន៍ដល់តម្រូវការដ៏ទទូចនិងថ្លៃថ្លានៃនិស្សិតកម្ពុជាក្នុងការសិក្សា និងស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។

# សេចក្តីបញ្ជាក់
# នៃមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

សៀវភៅសិក្សានេះជាលទ្ធផលនៃការស្នើសុំអនុវត្តថវិកាមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងគម្រោងរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សានេះ ត្រូវបានរៀបរៀង និពន្ធ ឬកែលម្អដោយមានការធានាអះអាងថាជាស្នាដៃរបស់អ្នកនិពន្ធផ្ទាល់ និងបានឆ្លងកាត់ត្រួតពិនិត្យ ផ្តល់យោបល់ និងវាយតម្លៃដោយក្រុមប្រឹក្សាអប់រំ ក្រុមប្រឹក្សាស្រាវជ្រាវ ឬក្រុមប្រឹក្សាដែលមានតម្លៃស្មើនៃគ្រឹះស្ថានឧត្តមសិក្សា និងតាមរយៈកិច្ចសន្យាដែលបានធ្វើឡើង និងដែលបានតម្កល់ទុកនៅមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍។ រាល់ខ្លឹមសារ ការបកស្រាយ ឬរូបភាព ដែលមាននៅក្នុងសៀវភៅនេះ គឺជាជំហរនិងទស្សនៈផ្ទាល់របស់អ្នកនិពន្ធ ហើយពុំឆ្លុះបញ្ចាំង ឬជាតំណាងដល់មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំ យុវជន និងកីឡាឡើយ។

# សេចក្តីថ្លែងអំណរគុណ

សៀវភៅ "**ការគ្រប់គ្រងធនាគារ និងស្ថាប័នហិរញ្ញវត្ថុ**" នេះអាចប្រសូត្រចេញបានក៏ដោយសារមានការចូលរួមនិង ការផ្តល់វិភាគទានយ៉ាងធំធេងពីបណ្តាអ្នកវិទ្យាសាស្ត្រ និងឥស្សរជនដែលមានបទពិសោធន៍នៅក្នុងផ្នែកស្រាវជ្រាវកសិកម្មជាច្រើនរូប។

ខ្ញុំសូមថ្លែងអំណរគុណជាអនេកប្បការដល់ការពិនិត្យ ជួយកែលម្អ អក្ខរាវិរុទ្ធ ឃ្លាប្រយោគ ខ្លឹមសារអត្ថបទ លះបង់ពេលវេលាដ៏មានតម្លៃមិនខ្លាចនឿយហត់ និងផ្តល់ជាមតិល្អៗក្នុងការរៀបចំសៀវភៅនេះដល់៖

- ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ង៉ោ ប៊ុនថាន** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ក៏ដូចជាអង្គភាពសាមីុ(សាកលវិទ្យាល័យភូមិន្ទកសិកម្ម)
- ឯកឧត្តមបណ្ឌិត **សាន វឌ្ឍនា** អនុរដ្ឋលេខាធិការនៃក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍
- សាស្ត្រាចារ្យរងបណ្ឌិត **ហួន ថាវរៈ** សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម
- លោក **ខង សុជាតិ** នាយករងផ្នែកស្រាវជ្រាវនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម
- គណៈកម្មការត្រួតពិនិត្យមហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ និងគណៈកម្មការត្រួតពិនិត្យសាកលវិទ្យាល័យភូមិន្ទកសិកម្ម ដែលបានជួយជ្រុមជ្រែងក្នុងការស្រាវជ្រាវ
- គណៈកម្មការត្រួតពិនិត្យ៖ លោកបណ្ឌិត សឺន សុទ្ធ លោកបណ្ឌិត ម៉ក់ ពុទ្ធី លោកបណ្ឌិត ឆាំង ហ៊ុយ លោកបណ្ឌិត ហែម ឡាច លោកបណ្ឌិត វង្ស ឌីណា លោក អេង លេង លោកស្រី ហ៊ូ ផល្លា លោកស្រី ឆាយ ស្រីល័ក្ខ និងលោកស្រី ឆាយ ស្រីមុំ
- អ្នកផ្តល់យោបល់នានា ក៏ដូចជាអ្នកផ្តល់ជាឯកសារយោងទាំងភាសាជាតិ និងភាសាបរទេសនានា
- ភរិយា និងកូនស្រីទាំងពីរជាទីស្រឡាញ់របស់ខ្ញុំ ព្រមទាំងមិត្តភក្តិដែលបានជួយជ្រោមជ្រែងទាំងអស់

ខ្ញុំសូមថ្លែងអំណរគុណជាអនេកប្បការដល់៖

- Prof. Dr. Joon-Keun Park, Professor Emeritus, Department of Agricultural Economics, Graduate School, Chonnam National University (CNU), Gwangju City, South Korea.
- លោកស្រី យ៉ែម ម៉ុយហ៊ុង
- កញ្ញា គង្គា សុជាតា និស្សិតឆ្នាំទី៤ ផ្នែកឱសថការីឧត្តម សាលាអន្តរជាតិ មហាវិទ្យាល័យឱសថការីនៃសាកលវិទ្យាល័យជិនណាន សាធារណរដ្ឋប្រជាមានិតចិន (International School, College of Pharmacy, Jinan University, China)។

- កញ្ញា គង្គា សិរីល័ក្ខ សិស្សថ្នាក់ទី៩ នៃសាលារៀនប៊ែលធីអន្តរជាតិ សាខាទី៩ នៃព្រះរាជាណាចក្រកម្ពុជា។

ដែលបានជួយផ្ទៀងផ្ទាត់អក្ខរាវិរុទ្ធ និងឃ្លាប្រយោគ ការវាយអត្ថបទ ការរចនារូបភាព ដ្យាក្រាម និងក្រាភិចមួយចំនួនតាមកម្មវិធីកុំព្យូទ័រសម្រាប់ជាឧទាហរណ៍នៅក្នុងការគណនា និងការវិភាគទិន្នន័យនានានៅក្នុងវិធីសាស្ត្ររៀបចំតាមកម្មវិធីកុំព្យូទ័រនានាដូចជា៖ SPSS, SAS, MiniTab, GAME, ...។ល។

# អារម្ភកថា

សៀវភៅ ការគ្រប់គ្រងធនាគារ និងស្ថាប័នហិរញ្ញវត្ថុ (Bank Management and Financial Institution) គឺជាសៀវភៅមួយដែលសិក្សាផ្ដោតទៅលើវិស័យធនាគារ និងហិរញ្ញវត្ថុ និងយុទ្ធសាស្ត្រនានាក្នុងការគ្រប់គ្រងអាជីវកម្មផ្នែកធនាគារ និងហិរញ្ញវត្ថុ គណនេយ្យធនាគារ និង ម៉ាឃីតធីងធនាគារ ជាដើម។ ការគ្រប់គ្រងធនាគារ និងស្ថាប័នហិរញ្ញវត្ថុគឺជាបណ្ដុំនៃទស្សនាទានធនាគារ ហិរញ្ញវត្ថុ ហានិភ័យនានាក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ មីក្រូសេដ្ឋកិច្ច និងម៉ាក្រូសេដ្ឋកិច្ចផងដែរ។

សៀវភៅនេះមិនមែនមានលក្ខណៈល្អបំផុតលើសសៀវភៅនានាផ្សេងទៀតនោះទេ វាគ្រាន់តែជាឯកសារស្រាវជ្រាវជាភាសាខេមរៈភាសាមួយដែលចូលរួមចំណែកក្នុងការផ្ដល់ចំណេះដឹង និងជួយពង្រឹងគុណភាព សមត្ថភាពដល់និស្សិត បញ្ញវន្ត និងអ្នកសិក្សាស្រាវជ្រាវតែប៉ុណ្ណោះ។

ម្យ៉ាងទៀតសព្វថ្ងៃនេះ បរិមាណបញ្ញាវន្ត គឺកាន់តែកើនឡើងច្រើន បើប្រៀបធៀបទៅនឹងប៉ុន្មានឆ្នាំកន្លងមក ក៏ប៉ុន្តែយើងពុំសូវឃើញមានសៀវភៅសិក្សា សៀវភៅបច្ចេកទេស និងឯកសារស្រាវជ្រាវពីសកម្មភាពធនាគារ និងហិរញ្ញវត្ថុផ្សេងៗឯទៀតជាភាសារខ្មែរឱ្យច្រើនសំបូរនៅឡើយទេ។

ខ្ញុំជឿជាក់ថា អ្នកខ្លះមានចិត្តចង់សសេរដែរ តែកង្វះខាតជីវភាពរស់នៅ និងថវិកា អ្នកចេះដឹង និងបញ្ញវ័ន្តជាច្រើនជាប់រវល់មមាញឹកធ្វើការឱ្យអង្គការឯកជន ក្រុមហ៊ុនអាជីវកម្មនានា អង្គការមនុស្សធម៌ ដើម្បីអ្វី គឺដើម្បីរកប្រាក់មកចិញ្ចឹមគ្រួសាររបស់គេ គេពុំបានយកចិត្តទុកដាក់ក្នុងការចងក្រងជាសៀវភៅ ឯកសារបច្ចេកទេស សម្រាប់ទុកឱ្យក្មេងជំនាន់ក្រោយនៅឡើយ។ បញ្ហាមួយទៀត អ្នកដែលទើបនឹងបញ្ចប់ថ្នាក់ឧត្តម(បរិញ្ញាបត្រ) ភាគច្រើន មានបទពិសោធន៍ផ្នែកបច្ចេកទេស និងចំណេះដឹងផ្នែកភាសាបរទេស ពុំទាន់បានជ្រៅជ្រះនៅឡើយ ដែលជាបញ្ហារមួយពិបាកដល់ការស្រាវជ្រាវរកឯកសារបច្ចេកទេស។

ខ្ញុំបាទដែលជាអ្នករៀបរៀងសៀវភៅនេះនឹងរង់ចាំទទួលនូវការរិះគន់កែលម្អក្នុងន័យស្ថាបនា និងការអភិវឌ្ឍន៍ ដើម្បីធ្វើឱ្យឯកសារនេះកាន់តែមានគុណតម្លៃនិងភាពសុក្រិតថែមទៀត។ ខ្ញុំបាទសូមអភ័យទោសដល់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី បញ្ញវន្ត និស្សិត អ្នកស្រាវជ្រាវ និងប្រជាជនទាំងអស់ ព្រមទាំងមិត្តអ្នកអានទាំងអស់ផងដែរ ប្រសិនបើមានការខុសឆ្គងដោយអចេតនាក្នុងការប្រើឃ្លាប្រយោគ ឬកំហុសអក្ខរាវិរុទ្ធ ដែលកើតមាននៅក្នុងសៀវភៅនេះ។

ជាអវសានសេចក្ដី ខ្ញុំបាទសូមជូនពរ ដល់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាង អ្នកស្រាវជ្រាវ បញ្ញវន្ត និស្សិត និងមិត្តអ្នកអានទាំងអស់សូមជួបតែនឹងពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ

សុខៈ និងពលៈ ព្រមទាំងមានសុភមង្គលល្អប្រពៃទាំងក្នុងជីវិតផ្ទាល់ខ្លួន និងក្នុងជីវិតក្រុមគ្រួសារ ថែមទាំងមានសំណាងល្អ និងទទួលបាននូវសេចក្តីចម្រុងចម្រើនគ្រប់ពេលវេលាជានិច្ច។

ថ្ងៃសុក្រ ០១កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ពស ២៥៦៥.
រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១
**អ្នកនិពន្ធ**

**សាស្ត្រាចារ្យរង បណ្ឌិត ឆាយ គង្គា**
Assoc.Prof.CHHAY Kongkea, Ph.D.

# អំពីអ្នកនិពន្ធ



**នាម និងគោត្តនាម** ៖ សាស្ត្រាចារ្យរង បណ្ឌិត **ឆាយ គង្គា**
(Assoc. Prof. CHHAY Kongkea, Ph.D.)

**អាស័យដ្ឋាន** ៖ ភូមិសំបួរ សង្កាត់ជង្កា ខណ្ឌដង្កោ រាជធានីភ្នំពេញ

**ស្ថាប័នការងារ** ៖ មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ
សាកលវិទ្យាល័យភូមិន្ទកសិកម្ម

**ឯកទេស ឬមុខជំនាញ** ៖ បណ្ឌិតផ្នែក វិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញសេដ្ឋកិច្ចកសិកម្ម

**ប្រវត្តិការសិក្សា៖**

- 2003-2006 Ph.D. Degree in Economics, Major in Agricultural Economics
Chonnam National University, Gwangju City, South Korea.
- 2001–2003 Master's Degree in Economics, Major in Agricultural Economics
Chonnam National University, Gwangju City, South Korea.
- 1993-1998 Bachelor's Degree in Economics, Major in Enterprise Management
Faculty of Law and Economics, Phnom Penh, Cambodia
[Present: Royal university of Law and Economics (RULE) ]
- 1993-1996 Diplôme de Baccalauréat en sciences économiques, Faculté de droit et des sciences économiques, Royaume du Cambodge.
- 1990-1992 Diplima Up-Grading of Psychogical Pedagogy, Major in Mathematics,
Battambang Psychogical Pedagogy School, Battamabng Province.
- 1992-1993 Certificate of Preparatory Class, Institute of Economic Sciences
(Present: National University of Management) , Cambodia.
- 1990-1992 Diplima of Sinor Hight School, Battambang Secondary School, Battambang Province, Kingdom of Cambodia.

**បទពិសោធន៍ការងារ៖**

- 2007 - បច្ចុប្បន្ន៖ព្រឹទ្ធបុរសរង (Vice Dean) មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ព្រះរាជាណាចក្រកម្ពុជា
- 2012 - បច្ចុប្បន្ន៖សាស្ត្រាចារ្យរង (Associate Professor) តាមអនុក្រឹត្យលេខ ៥៤៤ អនក្រ.តក ស្តីពីការតែងតាំងឋានៈជាសាស្ត្រាចារ្យរងជូនមន្ត្រីរាជការ និងគ្រូបង្រៀនថ្នាក់ឧត្តម ក្នុងវិស័យកសិកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា

ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ2012

- 1990 - 1992៖ជាប្រធានគណនេយ្យ នៃការិយាល័យគណនេយ្យ និងហិញ្ញវត្ថុ នៃក្រុមហ៊ុនដានីម៉ិច រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
- 1998 - បច្ចុប្បន្ន៖គ្រូបង្រៀនតាមសាកលវិទ្យាល័យនានា៖ NUM, BBU, NIB, HRU, UME, ...

# អំពីសហអ្នកនិពន្ធ



**នាម និងគោត្តនាម** ៖ជា សុភៈមករា

**អាសយដ្ឋានសព្វថ្ងៃ** ៖ ភូមិជន្លង សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប

**ទីកន្លែងកំណើត** ៖ ភូមិរវៀង ឃុំរវៀង ស្រុករវៀង ខេត្តព្រះវិហារ

**ស្ថាប័នការងារ** ៖ ការិយាល័យកសិ ឧស្សាហកម្ម នៃមន្ទីរកសិកម្ម-រុក្ខាប្រមាញ់ និងនេសាទ ខេត្តសៀមរាប

**ឯកទេស ឬមុខជំនាញ** ៖- បរិញ្ញាប័ត្រជាន់ខ្ពស់វិទ្យាសាស្រ្ត ជំនាញ ការគ្រប់គ្រងកសិធុកិច្ច (Taiwan)
- បរិញ្ញាប័ត្រជាន់ខ្ពស់ វិទ្យាសាស្ត្រ ជំនាញ គីមីជីវវិទ្យា (CNU, Korea)

## ប្រវត្តិការសិក្សា

- 2010-2012 Master's Degree of Science, Major in Agribusiness Management, National Pingtung University of Science and Technology (NPUST) , Pingtung City, Taiwan
- 2005-2007 Master's Degree of Science, Major in Biotechnology, Chonnam National University (CNU) , Gwangju City, South Korea.
- 1993-1997 Bachelor's Degree of Science, Major in Forestry Management, Faculty of Forestry, Royal University of Agriculture (RUA) , Phnom Penh, Cambodia
- 1992-1993 Certificate of Preparatory Class, Faculty of Medicine, Phnom Penh, Cambodia
- 1988-1992 Diploma of High School, KUBA Secondary School, Phnom Penh, Kingdom of Cambodia

## បទពិសោធន៏ការងារ

- 1998-2010 ៖ បម្រើការងារនៅនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- 2010-2013 ៖ បម្រើការងារនៅការិយ៉ាយផែនការ-ស្ថិតិ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តសៀមរាប
- 2013-2021 ៖ បម្រើការងារនៅការិយ៉ាយកសិ-ឧស្សាហកម្ម នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តសៀមរាប

## បទពិសោធន៏បង្រៀនពីឆ្នាំ ២០១២២០២១-

សាកលវិទ្យាល័យបៀលប្រាយ សាខាខេត្តសៀមរាប បាត់ដំបង និងខេត្តតាកែវ -

សាកលវិទ្យាល័យ -CUS សាខាខេត្តសៀមរាប និងកំពង់ធំ
សាកលវិទ្យាល័យអង្គ -រ ខេត្តសៀមរាប។

# មាតិកា

បុព្វកថា និងសេចក្តីបញ្ជាក់នៃមូលនិធិ

**ទំព័រ**

សេចក្តីថ្លែងអំណរគុណ.............................................................i
អារម្ភកថា..........................................................................iii
មាតិកា............................................................................ix

## មេរៀនទី១
## ឧស្សាហកម្មធនាគារ និងឧស្សាហកម្មសេវាកម្មហិរញ្ញវត្ថុ

១.១.មុខងារនៃប្រព័ន្ធហិរញ្ញវត្ថុ.............................................. ១
១.២.ក្រុមហ៊ុនសេវាកម្មហិរញ្ញវត្ថុ និងឧស្សាហកម្មសេវាហិរញ្ញវត្ថុ............. ១
១.៣.ធនាគារ..........................................................................២
១.៤.ប្រភេទនៃធនាគារពាណិជ្ជកម្ម........................................... ៥
១.៥.សេវាកម្មដែលធនាគារបានផ្តល់ឱ្យសាធារណៈជន .........................៧
១.៥.១.តួនាទីធនាគារ ..................................................................៧
១.៥.២.មុខងារនៃប្រាក់បញ្ញើ (Function of deposit) ..............................៧
១.៥.៣.សេវាកម្មដែលធនាគារបានផ្តល់នៅក្នុងប្រវត្តិសាស្រ្ត........................ ៩
១.៥.៤.សេវាកម្មដែលធនាគារផ្តល់ក្នុងពេលបច្ចុប្បន្ន ...............................១០
១.៦.បណ្តានិន្នាការដែលកំពុងជះឥទ្ធិពលទៅលើធនាគារ ....................... ១២

## មេរៀនទី២
## គោលនយោបាយរបស់រដ្ឋាភិបាល និងនិយ័តកម្មលើធនាគារ

២.១.និយ័តកម្មធនាគារ.............................................................១៦
២.១.១.មូលហេតុនៃនិយ័តកម្មទៅលើធនាគារ .......................................១៦
២.១.២.ឥទ្ធិពលនៃនិយ័តកម្មទៅលើធនាគារ ..........................................១៩
២.២.ឥទ្ធិពលរបស់និយ័តកម្មទៅលើប្រតិបត្តិការរបស់ធនាគារ .....................១៩
២.៣.ប្រព័ន្ធធនាគារកណ្តាលៈនិយ័តកម្មរបស់វាទៅលើការសម្រេចចិត្ត និងគោលនយោបាយរបស់ធនាគារនីមួយៗ.............................................................. ២០
២.៣.១. រចនាសម្ព័ន្ធរបស់ Federal Reserve System ............................ ២១
២.៣.២.ការងារចម្បងរបស់ធនាគារកណ្តាលគឺការបង្កើត និងអនុវត្តគោលនយោបាយរូបិយវត្ថុ ..............................................................................២៣

## មេរៀនទី៣.
## របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ

៣.១.តារាងតុល្យការ និងរបាយការណ៍ប្រាក់ចំណេញ ........................................ ២៩
៣.២.តារាងតុល្យការ (របាយការណ៍ស្ថានភាព) ........................................ ២៩
៣.៣.ទ្រព្យរបស់ធនាគារ ........................................ ៣០
៣.៤.បំណុលរបស់ធនាគារ ........................................ ៣៧
៣.៥.ធាតុផ្សំនៃរបាយការណ៍ចំណេញ ........................................ ៣៩

**មេរៀនទី៤**

**វាស់វែង និងវាយតម្លៃធនាគារ**

៤.១. ការវាយតម្លៃប្រតិបត្តិការធនាគារ ........................................ ៤៣
៤.១.១ កំណត់គោលដៅរយៈពេលវែងរបស់ធនាគារ ........................................ ៤៣
៤.១.២. បង្កើនជាអតិបរមានៃតម្លៃក្រុមហ៊ុនរបស់ធនាគារ (ជាគោលសំខាន់របស់ធនាគារ) ........................................ ៤៣
៤.១.៣. អនុបាតប្រាក់ចំណេញ ........................................ ៤៤
៤.១.៤.រូបមន្តប្រាក់ចំណេញ ........................................ ៤៥
៤.១.៥.ការវិភាគលើចំណូលធៀបនឹងទុនផ្ទាល់ ........................................ ៤៦
៤.១.៦.ការវិនិយោគលើចំណូលធៀបនឹងទ្រព្យ (ROA) ........................................ ៤៦
៤.១.៧.រង្វាស់ប្រាក់ចំណេញ និងការបកស្រាយ ........................................ ៤៧
៤.២.ការជះឥទ្ធិពលនៃទំហំរបស់ធនាគារទៅលើប្រតិបត្តិការ ........................................ ៤៧

**មេរៀនទី៥**

**ការគ្រប់គ្រងទ្រព្យ និងបំណុល៖ កំណត់ការវាស់វែងអត្រាការប្រាក់ ព្រមទាំងត្រួតពិនិត្យគម្លាតការប្រាក់របស់ធនាគារ**

៥.១.យុទ្ធសាស្ត្រនៃការគ្រប់គ្រងទ្រព្យ និងបំណុល ........................................ ៤៩
៥.១.១. យុទ្ធសាស្ត្រនៃការគ្រប់គ្រងទ្រព្យ ........................................ ៤៩
៥.១.២.យុទ្ធសាស្ត្រគ្រប់គ្រងបំណុល ........................................ ៤៩
៥.១.៣.យុទ្ធសាស្ត្រគ្រប់គ្រងមូលធន ........................................ ៥០
៥.២.ហានិភ័យអត្រាការប្រាក់ : គឺការប្រឹងប្រែងរបស់ធនាគារក្នុងការគ្រប់គ្រងទ្រព្យនិងបំណុល ៥០
៥.២.១. កម្លាំងដែលកំណត់ពីអត្រាការប្រាក់ ........................................ ៥១
៥.២.២.ការវាស់វែងអត្រាការប្រាក់ ........................................ ៥២
៥.២.៣.សមាសធាតុនៃអត្រាការប្រាក់ ........................................ ៥៣
៥.២.៤.ការឆ្លើយតបរបស់ធនាគាររីកចំពោះ ហានិភ័យអត្រាការប្រាក់ ........................................ ៥៤
៥.៣.គោលដៅមួយនៃការលប់បំបាត់គ្រោះថ្នាក់នៃអត្រាការប្រាក់ ........................................ ៥៤
៥.៣.១.ការគ្រប់គ្រងរំញោចគម្លាតការប្រាក់ (Interest Sensitive Gap Management) ........................................ ៥៥

## មេរៀនទី៦
## ការផ្តល់ឥណទានដល់ក្រុមហ៊ុនអាជីវកម្ម


៦.១. ហិរញ្ញប្បទានដល់អ្នកលក់រាយ ....................................................................... ៦១
៦.២.ហិរញ្ញប្បទានផ្អែកលើទ្រព្យ .......................................................................... ៦២
៦.៣. ឥណទានរយៈពេលវែង...................................................................................... ៦២
៦.៣.១.ឥណទានអាជីវកម្មរយៈពេលវែង ............................................................. ៦២
៦.៣.២.ឥណទានវិល ( Revolving Credit Financing ) ...................................... ៦៣
៦.៣.៣.ឥណទានគំរោងរយៈពេលវែង ................................................................... ៦៣
៦.៤.ការវិភាគឥណទានអាជីវកម្ម ............................................................................ ៦៣
៦.៤.១.ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ................................................................៦៤
៦.៥.ការវិភាគអនុបាតហិរញ្ញវត្ថុ...............................................................................៦៦
៦.៥.១.ការគ្រប់គ្រងលើការចំណាយរបស់អតិថិជន ..............................................៦៦
៦.៥.២.ប្រសិទ្ធភាពនៃប្រតិបត្តិការ ........................................................................៦៦
៦.៥.៣.តារាងលក់ដាច់នៃផលិតផល..................................................................... ៦៧
៦.៥.៤.អនុបាតសង ................................................................................................ ៦៧
៦.៥.៥.សាច់ប្រាក់របស់អាជីវកម្ម..........................................................................៦៩
៦.៥.៦.ប្រាក់ចំណេញ ...............................................................................................៦៩
៦.៥.៧.អនុបាតបំណុល ............................................................................................៦៩
៦.៥.៨.បំណុលបំរុង .................................................................................................៦៩
៦.៦.ការគ្រប់គ្រងសេវាឥណទាន ( Credit services management )...........................៦៩
៦.៦.១.ដំណើរការឥណទាន ( Credit processing ) .............................................៦៩
៦.៦.២.សេវាប្រាក់បញ្ញើអតិថិជន ( Customer deposit service ) ...................... ៧០
៦.៦.៣.សេវាប្រាក់កម្ចីធនាគារ ( Bank loan services ) ..................................... ៧២
៦.៦.៤.សេវាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ( Microfinance institution services ) ........ ៧២
៦.៦.៥.តួនាទីសំខាន់របស់ធនាគារក្នុងសេដ្ឋកិច្ច ( Role of bank for economics ) ៧៣


## មេរៀនទី៧
## ថ្លៃរបស់ឥណទានអាជីវកម្ម


៧.១.វិធីបូកបន្ថែមលើការចំណាយ....................................................................... ៧៦
៧.២.គំរូថ្លៃនៃធនាគារធំៗ ........................................................................................ ៧៦
៧.២.១.ការបូកបន្ថែមដោយផ្អែកលើអត្រារបស់ទីផ្សារប្រាក់ ( Below-Prime Market Pricing ) ........................................................................................................ ៧៦

៧.២.២.ឥណទានដែលមានអត្រាអតិបរមា (Caps) ....................................... ៧៧
៧.២.៣. ការដាក់ថ្លៃឥណទានផ្អែកលើការចំណាយ និងផលប្រយោជន៍ (Cost-Benefit Loan Pricing) ........................................................................................ ៧៧

## មេរៀនទី៨
## ប្រព័ន្ធទូទាត់ និងការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិចនៅក្នុងឧស្សាហកម្មធនាគារ

៨.១.សេចក្តីផ្តើម................................................................................... ៧៩
៨.២.សេវាកម្មដែលផ្តល់ឲ្យតាម Internet................................................................. ៧៩
៨.៣.លទ្ធភាពប្រើ Internet ដោយធនាគារ ............................................................ ៧៩

## មេរៀនទី៩
## ទីផ្សារមូលបត្រ

Securities Markets

៩.១.ទិដ្ឋភាពទូទៅនៃទីផ្សារមូលបត្រ (An Overview of Securities Markets).............៨០
៩.២.គោលការណ៍សំខាន់ៗនៃច្បាប់ និងបទប្បញ្ញត្តិមូលបត្រ (Principles of Securities Regulations) ........................................................................................៨១
៩.២.១.ប្រភេទនៃបទប្បញ្ញត្តិមូលបត្រ :........................................................ ៨២
៩.៣.មុខងារនៃទីផ្សារមូលបត្រ (Function of Securities Market)............................៨៤
៩.៤.ប្រសិទ្ធភាពនៃទីផ្សារមូលបត្រ (Efficiency of Securities Markets) ....................៨៥
៩.៥.ការកំណត់ប្រភេទនៃមូលបត្រ (Definition of Securities) ..................................៨៥
៩.៥.១.ប្រភេទភាគហ៊ុន (Stocks/Shares) ..................................................៨៦
៩.៥.២.ប្រភេទសញ្ញាប័ណ្ណ (Bonds) ........................................................ ៨៧
៩.៦. អ្នកចូលរួមសំខាន់ៗនៅក្នុងទីផ្សារមូលបត្រ (participants in Securities Markets)៩០
៩.៦.១. ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ (issuers).........................................៩០
៩.៦.២. វិនិយោគិនមូលបត្រ (Investors).....................................................៩០
៩.៦.៣. អន្តរការីទីផ្សារមូលបត្រ (Securities Intermediaries)..........................៩០
៩.៧. ទីផ្សារមូលធន និងទីផ្សាររូបិវត្ថុ (Capital and Money Markets) ...............៩០
៩.៧.១. ទីផ្សារមូលធន (Capital Market)...................................................៩០
៩.៧.២. ទីផ្សាររូបិយវត្ថុ (Money Market).................................................៩១
៩.៨. ទីផ្សារដំបូង និងទីផ្សារបន្ទាប់ (Primary and Secondary Markets) ..........៩១
៩.៨.១. ទីផ្សារដំបូង (Primary market).....................................................៩១
៩.៨.២. ទីផ្សារបន្ទាប់ (Secondary Market) ............................................. ៩២
៩.៩. ទីផ្សារមូលបត្រ និងទីផ្សាររំលងបញ្ជារ (Exchanges and Over The Counter Market)៩២
៩.១០. សន្ទនីយភាព (Liquidity)..........................................................................៩៤

៩.១១. ការកំណត់តម្លៃ (Fair Price Determination)....................................................៩៤
៩.១២.សន្ទស្សន៍ថ្លៃ indexes និង សន្ទស្សន៍ថ្លៃ Averages....................................................៩៥

**មេរៀនទី ១០**
**ប្រភេទផ្សេងៗ នៃមូលបត្រ**
Types of Securities

១០.១.ប្រភេទសញ្ញាបណ្ណ (Bonds)....................................................................... ៩៧
១០.១.១. សញ្ញាបណ្ណបំណុលទូទៅ និងសញ្ញាបណ្ណប្រាក់ចំណូល (General Obligation and Revenue Bonds)....................................................................៩៩
១០.១.២. សញ្ញាបណ្ណរតនាគារ ឬរដ្ឋាភិបាល (Treasury/Government Bonds)...៩៩
១០.១.៣. បណ្ណរតនាគារ ឬរដ្ឋាភិបាល (Treasury/Government Notes) ........ ១០០
១០.១.៤. បណ្ណបំណុលរតនាគារ ឬរដ្ឋាភិបាល (Treasury/Government Bills) . ១០០
១០.១.៥. សញ្ញាបណ្ណចែករំលែកប្រាក់ចំណេញ (Participating Bonds) .......... ១០០
១០.១.៦. សញ្ញាបណ្ណដែលអាចប្តូរបាន (Convertible Bonds)....................... ១០០
១០.១.៧. សញ្ញាបណ្ណដែលមានខ័ណ្ឌបណ្ណសូន្យ (Zero Coupon Bonds)........ ១០១
១០.១.៨. សញ្ញាបណ្ណមានអត្រាទិន្នផលខ្ពស់ (High Yield "Junk" Bonds) ...... ១០១
១០.១.៩. សញ្ញាបណ្ណធានា (Warrant Bonds/Bonds with Warrants) .........១០២
១០.១.១០. សញ្ញាបណ្ណសន្ទស្សន៍ថ្លៃ (Indexed Bonds)..............................១០២
១០.១.១១. ផលបតពាណិជ្ជកម្ម (Commercial Paper) ..............................១០២
១០.១.១២. មូលបតដាក់បញ្ចាំ (Mortgage Backed Securities)................. ១០៣
១០.២. ប្រភេទមូលបត្រកម្មសិទ្ធិ (Securities Equities)...................................... ១០៣
១០.២.១. ភាគហ៊ុនមានសិទ្ធិបោះឆ្នោត (Common Stock) .......................... ១០៣
១០.២.២. ភាគហ៊ុនបរិមា (Preferred Stock) ............................................. ១០៤
១០.២.៣. តម្លៃចារឹកនៃភាគហ៊ុន (Par Value) ........................................... ១០៤
១០.២.៤. តម្លៃកត់ត្រា (Book Value) ....................................................... ១០៥
១០.២.៥. ប្រភេទនានានៃភាគហ៊ុន (Classes of Stock).............................. ១០៥
១០.២.៦. ភាគហ៊ុនបំបែក (Stock Splits) ................................................. ១០៦
១០.២.៧. ភាគលាភ (Dividends)...........................................................១០៧
១០.២.៨. ភាគហ៊ុនក្រុមហ៊ុន (Treasury Stock) ......................................... ១០៩
១០.២.៩. បណ្ណទទួលតម្កល់ភាគហ៊ុន (Depository Receipts) ...................... ១០៩
១០.៣. កិច្ចសន្យាទិញ-លក់ទំនិញ (Commodities)............................................ ១០៩

**មេរៀនទី១១**
**ការជួញដូរ ការជាត់ទាត់ និងការទូទាត់មូលបត្រ**

(Trading, Clearing and Settling Securities)
១១.១. ប្រភេទនានានៃការជួញដូរមូលបត្រ (Types of Securities Trades)............. ១១០
១១.១.១. ការបញ្ជាតាមថ្លៃ (Price Orders) ............................................. ១១០
១១.១.២.ការបញ្ជាមានកំណត់ (Limit Orders) ......................................... ១១១
១១.១.៣.ការបញ្ជាតាមពេលវេលា (Time Orders)....................................... ១១៥
១១.២. ការជួញដូរតាម Margin (Margin Trading) .............................................១១៧
១១.២.១. ការទិញ (purchases) ..........................................................១១៧
១១.២.២. ការខ្ចីមូលបត្រលក់ក្នុងរយះពេលខ្លី (Short Sales)......................... ១១៩
១១.២.៣. មូលបត្រអនាគត (Futures)..................................................... ១១៩
១១.៣.ការឲ្យខ្ចីមូលបត្រ (Securities Lending) .................................................. ១១៩
១១.៤. ការកេងយកចំណេញ (Arbitrage) ........................................................១២០
១១.៤.១. ការកេងយកចំណេញលើមូលបត្រ (Securities Arbitrage).............១២១
១១.៤.២. ការកេងយកចំណេញលើសន្ទស្សន៍ (Index Arbitrage)..................១២១
១១.៤.៣. ការកេងយកចំណេញពីហានិភ័យ (Risk Arbitrage).......................១២១
១១.៥.ការផាត់ទាត់ (Clearing) .......................................................................១២១
១១.៦. ការទូទាត់ (Settlement)........................................................................ ១២២
១១.៧. ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ (Transfer Agent) .......................................១២៤
១១.៨.មូលបត្រដែលត្រូវបានលួច បាត់ឫ ខូចខាត.................................................១២៥
១១.៩.ភ្នាក់ងារបញ្ជីការមូលបត្រ ......................................................................១២៦
១១.១០. ប្រតិបត្តិការរក្សាមូលបត្រ ....................................................................១២៦

**បណ្ណាល័យសាស្រ្ត**

# មេរៀនទី១
# ឧស្សាហកម្មធនាគារ និងឧស្សាហកម្មសេវាកម្មហិរញ្ញវត្ថុ

## ១.១.មុខងារនៃប្រព័ន្ធហិរញ្ញវត្ថុ

តួនាទីដ៏សំខាន់របស់ប្រព័ន្ធហិរញ្ញវត្ថុគឺការបែងចែកប្រភពធនធាន។ ប្រព័ន្ធហិរញ្ញវត្ថុបានអនុវត្តនូវមុខងារជាមូលដ្ឋាន 6 :

1.ទូទាត់រាល់ការចំណាយ (ប្រព័ន្ធទូទាត់)

2.ប្រមូលផ្តុំ និងចែកចាយទ្រព្យសំភារៈ និងសំរួលដល់ការចរាចរនៃមូលនិធិ ហេតុនេះហើយគេអាចផ្តល់ហិរញ្ញប្បទានដល់គមរោងតូច និងធំទាំងឡាយបាន

3.ផ្លាស់ប្តូរធនធានសេដ្ឋកិច្ចពីពេលមួយទៅពេលមួយ ពីកន្លែងមួយទៅកន្លែងមួយ និងពីឧស្សាហកម្មមួយទៅឧស្សាហកម្មមួយទៀត

4.ប្រមូលផ្តុំ វិភាគ និងចែកចាយព័ត៌មានសម្រាប់ការធ្វើការសម្រេចចិត្ត

5.ផ្តល់មធ្យោបាយសម្រាប់គ្រប់គ្រងជាក់លាក់ និងគ្រប់គ្រងហានិភ័យ

6.ផ្តល់មធ្យោបាយសម្រាប់ដោះស្រាយបញ្ហា សំរាប់ភាពមិនដូចគ្នានៃព័ត៌មាននូវក្នុងកិច្ចព្រមព្រៀងហិរញ្ញវត្ថុ។

នៅក្នុងករណីណាក៏ដោយ មុខងារទាំង 6 ខាងលើនេះ មិនមានផ្លាស់ប្តូរទេ ជាងនេះទៅទៀតនៅពេលដែលប្រព័ន្ធហិរញ្ញវត្ថុមានប្រសិទ្ធភាព ដោយសារការបង្កើតថ្មី នោងការប្រកួតប្រជែង ទំរង់ស្ថាប័ននេះនឹងមានទំនោរទៅតាមមុខងារខាងលើ។

## ១.២.ក្រុមហ៊ុនសេវាកម្មហិរញ្ញវត្ថុ និងឧស្សាហកម្មសេវាហិរញ្ញវត្ថុ

ក្រុមហ៊ុនដែលដើរតួសំខាន់នៅក្នុងឧស្សាហកម្មសេវាកម្មហិរញ្ញវត្ថុគឺៈ

**ធនាគារ** : មានធនាគារពាណិជ្ជកម្ម និងធនាគារវិនិយោគ ដែលជាធនាគារក្នុងស្រុក ឬធនាគារ

បរទេស។

**ស្ថាប័នសន្សំ និងអោយខ្ចី** (Thrift Institution) ផ្តល់ការសន្សំ និងប្រាក់កម្ចី ធនាគារសន្សំ និងសហជីព ឥណទាន

**ក្រុមហ៊ុនធានារ៉ាប់រង** : ការធានាជីវិត ការធានាទ្រព្យសម្បត្តិ និងការខូចខាត

**សោធននិវត្តន៍** : ផ្នែកឯកជន និងផ្នែករដ្ឋាភិបាល

**ក្រុមហ៊ុនហិរញ្ញវត្ថុ** : សំរាប់ពាណិជ្ជកម្ម និងអ្នកប្រើប្រាស់

**សង្គហធន** (Mutual Funds) ផ្សារប្រាក់ មូលប័ត្រ ផ្សារហ៊ុន

**ក្រុមហ៊ុនមិនមែនហិរញ្ញវត្ថុ (Non-financial Corporations)** : រួមមាន General Motor (GM) Acceptance Corporation , General Electric Capital Services and AT & T Universal ។

ដោយក្រុមហ៊ុនខាងលើនេះបានផ្តល់សេវាហិរញ្ញវត្ថុ ត្រូវបានគេហៅថា ជាក្រុមហ៊ុនផ្តល់សេវាកម្មហិរញ្ញវត្ថុ ឬក៏អន្តរការីហិរញ្ញវត្ថុ (Financial Intermediaries)។

## ១.៣.ធនាគារ

ជាទូទៅធនាគារ (Banking) គឺជាស្ថាប័នហិរញ្ញវត្ថុដែលធ្វើប្រតិបត្តិការផ្តល់សេវាកម្មហិរញ្ញវត្ថុច្រើនប្រភេទ ដូចជាទទួលប្រាក់បញ្ញើមិនមានមុខសញ្ញាប្រើប្រាស់ និងប្រាក់សន្សំពីសាធារណជនផ្តល់ឥណទានឱ្យឯកត្តជន និងក្រុមហ៊ុនអាជីវកម្មជំនួញ ដោយយកការប្រាក់ព្រមទាំងផ្តល់សេវាលើការងារទូទាត់ និងធ្វើវិនិយោគមូលនិធិស្ថិតក្រោមរូបភាពដូចជា សញ្ញាប័ណ្ណ (bond) និងមូលប័ត្រមានតម្លៃដើម្បីស្វែងរកនូវប្រាក់ចំណេញសម្រាប់ម្ចាស់ភាគហ៊ុន។ ធនាគារ គឺជាស្ថាប័ន ឬគ្រឹះស្ថានសម្រាប់ទទួលបញ្ញើ ឬបណ្តាក់ទុនជាបណ្តាញប្រមូលប្រាក់សន្សំដែលឥតប្រើប្រាស់ ឬនៅទំនេរក្នុងសេដ្ឋកិច្ចយកទៅវិភាជនៅតាមគ្រប់វិស័យសេដ្ឋកិច្ចតាមរយៈការឱ្យឥណទាន ដើម្បីជួយជំរុញលើកស្ទួយសកម្មភាព និងអភិវឌ្ឍសេដ្ឋកិច្ចសង្គម។

ធនាគារ គឺជាស្ថាប័នហិរញ្ញវត្ថុទទួលយកប្រាក់បញ្ញើ និងផ្តល់កម្ចី។ ពាក្យថាធនាគារ គឺជាក្រុមហ៊ុនដូចជាធនាគារពាណិជ្ជកម្ម សមាគមសន្សំ និងបំណុល។ ធនាគារសន្សំរួម និងសហគមឥណទានសុទ្ធតែមានតួនាទីប្រហាក់ប្រហែលគ្នា ប៉ុន្តែគេសង្កេតឃើញថា មានភាពខុសគ្នាលើគោលនយោបាយគ្រប់គ្រងហិរញ្ញវត្ថុ។ ធនាគារមានដំណើរការដូចក្រុមហ៊ុនដែរ ដោយគ្រាន់តែជំនួញលើរូបិយវត្ថុ។ ចាប់តាំងពីទសវត្សរ៍ទី៧០មក ធនាគារបានកើនឡើងយ៉ាងរហ័ស ដោយសារតែផ្តល់សុវត្ថិភាពដល់អ្នកជំនួញ។ ទន្ទឹមគ្នានេះ ដំណើរការដែលមានភាពអាប់អួ និងភាពបរាជ័យនៃធនាគារពាណិជ្ជកម្មក៏មានច្រើនដែរ ពីព្រោះការស្រុតចុះនៃល្បឿនសេដ្ឋកិច្ចដែលរដ្ឋាភិបាលមិនអាចត្រួតពិនិត្យសេដ្ឋកិច្ចរដ្ឋ និងតម្រូវការប្រាក់តម្កល់ចេះតែកើនឡើងច្រើនពេក។

ក្រោមច្បាប់ប្រទេសកម្ពុជា ធនាគារគឺនីតិសម្បទាពិសេសក្នុងការរើសយកប្រតិបត្តិការធនាគារជាមុខរបរប្រក្រតី។ ហើយប្រតិបត្តិការដែលជាសកម្មភាពធនាគាររួមមាន៖

- ការផ្តល់នូវឥណទានគ្រប់ប្រភេទដល់សាធារណជន ដោយមានកម្រៃរាប់បញ្ចូលទាំងឥណទានភតិសន្យា និងការសន្យាតាមហត្ថលេខា។
- ការទទួលប្រាក់បញ្ញើមិនមានមុខសញ្ញាប្រើពីសាធារណជន។
- ប្រព្រឹត្តកម្ម និងដាក់ឱ្យអតិថិជនប្រើប្រាស់នូវមធ្យោបាយទូទាត់ជារូបិយវត្ថុ ឬជារូបិយប័ណ្ណ។

ធនាគារមានសារៈសំខាន់ណាស់ចំពោះសេដ្ឋកិច្ច និងសហគមន៍ជំនួញ។ មនុស្សមួយចំនួនមានការភ័ន្តច្រឡំអំពីធនាគារ។ តាមពិតធនាគារអាចត្រូវបានគេស្គាល់ដោយសារមុខងាររបស់វា (សេវាកម្ម និងតួនាទី) នៅក្នុងសេដ្ឋកិច្ច។ ប៉ុន្តែ បញ្ហានៅត្រង់ថា នៅពេលមុខងាររបស់ធនាគារបានផ្លាស់ប្តូរ

មុខងាររបស់ស្ថាប័នហិរញ្ញវត្ថុមួយចំនួនដែលជាការប្រកួតប្រជែងរបស់វាក៏មានការផ្លាស់ប្តូរដែរ។ ស្ថាប័នតាំងនោះ (Security Dealers , Brokerage Firms , Mutual Funds , and Insurance Companies) បានព្យាយាមផ្តល់សេវាកម្មដូចធនាគារដែរ។ ជាលទ្ធផលធនាគារ ក៏ព្យាយាមផ្តល់សេវាកម្មថ្មីៗដល់អតិថិជនរបស់វា ដូចជាអាជីវកម្មជីផ្លី ធ្វើឈ្មួញកណ្តាលក្នុងការលក់ដូរមូលប័ត្រសេវាធានារ៉ាប់រង វិនិយោគក្នុង Mutual Funds (សង្គហធន)។

ឧទាហរណ៍ នៅក្នុងទសវត្ស 1980 ដើម្បីផ្តល់សេវាកម្មដូចធនាគារ ក្រុមហ៊ុនធានារ៉ាប់រង និងក្រុមហ៊ុនមូលប័ត្រមួយចំនួន រួមមាន Merrill Lynch, Dreyfus Corporation និង Prudential បានផ្តល់នូវសេវាកម្មធនាគារ ដែលគេហៅថា Non-bank Bank។ ក្រុមហ៊ុនទាំងនោះបានដឹងថា ក្រោមច្បាប់សហរដ្ឋ គ្រប់ស្ថាប័នទាំងអស់ដែលទទួលប្រាក់បញ្ញើ ត្រូវតែឬអនុញ្ញាតឱ្យគេដកប្រាក់តាមតម្រូវការ ហើយផ្តល់ប្រាក់កម្ចីដល់អាជីវកម្ម ដូចធនាគារដែរ។ Merrill Lynch និងក្រុមហ៊ុនមិនមែនជាធនាគារមួយចំនួន បានឆ្លៀតឱកាសនេះ ហើយគេចពីច្បាប់ធនាគារ ដើម្បីលក់សេវាកម្មដូចធនាគារទៅឱ្យសាធារណៈជន ពួកគេបានគ្រប់គ្រងលើការឱ្យខ្ចី និងគណនីចរន្ត។ ប៉ុន្តែក្រុមព្រឹក្សាភិបាលរបស់ Federal Reserve មិនសប្បាយនិងការរំលោភនេះទេ ហើយសំរេចបញ្ចូលពាក្យថា "ផ្តល់ប្រាក់កម្ចីដល់បុគ្គល និគ្រួសារ" នៅក្នុងនិយមន័យធនាគារ ហើយក៏បានបញ្ចូល Merrill Lynch និងក្រុមហ៊ុនដែលមានអាជីវកម្មប្រហាក់ប្រហែលគ្នាមួយចំនួនទៀត នៅក្រោមនិយមន័យធនាគារដែលស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាល។

ដោយសកម្មភាពខាងលើ ក្រុមហ៊ុនមូលប័ត្រធំៗមួយចំនួនបានធ្វើការប្តឹងតវ៉ាថា ក្រុមប្រឹក្សាភិបាលរបស់ Federal Reserve បានប្រតិបត្តិហួសអំណាចរបស់ខ្លួន។ នៅឆ្នាំ 1984 តុលាការសហព័ន្ធកជបានបញ្ជាឱ្យ Non-bank Bank មានសិទ្ធិប្រើប្រាស់ Federal Deposit Insurance។ ទន្ទឹមនឹងនេះដែរ ធនាគារមួយចំនួន ដូចជា Citicorp និង Manhattan ក៏បានបង្កើត Non-bank Bank របស់ខ្លួន ដើម្បីផ្តល់នូវសេវាកម្មដោយសេរី។ នៅឆ្នាំ 1987 សភាជាន់ខ្ពស់បានដាក់ Non-bank Bank ទាំងអស់ឱ្យនៅក្រោមច្បាប់តែមួយរបស់ធនាគារ ហើយឱ្យនិយមន័យ ធនាគារ ថា សមាជិករបស់ Federal Deposit Insurance Corporation។

នៅទសវត្សឆ្នាំ 1990 ធនាគារត្រូវបានគេអនុញ្ញាតឱ្យផ្តល់សេវាកម្មច្រើនប្រភេទអាចធ្វើការជាមួយក្រុមហ៊ុនមូលប័ត្រ ក្រុមហ៊ុនវិនិយោគ និងអនុញ្ញាតឱ្យក្រុមហ៊ុនឧស្សាហកម្ម មនាក្រុមហ៊ុនហិរញ្ញវត្ថុជារណប ហើយក្រុមហ៊ុនហិរញ្ញវត្ថុ អាចវិនិយោគក្នុងឧស្សាហកម្មផ្សេងៗ។

ព្រឹត្តការណ៍ខាងលើបានធ្វើឱ្យសាធារណៈជន (អាមេរិក) មានការច្រឡំពីធនាគារ និងក្រុមហ៊ុនមិនមែនធនាគារ។

**តារាង ១.១**

| ធនាគារ ១០ ធំបំផុតនៅអាស៊ី<br>The 10 Region's Biggest Banks | | | | |
|---|---|---|---|---|
| 2000 | | | Assets | Deposit |

| | Bank Name | Country | $ | $ |
|---|---|---|---|---|
| Rank | | | Millions | Millions |
| 1 | Bank of Tokyo-Mitsubishi | Japan | 680.095 | 453.494 |
| 2 | Fuji Bank | Japan | 550.155 | 346.998 |
| 3 | Sumitomo Bank | Japan | 510.832 | 344.729 |
| 4 | Dai-Ichi Kangyo Bank | Japan | 508.792 | 345.270 |
| 5 | Sakura Bank | Japan | 459.912 | 330.593 |
| 6 | Sanwa Bank | Japan | 444.118 | 3377.593 |
| 7 | Indi & Coml Bank of Japan | China | 427.546 | 360.212 |
| 8 | Industrial Bank of Japan | Japan | 450.147 | 64.936 |
| 9 | Bank of China | China | 350.736 | 239.738 |
| 10 | Tokai Bank | Japan | 288.651 | 201.871 |
| Source: Asia Week Financial 500, 2000 | | | | |

✳Reflects subsequent marger of Bank of Tokyo and Mitsubishi Bank

✳Reflects subseqiement merger with Chemical Bank of New York

Sources: Board of Govermors of the Federal Resurve System, Federal Deposit Insurance Corporation, and American Bankers Association.

### តារាង ១.២ ធនាគារដែលធំបំផុតក្នុងពិភពលោក (With Their total assets in billions of U.S dollars, and mid-year 1995)

| | | | |
|---|---|---|---|
| Deutsche Bank, Germany | $502,3 | West LG, Germany | $290,6 |
| Sumitomo Bank, Japan | 498,9 | Mitsubishi Trust & Banking, Japan | 283,7 |
| Dai-Ichi Kangyo Bank, Japan | 497,6 | Mitsui Trust & Banking, Japan | 283,7 |
| Fuji Bank, Japan | 486,4 | Compagnie Financiere de Paribas | 270,8 |
| Bank of Tokyo-Mitsubishi Bank, Ltd, Japan | 711,0 | Asahi Bank, Japan | 266,0 |
| Sakura Bank, Japan | 477,1 | National Westminster Bank, UK | 257,8 |
| Norinchukin Bank, Japan | 428,6 | Citicorp, United States | 255,3 |
| Credit Agricole Mutual, France | 384,3 | Barclays, United Kingdom | 254,5 |
| Industrial Bank, Japan | 360,6 | Daiwa Bank, Japan | 248,3 |
| ABN-AMRO Holdings, Netherlands | 339,4 | Dresdner Bank, Germany | 232,1 |
| Credit Lyonnais, France | 337,6 | Bank America, United States | 230,2 |
| Union Bank of Switzerland | 335,3 | Yasuda Trust & Banking, Japan | 224,2 |
| Chase Manhattan, United States | 333,8 | Tokyo Trust, Tokyo | 189,7 |
| Societe Generale, France | 324,8 | International Nederland, Netherlands | 253,5 |
| Bankque Nationale de Paris, France | 323,5 | | |
| Sumitomo Trust & Banking, Japan | 299,2 | | |
| Tokai Bank, Japan | 297,7 | | |
| Long-Term Credit Bank, Japan | 297,4 | | |

Reflects Subsequent Merger of Bank of Tokyo and Mitsubishi Bank.

•Reflects Subsequent Merger with Chemical Bank of New York.

Sources: Board of Governors of the Federal Reserve System, Federal Deposit Insurance Corporation, and American Bankers Association.

## ១.៤.ប្រភេទនៃធនាគារពាណិជ្ជកម្ម

ធនាគារពាណិជ្ជកម្មត្រូវបានគេបែងចែកជាច្រើនប្រភេទនៅក្នុងសហរដ្ឋអាមេរិកទៅតាមច្បាប់កំណត់ និងការផ្តល់ជាអាជ្ញាប័ណ្ណ។ ធនាគារជាតិ (National Bank) ត្រូវបានផ្តល់អាជ្ញាប័ណ្ណដោយការិយាល័យត្រួតពិនិត្យរូបិយប័ណ្ណ (Office of the Comptroller of the Currency)។ ចំណែកឯធនាគាររដ្ឋ (State Bank) អាជ្ញាប័ណ្ណ ត្រូវបានផ្តល់ដោយរដ្ឋនីមួយៗ រួមទាំងសង្កាត់ Columbia ធនាគាររដ្ឋមានសិទ្ធក្នុងការចូលក្នុង Federal Reserve System ចំណែកឯធនាគារជាតិមិនមានសិទ្ធទេ។ គ្រប់សមាជិករបស់ Federal Reserve ត្រូវបានបញ្ជាក់ដោយប្រាក់បញ្ញើសហព័ន្ធ (Federal Deposit)។

➢ ប្រភេទនៃធនាគារពាណិជ្ជ

- លក្ខន្តិកៈ (ភ្នាក់ងារសហព័ន្ធឬរដ្ឋ)
  - National Bank (Office of the Comptroller of the Currency, OCC)
  - State Bank (រដ្ឋ50 និង D.C)
- គ្រប់គ្រងដោយសហព័ន្ធ
  - National Bank (OCC)
  - State Member Bank (Federal Reserve)

- State Noninsured Bank (គ្រប់គ្រងដោយរដ្ឋ)
- Bank Holding Company (Federal Reserve)
- ធនាគារឬ Bank Holding Company ដែលមានភាគហ៊ុនចំនួន500 ឬក៏ច្រើនជាង (Securities and Exchange Commission-SEC)

▪ រចនាសម្ព័ន្ធឬទម្រង់នៃការចាត់ចែង
- Unit Bank
- Branch Bank
- Holding Company Bank
- One Bank Holding Company
- Multi-Bank Holding Company

▪ ប្រភេទអាជីវកម្ម
- ធនាគារលក់ដុំ
- ធនាគារលក់រាយ
- ធនាគារលក់ដុំ និងរាយ (សេវាកម្មគ្រប់ប្រភេទនិងអតិថិជនគ្រប់ប្រភេទ)
- Shadow Bank (កុងស៊ីជាកន្លែងទូទាត់សែកសម្រាប់បុគ្គលដែលពុំមានទ្រព្យផ្ទាល់ច្រើន)

▪ ទីផ្សារ
- ធនាគារសហគមន៍
- ធនាគារក្នុងតំបន់
- Superregional Bank
- ធនាគារពហុជាតិ

▪ ការបែងចែកទៅតាមទំហំដោយ (Federal Reserve)
- ធនាគារ10ដែលធំជាងគេបំផុត
- ធនាគារ ដែលក្នុងលំដាប់ទី11ដល់ 100
- ធនាគារដែលនៅក្នុងលំដាប់ទី101 ដល់ 1000
- ធនាគារដែលមិននៅក្នុងលំដាប់ខាងលើ (ធនាគារសហគមន៍)

## ក្រុមហ៊ុនធនាគារ (Bank Holding Company) BHC

ដោយ BHC ជាទំរង់ធនាគារដែលមានច្រើនជាងគេនៅសហរដ្ឋ BHC ត្រូវបានគេត្រួយពិនិត្យយ៉ាងល្អិតល្អន់ដោយយកប្រាក់បញ្ញើជាគោល។ នៅឆ្នាំ 1994 BHCs មានប្រាក់បញ្ញើក្នុងបណ្ដាស្ថាប័នទទួលប្រាក់បញ្ញើដែលកើនឡើងពី 61% នៅក្នុងឆ្នាំ1984។

## ១.៥.សេវាកម្មដែលធនាគារបានផ្តល់ឱ្យសាធារណៈជន

ធនាគារគឺជាក្រុមហ៊ុនផ្តល់សេវាកម្មហិរញ្ញវត្ថុ ព្រមទាំងប្រតិបត្តិនូវតួនាទីមួយចំនួនទៀតនៅក្នុងសេដ្ឋកិច្ច។

### ១.៥.១.តួនាទីធនាគារ

- **តួនាទីជាអន្តរការី:** បំលែងប្រាក់សន្សំពីសាធារណៈជនទៅជាឥណទាន (ប្រាក់កម្ចី) សំរាប់ក្រុមហ៊ុនអាជីវកម្ម ដើម្បីធ្វើវិនិយោគទៅលើអាគារ ឧបករណ៍ និងទំនិញផ្សេងៗ។
- **តួនាទីទូទាត់:** អនុវត្តការទូរទាត់លើទំនិញ និងសេវាកម្មជំនួសមុខឱ្យអតិថិជនរបស់ខ្លួន ដូចជាបោះពុម្ពមូលប្បទានប័ត្រ ទូទាត់មូលប្បទានប័ត្រ ផ្ទេរប្រាក់។ ល។
- **តួនាទីជាអ្នកធានា:** ឈរនៅពីក្រោយអតិថិជនរបស់ខ្លួន ដើម្បីសងបំណុល នៅពេលដែលអតិថិជននោះគ្មានលទ្ធភាពសង ដូចជា ការបើកលិខិតឥណទាន។
- **តួនាទីជាភ្នាក់ងារ:** ជំនួសឱ្យអតិថិជនរបស់ខ្លួនក្នុងការគ្រប់គ្រង និងការពារទ្រព្យសម្បត្តិ ឬការបោះពុម្ព និងផ្តល់សាច់ប្រាក់ដល់មូលប្បទានប័ត្រ។
- **តួនាទីក្នុងគោលនយោបាយរបស់រដ្ឋាភិបាល:** គឺជាឈ្នាន់របស់គោលនយោបាយរដ្ឋាភិបាល ដើម្បីគ្រប់គ្រងការលូតលាស់ផ្នែកសេដ្ឋកិច្ច នោងសម្រេចបាននៅគោលដៅសង្គម។

សាជីវកម្ម និងឧស្សាហកម្មធំៗអតិថិជនឯកត្តជន អាជីវកម្មតូចតាចទាំងអស់ បានពឹងផ្អែកលើធនាគារពាណិជ្ជ ដើម្បីបំពេញតម្រូវការគ្រប់ប្រភេទតម្រូវការហិរញ្ញវត្ថុ។ សម្រាប់តួនាទីទាំងបីផ្តល់ជាវិភាគទានដ៏សំខាន់ចំពោះសេដ្ឋកិច្ច។

### ១.៥.២.មុខងារនៃប្រាក់បញ្ញើ ( Function of deposit )

**ក.ប្រភេទសេវានៃប្រាក់បញ្ញើ ( Types of deposit services )**

តើគេទទួលប្រាក់បញ្ញើយ៉ាងដូចម្តេច? ទោះជាយ៉ាងណាក៏ដោយដើម្បីបង្កើន ឬពន្លឿនលំហូរចូលប្រាក់បញ្ញើ និងធ្វើឱ្យកាន់តែងាយដល់អតិថិជនសព្វថ្ងៃនេះ។ ធនាគារបានដាក់ចេញនូវមធ្យោបាយបន្ថែមជាច្រើន ដើម្បីទទួលបានប្រាក់បញ្ញើ។

- សេវាកម្មងាយស្រួល៖ ធនាគារពាណិជ្ជជាច្រើន ដើម្បីសម្រេចបាននូវឧត្តមភាពប្រៀបធៀបពួកគេ បានផ្តល់ភាពងាយស្រួលកាន់តែប្រសើរឡើង ដូចជាកន្លែងដាក់ប្រាក់សុវត្ថិភាពដែលជាប្រអប់ដាក់ប្រាក់ប្រព័ន្ធបច្ចេកវិទ្យា ឬការទាក់ទងដោយឥតយកថ្លៃ ធ្វើឱ្យងាយស្រួលដល់អតិថិជន។

- ប្រព័ន្ធផ្ទេរមូលនិធិតាមអេឡិចត្រូនិចៈ បង្កើតប្រព័ន្ធផ្ទេរប្រាក់តាមអេឡិចត្រូនិច (EFTS) បានបង្កើនមធ្យោបាយថែមទៀត ដើម្បីដាក់ប្រាក់ជាគណនីដោយអត់ត្រូវការអតិថិជនមកដល់ធនាគារ ឬការចំណាយពេលច្រើននោះទេ។
- ការផ្ទេររវាងធនាគារៈ អ្នកផ្ទេរតាមតេឡេក្រាម (Wire transfers) មានមធ្យោបាយដទៃទៀត ដើម្បីផ្ញើប្រាក់បញ្ញើជាគណនី ដោយមិនចាំបាច់ពាក់ព័ន្ធជាមួយបេឡាករ។
- ការផ្ទេរក្នុងធនាគារៈ វិធីសាស្ត្រសាមញ្ញបំផុត ដែលឥណទានត្រូវបានគេផ្តល់ គឺការស្រង់ឥណទានដាក់ចូលក្នុងឥណទានដូចគ្នា ក្នុងទម្រង់ជាសកម្មភាពប្រាក់បញ្ញើ។

### ខ.ការត្រួតពិនិត្យប្រាក់បញ្ញើ (Control deposit)

ការពិនិត្យប្រាក់បញ្ញើៈ មុនពេលទទួលយកប្រាក់បញ្ញើពីអតិថិជន វាជាការសំខាន់ណាស់ដែលត្រូវពិនិត្យវា ដូចនេះធនាគារដឹងថាធនាគារទទួលបានចំនួនប៉ុន្មាន?

- រូបិយប័ណ្ណក្លែងក្លាយៈ យើងត្រូវការពិនិត្យរូបិយប័ណ្ណក្លែងក្លាយយ៉ាងយកចិត្តទុកដាក់ នៅពេលទទួលយកប្រាក់បញ្ញើ ប្រសិនបើមានរូបិយប័ណ្ណក្លែងក្លាយត្រូវតែប្រគល់ឱ្យអ្នកដាក់ប្រាក់វិញ។
- រូបិយបដិភោគ (បញ្ជាក់លើខ្នងឯកសារ)ៈ មូលប្បទានប័ត្រតំណាងឱ្យសាច់ប្រាក់ ឬប្រាក់បញ្ញើគួរតែត្រូវគេពិនិត្យដើម្បីរៀបចំជាក្រដាសរូបិយបដិភោគ។ ដោយការទទួលឱ្យចារលើក្រដាសរូបិយបដិភោគបេឡាករធ្វើការនេះឱ្យបានល្អទាំងធនាគារ និងអតិថិជនរបស់ខ្លួន។
- ប្រាក់បញ្ញើអាជីវកម្មៈ តាមច្បាប់ជាទូទៅរូបិយប័ណ្ណ និងមូលប្បទានប័ត្រគេត្រូវរាប់ពិនិត្យហើយផ្ទៀងផ្ទាត់ ទោះជាយ៉ាងណាក៏ដោយក៏មានអតិថិជនអាជីវកម្មជាច្រើនបានដាក់ប្រាក់បញ្ញើរបស់គេជាកាស និងរូបិយប័ណ្ណយ៉ាងច្រើន។ ករណីទាំងនេះ ធនាគារ និងអ្នកដាក់ប្រាក់បញ្ញើបានយល់ព្រមគ្នាថាចំនួនប្រាក់ទាំងនេះ ត្រូវទទួលស្គាល់តាមចំនួនដែលផ្ទៀងផ្ទាត់ឃើញចុងក្រោយ ដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យពេលដាក់ និងពេលដក (ត្រួតពិនិត្យជាមួយគ្នាទៅវិញទៅមកពេលដាក់ និងដក)។

### គ.មុខងារទូទាត់ (Function of payment)

មូលប្បទានប័ត្រជាមធ្យោបាយងាយស្រួល ហើយមានសុវត្ថិភាពសម្រាប់ទូទាត់ ហើយត្រូវបានគេទទួលយក និងមានការជឿជាក់។

ឧទាហរណ៍ៈ រូបិយវត្ថុងាយបាត់ និងត្រូវគេលួច។ ប្រសិនបើ ការទូទាត់ត្រូវគេធ្វើឡើងជាសាច់ប្រាក់វិក្កយបត្រ ដែលគេផ្តល់អាចងាយបាត់។ ការទូទាត់ទំនើបវិញ យើងប្រើតាមយន្តការទូទាត់ដូចជាប្រព័ន្ធផ្ទេរប្រាក់តាមអេឡិចត្រូនិច ឬអេធីអឹម (ATM) ដើម្បីទទួលបាននូវសាច់ប្រាក់ដោយមិនប្រើមូលប្បទានប័ត្រ។

**ឃ.មុខងារឥណទាន** (Function of credit)

គឺមានប្រភេទផលប័ត្រ៤ ជាមូលដ្ឋាននៅក្នុងធនាគារពាណិជ្ជក្នុងការរាយការណ៍ទៅឱ្យភ្នាក់ងាររដ្ឋាភិបាល។

- ឥណទានអចលនទ្រព្យ៖ សម្រាប់មូលនិធិផ្តល់នូវការពាក់ព័ន្ធ និងអចលនទ្រព្យដែលធ្វើហិរញ្ញប្បទាន។ សម្រាប់អគារការិយាល័យថ្មីបណ្តុំហាងលក់ទំនិញការកសាងផ្ទះ។ ការពាក់ព័ន្ធរបស់គេមានពីរទម្រង់គឺឥណទានសាងសង់ និងឥណទាននិក្ខេប (Mortgage Loan)។
- ឥណទានធនាគារ៖ សំដៅទៅលើការផ្តល់ឥណទានយ៉ាងច្រើនដាក់ធនាគារផ្សេងៗ ពីធនាគារមួយទៅធនាគារមួយផ្សេងទៀត ដែលជារឿយៗការផ្តល់ឱ្យធនាគារដែលមានការទាក់ទង។
- ឥណទានអតិថិជន៖ ផ្តោតសំខាន់លើការផ្តល់ឥណទានទៅឱ្យអាជីវកម្មតូចតាច និងតម្រូវការរបស់អតិថិជនដទៃទៀត។
- ឥណទានឧស្សាហកម្ម និងពាណិជ្ជកម្ម៖ ផ្តោតសំខាន់លើប្រភេទឥណទានធំៗ ដែលផ្តល់ទៅឱ្យធនាគារ។ ឥណទានមួយចំនួនមានរយៈពេលលើសមួយឆ្នាំ។ ឥណទានប្រភេទនេះភាគច្រើនមានរយៈពេលខ្លីជាងមួយឆ្នាំ។ កាលវសានសាមញ្ញបំផុត គឺមានរយៈពេល ៣ខែ។

## ១.៥.៣.សេវាកម្មដែលធនាគារបានផ្តល់នៅក្នុងប្រវត្តិសាស្ត្រ

**អនុវត្តការដោះដូរអរូបិយវត្ថុ:** ប្រវត្តិសាស្ត្របានបង្ហាញថា សេវាកម្មមួយដែលផ្តល់ឱ្យធនាគារគឺការប្តូរអរូបិយវត្ថុ។ ធនាគារធ្វើការប្តូរពីរូបិយវត្ថុមួយទៅរូបិយវត្ថុផ្សេងៗទៀត ដោយយកតម្លៃនៃសេវាកម្មដោះដូរនេះ ឧទាហរណ៍ ដូចការប្តូរដុល្លាយកហ្វ្រង់។ ការដោះដូរនេះមានសារៈសំខាន់ណាស់ចំពោះអ្នកធ្វើដំណើរនៅក្នុងសម័យមុនក៏ដូចជាបច្ចុប្បន្នដែរ ព្រោះអ្នកធ្វើដំណើរអាចរស់នៅបានលុះត្រាតែគេទទួលបាននៅរូបិយប័ណ្ណប្រទេសដែលគេរស់នៅនោះ។

**ការទិញប័ណ្ណពាណិជ្ជកម្ម និងផ្តល់ឥណទានដល់អាជីវកម្ម:** ពួកអាជីវករ និងអ្នកលក់ដូរតែងតែលក់បំណុលរបស់ខ្លួនក្នុងទំរង់ជាប័ណ្ណពាណិជ្ជកម្ម ដើម្បីទទួលបាននូវសាច់ប្រាក់ភ្លាមៗ។ ធនាគារបានផ្តល់នូវឥណទានដល់អាជីវកម្ម ដើម្បីទិញទំនិញ ឬក៏សាងសង់មូលដ្ឋានពាណិជ្ជកម្ម។

**ទទួលយកប្រាក់បញ្ញើសញ្ជ័យ:** ការឱ្យឥទានបានផ្តល់ប្រាក់ចំណេញដល់ធនាគារ ហេតុនេះហើយធនាគារស្វែងរកប្រភពមូលធនផ្សេងទៀតដែលអាចឱ្យខ្ចីបាន។ ប្រភពមួយដែលមាននៅក្នុងប្រតិបត្តិការធនាគារគឺការទទួលយកប្រាក់បញ្ញើសញ្ជ័យ គឺប្រាក់ដែលមានការប្រាក់ត្រូវបានគេទុកនៅក្នុងធនាគារ ក្នុងរយៈពេលមិនកំណត់ មួយសប្តាហ៍ មួយខែ ឬមួយឆ្នាំ។ នៅក្នុងសម័យបុរាណក្រិចធនាគារបានផ្តល់ការប្រាក់រហូតដល់ 6 ភាគរយក្នុងមួយឆ្នាំ ដើម្បីលើកទឹកចិត្តដល់អ្នកផ្ញើរប្រាក់ ហើយផ្តល់ឥណទានកប៉ាល់ដល់អ្នកនៅក្នុងតំបន់សមុទ្រមេឌីទែរ៉ានេ ដែលមានអត្រាការប្រាក់ 2 ឬ 3 ដងច្រើនជាងការប្រាក់បញ្ញើ។

**ជាកន្លែងរក្សាទុករបស់មានតម្លៃ:** នៅក្នុងយុគសម័យកណ្តាលធនាគារចាប់ផ្តើមទទួលយកមាស និងវត្ថុមានតម្លៃផ្សេងទៀត ដែលជាទ្រព្យសម្បត្តិរបស់អតិថិជននៅក្នុងឃ្លាំងរបស់ធនាគារ។

ហើយធនាគារបានចេញបង្កាន់ដៃឱ្យអតិថិជនរបស់ខ្លួន ដោយចាត់ទុកជាបញ្ញើរបស់មានតម្លៃទាំងនោះ។ បង្កាន់ដៃនេះត្រូវបានគេចរចរ ដូចប្រាក់ ដូច្នោះដែរ។ បច្ចុប្បន្ននេះ ការរក្សាទុករបស់មានតម្លៃទាំងនោះរហូតដល់អតិថិជនត្រូវការ នៅក្នុងបន្ទប់ចាក់សោជិត។

**គាំទ្រសកម្មភាពរបស់រដ្ឋាភិបាលតាមរយៈឥណទាន** នៅក្នុងយុគសម័យកណ្តាល និងនៅពេលចាប់ផ្តើមនៃបដិវត្តឧស្សាហកម្ម ធនាគារបានចាប់ផ្តើមចល័តមូលធនរបស់ខ្លួន ហើយផ្តល់ឥណទានច្រើនទៅដល់អាជីវកម្ម ដែលធ្វើឱ្យមានការចាប់អារម្មណ៍នៅក្នុងរដ្ឋាភិបាល នៅក្នុងទ្វីបអឺរ៉ុប និងអាមេរិក។ ធនាគារត្រូវបានគេដាក់ឱ្យនៅក្នុងច្បាប់ដែលអាចទិញសញ្ញាប័ណ្ណ (Bond) របស់រដ្ឋាភិបាលដោយប្រើប្រាស់ចំណែកមួយនៃប្រាក់បញ្ញើ។ នៅឆ្នាំ 1781 Bank of North America ត្រូវបានកំណត់ដោយសភារដ្ឋហ្វីដែលឡាហ្វី ក្នុងការជួយប្រាក់ដល់ចនលាការតស៊ូរំលំរបស់អង់គ្លេស ហើយបង្កើតសហរដ្ឋអាមេរិក។ ដូចគ្នានេះដែរនៅក្នុងសម័យសង្គ្រាមស៊ីវិល សភាអាមេរិកបានដាក់ច្បាប់មួយចំពោះប្រព័ន្ធធនាគារ ដែលតម្រូវឱ្យគ្រប់ធនាគាររដ្ឋ (State Bank) ទាំងអស់ទិញ Bond រដ្ឋាភិបាល ហើយប្រាក់នេះត្រូវបានប្រើប្រាស់នៅក្នុងសង្គ្រាម។

**ផ្តល់សេវាកម្ម គណនីមូលប្បទានប័ត្រ (ប្រាក់បញ្ញើគ្មានកាលកំណត់)** បដិវត្តឧស្សាហកម្មនៅអឺរ៉ុប និងនៅសហរដ្ឋអាមេរិក នាំទៅដល់ការកែប្រែថ្មីក្នុងការអនុវត្តន៍ការងារធនាគារ និងសេវាកម្ម។ សេវាកម្មថ្មីក្នុងពេលនោះគឺប្រាក់បញ្ញើគ្មានកាលកំណត់ (Demand Deposit) ដែលជាគណនីមូលប្បទានប័ត្រ គណនីប្រភេទនេះអនុញ្ញាតឱ្យសរសេរជាប័ណ្ណ ដើម្បីទូទាត់ទំនិញ និងសេវាកម្ម ហើយធនាគារត្រូវទទួលយកប័ណ្ណនេះភ្លាមៗ។ សេវាកម្មនេះមានសារៈសំខាន់ណាស់សម្រាប់ឧស្សាហកម្ម ពីព្រោះវាអាចបង្កើននូវប្រសិទ្ធិភាពនៃដំណើរការទូទាត់ ធ្វើឱ្យដំណើរការអាជីវកម្មងាយស្រួលជាងរហ័សជាង និងសុវត្ថិភាពជាង។ បច្ចុប្បន្ន មូលប្បទានប័ត្រ គណនីបានពង្រីកទៅដល់

**ផ្តល់** Trust Services : ជាច្រើនឆ្នាំកន្លងមកហើយធនាគារបានចាត់ចែងការងារហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់បុគ្គល ឬក្រុមហ៊ុន ដោយទទួលបានកំរៃជើងសារទៅតាមចំនួនប្រាក់ ឬតំលៃនៃវត្ថុដែលធនាគារនោះគ្រប់គ្រង។ មុខងារចាត់ចែងទ្រព្យសម្បត្តិនេះត្រូវបានផ្តល់ឱ្យក្រុមហ៊ុន ឬអាជីវកម្មត្រូវបានគេហៅថា Commercial Trust Services។

## ១.៥.៤.សេវាកម្មដែលធនាគារផ្តល់ក្នុងពេលបច្ចុប្បន្ន

**ផ្តល់ឥណទានដល់អ្នកប្រើប្រាស់:** នៅក្នុងប្រវត្តិសាស្ត្រធនាគារមិនយកចិត្តទុកដាក់ក្នុងការឱ្យឥណទានទៅបុគ្គល ឬគ្រួសារទេ ដោយគេយល់ថាឥណទានប្រភេទនេះតូចពេកហើយមានហានិភ័យមិនសងខ្ពស់ ដែលបណ្តាលឱ្យធនាគារពុំមានប្រាក់ចំណេញ។ នៅក្នុងដើមសតវត្សនេះ ធនាគារផ្អែកទាំងស្រុងទៅលើប្រាក់បញ្ញើ ដើម្បីផ្តល់ឥណទានធំៗដល់ក្រុមហ៊ុន។ ក្រោយមកដោយមានការប្រកួតប្រជែងខ្លាំងពេក ធនាគារបានងាកទៅរកអ្នកប្រើប្រាស់ ហើយចាត់ទុកពួកគេជាអតិថិជន ដែលមានការស្មោះត្រង់ជាងក្រុមហ៊ុន។

នៅក្នុងទសវត្សឆ្នាំ 1920 និង 1930 ធនាគារនាំមុខគេមួយចំនួន ដូចជា Citicorp, Bank of America បានបង្កើតឡើងនូវផ្នែកឱ្យខ្ចីទៅអ្នកប្រើប្រាស់មួយដ៏រឹងមាំ។ បន្ទាប់ពីសង្គ្រាមលោកលើកទី 2 ឥណទានអ្នកប្រើប្រាស់បានកើនឡើងខ្លាំង។ ហើយអត្រានៃការកើនឡើងទើបតែថយចុះក្នុងពេលថ្មីៗនេះទេ ដោយសារធនាគារមានការប្រកួតប្រជែងខ្លាំង នៅក្នុងសេវាកម្មនេះ ហើយកំណើនសេដ្ឋកិច្ចក៏ធ្លាក់ចុះ។ តែទោះបីជាយ៉ាងណាក៏ដោយ អ្នកប្រើប្រាស់នៅតែជាប្រភពទុនសំខាន់របស់ធនាគារ និងជាប្រភពចំណូលដ៏សំខាន់របស់ធនាគារ។

**ការផ្តល់ដំបូន្មានផ្នែកហិរញ្ញវត្ថុ:** តាំងពីយូរណាស់មកហើយ ធនាគារត្រូវបានអតិថិជនសុំយោបល់ ជាពិសេសនៅពេលដែលអតិថិជនប្រើប្រាស់ឥណទាន និងប្រាក់សន្សំ ឬក៏វិនិយោគ។ បច្ចុប្បន្ននេះ ធនាគារជាច្រើនបានផ្តល់នូវសេវាកម្មប្រឹក្សាហិរញ្ញវត្ថុជាច្រើន ចាប់ពីការរៀបចំចំណូលពន្ធជា ផែនការហិរញ្ញវត្ថុសំរាប់បុគ្គលម្នាក់ៗ រហូតទៅដល់សេវាកម្មប្រឹក្សាអំពីឱកាសទីផ្សារ នៅក្នុងនៅក្រៅប្រទេស សំរាប់អតិថិជនរបស់ខ្លួន។

**ការគ្រប់គ្រងសាច់ប្រាក់:** ធនាគារបានរកឃើញថា ការងារដែលគេធ្វើរាល់ថ្ងៃជាសេវាកម្មដ៏មានតំលៃសំរាប់អតិថិជនរបស់ខ្លួន ឧតាហរណ៍ដែលលេចធ្លោជាងគេគឺសេវាកម្មគ្រប់គ្រងសាច់ប្រាក់។ ធនាគារត្រូវបានគេអនុញ្ញាតឱ្យប្រមូលសាច់ប្រាក់ បើកឱ្យក្រុមហ៊ុន ហើយប្រើប្រាស់សាច់ប្រាក់សល់នេះទៅវិនិយោគក្នុងមូលប័ត្ររយៈពេលខ្លី ឬផ្តល់ឥណទាន រហូតដល់សាច់ប្រាក់ត្រូវបានគេដក។

**ផ្តល់ការជួលឧបករណ៍:** ធនាគារជាច្រើនបានផ្តល់សេវាកម្មជួលឧបករណ៍ជំនួសការទិញវិញ។ ធនាគារ និងទិញឧបករណ៍ដែលអតិថិជនរបស់ខ្លួនត្រូវការ ហើយជួលទៅឱ្យអតិថិជននោះវិញ។ ច្បាប់ទាមទារឱ្យអតិថិជនប្រើប្រាស់សេវាកម្ម ជួលឧបករណ៍នោះ ដើម្បីធ្វការទូទាត់ដែលពេលខ្លះអាចសងស្មើនឹងតម្លៃទំនិញទាំងមូលនៃឧបករណ៍នោះ ហើយទទួលខុសត្រូវក្នុងជួសជុល និងបង់ពន្ធ។

**លក់សេវាកម្មធានារ៉ាប់រង:** ជាច្រើនឆ្នាំមកហើយធនាគារលក់សេវាធានារ៉ាប់រងទៅឱ្យអតិថិជនដែលខ្ចីប្រាក់ពីធនាគារ ដូច្នេះហើយប្រាក់ធានារ៉ាប់រងត្រូវបានគេប្រើប្រាស់ជាវត្ថុធានា នៅពេលដែលអតិថិជនស្លាប់ ឬពិការ។ នៅប្រទេសអាមេរិកច្បាប់បានហាមប្រាមមិនឱ្យធនាគារពាណិជ្ជផ្តល់សេវាធានារ៉ាប់រងច្រើនប្រភេទទេ។ ធនាគារភាគច្រើនសង្ឃឹមថា នឹងអាចផ្តល់នូវសេវាធនារ៉ាប់រងជីវិត និងការខូចខាតទ្រព្យសម្បត្តិ។ បច្ចុប្បន្ននេះ ធនាគារលក់គោលនយោបាយធនារ៉ាប់រង ដោយអនុញ្ញាតឱ្យក្រុមហ៊ុនធានារ៉ាប់រងដាក់ការិយាល័យនៅកន្លែងទទួលភ្ញៀវរបស់ខ្លួន ហើយទទួលបានចំណែកពីការលក់សេវានេះ។

**លក់ផែនការសោធននិវត្តៈ** ធនាគារ មានតួនាទីយ៉ាងសកម្មក្នុងការគ្រប់គ្រងសោធននិវត្តិ ដែលក្រុមហ៊ុនចាច្រើនបានផ្តល់ទៅឱ្យបុគ្គលិករបស់ខ្លួន។ ធនាគារបានវិនិយោគប្រាក់ដែលទទួលហើយសងទៅឱ្យអ្នកដែលត្រូវទទួលបានប្រាក់សោធននិវត្តន៍នេះ នៅពេលដែលគេដល់អាយុ ឬក៏ធ្លាក់ខ្លួនពិកាដោយប្រការណាមួយ។

**ផ្តល់សេវាកម្មជាអន្តរការីនៃការវិនិយោគមូលប័ត្រៈ** នៅក្នុងទីផ្សារហិរញ្ញវត្ថុធនាគារបានព្យាយាម ក្លាយខ្លួនជាហាងហិរញ្ញវត្ថុ (Financial Department Store) ដែលផ្តល់នូវសេវាច្រើន

ប្រភេទ ហើយអាចឱ្យអតិថិជនជ្រើសរើសនូវផលិតផលដែលខ្លួនត្រូវការ។ នេះគឺជាមូលហេតុមួយដែលធ្វើឱ្យធនាគារចាប់ផ្ដើមលក់សេវាកម្ម ជាអ្នកកណ្ដាល។ ធនាគារផ្ដល់ឱកាសឱ្យទៅអតិថិជនរបស់ខ្លួន ដើម្បីទិញភាគហ៊ុន សញ្ញាប័ណ្ណ និងមូលប័ត្រផ្សេងៗ ដោយមិនចាំបាច់ទាក់ទងផ្ទាល់នឹងអាជីវកម្មមូលប័ត្រ។ ក្នុងករណីខ្លះ ធនាគារបានទិញក្រុមហ៊ុនកួកជេ (Brokerage Company) ឬក៏បង្កើតក្រុមហ៊ុនចំរុះជាមួយក្រុមហ៊ុនគួកជេ។

**ផ្ដល់សង្គហធន និងធនលាភ** (Mutual Funds and Annuities) ទាក់ទងទៅនឹងការឱ្យការប្រាក់ទាបរបស់ធនាគារលើការប្រាក់បញ្ញើ មានអតិថិជនជាច្រើនចង់បានផលិតផលមួយ ដែលគេហៅថា ផលិតផលវិនិយោគពីធនាគាររបស់ខ្លួន ជាពិសេសគឺសង្គហធន ហើយនិងធនលាភ ដែលផ្ដល់ចំណូលខ្ពស់លើប្រាក់បញ្ញើធម្មតា ទោះបីជាមានហានិភ័យខ្ពស់ជាងក៏ដោយ។ ធនលាភ រួមមានផែនការសញ្ច័យធនរយៈពេលវែងដែលសន្យាសងវិញជាចរន្តដល់ម្ចាស់ធនលាភ ដែលចាប់ផ្ដើមនៅចំណុចមួយនាពេលអនាគត (ឧទាហរណ៍ ពេលចូលនិវត្តន៍)។ ផ្ទុយមកវិញ សង្គហធនត្រូវបានគ្រប់គ្រងដោយពួកអ្នកដែលមានអាជីពហិរញ្ញវត្ថុ។ ប្រាក់ត្រូវបានគេប្រើប្រាស់ត្រូវបានគេប្រើប្រាស់ដើម្បីទិញប័ណ្ណភាគហ៊ុន សញ្ញាប័ណ្ណ និងមូលប័ត្រ ផ្សេងៗទៀតដែលឆ្លើយតបទៅនឹងគោលដៅរបស់ប្រាក់នោះ។

**ផ្ដល់សេវាកម្ម ធនាគារវិនិយោគ** (Investment Banking) **និងសេវាកម្មធនាគារ** Merchant Bank សេវាកម្មធនាគារវិនិយោគ និងMerchant Bank រួមមាន ការបង្ហាញពីលទ្ធផលនៃការរួមបញ្ចូលគ្នារបស់ក្រុមហ៊ុន ការទិញក្រុមហ៊ុនអាជីវកម្មមូលប័ត្រ ផ្ដល់យោបល់ខាងយុទ្ធសាស្ត្រទីផ្សារ ផ្ដល់សេវាhedging ដល់អតិថិជន ដើម្បីលុបបំបាត់ហានិភ័យដែលកើតឡើងពីការឡើងចុះតម្លៃរូបិយវត្ថុ និងអត្រាការប្រាក់។ ធនាគារក៏បានចូលទៅយ៉ាងជ្រៅទៅក្នុងទីផ្សារធនាគារគាំទ្រ ការបោះពុម្ពបំណុលរបស់អាជីវកម្ម និងអតិថិជនជារដ្ឋាភិបាល ហេតុនេះហើយពួកអាចខ្ចីប្រាក់ពីទីផ្សារនូវតម្លៃទាប ឬស្ថាប័នឱ្យខ្ចីផ្សេងៗ។

## ១.៦.បណ្ដានិន្នាការដែលកំពុងជះឥទ្ធិពលលើធនាគារ

ការអង្កេតបានបង្ហាញថា ធនាគារកំពុងតែមានការផ្លាស់ប្ដូរទាំងមុខងារ និងទំរង់។ ការប្រែប្រួលនេះមានសារៈសំខាន់ណាស់ ដែលផ្នែកវិភាគជាច្រើនហៅនិន្នាការនេះថា ជាបដិវត្តធនាគារ។ ធនាគារជំនាន់ថ្មីអាចខុសគ្នាទាំងស្រុងពីធនាគារសព្វថ្ងៃ។

**ការសាយភាយសេវាកម្ម:** ដូចដែលបានបង្ហាញនៅក្នុងផ្នែកមុនៗ អនាគារមានការពង្រីកនូវសេវាកម្មហិរញ្ញវត្ថុរបស់ខ្លួនយ៉ាងឆាប់រហ័ស ការនេះត្រូវបានគេបង្កើននៅពេលថ្មីៗនៅក្រោមសម្ពាពនៃការកើនឡើងនៃការប្រកួតប្រជែង (ពីបណ្ដាស្ថាប័នហិរញ្ញវត្ថុផ្សេងៗទៀត)។ ការកើនឡើងផ្នែកចំណេះដឹង និងការទាមទារពីអតិថិជន និងការផ្លាស់ប្ដូរផ្នែកបច្ចេកវិជ្ជា។ ការពង្រីកសេវាកម្មក៏បានបង្កើនការចំណាយ និងហានិភ័យដល់ធនាគារផងដែរ។ សេវាកម្មថ្មីនេះមានឥទ្ធិពលល្អដល់ឧស្សាហកម្មធនាគារ

ដែលធ្វើឱ្យធនាគារទទួលបាននូវប្រភពចំណូលថ្មី និងមានការកើនឡើងដូចចំណូលដែលបានពីការប្រាក់ផងដែរ។

**ការកើនឡើងការប្រកួតប្រជែង:** ភាពខ្លាំងក្លានៃការប្រកួតប្រជែងបានកើនឡើង នៅពេលដែកធនាគារ និងដៃគូរប្រចែងបានពង្រីកសេវាកម្មរបស់ខ្លួន។ ធនាគារក្នុងស្រុកផ្តល់សេវាកម្មអាជីវកម្មឥណទាន សញ្ញ័យ ផែនការសោធននិវត្តន៍ និងសេវាប្រឹក្សាផ្នែកហិរញ្ញវត្ថុ ដែលប្រឈមមុខដោយផ្ទាល់ពីបណ្តាធនាគារ និងស្ថាប័នផ្សេងទៀត ដែលផ្តល់សេវាកម្មនោះដែរ។ ស្ថាប័នទាំងនោះរួមមាន សហព័ន្ធឥណទាន ក្រុមហ៊ុនមូលប័ត្រ (Merrill Lynch) , ក្រុមហ៊ុនហិរញ្ញវត្ថុ និងក្រុមហ៊ុនធានារ៉ាប់រង។ សម្ពាធនៃការប្រកួតប្រជែងបែបនេះ នឹងជំរុញឱ្យមានសេវាកម្មកាន់តែច្រើនក្នុងពេលអនាគត។

**ការលុបបំបាត់និយ័តកម្ម:** ការសាយភាយសេវាកម្ម និងការកើនឡើងការប្រកួតប្រជែងក៏បណ្តាលមកពីការលុបបំបាត់និយ័តកម្ម ដែលបន្ថយនូវការគ្រប់គ្រងរបស់រដ្ឋាភិបាល ចំពោះឧស្សាហកម្មហិរញ្ញវត្ថុ។ ការបន្ថយនិយ័តកម្ម រួមមានការលុបចោលការដាក់កំហិតលើអត្រាការប្រាក់ខ្ពស់បំផុត (Celling Rate) ចំពោះប្រាក់បញ្ញើសញ្ញ័យ។ នៅពេលជាមួយគ្នានេះដែរធនាគារបានផ្តល់នូវសេវាកម្មថ្មីៗដូចជា ប្រាក់បញ្ញើចរន្តដែលអនុញ្ញាតឱ្យសាធារណជនទទួលបានប្រាក់ពីគណនីទូទាត់របស់ខ្លួន។ ទន្ទឹមគ្នានេះដែរ គូប្រជែងរបស់ធនាគារក៏អនុញ្ញាតឱ្យពង្រីកសេវាកម្មរបស់ខ្លួនដែរ។ ប្រទេសធំៗមួយចំនួនដូចជា អូស្ត្រាលី កាណាដា អង់គ្លេស និងជប៉ុន ក៏បានចូលរួមក្នុងការលុបបំបាត់និយ័តភាពនេះដែរ ហើយបានពង្រីកតួនាទីផ្លូវច្បាប់ដល់ធនាគារ អាជីវកម្មមូលប័ត្រ និងក្រុមហ៊ុនសេវាកម្មហិរញ្ញវត្ថុផ្សេងៗទៀត ព្រមទាំងជំរុញឱ្យធនាគារចំណាយប្រាក់ច្រើនជាង និងបង្កើនហានិភ័យចំពោះឧស្សាហកម្មនេះ។

**ការកើនឡើងការចំណាយចំពោះមូលធន:** ការលុបបំបាត់និយ័តកម្ម និងការកើនឡើងការប្រកួតប្រជែង បាននាំទៅដល់ការកើនឡើង ការចំណាយចំពោះការលក់ប្រាក់បញ្ញើ (ដែលជាប្រភពមូលធនរបស់ធនាគារ)។ ការលុបចោលនិយ័តកម្ម បានបង្ខំធនាគារឱ្យចំណាយការប្រាក់ចំពោះប្រាក់បញ្ញើជុំ។ នៅពេលដូចគ្នា រដ្ឋាធិបាលជំរុញឱ្យធនាគារប្រើប្រាស់មូលធនផ្ទាល់ឱ្យបានច្រើន ដើម្បីបង្កើនទ្រព្យរបស់ខ្លួន។ ការប្រើប្រាស់ប្រភពដ៏មានតម្លៃនេះបានបង្ខំឱ្យធនាគារស្វែងរកមធ្យោបាយដើម្បីកាត់បន្ថយនូវការចំណាយរបស់ខ្លួន ដូចជា កាត់បន្ថយបុគ្គលិក ប្តូរឧបករណ៍ចាស់ៗ ទន្ទឹងនេះដែរ ធនាគារបានស្វែងរកប្រភពផ្សេងទៀតដែរ ដូចជា មូលប័ត្រតូបនីយកម្ម ដែលឥណទានត្រូវបានដាក់បញ្ចូលគ្នាហើយដកចេញពីតារាងតុល្យការ។ មូលប័ត្រដែលគាំទ្រដោយកញ្ចប់ឥណទាន ត្រូវបានគេលក់ក្នុងទីផ្សារសេរីដើម្បីបង្កើនមូលធន។ ប្រភពនេះអាចថោកជាង និងទុកចិត្តបាន ហើយទទួលបានកម្រៃច្រើនជាងប្រភពមូលធនដែលធ្លាប់ប្រើ។

**ការកើនឡើងភាពចំរុះនៃមូលធនដែលមានរំញោចការប្រាក់:** ការលុបបំបាត់និយ័តភាពនៅក្នុងឧស្សាហកម្មធនាគារធ្វើឱ្យអតិថិជនតទួលបាននូវអត្រាការប្រាក់ខ្ពស់ជាង។ អតិថិជនបានចល័តប្រាក់របស់ខ្លួនគណនី ដែលពីមុនទទួលបានការប្រាក់ទាប ទៅគណនីដែលមានការប្រាក់ខ្ពស់ជាង ហើយផ្លាស់ប្តូរទៅតាមស្ថានភាពទីផ្សារ ធនាគារបានរកឃើញថា ពួកគេកំពុងតែប្រឈមមុខជាមួយអតិថិជន

ដែលមានការអេប់រំខ្ពស់ និងដឹងពីការប្រែប្រួលអត្រាការប្រាក់។ បច្ចុប្បន្ននេះ អ្នកផ្ញើប្រាក់អាចត្រូវបានគេទាក់ទាញដោយគូរប្រកួតប្រជែងដែលផ្តល់ការប្រាក់ខ្ពស់ ហេតុនេះហើយធនាគាររឹត តែត្រូវខំប្រឹងដើម្បីឱ្យមានប្រៀបប្រកួតប្រជែងនូចអ្វីដែលគេបានផ្តល់ឱ្យទៅសាធារណៈជន ហើយត្រូវតែផ្លាស់ប្តូរទៅតាមចំណង់ចំណូលចិត្តរបស់អតិថិជនដែលទាក់ទងទៅនឹងការចែកចាយធនធាន។

**បដិវត្តបច្ចេកវិជ្ជាៈ** នៅក្នុងពេលថ្មីៗនេះធនាគារបានប្រឈមមុខ និងប្រតិបត្តិការចំណាយខ្ពស់ដែលនាំទៅដល់ការកើនឡើងប្រព័ន្ធស្វ័យប្រវត្តិ និងអេឡិចត្រូនិច ដើម្បីជំនួសប្រព័ន្ធប្រើកម្លាំងមនុស្សជាពិសេស ការទូទាត់ចំណាយ និថផ្តល់ឥណទាន។ លេចធ្លោជាងគេគឺ ATM (Automated Teller-Machines) នៅសហរដ្ឋអាមេរិកបច្ចុប្បន្ន មាន ATM ច្រើនជាង 100 000។ POS (point-of-sale) ជាឧបករណ៍នៅក្នុងហាងលក់ដូរដែលជំនួសការទូទាត់ដោយក្រដាស ហើយប្រព័ន្ធកុំព្យូទ័រដំណើរការប្រតិបត្តិការរាប់ពាន់នៅជុំវិញពិភពលោក។

ដូច្នេះហើយធនាគារ បានក្លាយទៅជាឧស្សាហកម្មផ្អែកទៅលើមូលធនច្រើន និងការចំណាយថេរច្រើន ហើយប្រើប្រាស់ពលកម្មមនុស្ស និងចំណាយប្រែប្រួលតិច។ អ្នកជំនាញការមានជំនឿថា ផលិតកម្ម សេវាកម្ម និងការផ្តល់សេវាកម្ម និងការផ្តល់សេវាកម្ម ត្រូវបានគេប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិដែលនាំទៅដល់លើការចំណាយមយឯកតា។ វានឹងនាំទៅដល់ដល់ធនាគារដែលគ្មានប្រើមនុស្ស និងភាពបាត់បង់ការងារ ប៉ុន្តែអតិថិជននៅតែចូលចិត្តមនុស្សផ្តល់សេវាកម្ម ព្រោះពួកគេអាចសួរពីសេវាកម្មដោយផ្ទាល់។

**ការរួមផ្គុំ និងការពង្រីកផ្នែកភូមិសាស្ត្រៈ** ការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិទាមទារឱ្យមានសេវាកម្មច្រើន ហេតុនេះហើយធនាគារត្រូវតែបង្កើនអតិថិជនរបស់ខ្លួនដោយពង្រីកប្រតិបត្តិការរបស់ខ្លួនទៅទីផ្សារឆ្ងាយៗ និងបង្កើនចំណាយគណនី។ សាខាធនាគារបានកើនឡើងយ៉ាងឆាប់រហ័ស និងការបង្កើតឡើងនូវក្រុមហ៊ុនធនាគារដែលបានទិញធនាគារតូចៗ ហើយបានបង្កើតនូវក្រុមហ៊ុនធនាគារដែលបានទិញធនាគារតូចៗ ហើយបានបង្កើតនូវស្ថាប័នដែលធនាគារមានការិយាល័យច្រើន។ ដូចគ្នានេះដែរ ធនាគារធំៗជាច្រើនក៏បានបញ្ចូលគ្នា ហើយក្លាយជាធនាគារធំៗ ដូចជា Chemical Bank និង Chase Manhattan Bank, Bank of America និង Nations Bank។ ចំនួនធនាគារដែលមានម្ចាស់ទោលបានថយចុះ ចំណែកធនាគារដែលមានទំហំកណ្តាលបានកើនឡើងគួរឱ្យកត់សម្គាល់។

សកលភាវូបនីយកម្មនៃធនាគារៈ ការពង្រីកផ្នែកភូមិសាស្ត្រ និងការប្រមូលផ្តុំរបស់ធនាគារបានទៅដល់នៅសកលភាវូបនីយកម្ម។ បច្ចុប្បន្នធនាគារធំៗនៅក្នុងពិភពលោកប្រកួតប្រជែងគ្នាគ្រប់ទ្វីប។ នៅឆ្នាំ 1980 ធនាគារជប៉ុន នាំមុខដោយ Dai-Ichi-Kangyo Bank និង Fuji Bank បានកើនឡើងលឿនជាងគូប្រែងក្នុងពិភពលោក។ ការលុបបំបាត់និយ័តកម្មបានជួយដល់ស្ថាប័នទាំងនេះប្រកួតប្រជែងជាមួយធនាគារអាមេរិក។

**បង្កើនហានិភ័យនៃភាពបរាជ័យរបស់ធនាគារ** និងធ្វើឱ្យប្រព័ន្ធប្រាក់បញ្ញើរបស់រដ្ឋាភិបាលចុះខ្សោយៈ ការប្រមូលផ្តុំ និងការពង្រីកផ្នែកភូមិសាស្ត្របានសម្រួលធនាគារជាច្រើនពីការទទួលលក្ខខណ្ឌសេដ្ឋកិច្ចក្នុងតំបន់ ប៉ុន្តែការកើនឡើងការប្រកួតប្រជែងរវាងធនាគារ និងស្ថាប័នមិនមែនធនាគារ បាន

បង្កើនបញ្ហាជាមួយឥណទាន និងភាពមិនស្ថិតស្ថេររបស់សេដ្ឋកិច្ច ដែលអាចនៃទៅដល់ភាពបរាជ័យរបស់ធនាគារនៅលើពិភពលោក។ ការបំបាត់និយ័តកម្មលើវិស័យហិរញ្ញវត្ថុ បានពង្រីកឱកាសរបស់ធនាគាររីក ប៉ុន្តែវាស្មើនឹងការចំណាយនៃការបង្កើតនូវភាពមិនជាក់លាក់លើទីផ្សារហិរញ្ញវត្ថុ ដែលធនាគារអាចបរាជ័យ និងរំលាយ។

# មេរៀនទី២
# គោលនយោបាយរបស់រដ្ឋាភិបាល និងនិយ័តកម្មលើធនាគារ

## ២.១.និយ័តកម្មធនាគារ

ធនាការទាំងអស់ធ្វើប្រតិបត្តិការនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុ ដោយផ្តល់នូវឥណទានទទួលប្រាក់បញ្ញើ និងផ្តល់នូវសេវាកម្មផ្សេងៗទៀត ធនាគារធ្វើការនៅក្រោមបរិយាកាសនៃនិយ័តកម្មដែលគេបង្កើតឡើង ដើម្បីការពារនូវប្រយោជន៍សាធារណៈជន។ នៅសហរដ្ឋ ពួកធនាគាររិកបាននិយាយថា លិខិត FDIC (Federal Deposit Insurance Corporation) មានន័យថា ការកើនឡើងតម្រូវការផ្នែកមូលធនមិនចេះចប់។ សម្រាប់ធនាគារអាមេរិក FDIC និងភ្នាក់ងារនិយ័តកម្មផ្សេងទៀត ហាក់ដូចជាត្រូវការអ្វីៗទាំងអស់មិនចេះចប់ ដូចជាមូលធន របាយការណ៍ សេវាកម្មសាធារណៈ។ ល។ គ្មានធនាគារណាមួយចូលក្នុងឧស្សាហកម្មនេះ ដោយគ្មានការអនុញ្ញាតពីរដ្ឋាភិបាលឡើយ។ ប្រភេទទាំងអស់នៃប្រាក់បញ្ញើ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងៗដែលធនាគារលក់ ដើម្បីបង្កើនមូលធនត្រូវទទួលរងទណ្ឌកម្មពីគ្រប់ភ្នាក់ងារនិយ័តកម្មធនាគារ។ ធនាគារតាំងអស់ត្រូវទទួលការអនុញ្ញាតជាមុននិយ័តកម្មទៅលើគុណភាពនៃឥណទាន វិនិយោគ និងការពង្រីកអគារ ការបញ្ចូលគ្នា ការពង្រីកសាខាទិញ ឬបង្កើតស្ថាប័នមិនមែនធនាគារ។ ម្យ៉ាងទៀតធនាគារមិនមានសិទ្ធបិទទ្វារធនាគាររបស់ខ្លួន ហើយដើរចេញដោយគ្មានការអនុញ្ញាត ជាពិសេសភ្នាក់ងាររបស់រដ្ឋាភិបាលដែលបានផ្តល់ការអនុញ្ញាតឱ្យបើកធនាគារនោះឡើយ។

### ២.១.១.មូលហេតុនៃនិយ័តកម្មទៅលើធនាគារ

មានហេតុផលច្រើនណាស់លើការត្រួតពិនិត្យដ៏ធ្ងន់ធ្ងររបស់រដ្ឋាភិបាល ហេតុផលខ្លះមានអាយុកាលរាប់សតវត្សមកហើយ។

ទី 1: ធនាគារជាកន្លែងដែលសាធារណៈជនទុកប្រាក់បញ្ញើរបស់ខ្លួន រួមមានប្រាក់បញ្ញើរបស់បុគ្គល និងរបស់ក្រុមគ្រួសារ។ ប្រាក់បញ្ញើសញ្ជ័យរបស់សាធារណៈជនមានរយៈពេលខ្លី ហើយជាចដកក្នុងរយៈពេលឆាប់ ធនាគារក៏ទទួលនៅប្រាក់បញ្ញើរយៈពេលវែងដែរ ដូចជាគណនីសោធននិវត្តន៍។ ការបាត់បង់ប្រាក់តាំងនេះដោយចោរកម្ម ឬក៏ការបរាជ័យក្នុងជំនួញ និងបង្កការលំបាកដល់បុគ្គលម្នាក់ៗដូចជាក្រុមគ្រួសារ។ ដោយអ្នកធ្វើភាគច្រើនខ្វះជំនាញ និងព័ត៌មានក្នុងការវាយតម្លៃធនាគារឱ្យបានត្រឹមត្រូវ ហេតុនេះហើយភ្នាក់ងារនិយ័តកម្មបានយកកម្រៃការទទួលខុសត្រូវក្នុងការប្រមូល និងវិភាគព័ត៌មានដើម្បីវាយតម្លៃអំពីហិរញ្ញវត្ថុរបស់ធនាគារ និងការពារផលប្រយោជន៍សាធារណៈជន។ ការការពារទាំងនោះ រួមមានការដាក់ម៉ាស៊ីនថត និងសន្តិសុខគារពារធនាការដើម្បីការពារចោរកម្ម ការត្រួតពិនិត្យ និងសវនកម្ម ដើម្បីកម្រិតការខាតពីការប្រើប្រាស់ប្រាក់មិនសមរម្យ ឬក៏បន្លំ ការផ្តល់ឥទានរបស់រដ្ឋាភិបាលទៅធនាគារ នៅពេលដែលធនាគារនោះ ប្រឈមមុខនឹងការខ្វះខាតសាច់ប្រាក់ ដែលមិនអាចទស្សន៍ទាយបាន។

ទី 2: ធនាគារត្រូវបានគេអង្កេតយ៉ាងយកចិត្តទុកដាក់ ពីព្រោះអំណាចរបស់វាក្នុងការបង្កើតប្រាក់ក្នុងទំរង់ប្រាក់បញ្ញើ ហើយឱ្យឥណទាន និងវិនិយោគ។ ការផ្លាស់ប្តូររបស់ប្រាក់នៅក្នុងធនាគារ វាមានទំនាក់ទំនងជាមួយសេដ្ឋកិច្ច ជាពិសេសការកើនឡើងចំនួនអ្នកមានការងារ និងអវត្តមាននៃអតិផរណា។ តាមពិតទៅផលប៉ះពាល់ដល់សេដ្ឋកិច្ច ដែលបណ្តាលមកពីការប្រាក់របស់ធនាគារ មិនមែនជាមូលហេតុទេដរាបណាធនាគារកណ្តាល (អ្នកបង្កើតគោលនយោបាយ) អាចគ្រប់គ្រងប្រាក់របស់ជាតិទាំងមូលបានបរិមាណប្រាក់នៅក្នុងធនាគារនីមួយៗ មិនមែនជាបញ្ហាគួរឱ្យបារម្ភរបស់ភ្នាក់ងារនិយ័តកម្ម ឬក៏របស់សាធារណៈជនឡើយ។

ទី 3: ធនាគារត្រូវបានគេធ្វើនិយ័តកម្ម ពីព្រោះពួកគេផ្តល់ឱ្យបុគ្គលម្នាក់ៗ និងអាជីវកម្មនូវឥណទានសម្រាប់ការប្រើប្រាស់ នោងវិនោយោគ។ ភ្នាក់ងារនិយ័តកម្មគិតថាសាធារណៈជនយកចិត្តទុកដាក់ទៅលើការគ្រប់គ្រងឥណទានគ្រប់គ្រាន់ពីធនាគារ ហើយម្យ៉ាងទៀត មានការរើសអើងក្នុងការផ្តល់ឥណទានរបស់ធនាគារ អ្នកដែលត្រូវបានគេរើសអើងនិង្លូវជួបឧបសគ្គក្នុងការរស់នៅ និងការបង្កើនគុណភាពនៃជីវិត។ ជាការពិតណាស់បើសិនឥណទានត្រូវបានគេបដិសេធដោយការរើសអើងទៅលើអាយុកាល ភេទ ជនជាតិ និងកត្តាផ្សេងៗទៀត។ ប៉ុន្តែរដ្ឋាភិបាលអាចលុបបំបាត់ចោលនីការរើសអើងនេះ ដោយជំរុញការប្រកួតប្រជែង រវាងធនាគារ និងស្ថាប័នផ្តល់សេវាកម្មហិរញ្ញវត្ថុដ៏ទៃទៀត។

ទី 4: ធនាគារមានប្រវត្តិវែងឆ្ងាយទាក់ទងជាមួយរដ្ឋាភិបាល។ រដ្ឋាភិបាលផ្អែកយ៉ាងខ្លាំងទៅលើឥណទានថោកៗរបស់ធនាគារ ហើយនិងការដកពន្ធពីធនាគារ ផ្តល់ទៅឱ្យកងទ័ព និងការប្រើប្រាស់ផ្សេងៗដែលរដ្ឋាភិបាលមិនចង់យកពន្ធផ្ទាល់ពីប្រជាជន។ ថ្មីៗនេះរដ្ឋាភិបាលពឹងផ្អែកលើធនាគារដើម្បីអនុវត្តគោលនយោបាយសេដ្ឋកិច្ចដកពន្ធ និងការចែកចាយចំណាយរបស់រដ្ឋាភិបាល។ ហេតុផលនេះត្រូវបានគេប្រឆាំងថ្មីនេះ ព្រោះថាធនាគារអាចផ្តល់សេវាកម្មហិរញ្ញវត្ថុដល់រដ្ឋាភិបាល បើសិនវាមានចំណេញ សូម្បីតែគ្មាននិយ័តកម្ម។

នៅក្នុងសហរដ្ឋ និយ័តកម្មលើធនាគារត្រូវបានគេធ្វើតាមរយៈប្រពន្ធធនាគារ (Dual Banking System) គឺពីសំណាក់សហព័ន្ធ និងរដ្ឋ ដែលមានអំណាចយ៉ាងខ្លាំងលើនិយ័តកម្មធនាគារ។ ប្រព័ន្ធនេះត្រូវបានរៀបចំដើម្បីផ្តល់អំណាចដល់រដ្ឋនីមួយៗត្រួតពិនិត្យយ៉ាងជិតដល់ទៅលើប្រតិបត្តិការនៅក្នុងព្រំដែនរបស់វិស័យនេះ ហើយឆ្លងកាត់និយ័តកម្មរបស់សហព័ន្ធដែរ ដើម្បីបញ្ជាក់ថា ធនាគារត្រូវបានគេយកចិត្តទុកដាក់ដូចៗគ្នាក្នុងរដ្ឋនីមួយៗ និងសហគមន៍ ដែលធនាគារមានប្រតិបត្តិការ។ ភ្នាក់ងារនិយ័តកម្មរបស់សហរដ្ឋគឺ Comptroller of the Currency, The Federal Reserve System ហើយនឹង Federal Deposit Insurance Corporation។

តារាង២.១: Banking`s Principle Regulatory Agencies and Their Responsibilities

| |
|---|
| Federal Reserve System |
| • Supervises and regulary examines all State-Chartered Member banks and bank holding companies operating in the US. |
| • Imposes reserve requirements on deposits ( regulation D ) |
| • Must approve all applications of member bank to merge, establish branches or exercise trust powers. |
| • Charter, supervises and examines international banking corporations operating in United State. |
| Comptroller of the Currency |
| • Issues charters for new national banks. |
| • Supervises and regularly examines all national banks. |
| • Must approve all national bank application for new branch office, trust power, mergers, and acquisitions. |
| Federal Deposit Insurance Corporation |
| • Insures deposit of bank comforming to it regulations. |
| • Must approve all application of insures bank to estabilsh branches or exercise trust power. |
| • Requrie all insured bank to submit reports on their financial condition. |
| Department of Justice |
| • Must approve public offerings of debt and equity securities by bank or bank holding companies. |
| State Banking Boards or Commission |
| • Issue charters for new banks. |
| • Supervise and regularly examine all state chartered banks. |
| • Reserve the right to approve all applications of bank operating with in state borders to form a holding company acquire affiliates and subsidiaries or establish branch offices. |

## ២.១.២.ឥទ្ធិពលនៃនិយ័តកម្មទៅលើធនាគារ

នៅពេលដែលមូលហេតុនិយ័តកម្ម លើធនាគារត្រូវបានគេដឹងគ្រប់គ្នា ផលប៉ះពាល់នៃនិយ័តកម្មទៅលើធនាគារ ស្ថិតនៅក្នុងភាពមិនដាច់ស្រេចនៅឡើយ។ ទ្រឹស្តីដំបូងបំផុតនៃនិយ័តកម្ម ដោយ

អ្នកសេដ្ឋសាស្ត្រ George Stigler បានអះអាងថា ក្រុមហ៊ុនមួយនៅក្នុងឧស្សាហកម្ម ដែលត្រូវបានធ្វើនិយ័តកម្ម តាមពិតវាចង់បាននិយ័តកម្មពីរដ្ឋាភិបាល ពីព្រោះវាអាចនាំមកនូវផលប្រយោជន៍ ដែលបានមកពីភាពផ្តាច់មុខដែលបណ្តាលមកពីការរារាំងមិនឱ្យអ្នកថ្មីចូលមកក្នុងឧស្សាហកម្ម ដែលត្រូវបានធ្វើនិយ័តកម្មនេះ។ ហេតុនេះហើយ ធនាការខ្លះអាចបាត់បង់ប្រាក់ បសិនបើនិយ័តកម្មត្រូវបានដកចេញ ពីព្រោះធនាគារទាំងនោះមិនអាចរក្សាបាននូវភាពផ្តាច់មុខបានឡើយ។ ផ្ទុយកមវិញ Sam Pelzman បានអះអាងថា និយ័តកម្មបានការពារធនាគារពីការផ្លាស់ប្តូរតម្រូវការ និងការចំណាយ ព្រមទាំងបន្ថយនូវហានិភ័យ។ ការដកចេញនិយ័តកម្ម អាចបណ្តាលឱ្យមានហានិភ័យខ្ពស់ ដែលនាំទៅដល់ការបរាជ័យនៃធនាគារជាច្រើន។

ថ្មីៗនេះ Edward Kane បានជំទាស់ថា និយ័តកម្មអាចបង្កើនការទុកចិត្តរបស់អតិថិជនទៅលើធនាគារ ហើយអាចបង្កើតភាពស្មោះស្ម័គ្ររបស់ពួកគេលើធនាគារ។ Kane ជឿថា និយ័តករផ្សេងៗធ្វើការប្រកួតប្រជែងទៅវិញទៅមកក្នុងការផ្តល់សេវាកម្ម ដើម្បីបង្កើនឥទ្ធិពលរបស់ខ្លួនក្នុងចំណោមធនាគារ និងសាធារណៈជន។ ជាងនេះទៅទៀត គាត់ជំទាស់ថា ការតស៊ូធនាគារដែលត្រូវគេបានគេធ្វើនិយ័តកម្ម និងនិយ័តករ ត្រូវបានគេហៅថា Regulatory Dialectic។ វាមានន័យថា នៅពេលដែលនិយ័តកម្មត្រូវបានគេពង្រាង ហើយដាក់ឱ្យប្រើប្រាស់ក្នុងក្រុមធនាគរវិក ត្រូវតែរិះរកមធ្យោបាយថ្មី ដូចជាការបង្កើតផលិតផលថ្មីៗ ដើម្បីបង្កើនតម្លៃរបស់ធនាគារឱ្យបានច្រើនបំផុត។ ប្រសិនបើ ធនាគារទទួលបានជោគជ័យក្នុងការឆ្លៀតយកប្រយោជន៍ក្នុងច្បាប់កំពុងមាន ច្បាប់ថ្មីនឹងត្រូវបានគេបង្កើត។ ការនេះនឹងជំរុញឱ្យធនាគារស្វែងរកការបង្កើតថ្មីនៃសេវាកម្ម និងបច្ចេកទេសរបស់ខ្លួន ហើយហេតុនេះហើតការតស៊ូរបស់ធនាគារ និងនិយ័តករ និងបន្តគ្មានទីបញ្ចប់។ Kane បានជឿថានិយ័តកម្មផ្តល់នូវការលើកទឹកចិត្តដល់អាជីវកម្មដែលទទួលនិយ័តកម្មតិចក្នុងការព្យាយាមស្រូបយកអតិថិជនពីអាជីវកម្មដែលទទួលនិយ័តកម្មខ្លាំង។ វាហាក់ដូចជាបានបង្ហាញក្នុងឧស្សាហកម្មធនាគារក្នុងពេលថ្មីៗ ដោយថាសង្គហធន កម្មវិធីសោធននិវត្ត និងអាជីវកម្មផ្សេងទៀត ដែលមាននិយ័តកម្មតិចជាងបានដណ្តើមភ្ញៀវល្អៗពីធនាគារ។

## ២.២.ឥទ្ធិពលរបស់និយ័តកម្មទៅលើប្រតិបត្តិការរបស់ធនាគារ

ការផ្លាស់ប្តូរច្បាប់ធនាគារ និងនិយ័តកម្មក្នុងពេលថ្មីៗនេះ មានឥទ្ធិពលជាច្រើនលើធនាគារ និងអតិថិជនរបស់ធនាគារ។ ខាងក្រោមនេះជាឥទ្ធិពលធំៗ :

1. បង្គុំនៃប្រាក់បញ្ញើនៅក្នុងធនាគារភាគច្រើន បានប្តូរទៅគណីរបស់អតិថិជនដែលធនាគារត្រូវចំណាយខ្ពស់។ មានន័យថា ការចំណាយពិតប្រាកដជាមធ្យមលើប្រាក់បញ្ញើប្រហែលជាអាចកើនឡើង ពីព្រោះប្រាក់បញ្ញើភាគច្រើនមានអត្រាការប្រាក់ទាក់ទងទៅនឹងស្ថានភាពបច្ចុប្បន្ននៃទីផ្សារការ
2. ទំរង់មួយចំនួនរបស់ហានិភ័យធនាគារក៏អាចកើនឡើង ជាពិសេសហានិភ័យការប្រាក់ (Interest Rate Risk) ហើយនិងហានិភ័យនៃការបរាជ័យរបស់ធនាគារ។ ដោយអត្រា

ការប្រាក់បញ្ញើ មានការទាក់ទងយ៉ាងជិតស្និទ្ធជាមួយអត្រាការប្រាក់នៅក្នុងផ្សារចំហរ ការឡើងចុះនៃអត្រាការប្រាក់ក្នុងទីផ្សារជះឥទ្ធិពលទៅលើចំណែកមូលធនរបស់ធនាគារ។ ធនាគារត្រូវប៉ះពាល់ ឬទទួលឥទ្ធិពលផ្សេងៗពីការផ្លាស់ប្តូរស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយទទួលបានការការពារតិចតួចពីផលវិបាកដែលបណ្តាលពីការគ្រប់គ្រងខុស។

3. ការកើនឡើងចំណាយប្រតិបត្តិ ជាពិសេសលើប្រាក់បញ្ញើ ដី និងឧបករណ៍ បានជំរុញឱ្យធនាគារបន្ថយប្រាក់ចំណាយតាមមធ្យោបាយផ្សេងៗ ដូចជា ការកាត់ចំណាយបុគ្គលិក នឹងការចំណាយមិនផ្ទាល់ដោយជំនួសវិញដោយប្រព័ន្ធស្វ័យប្រវត្តិ និងការរើសបុគ្គលិកនៅតាមសាខា។
4. ការកើនឡើងចំណាយប្រតិបត្តិការ ជំរុញឱ្យធនាគារបង្កើនចំណូលរបស់ខ្លួនយ៉ាងខ្លាំងក្លា។ សេវាកម្មពីមុនជាច្រើនដែលគ្មានកម្រៃ បច្ចុប្បន្នត្រូវធនាគារយកម្រៃ គេក៏បានយកចិត្តទុកដាក់ទៅលើការយកកម្រៃពេញលើអតិថិជន ដែលប្រើសេវាកម្មធនាគារ ហើយធនាគារជាច្រើនបានរិះរកសេវាកម្មថ្មីៗ ដែលអាចបង្កើតចំណូល ដើម្បីទូទាត់ការចំណាយ ហើយបង្កើតប្រាក់ចំណេញ។
5. អតិថិជនទទួលបាន អត្ថប្រយោជន៍លើពិយ័តកម្មការប្រាក់ ដោយទទួលបានការប្រាក់ខ្ពស់ចំពោះប្រាក់បញ្ញើរបស់ខ្លួន ដែលឆ្លុះបញ្ចាំងពីស្ថានភាពទីផ្សារ និងមានជម្រើសច្រើនក្នុងសេវាកម្មធនាគារ។

## ២.៣.ប្រព័ន្ធធនាគារកណ្តាលៈនិយ័តកម្មរបស់វាទៅលើការសម្រេចចិត្ត និងគោលនយោបាយរបស់ធនាគារនីមួយៗ

ការពិភាក្សាទៅលើធនាគារ និងនិយ័តករ តែមួយផ្នែកមិនទាន់ពេញលេញនៅឡើយទេ លុះត្រាតែពិភាក្សាទៅលើគោលនយោបាយ និងសកម្មភាពរបស់ធនាគារកណ្តាល ជាពិសេសគឺធនាគារកណ្តាលរបស់អាមេរិក (Federal Reserve System- Fed)។ ដូចធនាគារកណ្តាលផ្សេងៗទៀតដែរនៅលើពិភពលោកដែរ Fed មានឥទ្ធិពលច្រើនទៅលើសកម្មភាពរៀងរាល់ថ្ងៃរបស់ធនាគារ ជាងទីភ្នាក់ងាររបស់រដ្ឋាភិបាលផ្សេងៗ។ ការងារចំបងរបស់ធនាគារកណ្តាលគឺៈនុវត្តគោលនយោបាយរូបិយវត្ថុដែលទាក់ទងនឹងការធ្វើឱ្យធនាគារ និងប្រព័ន្ធហិរញ្ញវត្ថុមានដំណើរការស្រួល ហើយផ្គត់ផ្គង់រូបិយវត្ថុពីប្រព័ន្ធនេះឆ្លើយតបទៅនឹងគោលដៅសេដ្ឋកិច្ចរបស់ប្រទេស។ ផ្អែកទៅលើការគ្រប់គ្រងកំណើននៃរូបិយវត្ថុ និងឥណទាន (ប្រាក់ឱ្យខ្ចី និងវិនិយោគ) ធនាគារកណ្តាល (ក្នុងពិភពលោក) ព្យាយាមបញ្ជាក់ថាសេដ្ឋកិច្ចមានការកើនឡើងក្នុងកម្រិតមួយដែលអាចទទួលយកបាន ភាពអត់ការងារធ្វើចុះទាបបំផុត និងអតិផរណាទាប ហើតតម្លៃនៃប្រាក់ដុល្លាក៏ត្រូវបានការពារ។

នៅក្នុងសហរដ្ឋ Fed មានសេរីភាពក្នុងការសម្រេចគោលដៅខាងលើនេះ ដោយមិនចាំបាច់រកប្រាក់ខាងរដ្ឋាភិបាលទេ។ Fed រកប្រាក់បានដោយសារសេវាកម្មរបស់ខ្លួន និងធ្វើពាណិជ្ជកម្មមូលប័ត្រ។ ហើយប្រាក់ទាំងនេះត្រូវបានបញ្ជូនទៅរតនាគារសហរដ្ឋ បន្ទាប់ពីចែកភាគខ្លះទៅឱ្យធនាគារមួយ

ចំនួនដែលមានភាគហ៊ុនក្នុង Fed។ ធនាគារនៅស្វីស និងនៅអាល្លឺម៉ង់ គេក៏មានធនាគារកណ្តាលមួយឯករាជ្យ និងសេរីមួយដែរ ដែលទទួលបានជោគជ័យក្នុងការត្រួតពិនិត្យអតិផរណា។ តែផ្ទុយទៅវិញធនាគារកណ្តាលរបស់ ជប៉ុន អង់គ្លេស បារាំង អ៊ីតាលី អេស្បាញ និងបណ្តាប្រទេសផ្សេងទៀត មានទំនាក់ទំនងយ៉ាងជិតស្និតជាមួយការគ្រប់គ្រងរបស់រដ្ឋាភិបាល ហើយមានបទពិសោធន៍ក្នុងការឡើងខ្ពស់អតិផរណា និងបញ្ហាសេដ្ឋកិច្ចផ្សេងក្នុងពេលថ្មីៗនេះ។ ដោយវាជាបញ្ហាចំពោងចំរាស់ក្នុងពេលថ្មីៗនេះ ទើបមានការសិក្សាមួយដោយ Pollard និង Walsh។ អ្នកទាំងពីរនេះអះអាងថា កាលណាធនាគារកណ្តាលកាន់តែឯករាជ្យពីរដ្ឋាភិបាល វាអាចឈានទៅជិតគោលដៅសេដ្ឋកិច្ចរយៈពេលយូរជាង ដែលបណ្តាលមកពីការគ្មានការគាបសង្កត់ពីនយោបាយ។

## ២.៣.១. **រចនាសម្ព័ន្ធរបស់** Federal Reserve System

Fed ជាប់ទាក់ទងទៅនឹងការិយាល័យនិយមពាក់កណ្តាលរដ្ឋភិបាល ដែលធំនិងស្មុគស្មាញ (មើលរូប2.1)។ អំណាចកណ្តាល និងប្រព័ន្ធសម្រេចនៅក្នុងប្រព័ន្ធ Fed គឺក្រុមប្រឹក្សាអភិបាល (Board of Governors) នៅក្រុង Washington D.C តាមផ្លូវច្បាប់អង្គការគ្រប់គ្រងនេះត្រូវមានសមាជិកមិនហួសពី 7 នាក់ឡើយ ហើយសាមាជិកនីមួយៗត្រូវ បានជ្រើសរើសដោយប្រធានាធិបតេយ្យសហរដ្ឋ ហើយប្រកាសទទួលស្គាល់ពីសភារបស់សហរដ្ឋអាមេរិក ចំណែកអាណត្តិមិនលើសពី14ឆ្នាំឡើយ។ ប្រធាននៃក្រុមប្រឹក្សាអភិបាលនិងអនុប្រធានត្រូវបានចាត់ចែងដោយប្រធានដែលមកពីក្នុងចំណោម 7 នាក់ ចំណែកឯរយៈពេលកាន់មុខដំណែងគឺ4 ឆ្នាំ។ ក្រុមប្រឹក្សាត្រួតពិនិត្យសកម្មភាពទាំងអស់នៃ Reserve Bank ចំនួន 12 នៅតាមស្រុក និងសាខារបស់វា។ វាកំណត់នូវការបំរុងទុកចាំបាច់លើប្រាក់បញ្ញើ ដែលកាន់កាប់ដោយធនាគារ និងស្ថាប័នផ្ញើរប្រាក់ផ្សេងៗ។ វាផ្តល់ការអនុញ្ញាតទៅលើការផ្លាស់ប្តូរអត្រាអប្បហារ ដែលប្រកាសដោយ Reserve Bank ទាំង 12 ហើយដឹកនាំប្រព័ន្ធទាំងមូលក្នុងការកំណត់គោលនយោបាយបើកចំហរ ដើម្បីជះឥទ្ធិពលទៅលើការប្រាក់ និងកំណើនរូបិយវត្ថុ និងឥណទានធនាគារ។

សមាជិករបស់ក្រុមប្រឹក្សា បានបង្កើតនូវការបោះឆ្នោតចំបងនៃគណកម្មការសហព័ន្ធផ្សារចំហរ (Federal Open Market Committee-FOMC)។ ចំណែកឯ សមាជិកបោះឆ្នោតផ្សេងទៀតរួមមាន 5 ក្នុងចំណោមប្រធាន Federal Reserve Bank ទាំង 12។ សមាជិកនេះកាន់តំណែងបានមួយឆ្នាំដើម្បីបំពេញ 5 កៅអី ដែលអាចបោះឆ្នោតជាផ្លូវការបាននៅឯ FOMC (លើកលែងតែប្រធាន Federal Reserve Bank នៅញូវយ៉កចេញ ព្រោះគាត់ជាសមាជិកបោះឆ្នោតអចិន្ត្រៃ)។ ការងារ FOMC គឺដាក់ចេញនូវគោលនោបាយដែលណែនាំពីការប្រព្រឹត្តនៃប្រតិបត្តិការផ្សារចំហរ (ការទិញលក់មូលប័ត្រដោយ Federal Reserve Bank)។ FOMC មើលទៅលើគោលនយោបាយទាំងអស់របស់ Fed និងសេវាកម្មដើម្បីជះឥទ្ធិពលដល់ប្រព័ន្ធសេដ្ឋកិច្ច និងធនាគារ។

**រូបភាព 2.1. រចនាសម្ព័ន្ធនៃ Federal Reserve System**




Federal Reserve System ត្រូវបានគេចែកជា 12 ស្រុក ដែលមាន Federal Reserve Bank នៅតាមស្រុកនីមួយៗ ដើម្បីត្រួតពិនិត្យ និងបំរើធនាគារផ្សេងៗដែលជាសមាជិក។ សេវាកម្មសំខាន់ៗដែល Federal Reserve Bank បានផ្តល់ឱ្យគឺ

(1) ការផ្ទេរប្រាក់ពីធនាគារមួយទៅស្ថាប័នផ្ញើប្រាក់ដ៏ទៃទៀត

(2) រក្សាសន្តិសុខដល់មូលប័ត្រដែលជាកម្មសិទ្ធរបស់ធនាគារ និងអតិថិជនរបស់ពួកគេ

(3) បោះពុម្ពនូវមូលប័ត្រពីរតនាគារ ហើយជ្រើសរើសធនាគាររបស់សហព័ន្ធ

(4) ផ្តល់ឥណទានរយៈពេលខ្លីដល់ធនាគារ និងស្ថាប័នប្រាក់បញ្ញើផ្សេងទៀត

(5) រក្សា និងផ្គត់ផ្គង់រូបិយវត្ថុ និងប្រាក់កាក់

(6) ទូទាត់ និងប្រមូលមូលប្បទានប័ត្រ និងខ្ទង់ជាសាច់ប្រាក់ផ្សេងៗដែលចល័តពីទីក្រុងមួយទៅទីក្រុងមួយទៀត

(7) ផ្តល់ព័ត៌មានដល់ធនាគារិកនិងសាធារណៈអំពីការផ្លាស់ប្តូរនិយ័តកម្ម និងការប្រែប្រួលដែលអាចប៉ះពាល់ដល់កាងារបស់ស្ថាប័ន។

គ្រប់ធនាគារទាំងអស់ដែលផ្តល់អាជ្ញាប័ណ្ណដោយ Comptroller Of the Currency [ (National Bank) និងធនាគាររដ្ឋ (State Bank) ] មានបំណងអនុលោមតាមការត្រួតពិនិត្យនិងនិយ័តកម្ម ត្រូវបានគេចាត់ទុកថា សមាជិក។ ស្ថាប័នជាសមាជិកត្រូវតែទិញភាគហ៊ុន (រហូតដល់ 6% នៃមូលធនផ្ទាល់របស់ខ្លួន ឬក៏ច្រើនជាង) នៅក្នុង Federal Reserve Bank នៅក្នុងស្រុកនីមួយៗ ហើយសកម្មភាពអាជីវកម្មត្រូវបានត្រួតពិនិត្យយ៉ាងល្អិតល្អន់ពីបុគ្គលិករបស់ Fed។ វាមានករណីតិចតួចណាស់ដែលគេអនុញ្ញាតមិនឱ្យធនាគារត្រូវសោមាជិករបស់ Fed ពីព្រោះសេវាកម្មរបស់ Fed (ដូចគ្នា) ក៏អាចមានចំពោះស្ថាប័នប្រាក់បញ្ញើ ដូចជាការរក្សាទុកប្រាក់បំរុងនៅឯ Fed។ តែធនាគារខ្លះជឿថា នៅក្រោមប្រព័ន្ធនេះគេទទួលបាននូវកិត្តិយស និងបរិយាកាសសុវត្ថិភាព ដែលជួយធនាគារជាសមាជិកទាក់ទាញ និងទទួលបានប្រាក់បញ្ញើច្រើនៗ។

## ២.៣.២.ភារកិច្ចចម្បងរបស់ធនាគារកណ្តាលគឺការបង្កើត និងអនុវត្តគោលនយោបាយរូបិយវត្ថុ

មុខងារសំខាន់របស់ធនាគារកណ្តាលគឺបង្កើត និងអនុវត្តគោលនយោបាយរូបិយវត្ថុនិងឥណទាន ដើម្បីជំរុញឱ្យមានកំណើនសេដ្ឋកិច្ច ព្រមជាមួយគ្នាដែរ ដើម្បីជៀសវាងនូវអតិផរនាធ្ងន់ធ្ងរហើយសំរេចបាននូវគោលដៅសេដ្ឋកិច្ចផ្សេងៗ។ ដើម្បីសម្រេចបាននូវមុខងារសំខាន់នេះ ធនាគារកណ្តាលភាគច្រើនប្រើប្រាស់មធ្យោបាយផ្សេងៗ ដើម្បីជះឥទ្ធិពលលើការតំកល់ប្រាក់ផ្លូវច្បាប់នៃប្រព័ន្ធធនាគារ Reserve និងអត្រាការប្រាក់លើឥណទានព្រមទាំងតំលៃនៃរូបិយវត្ថុនៅក្នុងទីផ្សារប្តូរប្រាក់អន្តរជាតិ។ ប្រាក់តំកល់ទុកផ្លូវច្បាប់ (Legal Reserve) រួមមានទ្រព្យសកម្មទាំងអស់របស់ធនាគារនីមួយៗ។ នៅសហរដ្ឋ ប្រាក់តំកល់ទុកផ្លូវច្បាប់ រួមមានសាច់ប្រាក់ក្នុងឃ្លាំងហើយនិងប្រាក់បញ្ញើនៅក្នុង Federal Reserve Bank ថ្នាក់ស្រុក។ មធ្យោបាយនីមួយៗរបស់ Fed បង្កើនអត្រាការប្រាក់ខ្ពស់នៅពេលដែលគេចង់ខ្ចី និងឱ្យខ្ចីនៅក្នុងសេដ្ឋកិច្ច និងបន្ថយកំណើនសកម្មភាពសេដ្ឋកិច្ច ផ្ទុយទៅវិញ Fed កាត់បន្ថយអត្រាការប្រាក់ នៅពេលដែលគេចង់បង្កើនសកម្មភាពសេដ្ឋកិច្ច និងបង្កើនការឱ្យខ្ចីទៅអ្នកប្រើប្រាស់។ ធនាគារកណ្តាលក៏អាចជះឥទ្ធិពលទៅលើតម្រូវការរបស់រូបិយវត្ថុរបស់ប្រទេសខ្លួនដោយផ្លាស់ប្តូរនូវកម្រិតអត្រាការប្រាក់ និងការផ្លាស់ប្តូចជំហ៊ានសេដ្ឋកិច្ចក្នុងស្រុក។

ដើម្បីជះឥទ្ធិពលទៅលើប្រាក់តំកល់ផ្លូវច្បាប់ (Legal Reserve) អត្រាការប្រាក់ និងតំលៃរូបិយវត្ថុ Fed បានប្រើប្រាស់មធ្យោបាយ 3 សំខាន់ៗ គឺប្រតិបត្តិការទីផ្សារចំហរ (Open Market Operation) អត្រាអប្បហារ (Discount Rate) ហើយនិងប្រាក់តម្កល់ទុកផ្លូវច្បាប់ចាំបាច់ (Legal Reserve Requirement ) ទៅលើបំណុលរបស់ធនាគារផ្សេងៗ។

### ក.គោលនយោបាយផ្សារចំហរ

នៅសហរដ្ឋ ការទិញនិងលក់មូលប័ត្រ (រូបិយណត្ថិ សញ្ញាប័ណ្ណ និងប័ណ្ណផ្សេងៗ) របស់រដ្ឋាភិបាល ត្រូវបានគេបង្កើនឡោះងដើម្បីបង្ខិតប្រាក់តម្កល់របស់ធនាគារ និងអត្រាការប្រាក់ទៅដល់កម្រិតមួយដែលគេចង់បាន ហៅថាប្រតិបត្តិការផ្សារចំហរ។ ប្រតិបត្តិការផ្សារចំហរត្រូវបានគេចាត់ទុកថា ជាមធ្យោបាយដែកបន់បែនរបស់មធ្យោបាយនៃ Fed ពីព្រោះទី1 មធ្យោបាយនេះត្រូវបានគរប្រើប្រាស់រៀងរាល់ថ្ងៃ (អាចច្រើនជាងមួយដងក្នុងមួយថ្ងៃ) ទី2 បើសិន Fed មានកំហុស វាអាចកែតម្រូវមកវិញយ៉ាងឆាប់រហ័សឆ្លងតាមការទិញ និងលក់ប្រតិបត្តិការ។

រាល់ការទិញលក់មូលប័ត្រប្រព្រឹត្តិទៅនៅឯតុពាណិជ្ជកម្មនៅឯ Federal Reserve Bank of New York នៅក្នុងស្រុកហិរញ្ញវត្ថុ Manhattan។ អ្នកចាត់ការ និងបុគ្គលិកនៅឯតុពាណិជ្ជកម្មបានជួបគ្នារាល់ព្រឹក ដើម្បីពិនិត្យមើលទីផ្សារហិរញ្ញវត្ថុ បំរែបំរួលថ្មីនៃសេដ្ឋកិច្ច ហើយសម្រេចថាទិញ និងលក់មូលប័ត្រមួយណា។ ការលក់ដូរនេះធ្វើតែជាមួយពាណិជ្ជករណាដែលមានការអនុញ្ញាតពីរដ្ឋាភិបាល អ្នកគ្រប់គ្រង និងបុគ្គលិកនៅតុពាណិជ្ជកម្មបានជ្រើសរើសមូលប័ត្រនាដែលមានតម្លៃល្អពីអ្នកលក់។ ការលក់ដូរត្រូវបានបញ្ចប់នៅពេលដែលប្រាក់ត្រូវសេងពីមូលនិធិសហព័ន្ធ ទៅឱ្យធនាគាររបស់ពាណិជ្ជករ នៅពេលដែល Fed ទិញមូលប័ត្រ។ ចំពោះ Fed លក់មូលប័ត្រវិញ ធនាគារពាណិជ្ជករបានផ្ទេរប្រាក់ទៅឱ្យ Fed។

ការលក់មូលបប័ត្ររបស់ធនាគារកណ្តាល (Fed) មាននិន្នាការបន្ថយប្រាក់បញ្ញើ និងឥណទានរបស់ធនាគារទាំងអស់។ នៅពេលដែល Fed លក់មូលប័ត្ររបស់រដ្ឋាភិបាលសហរដ្ឋអាមេរិកពាណិជ្ជករទិញមូលប្ប័ត្រទាំងនោះដោយអនុញ្ញាតឱ្យ Fed ដកប្រាក់ពីគណនីនៃពាណិជ្ជករទាំងនោះនៅក្នុងស្រុកមួយនៃ Federal Reserve Bank ដូច្នេះហើយធនាគារមានប្រាក់តិចជងាសម្រាប់ឱ្យខ្ចី និងផ្តល់ឥទានផ្សេងៗ។ ផ្ទុយមកវិញ ការទិញមូលប័ត្ររបស់ធនាគារកណ្តាលមាននិន្នាការបង្កើនកំណើនប្រាក់បញ្ញើ និងឥណទាន Fed បនាសងការទិញមូលប័ត្ររបស់ខ្លួន ដោយគ្រាន់តែបូចូលប្រាក់ទៅក្នុងគណនីតម្កល់របស់ពាណិជ្ជករដែលមាននៅក្នុងស្រុកមួយរបស់ Federal Reserve Bank។

បច្ចុប្បន្ន Fed តម្រង់ទិសទៅរកអត្រាការប្រាក់នៃមូលនិធិសហព័ន្ធ ដែលភ្ជាប់ជាមួយឥណទាននៃប្រាក់តម្កល់រវាងធនាគារ និងធនាគារ។ បើសិនជា Fed មានបំណងចង់ឱ្យមូលនិធិសហព័ន្ធមានអត្រាខ្ពស់ និងបន្ថយការខ្ចី និងចំណាយជាធម្មតា Fed លក់មូលប័ត្រនៅក្នុងផ្សារចំហរ។ ការបន្ថយប្រាក់តម្កល់របស់ Fed និងការចង់ឱ្យឥណទានថ្មីរបស់ធនាគារ នាំទៅដល់ការកើនឡើងចំនួនខ្ចីពីប្រាក់តម្កល់របស់ធនាគារ ដែលបង្កឱ្យអត្រាការប្រាក់នៅក្នុងទីផ្សារឡើងខ្ពស់ និងកំណើនសេដ្ឋកិច្ចយឺត។ ម្យ៉ាងទៀត ប្រសិនបើ Fed មានបំណងបញ្ចុះអត្រាការប្រាក់ ដើម្បីបង្កើនការខ្ចី និងការចំណាយនៅក្នុងសេដ្ឋកិច្ច Fed តែងតែទិញមូលប័ត្រនៅក្នុងផ្សារចំហរ។ ការកើនឡើងប្រាក់តម្កល់ ហើយនឹងធនាគារចង់ឱ្យឥណទានថ្មីៗ ព្រមទាំងមានការគៀបសង្កត់ឱ្យខ្ចីពីទីផ្សារមូលនិធិសម្ព័ន្ធ ដែលនាំទៅដល់ការធ្លាក់ចុះនៃអត្រាការប្រាក់ និងជំរុញល្បឿនសេដ្ឋកិច្ច។ (រូបភាព 2-2)

## ខ.គោលនយោបាយអត្រាអប្បហា

ធនាគារកណ្ដាលជាប្រភពដ៏សំខាន់នៃមូលនិធិរយៈពេលខ្លីសម្រាប់ធនាគារ និងស្ថាប័នប្រាក់បញ្ញើផ្សេងទៀត ជាពិសេសធនាគារធំៗដែលខ្ចីសម្រាប់បំពេញនូវប្រាក់តម្កល់ផ្លូវច្បាប់របស់ខ្លួន។ ធនាការអាមេរិកភាគច្រើនបានដាក់លិខិតអនុញ្ញាតឱ្យខ្ចី នៅឯ Federal Reserve Bank នៅក្នុងស្រុករបស់ខ្លួនសម្រាប់ការខ្ចី។ រូបខាងក្រោមបង្ហាញថានៅពេលដែលឥណទានរបស់ Fed តម្កល់ក្នុងធនាគារខ្ចី (Borrowing Bank) ការផ្គត់ផ្គង់ប្រាក់តម្កល់ផ្លូវច្បាប់បានកើនឡើងចាបណ្ដោះអាសន្នបណ្ដាលឱ្យឥណទាន និងប្រាក់បញ្ញើកើន។ ក្រោយមកនៅពេលដែលឥណទានត្រូវបានសង ធនាគារខ្ចី (Borrowing Bank) អាចបាត់បង់ប្រាក់តម្កល់ ហើយបញ្ឈប់កំណើនឥណទាន និងប្រាក់បញ្ញើ។ អត្រាឥណទានដែលត្រូវបង់ឱ្យ Fed គឺអត្រាអប្បហា ដែលត្រូវបានគេកំណត់ដោយក្រុមប្រឹក្សាភិបាលនៃ Federal Bank នីមួយៗ។ ឥណទានជាអប្បហាភាគច្រើនគឺសម្រាប់តែឥណទានកែតម្រូវរយៈពេលខ្លី ឬក៏ឥណទានរដូវកាល ដើម្បីបំពេញការខ្វះខាតនៃប្រាក់តម្កល់ ហើយមានរយៈពេលត្រឹមតែ 2 ឬ 3 ថ្ងៃ។ ឥណទានរយៈពេលវែងជាងនេះ គឺវែងជាងមួយខែ ដែលសម្រាប់ជួយធនាគារណាដែលប្រឈមមុខនឹងការខ្វះខាតសាច់ប្រាក់ងាយស្រួល ហើយឥណទាននេះមានអត្រាអប្បហាខ្ពស់។

បង្កើនអត្រាអប្បហា Fed ផ្ដល់ឥណទានថ្មីៗពីគោលនយោបាយអត្រាអប្បហាដែលមានចំណាយខ្ពស់។ ការនេះបានរារាំងធនាគារជាច្រើនមិនឱ្យខ្ចីប្រាក់ពីប្រាក់តម្កល់ ដែលនាំទៅដល់ការយឺតយ៉ាវនៃឥណទាន។ ការបន្ថយអត្រាអប្បហា បានជួយជំរុញធនាគារឱ្យខ្ចីពី Fed ហើយធនាគារអាចឱ្យឥណទានទៅអតិថិជនដោយសេរី។ ការផ្លាស់ប្ដូរអត្រាអប្បហាអាចជះឥទ្ធិពលទៅលើអត្រាការប្រាក់ផ្សេងៗនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុ ដែលជាធម្មតារុញអត្រាការប្រាក់ទៅតាមទិសនៃអត្រាអប្បហា។ ម្យ៉ាងទៀតការផ្លាស់ប្ដូរអប្បហាអាចមានឥទ្ធិពលចិត្តសាស្ត្រ ដែលនាំតៅដល់ការរំពឹងទុករបស់អ្នកវិនិយោគចំពោះអត្រាការប្រាក់ខ្ពស់ឬទាប។ (រូបភាព 2.3)

ការផ្លាស់ប្ដូរប្រាក់តម្កល់ចាំបាច់ (ចំពោះប្រាក់បញ្ញើ និងបំណុលផ្សេងៗរបស់ធនាគារ)

ធនាគារ និងស្ថាប័នប្រាក់បញ្ញើផ្សេងៗដែលលក់ប្រាក់បញ្ញើ ដែលខ្លួនទទួលខុសត្រូវដាក់តែមួយចំណែកតូចណាមួយនៃប្រាក់បញ្ញើនោះទៅក្នុងប្រាក់តម្កល់ក្នុងទម្រង់សាច់ប្រាក់ក្នុងឃ្លាំង ឬក៏តម្លៃនៅឯ Federal Reserve Bank។ ការជ្រើសរើសយកប្រភពផ្សេងៗទៀតដូចប្រាក់បញ្ញើមានរយៈពេលកំណត់សម្រាប់លក់ទៅឱ្យពាណិជ្ជកម្ម ឬក៏ស្ថាប័នផ្សេងៗ ហើយនឹងប្រាក់បញ្ញើជារូបិយវត្ថុបរទេសដែលគេខ្ចីពីប្រទេសក្រៅក៏ត្រូវតែតម្កល់ទុក ដែលតម្រូវឱ្យក្រុមប្រឹក្សាអភិបាលនៃ Federal Reserve Bank System។ ប៉ុន្ដែបច្ចុប្បន្ននេះមានតែប្រាក់បញ្ញើ ដែលអាចត្រួតពិនិត្យបានទើបត្រូវមានប្រាក់តម្កល់។

ការផ្លាស់ប្ដូរចំនួនភាគរយនៃប្រាក់បញ្ញើ និងប្រភពប្រាក់ផ្សេងៗរបស់ធនាគារ ដែលទាមទារឱ្យមានប្រាក់តម្កល់នៅក្នុង Fed អាចមានឥទ្ធិពលយ៉ាងខ្លាំងតៅលើការពង្រីកឥណទានរបស់ធនាគារ ការបង្កើនប្រាក់តម្កល់ចាំបាច់ មានន័យថា ធនាគារត្រូវរក្សាទុកមួយចំណែកនៃប្រាក់បញ្ញើដែលខ្លួនទទួលបាន ហើយធ្វើឱ្យប្រាក់ដែលអាចឱ្យខ្ចីមានចំនួនតិច។ ជាងនេះទៅទៀត ការបង្កើនប្រាក់តម្កល់ធ្វើឱ្យអ

ត្រាការប្រាក់កើនឡើងពីព្រោះធនាគារមានប្រាក់ ដែលអាចឱ្យខ្ចីបានតិចជាង។ ម្យ៉ាងទៀត ការបន្ថយប្រាក់តម្កល់ចាំបាច់ជាចបង្កើនការខ្ចីចេញពីប្រាក់តម្កល់របស់ Fed ចំណែកឯអត្រាការប្រាក់ក៏អាចធ្លាក់ចុះ ពីព្រោះធនាគារមានប្រាក់ច្រើនដើម្បីឱ្យខ្ចី។

ទោះបីជា Fed ត្រូវបានគេផ្តល់អំណាចឱ្យធ្វើដូច្នេះក៏ដោយ វាពិបាកនិងផ្លាស់ប្តូរភាគរយនៃប្រាក់បញ្ញើ និងបំណុលអាចតម្កល់ទុក ដូច្នេះហើយត្រូវបានគេរក្សាជាទម្រង់ប្រាក់តម្កល់។ បទពិសោធន៍បានបង្ហាញថា ការផ្លាស់ប្តូរអាចនាំទៅដល់ការផ្លាស់ប្តូឥណទានដែលមាន និងអត្រាការប្រាក់។ Fed ចូលចិត្តប្រើប្រាស់ប្រតិបត្តិការផ្សារចំហរ និងអត្រាអប្បហារដើម្បីផ្លាស់ប្តូរគោលនយោបាយឥណទាន និងលក្ខខណ្ឌសេដ្ឋកិច្ច។

### គ.ឧបករណ៍ផ្សេងទៀតរបស់ Fed

ឧបករណ៍ផ្សេងទៀតនៃគោលនយោបាយរបស់ Fed ប្រើប្រាស់ដើម្បីជះឥទ្ធិពលទៅលើសេដ្ឋកិច្ចនិងការប្រព្រឹត្តរបស់ធនាគារ គឺការបញ្ចុះបញ្ចូលបែបសីលធម៌ និងគម្លាតចាំបាច់ : Fed ព្យាយាមដាក់សម្ពាធផ្នែកចិត្តសាស្ត្រ ដើម្បីឱ្យបុគ្គល និងស្ថាប័នអនុវត្តតាមគោលនយោបាយរបស់ Fed ដោយទំនាក់ទំនងតាមទូរស័ព្ទ ការសរសេរសំបុត្រទៅឱ្យធនាគារិក ការផ្តល់សន្ទរកថា និងការបកស្រាយនៅមុខព្រឹទ្ធសភា ដើម្បីពន្យល់និងបកស្រាយពីគោលនយោបាយរបស់ Fed។ ធនាគារិកតែងតែយកចិត្តទុកដាក់ចំពោះការហៅតាមទូរស័ព្ទ ឬសំបុត្រពីធនាគារកណ្តាល ដោយគិតថាការគ្រប់គ្រងដ៏តឹងរឹងត្រូវបានគេអនុវត្ត។

ការត្រួតពិនិត្យលើការចាំបាច់ទៅលើការទិញប័ណ្ណភាគហ៊ុន ឬសញ្ញាប័ណ្ណរបស់សាធារណៈជន។ អ្នកវិនិយោគម្នាក់ទិញមូលប័ត្រ ត្រូវតែប្រើប្រាស់ប្រាក់ផ្ទាល់របស់ខ្លួន ដើម្បីសងតៅលើចំនួនជាភាគរយជាក់លាក់នៃមូលប័ត្រដែលខ្លួនបានទិញ ចំណែងភាគរយផ្សេងទៀត គេអាចខ្ចីដោយប្រើមូលប័ត្រដែលខ្លួនបានទិញជាវត្ថុបញ្ចាំ។ ចាប់ពីឆ្នាំ 1974 គម្លាតចាំបាច់ត្រូវបានគេប្រើទៅលើសញ្ញាប័ណ្ណ ដែលអាចដូរយកប្រាក់បាន និងប័ណ្ណភាគហ៊ុន ហើយចំពោះ short sales នៃមូលប័ត្រទាំងនោះ គឺធ្វើបានត្រឹម 50% មានន័យថា អ្នកវិនិយោគសងប្រាក់ពាក់កណ្តាលនៃតម្លៃមូលប្ប័ពីហោប៉ៅរបស់ខ្លួន ហើយអាចខ្ចី 50% ទៀត គិតតាមតម្លៃទីផ្សាររបស់មូលប័ត្រ។

**រូបភាព 2-2 ប្រតិបត្តិការផ្សារចំហររបស់ Fed**




**រូបភាព 2-3 ធនាគារខ្ចីប្រាក់ពីមូលនិធិអប្បហាររបស់ Fed**



# មេរៀនទី៣.
# របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ

## ៣.១.តារាងតុល្យការ និងរបាយការណ៍ប្រាក់ចំណេញ

របាយការណ៍ហិរញ្ញវត្ថុពីរដែលសំខាន់បំផុតរបស់ធនាគារគឺ តារាងតុល្យការណ៍ និងរបាយការណ៍ប្រាក់ចំណេញ។ តារាងតុល្យការណ៍ ឬរបាយការណ៍ស្ថានភាព បានបង្ហាញពីចំនួនទឹកប្រាក់ និងសមាសធាតុនៃប្រភពធន ដែលធនាគារបានប្រើប្រាស់ដើម្បីឱ្យខ្ចី សម្រាប់វិនិយោគលើមូលប័ត្រ និងមូលធនសម្រាប់ការប្រើប្រាស់ផ្សេងៗ។

ផ្ទុយមកវិញ Financial Input ហើយនិង Output នៅក្នុងរបាយការន៍ចំណូលបានបង្ហាញពីប្រាក់ដែលធនាគារបានចំណាយដើម្បីទិញប្រាក់បញ្ញើ និងប្រភពមូលធនផ្សេងៗហើយនឹងការបង្កើតចំណូល ដែលបានមកពីការប្រើប្រាស់មូលធនទាំងនោះ។ ការចំណាយទាំងនោះរួមមានការប្រាក់ដែលបានសងទៅឱ្យប្រាក់បញ្ញើ ម្ចាស់បំណុលផ្សេងៗ នៅក្នុងការទិញនិងប្រើប្រាស់សម្ភារៈ និងការិយាល័យ និងពន្ធដែលបង់ទៅរដ្ឋាភិបាល។ របាយការណ៍ចំណូលនៅបានបង្ហាញពីចំណូល (ការហូរនៃសាច់ប្រាក់) ដែលបានមកពីការលក់សេវាកម្មរបស់ធនាគារតៅឱ្យសាធារណជន ដែលរួមមានឥណទាន ការជួល និងសេវាកម្មផ្សេងៗ។ ម៉្យាងទៀត របាយការណ៍ចំណូលរបស់ធនាគារ បានបង្ហាញពីការរកចំណូលសុទ្ធរបស់ធនាគារ បន្ទាប់ពីដកចេញពីការចំណាយទាំងអស់ ភាគខ្លះនៃចំណូលត្រូវបានគេយកទៅវិនិយោគវិញ ហើយភាគខ្លះទៀតត្រូវបានបែងចែកទៅឱ្យម្ចាស់ភាគហ៊ុននីមួយៗ។

## ៣.២.តារាងតុល្យការ (របាយការណ៍ស្ថានភាព)

តារាងតុល្យការណ៍បានចុះឈ្មោះទ្រព្យសកម្មទាំងអស់ បំណុល និងមូលធនផ្ទាល់ (ជាមូលធនរបស់ម្ចាស់) ដែលមាននៅក្នុងធនាគារនៅក្នុងពេលកំណត់មួយ ពីព្រោះធនាគារជាក្រុមហ៊ុនអាជីវកម្មមួយ ដែលលក់ផលិតផលដោយឡែកមួយ។

**តារាង 3-1 Financial Outputs និង Inputs នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងបីរបស់ធនាគារ**

| តារាងតុល្យការ | |
|---|---|
| Financial Outputs | Financial Inputs |
| ឥណទាន និងជួល | ប្រាក់បញ្ញើពីសាធារណៈជន |
| ការវិនោយោគនៅក្នុងមូលប័ត្រ | ការខ្ចីដែលមិនមែនជាប្រាក់បញ្ញើ |
| សាច់ប្រាក់ និងប្រាក់បញ្ញើនៅស្ថាប័នផ្សេងៗ | មូលធនផ្ទាល់ពីម្ចាស់ក្រុមហ៊ុន |
| ដូចក្រុមហ៊ុនផ្សេងទៀតដែរ តារាងតុល្យការរបស់ធនាគារ អស់ស្មើនិងការប្រើប្រាស់មូលធនទាំងអស់របស់ធនាគារ (Total assets = Total liabilities + Equity capital) | គឺប្រភពមូលធនរបស់ធនាគារទាំង |

| របាយការណ៍ប្រាក់ចំណេញ (ចំណូល) | |
|---|---|
| Financial Outputs | Financial Inputs |
| (ចំណូលពីការប្រើប្រាស់មូលធនរបស់ ឬបំណុល | (ចំណាយលើការទិញមូលធន |
| ធនាគារ និងការលក់សេវាកម្ម) | និងទុនផ្ទាល់) |
| ចំណូលពីឥណទាន | ចំណាយលើការប្រាក់បញ្ញើ |
| ចំណូលពីមូលប័ត្រ | ចំណាយលើការខ្ចីផ្សេងៗ |
| ចំណូលពីប្រាក់បញ្ញើនៅក្នុងស្ថាប័នផ្សេងៗ | ចំណាយបុគ្គលិក |
| ចំណូលពីសេវាកម្មផ្សេងៗ | ចំណាយមិនផ្ទាល់ |

ដូចក្រុមហ៊ុនដទៃទៀតដែរ ចំណូលសរុបដកចំណាយសរុបស្មើនឹងចំណេញសុទ្ធរបស់ធនាគារ អត្តសញ្ញាណមូលដ្ឋាននៃតារាងតុល្យការគឺ:

ទ្រព្យ (Assets) = បំណុល (Liabilities) + មូលធនផ្ទាល់ (Equity Capital) (1)

ទ្រព្យនៅក្នុងធនាគារ រួមមាន 4 ប្រភេទសំខាន់ៗ គឺសាច់ប្រាក់នៅក្នុងឃ្លាំង និងស្ថាប័នប្រាក់បញ្ញើផ្សេងៗ (C) មូលប័ត្ររបស់រដ្ឋនិងឯកជនដែលបានទិញក្នុងទីផ្សារ (S) ឥណទាន និងការជួល (ហិរញ្ញវត្ថុ) ទៅឱ្យអតិថិជន (L) និងទ្រព្យផ្សេងៗ (MA)។ បំណុលមានពីរប្រភេទជាមូលដ្ឋានគឺ ប្រាក់បញ្ញើរបស់អតិថិជន (D) និងប្រាក់កម្ចីពីទីផ្សារប្រាក់ និងទីផ្សារមូលធន (NDB)។ មូលធនផ្ទាល់ (Equity) គឺតំណាងមូលធនរយៈពេលវែងដែលមានម្ចាស់បានទៅដាក់នៅក្នុងធនាគារ (EC)។ (មើលរូបទី 3-2) ដូច្នេះតារាងតុល្យការរបស់ធនាគារត្រូវបានគេសរសេរដូចខាងក្រោម:

$$C + S + L + MA = D + NDB + EC \quad (2)$$

សាច់ប្រាក់ (C) ត្រូវបានគេរៀបចំដើម្បីបំពេញតម្រូវការ Liquidity (សាច់ប្រាក់ងាយស្រួល សាច់ប្រាក់ដែលអាចចាយបានភ្លាមៗ) ក្នុងការឆ្លើយតបទៅនឹងការដកប្រាក់បញ្ញើ ឥណទានដែលត្រូវការដោយអតិថិជន និងតម្រូវការសាច់ប្រាក់ផ្សេងៗទៀតដែលមិនបានព្រៀងទុក។ ការរក្សាទុកមូលប័ត្រ (S) គឺជាប្រភពបំរុងសម្រាប់សាច់ប្រាក់ងាយស្រួល (Liquidity) និងចំណូលបន្ថែម។ ឥណទានគឺសម្រាប់ផ្តល់ចំណូល ចំណែងទ្រព្យផ្សេងៗ (MA) ជាធម្មតាភាគច្រើនគឺជាអចលទ្រព្យរបស់ធនាគារ (ឧបករណ៍ និងអគារ) និងការវិនិយោគទៅលើសាខារបស់ធនាគារ។ ប្រាក់បញ្ញើ (D) ជាប្រភពសំខាន់របស់ធនាគារ ជាមួយនឹងប្រាក់កម្ចីផ្សេងៗ ត្រូវបានគេប្រើសម្រាប់បន្ថែមទៅលើប្រាក់បញ្ញើ និងជាប្រាក់បន្ថែមទៅលើសាច់ប្រាក់ងាយស្រួល (Liquidity)។ មូលធនផ្ទាល់ (Equity Capital) ផ្តល់ប្រភពទុនរយៈពេលវែង ដែលធនាគារពឹងផ្អែកដើម្បីអភិវឌ្ឍ និងដើម្បីសងទៅលើការខាតបង់ផ្សេងៗដែលកើតមាន។

ផលប្រយោជន៍មួយនៃការពិនិត្យមើលអត្តសញ្ញាណតារាងតុល្យការរបស់ធនាគារ គឺដើម្បីកត់សម្គាល់ថា បំណុល និងមូលធនផ្ទាល់ គឺជាប្រភពមូលធនបង្គ (Accumulated Sources of Funds) ដែលផ្តល់កម្លាំងចំណាយដើម្បីទិញទ្រព្យ។ ម្យ៉ាងទៀតទ្រព្យរបស់ធនាគារគឺជាការប្រើប្រាស់បង្គនៃមូលធន (Accumulated Uses of Funds) ដើម្បីបង្កើតចំណូលសម្រាប់ភាគទុនិក សងការប្រាក់ដល់ប្រាក់បញ្ញើ និងសងតៅដល់និយោជិកសម្រាប់ឈ្នួលពលកម្ម និងទេពកោសល្យរបស់គេ។ ហេតុនេះហើយអត្តសញ្ញាណតារាងតុល្យការរបស់ធនាគារមានរូបរាងយ៉ាងងាយដូចខាងក្រោមៈ

ការប្រើប្រាស់បង្គរនៃមូលធនធនាគារ (Accumulated Uses of Bank Funds)
= ប្រភពបង្គរនៃមូលធនធនាគារ (Accumulated Sources of Bank Funds) ឬទ្រព្យ ឬក៏បំណុលនិងទុនផ្ទាល់ (3)

គ្រប់ការប្រើប្រាស់មូលធនត្រូវបានគេគាំទ្រដោយប្រភពមូលធន ដូច្នេះហើយការប្រើប្រាស់បង្គរនៃមូលធនត្រូវតែស្មើនឹងប្រភពបង្គរនៃមូលធន។

តាមពិតទៅតារាងតុល្យការមានភាពស្មុគ្រស្មាញជាងប្រភពបង្គរ និងការប្រើប្រាស់ឆ្ងាយណាស់ បីព្រោះខ្ទង់នីមួយៗនៃតារាងតុល្យការរបស់ធនាគារតែងតែមានគណនីជាច្រើន ហើយវាត្រូវបានបង្ហាញនៅក្នុងតារាង 3-3សូមពិនិត្យមើលដោយយកចិត្តទុកដាក់លើសមាសធាតុជាមូលដ្ឋានរបស់វា។

## ៣.៣.ទ្រព្យរបស់ធនាគារ

គណនីសាច់ប្រាក់ (Cash Account) ខ្ទង់ដំបូងបំផុតនៃទ្រព្យដែលបានចុះនៅក្នុងរបាយការណ៍ស្ថានភាពរបស់ធនាគារ គឺសាច់ប្រាក់ និងប្រាក់បញ្ញើរនៅធនាគារដ៏ទៃទៀត។ ខ្ទង់នេះ រួមមានសាច់ប្រាក់ក្នុងឃ្លាំង ប្រាក់បញ្ញើដែលបានដាក់នៅធនាគារផ្សេងៗ សាច់ប្រាក់ដែលកំពុងប្រមូល (នៅក្នុងទម្រង់មូលប័ត្រមិនទាន់ទូទាត់) ហើយនឹងគណនីប្រាក់បម្រុងនៅក្នុង Fed (ប្រាក់តម្កល់ចាំបាច់)។ មានន័យថា ខ្ទង់សាច់ប្រាក់នេះគឺជាបន្ទាត់ទីមួយរបស់ធនាគារ ដើម្បីការដកប្រាក់ ហើយជាប្រភពមូលធនដំបូងដែលធនាគារត្រូវពិនិត្យមើល នៅពេលដែលអតិថិជនមកសុំឥណទានដោយគ្មានការព្រៀងទុក។ ជាធម្មតាធនាគារព្យាយាមរក្សាទំហំនៃគណនីនេះឱ្យទាបបំផុត ដែលអាចធ្វើបាន ពីព្រោះគុល្យភាពសាច់ប្រាក់អាចបង្កើតប្រាក់ចំណូលសម្រាប់ធនាគារតិចតួចណាស់។ គួរចងចាំថា 1.643 លានដុល្លា ជាសាច់ប្រាក់ និងពីធនាគារផ្សេងៗក្នុងតារាង 3-3 គឺស្មើមិនដល់ 8% នៃទ្រព្យរបស់វាផង ( 21.7 កោដិ)

### តារាង3-2 ខ្ទង់សំខាន់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុធនាគារ

| តារាងតុល្យការ (របាយការណ៍ស្ថានភាព) |
|---|
| ទ្រព្យ (Accumulated Uses of Funds) |

- សាច់ប្រាក់ (ប្រាក់តម្កល់ចាំបាច់)
    - មូលប័ត្រក្នុងដៃ ហើយអាចលក់បានងាយ (ប្រាក់តម្កល់ទី 2)
    - មូលប័ត្រវិនិយោគ (Investment Securities)
    - ឥណទាន
        - អ្នកប្រើប្រាស់
        - ដីធ្លី
        - ពាណិជ្ជកម្ម
        - ស្ថាប័នហិរញ្ញវត្ថុ
    - ទ្រព្យផ្សេងៗ (អាគារ ឧបករណ៍។ល។ )

<u>បំណុល និងទុនផ្ទាល់ (Accumulated Sources of Funds)</u>

- ប្រាក់បញ្ញើ
    - តាមតម្រូវការ (Demand)
    - NOWs
    - សញ្ច័យ (គ្មានកំណត់)
    - រយៈពេលវែង
- ប្រាក់កម្ចីផ្សេងៗដែលមិនមែនជាប្រាក់បញ្ញើ
- ទុនផ្ទាល់ :
    - ភាគហ៊ុន
    - មូលធនលើស
    - ប្រាក់ចំណេញរក្សាទុក
- ទុនតម្កល់

របាយការណ៍ចំណូល

<u>ចំណូល (</u>ចំណូលរបស់ធនាគារពីការផ្តល់សេវាកម្ម)

- ចំណូលពីឥណទានវិនិយោគ
- ចំណូលពីវិនិយោគ
- ចំណូលផ្សេងៗដែលមិនមែនការប្រាក់ (កម្រៃសេវាកម្មលើប្រាក់បញ្ញើ)

| |
|---|
| ចំណាយ (ចំណាយលើប្រភពមូលធនរបស់ធនាគារ ដែលចាំបាច់ដើម្បីបង្កើតសាវ៉ាកម្ម) |
| - ចំណាយការប្រាក់លើប្រាក់បញ្ញើ<br>- ចំណាយការប្រាក់លើប្រាក់កម្ចីដែលមិនមែនជាប្រាក់បញ្ញើ<br>- បៀវត្ស (ការសងទៅលើនិយោជិក)<br>- សំវិធានធនទៅលើការបាត់បង់ឥណទាន (ការបែងចែកចំពោះប្រាក់តម្កល់សម្រាប់លទ្ធភាពបាត់បង់របស់ឥណទាន)<br>- ការចំណាយផ្សេងៗ<br>- ចំណូលមុនពន្ធ និងប្រតិបត្តិការមូលប័ត្រ<br>- ពន្ធ<br>- ខាត ឬចំណេញពីពាណិជ្ជកម្មមូលប័ត្រ<br>- ចំណូលសុទ្ធបន្ទាប់ពីពន្ធ និងខាត ឬចំណេញពីមូលប័ត្រ |

**តារាង3.3 តារាងតុល្យការរបស់ធនាគារដ៏ធំមួយ (ឯកតាលានដុល្លា)**

| | | |
|---|---|---|
| ឆ្នាំទើបតែបញ្ចប់ ៦ខែមុន | | |
| ទ្រព្យសកម្ម (ការប្រើប្រាស់បង្គរនៃមូលធន) | | |
| សាច់ប្រាក់ និងប្រាក់បញ្ញើនៅធនាគារផ្សេងៗ | 1.643 | 2.300 |
| វិនិយោគលើមូលប័ត្រ | 2.803 | 3.002 |
| គណនីមូលប័ត្រកំពុងធ្វើពាណិជ្ជកម្ម | 21 | 96 |
| មូលធនសហព័ន្ធដែលបានលក់ និងមូលប័ត្រដែលបានទិញ | | |
| ក្រោមកិច្ចព្រមព្រៀងលក់វិញ | 278 | 425 |
| ឥណទានសរុប (រួមមានដីធ្លី ពាណិជ្ជកម្ម កសិកម្ម | | |
| ស្ថាប័នហិរញ្ញវត្ថុ និងឥណទានប្រើប្រាស់ និងការជួល) | 15.887 | 15.412 |
| ដក : ប្រាក់បំរុងសម្រាប់ការបាត់បង់ឥណទាន ដែលអាចមាន | (349) | (195) |
| ការបន្ថយតម្លៃលើឥណទាន | (117) | (137) |
| ឥណទានសរុប | 15.421 | 15.080 |
| ហិរញ្ញប្បទានជួលដែលអាចទទួលបាន (Lease Financing Receivable) | 201 | 150 |
| ទីតាំង និងឧបករណ៍ផ្សេងៗរបស់ធនាគារ (សុទ្ធ) | 365 | 363 |
| បំណុលអតិថិជន | 70 | 111 |
| ទ្រព្យផ្សេងៗ | 903 | 1.059 |
| ទ្រព្យទាំងអស់ | 21.750 | 22.586 |

បំណុល និងទុនផ្ទាល់របស់ភាគទុនិក

| | | |
|---|---|---|
| (ប្រភពមូលធនបង្គរ) | | |
| ប្រាក់បញ្ញើ | | |
| ប្រាក់បញ្ញើចរន្តដែលគ្មានការប្រាក់ | 3.427 | 3.831 |
| ប្រាក់បញ្ញើសញ្ច័យ និងសញ្ច័យគ្មានការប្រាក់ (Now Acct) | 914 | 937 |
| គណនីប្រាក់បញ្ញើទីផ្សារប្រាក់ (Money Market Deposit Acct) | 1.914 | 1.965 |
| ប្រាក់បញ្ញើរយៈពេលកំណត់ | 9.452 | 9.981 |
| ប្រាក់បញ្ញើមានរយៈពេលកំណត់ | 787 | 869 |
| ប្រាក់បញ្ញើនៅសាខាបរទេស | 16.494 | 17.583 |
| ប្រាក់បញ្ញើសរុប | | |
| កម្ចីដែលមិនមែនជាប្រាក់បញ្ញើ | | |
| មូលធនសហព័ន្ធដែលទិញ និងមូលប័ត្រដែលលក់នៅក្រោមកិច្ចព្រមព្រៀងដើម្បីទិញជាថ្មី | 2.132 | 1.836 |
| បំណុលរយៈពេលខ្លីផ្សេងទៀត | 897 | 714 |
| ប័ណ្ណបំណុល | 417 | 419 |
| ប័ណ្ណបំណុល (Debentures) | 200 | 200 |
| បំណុលផ្សេងទៀត | | |
| ប័ណ្ណទទួល (Acceptance) (បំណុល) ដែលពុំទាន់ទូទាត់ | 70 | 111 |
| បំណុលផ្សេងៗ | 348 | 428 |
| បំណុលសរុប | 20.558 | 21.306 |
| ទុនផ្ទាល់របស់ភាគទុនិក | | |
| ភាគហ៊ុនធម្មតា | 212 | 212 |
| ភាគហ៊ុនអត្តិភាព | 1 | 1 |
| មូលធនលើស | 603 | 601 |
| ប្រាក់ចំណេញរក្សាទុក | 332 | 466 |
| ភាគហ៊ុនរតនាគារ | (1) | - |
| ទុនផ្ទាល់របស់ភាគទុនិក | 1.147 | 1.280 |
| បំណុល និងផ្ទាល់របស់ភាគទុនិកសរុប | 21.705 | 22.586 |

**មូលប័ត្រវិនិយោគ**: (ចំណែកដែលងាយប្តូរយកប្រាក់) បន្ទាត់ទី 2 ដែលប្រើប្រាស់ដើម្បីឆ្លើយតបទៅនឹងតម្រូវការសាច់ប្រាក់ ជាប្រភពមូលធនដែលងាយប្តូរយកប្រាក់ ត្រូវបានគេហៅថា ប្រាក់តម្កល់ទី2។ ខ្ទង់នេះរួមមានមូលប័ត្ររដ្ឋាភិបាល និងមូលប័ត្រទីផ្សារប្រាក់ (ប្រាក់បញ្ញើដែលមានការប្រាក់នៅធនាគារផ្សេងៗ និងប័ណ្ណពាណិជ្ជកម្ម) ប្រាក់តម្កល់ទី2 គ្របដណ្តប់លើតំបន់មួយរវាងសាច់

ប្រាក់សុទ្ធ និងឥណទាន។ ផ្នែកនេះអាចបង្កើតបានប្រាក់ចំណូលខ្លះ ប៉ុន្តែត្រូវបានគេទុកដើម្បីបម្លែងទៅជាសាច់ប្រាក់សុទ្ធក្នុងរយៈពេលខ្លី។ នៅក្នុងតារាង3-3 ផ្នែកខ្លះនៃទឹកប្រាក់ $2.803 លាន គឺជាមូលប័ត្រវិនិយោគ និងត្រូវប្រើជាប្រាក់តម្កល់ទី 2 សម្រាប់ដោះស្រាយសាច់ប្រាក់។

**មូលប័ត្រវិនិយោគ** (ចំណែកដែលបង្កើតប្រាក់ចំណូល) សញ្ញាប័ណ្ណ ប័ណ្ណ និងមូលប័ត្រផ្សេងៗដែលបានកាន់កាប់ដោយធនាគារសម្រាប់ចំណូលដែលគេរំពឹងត្រូវបានស្គាល់ថា ជាមូលប័ត្រវិនិយោគ។ មូលប័ត្រមិនជាប់ពន្ធ រួមមានសញ្ញាប័ណ្ណរបស់រដ្ឋាភិបាល (USA) ហើយចំណូលដែលបានមកត្រូវរួចពន្ធសហព័ន្ធ។

មូលប័ត្រវិនិយោគត្រូវបានគេកត់ត្រាក្នុងសៀវភៅធនាគារតាមតម្លៃដំបូងដែលជាតម្លៃទីផ្សារ ឬក៏តម្លៃទាបជាង ឬមួយក៏ជាតម្លៃទីផ្សារ។ ធនាគារភាគច្រើនកត់ត្រាមូលប័ត្ររបស់ខ្លួននូវតម្លៃដែលខ្លួនបានទិញ ហើយទ្រព្យ និងបំណុលផ្សេងទៀតតាមតម្លៃដើម។ នៅពេលដែលអត្រាការប្រាក់ឡើងខ្ពស់បន្ទាប់ពីទិញមូលប័ត្រថ្លៃទីផ្សាររបស់មូលប័ត្រ នឹងទាបជាងថ្លៃចុះបញ្ជី ( ដូច្នេះហើយធនាគារដែលកត់ត្រាមូលប័ត្ររបស់ខ្លួនតាមតម្លៃដំបូងបានដាក់វង់ក្រចកដើម្បីបញ្ជាក់ពីតម្លៃទីផ្សារបច្ចុប្បន្នរបស់មូលប័ត្រ។

ធនាគារនេះមានគណនីមូលប័ត្រពាណិជ្ជកម្ម (Trading Account Securities) តូចៗមានន័យថា ធនាគារគឺជាអ្នកជំនួញមូលប័ត្រ។ ចំនួនដែលបានកត់ត្រា បង្ហាញថា ធនាគារមានបំណងលក់មូលប័ត្រទាំងនោះមុនកាលអវសាន្ត។

**ឥណទាន**: ខ្ទង់ទ្រព្យដែលធំជាងគេគឺឥណទាន ដែលជាធម្មតាមានប្រហែលពីពាក់កន្តាលដល់ 3/4 នៃទ្រព្យសរុបរបស់ធនាគារ។ តារាង3-3 បង្ហាញពីឥណទានពីរ ក្នុងតារាងតុល្យការ។ ឥណទានដែលធំជាងគេ ហៅថាឥណទានសរុប (Gross Loan) ដែលជាចំនួនសរុបមិនទាន់ទូទាត់ ដែលត្រូវគេជំពាក់នៅក្នុងទម្រង់ឥណទានប្រើប្រាស់ ឥណទានដីធ្លី ឥណទានពាណិជ្ជកម្ម និងឥណទានកសិកម្ម បូកនឹងឥណទានដែលបន្តទៅឱ្យក្រុមហ៊ុនជួញមូលប័ត្រនិងស្ថាប័នហិរញ្ញវត្ថុផ្សេងៗទៀត។ នៅក្នុងតារាងខាងលើ ឥណទានសរុបមានចំនួន 15 887 លានដុល្លា ក្នុងឆ្នាំថ្មីៗនេះ ឬប្រហែល 73% នៃទ្រព្យរបស់ធនាគារ។

ឥណទានបាត់បង់ (ទាំងបច្ចុប្បន្ននិងការព្យាករណ៍) ត្រូវបានគេដកចេញពីឥណទានសរុប។ នៅក្នុងច្បាប់ពន្ធធនាគារបច្ចុប្បន្នរបស់ U S ធនាគារត្រូវបានអនុញ្ញាតឱ្យបង្កើនប្រាក់តម្កល់សម្រាប់ឥណទានបាត់បង់នៅពេលអនាគត ដែលហៅប្រាក់បម្រុងសម្រាប់ឥណទានបាត់បង់ដែលអាចកើតមាន (Allowance for Possible Loan Losses-ALL) ALLគឺជា Contra-Account វាតំណាងឱ្យប្រាក់បង្គរ ដែលមានបំណងសម្រាប់បង្គរឥណតានមិនអាចប្រមូលបាន។ នេះមានន័យថា ឥណទានអាក្រក់ (Bad Loans) ជាធម្មតាមិនមានការប៉ះពាល់ដល់ចំណូលបច្ចុប្បន្នរបស់ធនាគារឡើយ (លើកលែងតែមិនសងកើតឡើងដោយមិនមានគ្រោងទុក ហើយគ្មានប្រាក់តម្កល់ត្រូវបានគេរក្សាទុក)។ នៅពេលដែលឥណទានត្រូវបាគេគិតថា មិនអាចប្រមូលបាន នាយកដ្ឋានគណនេយ្យរបស់ធនាគា និងដកវាចេញពីសៀវភៅកត់ត្រាដោយបន្ថយគណនី ALL ស្មើនឹងចំនួនឥណទានដែលមិនអាចប្រមូលបាន

ហើយពេលជាមួយគ្នាក៏បន្ថយគណនីទ្រព្យរបស់ឥណទានសរុប។ ឧទាហរណ៍ ធនាគារមួយផ្តល់ $10 លាន ឥណទានទៅឱ្យក្រុមហ៊ុនអភិវឌ្ឍន៍ចលទ្រព្យ ដើម្បីកសាងមជ្ឈមណ្ឌលលក់ដូរមួយ ប៉ុន្តែក្រោយមក ក្រុមហ៊ុនបិទទ្វារ។ ប្រសិនបើ ធនាគាររំពឹងថាងាចប្រមូលបានប្រាក់ $1 លាននៃចំនួន10 លាន ចំនួន $9 លាន ដែលមិនសងត្រូវបានគេដកពីគណនីឥណទានសរុបរបស់ ធនាគារហើយនឹងពីគណនី ALL។

ប្រាក់បម្រុងសម្រាប់ឥណទានបាត់បង់ ត្រូវបានគេបង្កើនជាជំហាន គឺមួយឆ្នាំទៅមួយឆ្នាំដោយដកចេញពីចំណូលបច្ចុប្បន្ន។ ការដកនេះត្រូវបានបង្ហាញនៅលើរបាយការណ៍ចំណូលរបស់ធនាគារថាការចំណាយមិនមែនសាច់ប្រាក់ហៅថា សំវិធានធនសម្រាប់ឥណទានបាត់បង់ (PLL)។ ប្រសិនបើការដកចេញឥណទានចំនួនច្រើនបានបន្ថយសមតុល្យនីក្នុងគណនី ALL យ៉ាងច្រើន ពួកអ្នកគ្រប់គ្រងនឹងត្រូវបានគេកោះហៅក្នុងពេលមានកំនើនការដក PLL ប្រចាំឆ្នាំ (ដែលនឹងបន្ថយចំណូលបច្ចុប្បន្នសុទ្ធ) ដើម្បីរក្សាទុក ALL នៅក្នុងកម្រិតសុវត្ថិភាព។ គេតែងតែបន្ថែម ALL នៅពេលដែលចង្កោមរបស់ធនាគាររីកធំ នៅពេលដែលឥណទានត្រូវបានគេចាត់ទុកថា មិនអាចប្រមូលបាន ឬក៏នៅពេលដែលឥណទានត្រូវបានគេចាត់ទុកថាមិនងាចប្រមូលបាន ឬក៏នៅពេលឥណទានមិនអាចប្រមូលបានដោយមិនបានរំពឹងទុក ដែលមិនត្រូវបានគេតម្កល់ទុក។ ការចុះបញ្ជីគណនេយ្យគឺគ្រាន់តែបង្កើនគណនី Contra-Assets ហើយនឹងគណនីចំណាយ PLL។ ចំនួនសរុបនៅក្នុងប្រាក់តម្កល់ឥណទានបាត់បង់ (ALL) ក្នុងតារាងតុល្យការរស់ធនាគារ ត្រូវបានគេដកពីឥណទានសរុបដើម្បីជួយក្នុងការចុះបញ្ជីគណនេយ្យ ហៅថាឥណទានសុទ្ធ (Net Loans) នៅក្នុងតារាងតុល្យការរបស់ធនាគារ។

ខ្ទង់មួយទៀតដែលដកចេញពីឥណាទានសរុបដើម្បីឱ្យទៅជាឥណទានសុទ្ធ ត្រូវបានគេហៅថា Unearned Discounts។ ខ្ទង់នេះរួមមាន ការប្រាក់ដែលបានពីឥណទានដែលបានបង់ឱ្យអតិថិជន ប៉ុន្តែមិនទាន់ចាត់ទុកជាចំណូលនៅឡើយបើតាមគណនេយ្យបង្គរ (Accrue Accounting)។ ឧទាហរណ៍ អតិថិជនខ្ចីប្រាក់ពីធនាគារ ហើយបានសងប្រាក់មុនពេលត្រូវសងធនាគារមិនអាចកត់ត្រាជាប្រាក់សងទេ ពីព្រោះអតិថិជនមិនទាន់ប្រើប្រាស់ឥណទានតាមពេលវេលាកំណត់នៅឡើយ។ នៅក្នុងជីវិតនៃឥណទាននេះ ការប្រាក់នឹងត្រូវចាត់ទុកជាចំណូលបណ្តើរៗ ហើយចំនួនចាំបាច់និងត្រូវបញ្ជូនពី Unearned Discounts ទៅគណនីចំណូលការប្រាក់។

ធនាគារមានខ្ទង់មួយទៀតនៅក្នុងគណនីនេះ គឺឥណទានមិនប្រតិបត្តិ (Non-Preforming Loans) ដែលជាឥណទានមិនផ្តល់ប្រាក់ឱ្យធនាគារ ឬធនាគារត្រូវរៀបចំឡើងវិញនូវឥណទាននោះសម្រាប់អ្នកខ្ចី។ នៅក្រោមច្បាប់បច្ចុប្បន្ន ឥណទានដែលគេចាត់ទុកឥណទានមិនប្រតិបត្តិ កាលណាវាមិនត្រូវបានសងតាមពេលកំណត់រយៈពេល ៩០ថ្ងៃ។ នៅពេលដែលឥណទានគេចាត់ថ្នាក់ជាឥណទានមិនប្រតិបត្តិ ការប្រាក់ដែលគេកត់ទុកក្នុងគណនេយ្យ (តែមិនទាន់ទទួលនៅឡើយ) ត្រូវតែដកចេញពីចំណូលឥណទាន។ ធនាការត្រូវបានហាមឃាត់មិនឱ្យចុះបញ្ជីនូវការប្រាក់តាំងឡាយណាដែលមិនទាន់ទទួលបានជាសាច់ប្រាក់។

**មូលធនសហព័ន្ធដែលលក់ និងមូលប័ត្រដែលទិញដែលមានកិច្ចព្រមព្រៀងលក់វិញ:** ប្រភេទឥណទានផ្សេងទៀតដែលបានចុះក្នុងតារាងតុល្យការគឺមូលធនសហព័ន្ធដែលលក់ និងមូលប័ត្រដែលទិញ ក្រោមកិច្ចព្រមព្រៀងលក់វិញ ខ្ទង់នេះរួមមានឥណទានបណ្តោះអាសន្ន ដែលផ្តល់ឱ្យធនាគារផ្សេងៗ និងពាណិជ្ជកម្មមូលប័ត្រ ឬក៏បណ្តាក្រុមហ៊ុនផ្សេងៗទៀត។ ប្រាក់សម្រាប់ឥណទានបណ្តោះអាសន្ននេះ បានមកពីប្រាក់តម្កល់នៅក្នុង The Federal Reserve ដូច្នេះហើយទើបគេហៅថាមូលធនសហព័ន្ធ។ ឥណទានប្រភេទនេះខ្លះត្រូវបានគេពន្យានៅក្នុងទម្រង់ទិញមកវិញ (លក់វិញ) នៅក្រោមកិច្ចព្រមព្រៀងមួយ ដែលធនាគារទិញបណ្តោះអាសន្ននៅមូលប័ត្រពីអ្នកខ្ចី ហើយរក្សាទុកមូលប័ត្រទាំងនោះមួយរយៈសម្រាប់ធានារហូតដល់បំណុលនោះត្រូវបានសង។

**បំណុលអតិថិជនលើប័ណ្ណបំណុលទទួល** (Acceptance) : ធនាគារធំៗជាច្រើនតែងតែផ្តល់ឥណទានដល់អតិថិជនរបស់ខ្លួនក្នុងទម្រង់ជាហិរញ្ញប្បទានប័ណ្ណបំណុល។ ចំនួនប្រាក់ត្រូវបានគេបង្ហាញនៅក្នុងគណនីទ្រព្យមានឈ្មោះថា បមណុលអតិថិជនមានទម្រង់ជាប័ណ្ណបំណុលមិនទាន់សង។ អ្នកអាចនឹងកត់សម្គាល់ថា ខ្ទង់នេះដូចគ្នាបេះបិទ និងខ្ទង់មួយទៀតដែលនៅក្រោមបំណុលរបស់ធនាគារ ដែលមានឈ្មោះថា ប័ណ្ណបំណុលមិនទាន់ទូទាត់។ គណនីទាំងពីរនេះមិនទាន់កើនឡើង មានន័យថា ធនាគារប្រមនៅពីខាងក្រោយក្រុមហ៊ុន ដើម្បីជួយក្រុមហ៊ុននោះក្នុងការសងថ្លៃទំនិញ ដែលនាំចូលពីបរទេស។ នីក្នុងករណីនេះ ធនាគារយល់ព្រមចេញប័ណ្ណបំណុល (លិខិតឥណទានដែលមានចុះហត្ថាលេខា) ដែលអនុញ្ញាតឱ្យភាគទី 3 (អ្នកនាំចូល) ចេញប័ណ្ណមួយដែលអាចដកប្រាក់ពីធនាគារដែលបោះពុម្ពប័ណ្ណនោះ នៅចំនួនដែលបានបញ្ជាក់និងថ្ងៃកំណត់។ នៅថ្ងៃ ឬមុនថ្ងៃដែលកំណត់ អតិថិជនដែលស្នើសុំប័ណ្ណបំណុលនៅគេត្រូវតែសងចំនួនទាងអស់ដូចបានចែងលើប័ណ្ណ ហើយធនាគារដែលចេញប័ណ្ណនោះ ទទួលយកប័ណ្ណលើបំណុលនេះនៅថ្ងៃត្រូវបើក ហើយប្រគល់ប្រាក់ទាំងអស់ដែលកត់ត្រាលើប័ណ្ណនោះទៅឱ្យម្ចាស់ប័ណ្ណបច្ចុប្បន្ន។

ដូច្នេះការបង្កើតប័ណ្ណបំណុលបានផ្តល់ការកើនឡើងព្រមគ្នាចំពោះទ្រព្យសកម្ម (បំណុលអតិថិជនចំពោះធនាគារ) និងបំណុល (ធនាគារសន្យាទទួលយកប័ណ្ណនៅថ្ងៃកំណត់)។ ប័ណ្ណបមណុលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយក្នុងបេលបច្ចុប្បន្នចំពោះពាណិជ្ជកម្មអន្តរជាតិសម្រាប់ទិញរូបិយវត្ថុ និងគាំទ្រដល់ការដឹកជញ្ជូនបឬក៏ក្នុងឃ្លាំង និងទំនិញកសិកម្មនៅក្នុងសេដ្ឋកិច្ចជាតិ។

**ទ្រព្យផ្សេងទៀត**: ទ្រព្យសកម្មរបស់ធនាគារ រាប់បញ្ចូលផងដែរនូវតម្លៃសុទ្ធនៃអគារ និងឧបករណ៍ប្រើប្រាស់ក្នុងធនាគារ (បន្ទាប់ពីដករំលោះ) ការវិនិយោគលើក្រុមហ៊ុនរណប ការប៉ង់ធានារ៉ាប់រងជាមុន ព្រមតាំងខ្ទង់ទ្រព្យផ្សេងៗទៀត។ ជាធម្មតាធនាគារចំណាយប្រាក់ប្រហែលជា 1 ទៅ 2 ភាគរយនៃទ្រព្យរបស់ខ្លួនបុណ្ណោះសម្រាប់អចលនទ្រព្យ ដើម្បីសម្រាប់អាជីវកម្មរៀងរាល់ថ្ងៃ។ ទោះបីជាទ្រព្យរបស់ធនាគារជាឥណទាននិងមូលប័ត្រ ប៉ុន្តែអចលនទ្រព្យក៏បានបង្កើតនូវចំណាយថេរ ដែលមានទម្រង់ជារំលោះ ពន្ធលើទ្រព្យសម្បត្តិ។ ល។ ដែលផ្តល់ ប្រៀបផ្នែកប្រតិបត្តិការ ហើយអនុញ្ញាតឱ្យធនាគារជម្រុញការរកចំណូល ប្រសិនបើវាថាចបង្កើននូវចំនួនសេវាកម្មដែលបានលក់ច្រើនព្រមទាំងងាចរកចំណូលបានច្រើនជាងការចំណាយទៅលើអចលនទ្រព្យនោះទេ។ ប៉ុន្តែដោយសារ

ចំនួនអចលនទ្រព្យមានតិចតួចប្រៀបជាមួយទ្រព្យផ្សេងទៀត ហើយធនាគារមិនអាចផ្អែកប្រៀបលើប្រតិបត្តិការ (Operating Leverage) ដើម្បីបង្កើនការរកចំណូលរបស់ខ្លួនឡើយ វាត្រូវតែផ្អែកលើប្រៀបហិរញ្ញវត្ថុ (Financial Leverage) គឺការប្រើប្រាស់កម្ចី ដើម្បីបង្កើនការរកចំណូល នឹងរក្សាផាពប្រកួតប្រជែងជាមួយនឹងឧស្សាហកម្មផ្សេងទៀត ដើម្បីទាក់ទាញមូលធន។

## ៣.៤.ចំណូលរបស់ធនាគារ

**ប្រាក់បញ្ញើ**: មូលដ្ឋានបំណុលរបស់ធនាគារគឺ ប្រាក់បញ្ញើដែលជាការទាមទារហិរញ្ញវត្ថុ (Financial Claims) របស់អាជីវកម្ម គ្រួសារ និងរដ្ឋាភិបាលចំពោះធនាគារ។ ទោះក្នុងករណីធនាគារមានប្រាក់គ្រប់គ្រាន់សម្រាប់សងក៏ដោយ ក៏ធនាគារត្រូវប្រើប្រាស់ចំណូលពីការលក់ទ្រព្យសកម្មរបស់ខ្លួនដើម្បីសងអ្នកដែលផ្ញើរប្រាក់។ ចំណែកឯម្ចាស់បំណុលផ្សេងទៀតនិម្ចាស់ភាគហ៊ុនរបស់ធនាគារទទួលមូលធនដែលនៅសល់។ ប្រាក់បញ្ញើរួមមាន 5 ប្រភេទសំខាន់ៗ។

1. ប្រាក់បញ្ញើដែលគ្មានការ : ឬជាគណនីមូលប្បទានប័ត្រជម្មតា ដែលអនុញ្ញតឱ្យសរសេរមូលប្បទានប័ត្រដោយគ្មានកំណត់
2. ប្រាក់បញ្ញើសញ្ជ័យ : ជាធម្មតាគណនីនេះទទួលបានការប្រាក់ទាបជាងគេក្នុងចំណោមប្រាក់បញ្ញើទាំងអស់ ប៉ុន្តែធនាគារខ្លះកំណត់នូវចំនួនដែលទាបបំផុត ដែលតម្កល់ក្នុងគណនី ចំណែកឯម្ចាស់គណនីងាចដកប្រាក់របស់ខ្លួននូវចំនួន និងពេលវេលាដែលខ្លួនចង់បាន
3. គណនី NOW : ដែលអនុញ្ញាតឱ្យប្រើប្រាស់តែចំពោះបុគ្គល និងស្ថាប័នមិនមែនរកប្រាក់ចំណេញ គណនីនេះទទួលបានការប្រាក់ ហើយអាចសរសេរជាមូលប្បទានប័ត្របានដើម្បីទូទាត់ភាគីទី 3
4. គណនីប្រាក់បញ្ញើទីផ្សារប្រាក់ (MMDAs) គណនីនេះអាចទទួលបានការប្រាក់ដែលមានការប្រេតប្រកួតប្រជែងពីធនាគារ ប៉ុន្តែសិទ្ធនៃការចេញមូលប្បទានប័ត្រត្រូវបានគេកំរិត។ វាគ្មានរយៈពេលកំណត់ ឬចំនួនតម្កល់ទាបបំផុតដែលត្រូវបានចែងនៅក្នុងច្បាប់ទេ ដូច្នេះហើយ ស្ថាប័នប្រាក់បញ្ញើត្រូវរក្សាសិទ្ធ 7 ថ្ងៃ នៃការជូនដំណឹងមុនពេលដកប្រាក់។
5. ប្រាក់បញ្ញើមានកាលកំណត់ (ប័ណ្ណប្រាក់បញ្ញើ) ជាធម្មតាវាមានពេលកំណត់ក្នុងការដកហើយបានបញ្ជាក់ពីអត្រាការប្រាក់ ប៉ុន្តែមានចំនួនផ្សេងៗគ្នា។ ការប្រាក់នឹងថ្ងៃកំណត់ ត្រូវបានព្រមព្រៀងដោយធនាគារនេងអ្នកផ្ញើរ។

**ការខ្ចីពីប្រភពដែលមិនមែនជាប្រាក់បញ្ញើ** : ប្រាក់បញ្ញើចាផ្អែកដ៏ធំជាងគេនៃប្រភពចំណូលរបស់ធនាគារ ប៉ុន្តែមូលធនធំខ្លះក៏បានមកពីគណនីបំណុលផ្សេងទៀតដែរ។ បើសិនជាធនាគារកាន់តែធំការប្រើប្រាស់ប្រភពធននេះក៏បានកាន់តែធំ។ មូលហេតុមួយដែលធនាគារប្រើប្រាស់ប្រភពធននេះពីព្រោះវាទាមទារការតម្កល់ប្រាក់សម្រាប់មូលធននេះ ដែលបន្ថយការចំណាយចំពោះមូលធនដែលមិនមែនជាប្រាក់បញ្ញើ ម្យ៉ាងទៀតការខ្ចីប្រាក់ពីទីផ្សារប្រាក់អាចធ្វើឡើងនៅពេលតែ 2 ឬ 3 នាទីប៉ុណ្ណោះ

ហើយមូលធននេះត្រូវបានបញ្ជូនតាមប្រព័ន្ធអេឡិចត្រូនិច ទៅធនាគារដែលត្រូវការ។ ប៉ុន្តែ គុណវិបត្តិមួយរបស់វាគឺអត្រាការប្រាក់មានការប្រែប្រួលឆាប់រហ័ស។ ប្រសិនបើ មានសញ្ញាខ្លះអំពីបញ្ហាហិរញ្ញវត្ថុដែលមាននៅក្នុងធនាគារតម្លៃនៃការខ្ចីគឺឡើងខ្ពស់ភ្លាម ឬក៏អ្នកដែលឱ្យខ្ចីនៅក្នុងទីផ្សារប្រាក់ បដិសេធន៍មិនបន្តឥណទាននេះតទៅទៀត។

**គណនីមូលធនផ្ទាល់** : គណនីមូលធនផ្ទាល់របស់ធនាគារបង្ហាញពីភាគហ៊ុនរបស់ម្ចាស់ធនាគារ។ គ្រប់ធនាគារថ្មីៗទាំងអស់បានចាប់ផ្តើមពីមូលធនផ្ទាល់ (យ៉ាងហោចណាស់ $1 លាន) ហើយបន្ទាប់មកខ្ចីប្រាក់ពីសាធារណៈជន ដើម្បីបំពេញប្រតិបត្តិការរបស់ខ្លួន។ ធនាគារគឺជាពាណិជ្ជកម្មមួយបែបដែលមានកម្រិតបំណុលខ្ពស់ជាងគេបំផុត គណនីទុនផ្ទាល់របស់ធនាគារជាធម្មតាមានប្រហែលជា 10% នៃទ្រព្យរបស់ធនាគារទាំងមូល។

ទោះបីជា មូលធនផ្ទាល់របស់ធនាគារតូចក៏ដោយ ក៏គណនីនេះរួមមានខ្ទង់ផ្សេងៗ ដូចបណ្តាអាជីវកម្មផ្សេងទៀតដែរ។ ចំនួនសរុបនៃតម្លៃប័ណ្ណភាគហ៊ុនធម្មតា (Common Stock) ដែលមិនទាន់បានសងត្រូវបានគេចុះបញ្ជី ហើយភាគហ៊ុននេះត្រូវបានលក់ នឹងត្រូវបានបញ្ចូលក្នុងគណនីមូលធនផ្ទាល់លើស (Capital Surplus)។ ធនាគារខ្លះបោះពុម្ព Preferred Stock ដែលម្ចាស់ភាគហ៊ុននេះទទួលនូវភាគលាភប្រចាំឆ្នាំ មុនម្ចាស់ភាគហ៊ុនធម្មតា។ Preferred Stock ត្រូវបានគេគិតថាមានថ្លៃខ្ពស់ សម្រាប់ពួកធនាគារ ហើយចំនួលដែលតទូលបានមកត្រូវហូរទៅម្ចាស់Preferred Stock។ ជាធម្មតាខ្ទង់ដែលធំជាងគេនៅក្នុងគណនីមូលធនផ្ទាល់ គឺ Retained Earnings ដែលជាបង្គរនៃប្រាក់ចំណេញពីមុនមក បន្ទាប់ពីចែកភាគលាភទៅឱ្យម្ចាស់ភាគហ៊ុន។ វាមានប្រាក់បង្គរបំរុង ដែលរក្សាទុកសម្រាប់ការពារទល់នឹងការខាតដែលមិនអាចដឹងមុន និងហ៊ុនរតនាគារ (Treasury Stock) ដែលដល់ថ្ងៃកំណត់។

ខ្ទង់មួយទៀតដែលកើតមានពុំសូវញឹកញាប់ចំពោះធនាគារ ដែលមានទំហំមធ្យម និងធំគឺប័ណ្ណ និងបំណុលបន្ទាប់បន្សំ វាគឺជាមូលប័ត្របំណុលដែលមានរយៈពេលវែង ដែលទាមទារទល់នឹងទ្រព្យរបស់ធនាគារ ដែលឈរបន្ទាប់ពីប្រាក់បញ្ញើ។ ធនាគារជាច្រើនមើលថា ប័ណ្ណនិងប័ណ្ណបំណុលបន្ទាប់បន្សំ គឺជាផ្នែកមួយនៃមូលធនផ្ទាល់របស់ធនាគារ ដូចជាភាគហ៊ុនធម្មតា ពីព្រោះការទាមទាររបស់ប័ណ្ណបន្ទាប់បន្សំមានអាទិភាពទាប។

## ៣.៥.ធាតុផ្សំនៃរបាយការណ៍ចំណេញ

របាយការណ៍ចំណេញបានបង្ហាញពីចំនួននៃប្រាក់ចំណូលដែលទទួលបាន ហើយនិងការចំណាយ នៅក្នុងកំឡុងពេលមួយជាក់លាក់។ តារាងតុល្យការ និងរបាយការណ៍ចំណូលរបស់ធនាគារមានទំនាក់ទំនងគ្នាយ៉ាងជិតស្និតលើទំហំនៃខ្ទង់សំខាន់មួយចំនួន។ ទ្រព្យទាំងអស់នៅក្នុងតារាងតុល្យការជាអ្នកបង្កើតចំណូលយ៉ាងសំខាន់ ប៉ុន្តែបំណុលជាអ្នកបង្កើតចំណាយប្រតិបត្តិការ។

ប្រភពចំណូលជាមូលដ្ឋានរបស់ធនាគារគឺចំណូលពីការប្រាក់ ដែលបង្កើតដោយទ្រព្យរបស់ធនាគាររួមមាន ឥណទាន (L) មូលប័ត្រ (S) ប្រាក់បញ្ញើ ដែលមានការប្រាក់ ដែលជាផ្នែកមួយនៃសាច់ប្រាក់ ( C ) ស្ថិតនៅក្នុងធនាគារដ៏ទៃទៀត និងបណ្តាទ្រព្យផ្សេងៗទៀតដែលបង្កើតប្រាក់

ចំណូល (M)។ ចំពោះការចំណាយក្នុងការបង្កើតចំណូលរួមមាន ការប្រាក់ដែលផ្តល់ទៅឱ្យប្រាក់បញ្ញើ (D) ការប្រាក់ដែលជំពាក់លើកម្ចីដែលមិនមែនជាប្រាក់បញ្ញើ (NDB) ការចំណាយសម្រាប់មូលធនផ្ទាល់ (EC) ប្រាក់ខែ និងប្រាក់ឧបត្ថម្ភផ្សេងៗសម្រាប់បុគ្គលិកធនាគារ (SWB) ការចំណាយមិនផ្ទាល់ផ្សេងៗទាក់ទងនិងអចលទ្រព្យ (O) ប្រាក់ដែលតម្កល់ទុកសម្រាប់លទ្ធភាពបាត់បង់ពីឥណទាន (PLL) ពន្ធ (T) និងការចំណាយផ្សេងៗ (ME)។ ភាពខុសគ្នារវាងចំណូលសរុប និងចំណាយសរុប គឺចំណេញសុទ្ធ។

ចំណេញសុទ្ធ = ចំណូលសរុប – ចំណាយសរុប

**ចំណូល**

↓

(សាច់ប្រាក់ X ចំណូលមធ្យមពីសាច់ប្រាក់ + ការវិនិយោគមូលប័ត្រ X ចំណូលមធ្យមពីវិនិយោគលើមូលប័ត្រ +ឥណទានមិនទាន់សង X ចំណូលមធ្យមលើឥណទាន + ទ្រព្យសកម្មផ្សេងៗ X ទិន្នផលមធ្យមលើទ្រព្យសកម្មផ្សេងៗ)

**ដក (-) ចំណាយ**

↓

(ប្រាក់បញ្ញើសរុប X ចំណាយការប្រាក់មធ្យមលើប្រាក់បញ្ញើ + កម្ចីមិនមែនជាប្រាក់បញ្ញើ X ចំណាយការប្រាក់មធ្យមលើកម្ចីមិនមែនប្រាក់បញ្ញើ + មូលធនផ្ទាល់ X ការចំណាយមធ្យមលើមូលធនផ្ទាល់ + បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ + ការចំណាយមិនផ្ទាល់ + សំវិធានធនសម្រាប់លទ្ធភាពបាត់បង់ឥណទាន + ការចំណាយផ្សេងៗ+ ពន្ធ

បើយើងយក r ជាចំណូលមធ្យមពីទ្រព្យសកម្ម i ហើយជាចំណាយការប្រាក់បញ្ញើ កម្ចីដែលមិនមែនប្រាក់បញ្ញើ និងចំណាយលើមូលធនផ្ទាល់ ដូច្នេះចំណេញសុទ្ធគឺ

$$\text{ចំណេញសុទ្ធ} = (CXr_{cash} + SXr_{sec} + LX_{loans} + MXr_m) - (DXi_d + NDBXi_{ndb} + ECXi_{ec} + SWB + O + PLL + ME + T)$$

រូបមន្តខាងលើបានបង្ហាញថា ចំណេញសុទ្ធកើនឡើងបណ្តាលមកពីករណីដូចខាងក្រោម :

(1) ការកើនឡើងចំណូលមធ្យមលើទ្រព្យនីមួយៗ

(2) ការបែងចែកទ្រព្យជាថ្មី ដោយបង្កើនទ្រព្យដែលមានចំណូលខ្ពស់

(3) បន្ថយការចំណាយលើការប្រាក់ចំពោះប្រាក់បញ្ញើ កម្ចីមិនមែនប្រាក់បញ្ញើ និងមូលធនផ្ទាល់ ឬការចំណាយមិនមែនការប្រាក់

**តារាង 3-4 របាយការណ៍ចំណេញរបស់ Midwestern Bank**

(ឯកតាជាលានដុល្លា)

| | |
|---|---|
| ចំណូល និងចំណាយ | |
| ចំណូលលើការប្រាក់ : | $780 |

| | |
|---|---|
| ការប្រាក់ និងកម្រៃពីឥណទាន | |
| ការប្រាក់ពីមូលប័ត្រវិនិយោគ | |
| ចំណូលជាប់ពន្ធពីមូលប័ត្រ | 76 |
| ចំណូលមិនជាប់ពន្ធពីមូលប័ត្រ | 40 |
| ចំណូលការប្រាក់ផ្សេងៗទៀត | 37 |
| ចំណូលការប្រាក់សរុប | 923 |
| ចំណាយលើការប្រាក់ | |
| ចំណាយការប្រាក់លើ ប្រាក់បញ្ញើ | 513 |
| ការប្រាក់លើបំណុលរយៈពេលខ្លី | 101 |
| ការប្រាក់លើបំណុលរយៈពេលវែង | 30 |
| ចំណាយការប្រាក់សរុប | 644 |
| ចំណូលការប្រាក់សុទ្ធ (ចំណូលការប្រាក់សរុប - ចំណាយការប្រាក់សរុប) | 279 |
| សំវិធានធនសម្រាប់លទ្ធភាពបាត់បង់ឥណទាន | 255 |
| ចំណូលការប្រាក់សុទ្ធ បន្ទាប់ពីដកសំវិធានធននៃឥណទានបាត់បង់ | 24 |
| ចំណូលមិនមែនការប្រាក់ | |
| កម្រៃសេវាលើប្រាក់បញ្ញើអតិថិជន | 29 |
| ចំណូលពីនាយកដ្ឋាននានា | 26 |
| ចំណូលពីប្រតិបត្តិការនានា | 119 |
| ចំណូលមិនមែនការប្រាក់សរុប | 174 |
| ចំណាយមិនមែនការប្រាក់ | |
| បៀវត្ស និងចំណាយបុគ្គលិក | 130 |
| ចំណាយលើឧបករណ៍ និងការកាន់កាប់ | 44 |
| ការចំណាយប្រតិបត្តិការផ្សេងៗ | 135 |
| ចំណាយមិនមែនការប្រាក់សរុប | 309 |
| ចំណូលមិនមែនប្រាក់សុទ្ធ | (135) |
| ចំណេញ (ខាត) មុនបង់ពន្ធ | (111) |
| សំវិធានធនពន្ធលើប្រាក់ចំណូល | (3) |
| ចំណេញសុទ្ធ (ខាតសុទ្ធ) បន្ទាប់ពីបង់ពន្ធ | (114) |
| ចំនួនភាគហ៊ុនធម្មតា | (3) |
| ចំណេញ (ខាត) ចំពោះភាគហ៊ុននីមួយៗ | (114) |
| ចំនួនភាគហ៊ុនធម្មតា | 42.384.000 |
| ចំណេញ (ខាត) ចំពោះភាគហ៊ុននីមួយៗ | $ (268) |

**ចំណូលការប្រាក់** ៖ ចំណូល និងកម្រៃពីឥណទាន ជាចំណូលដែលច្រើនជាងគេរបស់ធនាគារ (ស្មើ 2/3 ឬច្រើនជាងនៃចំណូលសរុប) នៅតារាងខាងលើគឺ $780 លាន ដែលស្មើនឹង 70% នៃចំណូលពីការប្រាក់ និងចំណូលមិនមែនការប្រាក់។ ចំណូលឥណទានបន្ទាប់មកទៀតពីការវិនិយោគមូលប័ត្រ ដែលត្រូវបង់ពន្ធ ឬលើកលែងពន្ធ ចំណូលពីកិច្ចសន្យាឥណទាន និងលក់មូលធនសហព័ន្ធ ហើយនឹងចំណូលការប្រាក់ពីប្រាក់បញ្ញើនៅធនាគារផ្សេងៗ។ ចំណូលនេះមានការផ្លាស់ប្តូរពីមួយឆ្នាំទៅមួយឆ្នាំតាមការផ្លាស់ប្តូរអត្រាការប្រាក់ ការផ្លាស់ប្តូរឥណទាន។

**ចំណាយការប្រាក់** ៖ ការចំណាយធំទីមួយរបស់ធនាគារគឺ ការប្រាក់លើប្រាក់បញ្ញើ ដូចបានបង្ហាញក្នុងតារាង 3-6។ ចំណាយការប្រាក់សរុប 54% នៃការចំណាយរបស់ធនាគារទាំងមូល។ ចំណាយការប្រាក់ដែលសំខាន់ ហើយកើនលឿនជាងគេនោះគឺការប្រាក់លើកម្ចីរយៈពេលខ្លីពីទីផ្សារប្រាក់។ ការប្រាក់ពីបំណុលរយៈពេលខ្លីគឺ 15% នៃចំណាយសរុបរបស់ធនាគារ។

**ចំណូលការប្រាក់សុទ្ធ** ៖ ធនគារជាច្រើនបានដកចំណាយការប្រាក់សរុបពីចំណូលការប្រាក់សរុប ដើម្បីទទួលបានចំណូលការប្រាក់សុទ្ធ ចំនួននេះគេតែងហៅថា គម្លាតការប្រាក់ដែលជាគម្លាតរវាងចំណូលការប្រាក់ ដែលធនាគារទទួលបានពីឥណទាន និងមូលប័ត្រ និងការចំណាយការប្រាក់លើការខ្ចីមូលធន។ ខ្ទង់នេះជាកត្តាកំណត់ភាពចំណេញរបស់ធនាគារ នៅពេលដែលគម្លាតការប្រាក់ធ្លាក់ចុះ ធនាគារមានបទពិសោធន៍ក្នុងការទទួលបានប្រាក់ចំណេញសុទ្ធទាប។

**ការចំណាយលើឥណទានបាត់បង់** ៖ ខ្ទង់ចំណាយមួយទៀតដែលធនាគារដកចេញជាចំណូលគឺសមវិធានធននៃឥណទានដែលអាចបាត់បង់ (Provision for Possible Loan Losses)។ ការចំណាយនេះមិនមែនចាចំណាយសាច់ប្រាក់ទេ វាត្រូវបានបង្កើតចុះបញ្ជីគណនេយ្យគោលបំណងសំខាន់ក្នុងប្រតិបត្តិការនេះគឺសម្រាប់ការពារផ្នែកខ្លះនៃចំណូលពីការបង់ពន្ធ ដើម្បីជួយដល់បំណុលអាក្រក់។ សំវិធានធនឥណទាន បាត់បង់ត្រូវដកចេញពីចំណូលបច្ចុប្បន្នមុនការដកពន្ធ។

**ចំណូលមិនមែនការប្រាក់** ៖ ក្រៅពីចំណូលឥណទាននិងមូលប័ត្រ ធនាគារនូវមានចំណូលផ្សេងទៀត ដែលហៅថា ចំណូលមិនមែនការប្រាក់ដែលរួមមានសេវាកម្មលើការធានាសេវាកម្មលើគណនីប្រាក់បញ្ញើ និងកម្រៃផ្សេងៗ។ បច្ចុប្បន្ននេះធនាគារដាក់គោលដៅលើចំណូលមិនមែនការប្រាក់ដែលត្រូវបានស្គាល់ថា ជាចំណូលពីការលក់សេវាកម្មដ៏ខ្លាំងក្លា (ដូចជាកម្រៃជើងសារមូលប័ត្រ ធានារ៉ាប់រង និងសេវាធនធាន) ធនាគារបានរកឃើញមធ្យោបាយមួយដើម្បីធ្វើឱ្យឡើងនូវបន្ទាត់ចុងក្រោយនៃរបាយករណ៍ចំណូលរបស់ខ្លួន ធ្វើឱ្យមានប្រភពចំណូលច្រើនប្រភេទ និងរារាំងពីការប្រែប្រួលដោយអត្រាការប្រាក់។ តារាង 3-6 បានបង្ហាញថា 16% នៃចំណូលសរុបគឺចំណូលសរុបមិនមែនការប្រាក់។

**ចំណាយមិនមែនការប្រាក់** ៖ ការចំណាយមិនមែនការប្រាក់ដែលសំខាន់ជាងគេគឺបៀវត្ស និងការចំណាយបុគ្គលិក ដែលថ្មីៗនេះបានកើនឡើងយ៉ាងលឿន ពីព្រោះធនាគារបានជ្រើសរើសអ្នកបញ្ចប់ការសិក្សាដែលមានគុណភាពខ្ពស់ ដើម្បីដឹកនាំក្រុមអ្នកគ្រប់គ្រងរបស់ខ្លួនហើយនឹងទាក់ទងអ្នកគ្រប់គ្រង ដែលមានបទពិសោធន៍ពីគូប្រជែងរបស់ខ្លួន។ ការចំណាយលើឧបករណ៍សង្ហារឹម ក៏ស្ថិតនៅ

ក្នុងប្រភេទការចំណាយមិនមែនការប្រាក់ដែរ ការចំណាយមិនមែនការប្រាក់ផ្សេងទៀត រួមមានថ្លៃសេវាកម្មច្បាប់ សម្ភារៈការិយាល័យ និងការជួលផុល។

**ចំណេញសុទ្ធ** : ក្នុងការអនុវត្តន៍ការដកចំណាយមិនមែនការប្រាក់ និងចំណាយការប្រាក់ពីផលបូកនៃចំណូលការប្រាក់ និងចំណូលមិនមែនការប្រាក់ និងទទួលបានចំណេញ (ឬខាត) មុនការបង់ពន្ធ បន្ទាត់ក្រោមបំផុតនៃរបាយការណ៍ចំណូលរបស់ធនាគារគឺចំណូលសុទ្ធបន្ទាប់ពីពន្ធដែលជាធម្មតាត្រូវបានចែកចាពីរប្រភេទ។ ប្រភេទទីមួយ គឺភាគលាភត្រូវបានចែកទៅឱ្យម្ចាស់ភាគហ៊ុន ហើយប្រភេទទីពីរគឺប្រាក់ចំណេញរក្សាទុកដើម្បីប្រើប្រាស់ក្នុងការវិនិយោគបន្តនឹងអភិវឌ្ឍធនាគារទៅថ្ងៃអនាគត។

# មេរៀនទី៤
# វាស់វែង និងវាយតម្លៃធនាគារ

## ៤.១. ការវាយតម្លៃប្រតិបត្តិការធនាគារ

តើយើងប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារយ៉ាងដូចម្តេច? ជាពិសេសតារាងតុល្យការ និងរបាយការណ៍ចំណូលដើម្បីវាយតម្លៃប្រតិបត្តិការរបស់ធនាគារ? ។ តើយើងគយរតែពិនិត្យទៅលើអ្វីដែលអាចជួយយើងឱ្យបានដឹងថា ធនាគារមួយកំពុងតែជួបបញ្ហាដ៏ធ្ងន់ធ្ងរ ដែលកត្រុមអ្នកគ្រប់គ្រងត្រូវតែដោះស្រាយ? ។

### ៤.១.១ កំណត់គោលដៅរយៈពេលវែងរបស់ធនាគារ

ជំហានទីមួយក្នុងការវិភាគរបាយការណ៍ហិរញ្ញវត្ថុធនាគារ គឺការកំណត់គោលដៅរបស់ធនាគារ ឬក៏អ្វីដែលធនាគារចង់សម្រេចបាន។ ប្រតិបត្តិការរបស់ធនាគារត្រូវតែតម្រង់ទិសរកគោលដៅជាក់លាក់ ការវាយតម្លៃដ៏ត្រឹមត្រូវមួយពីប្រតិបត្តិការរបស់ធនាគារ គួតែចាប់ផ្តើមពីការវាយតម្លៃ ថាតើធនាគារនេះអាចសម្រេចបាននូវគោលដៅរបស់អ្នកគ្រប់គ្រងនិងម្ចាស់ភាគហ៊ុនដែលចង់បានដែរឬទេ?

ធនាគារជាច្រើនមានគោលដៅខុសគ្នា ធានាគារខ្លះចង់ឱ្យមានកំណើនខ្លាំងដើម្បីសម្រេចឱ្យបាននូវគោលដៅរីកចម្រើនរយៈពេលវែង ហើយខ្លះទៀតចូលចិត្តនៅស្ងៀមដើម្បីបន្ថយហានិភ័យចាអប្បបរមារ។

### ៤.១.២. បង្កើនជាអតិបរមានៃតម្លៃក្រុមហ៊ុនរបស់ធនាគារ (ជាគោលសំខាន់របស់ធនាគារ)

បច្ចុប្បន្ន ធនាគារបានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើតម្លៃនៃភាគហ៊ុនរបស់វាការបង្កើនជាអតិបរមានៃតម្លៃភាគហ៊ុនរបស់ធនាគារ គឺជាគោលដៅគន្លឹះដែលត្រូវបានផ្តល់ជាអទិភាពខ្ពស់ជាងគេ។ គ្រប់ធនាគារត្រូវបានរួមបញ្ចូលគ្នាដោយភាគហ៊ុនជាច្រើនបើសិនជាភាគហ៊ុនទាំងនោះមិនបានកើនឡើងតម្លៃ ដូចជាការរំពឹងទុករបស់ម្ចាស់ភាគហ៊ុន ភាគហ៊ុននិកបច្ចុប្បន្ននិងព្យាយាមលក់ប័ណ្ណភាគហ៊ុនរបស់ខ្លួនចេញ ហើយធនាគារនឹងជួបប្រទះការលំបាកក្នុងការរកមូលធនថ្មីៗ ដើម្បីការលូតលាស់របស់ខ្លួនក្នុងពេលអនាគត។ ហេតុដូច្នេះហើយ ពួកអ្នកគ្រប់គ្រងធនាគារត្រូវតែសម្រេចឱ្យបាននូលគោលដៅក្នុងការបង្កើនតម្លៃរបស់ភាគហ៊ុន។

តើអ្វីជាកត្តានៃឱ្យតម្លៃរបស់ភាគហ៊ុនធនាគារកើនឡើង?

ថ្លៃភាគហ៊ុនធនាគារជាអនុគមន៍ទៅនឹង :

$$\text{តម្លៃនៃភាគហ៊ុនធនាគារ1 } (P_0) = \frac{\text{ភាគលាភដែលរំពឹងទុករបស់ភាគហ៊ុនិក}}{\text{មេគុណអប្បហារ (ជាអត្រាចំណូលទាបបំផុតដែលទាមទារដោយទីផ្សារចំពោះទុនផ្ទាល់រាប់បញ្ចូលទាំងហានិភ័យ)}}$$

$$= \sum_{t=0}^{\infty} \frac{(D_t)}{(1+r)^{t}} \quad (1)$$

E $(D_t)$: ភាគលាភដែលរំពឹងទុកនឹងត្រូវបានគេសងក្នុងពេលអនាគត តម្លៃភាគហ៊ុនរបស់ធនាគារនឹងកើនឡើងនៅក្រោមស្ថានភាពដូចខាងក្រោមៈ

$$P_0 = \frac{D_1}{(1-r)^1} + \frac{D_2}{(1+r)^2} + \dots + \frac{D_n}{(1+r)^n} + \frac{P_n}{(1+r)^n} +$$

1. តម្លៃនៃចរន្តភាគលាភទៅអនាគតត្រូវបានគេរំពឹងថានឹងកើនឡើង ដោយហេតុថា ថ្មីៗនេះមានកំណើននៅក្នុងទីផ្សារដែលធនាគារកំពុងតែប្រតិបត្តិការ ឬក៏ទិញនូវទ្រព្យផ្សេងៗដែលអាចមានចំណេញ

2. ហានិភ័យ ដែលធនាគារបានគិតធ្លាក់ចុះ ដែលបណ្តាលមកពីការកើនឡើងផ្នែកមូលធន ឬក៏ការថយចុះនូវឥណទានបាត់បង់

3. ភាគលាភដែលរំពឹងទុកថាមានការកើនឡើង ព្រមជាមួយនឹងការថយចុះហានិភ័យដែលសង្ឃឹមដោយពួកអ្នកវិនិយោគ

ការសិក្សាស្រាវជ្រាវបានរកឃើញថា តម្លៃភាគហ៊ុនរបស់ធនាគារប្រែប្រួលជាពិសេសទៅតាមអត្រាការប្រាក់ អត្រាប្តូរប្រាក់ និងភាពខ្លាំង ឬខ្សោយនៃសេដ្ឋកិច្ចរបស់ប្រទេសដែលធនាគារនោះស្ថិតនៅ។ ពួកអ្នកគ្រប់គ្រងនឹងអាចសម្រេចបាននូវគោលនយោបាយបង្កើនថ្លៃរបស់ភាគហ៊ុន។

## ៤.១.៣. អនុបាតប្រាក់ចំណេញ

នៅក្នុងទ្រឹស្តី ចរិតនៃថ្លៃភាគហ៊ុនជាសញ្ញាសំខាន់បំផុតរបស់អាជីវកម្មភាគច្រើន ប៉ុន្តែនៅក្នុងឧស្សាហកម្មធនាគារមិនត្រូវបានគេចាត់ទុកជាសញ្ញាគួរឱ្យទុកចិត្តទេ។ មូលហេតុគឺថា ភាគហ៊ុនរបស់ធនាគារភាគច្រើន ជាពិសេសធនាគារតូចៗមិនត្រូវបានគេចរាចរត្រលំទូលាយនៅក្នុងទីផ្សារជាតិ និងអន្តរជាតិទេ។ ការនេះបង្ខំឱ្យអ្នកវិភាគហិរញ្ញវត្ថុមកពិនិត្យមើលនូវសញ្ញាផ្សេងៗនៃអនុបាតប្រាក់ចំណេញ។

អនុបាតប្រាក់ចំណេញសំខាន់ក្នុងឧស្សាហកម្មធនាគារ

$$\text{ចំណូលធៀបនឹងមូលធនផ្ទាល់ (ROE)} = \frac{\text{ចំណូលសុទ្ធបន្ទាប់ពីពន្ធ}}{\text{មូលធនផ្ទាល់សរុប}} \quad (2)$$

$$\text{ចំណូលធៀបនឹងទ្រព្យ (ROA)} = \frac{\text{ចំណូលសុទ្ធបន្ទាប់ពីពន្ធ}}{\text{ទ្រព្យទាំងអស់}} \quad (3)$$

$$\text{គម្លាតការប្រាក់សុទ្ធ} = \frac{\text{(ចំណូលការប្រាក់ពីឥណទាន និងវិនិយោគមូលប័ត្រ – ចំណាយការប្រាក់លើប្រាក់បញ្ញើ និងបំណុលដទៃទៀត}}{\text{ទ្រព្យសរុប}} \quad (4)$$

$$\text{គម្លាតមិនមែនការប្រាក់សុទ្ធ} = \frac{\text{(ចំណូលមិនមែនការប្រាក់ – ចំណាយមិនមែនការប្រាក់)}}{\text{ទ្រព្យសរុប}} \quad (5)$$

$$\text{គម្លាតប្រាក់ចំណេញប្រតិបត្តិការ} = \frac{\text{ចំណូលពីប្រតិបត្តិការសរុប} - \text{ចំណាយពីប្រតិបត្តិការសរុប)}}{\text{ទ្រព្យសរុប}} \quad (6)$$

$$\text{ចំណូលសុទ្ធមុនពេលប្រតិបត្តការពិសេស (NRST)} = \frac{\text{ចំណេញ (ខាត) ពីមូលប័ត្រ និងខ្ទង់ផ្សេងៗ}}{\text{ទ្រព្យសរុប}} \quad (7)$$

$$\text{ប្រាក់ចំណេញលើភាគហ៊ុននីមួយៗ} = \frac{\text{ចំណេញសុទ្ធ បន្ទាប់ពន្ធ}}{\text{ចំនួនភាគហ៊ុនធម្មតា}} \quad (8)$$

ការបកស្រាយអនុបាតប្រាក់ចំណេញ ៖ អនុបាតនីមួយៗពិនិត្យទៅលើផ្នែកផ្សេងៗរបស់ប្រាក់ចំណេញធនាគារ

ROA គឺជាសញ្ញានៃប្រសិទ្ធភាពរបស់អ្នកគ្រប់គ្រង ដែលប្រាប់ពីសមត្ថភាពនៃការគ្រប់គ្រងដែលបម្លែងពីទ្រព្យទៅប្រាក់ចំណូល

ROE សម្រាប់វាស់វែងអត្រាចំណូលដែលហូរទៅម្ចាស់ភាគហ៊ុន

ចំពោះគម្លាតប្រតិបត្តិការសុទ្ធ គម្លាតការប្រាក់សុទ្ធ និងគម្លាតមិនមែនការប្រាក់គឺ សម្រាប់វាស់ប្រសិទ្ធភាព នឹងប្រាក់ចំណេញដែលបង្ហាញពីកម្រិតប្រសើរនៃអ្នកគ្រប់គ្រង និងបុគ្គលិកក្នុងការរកប្រាក់ចំណូលឱ្យបានច្រើនជាងការចំណាយ (រួមមានការចំណាយការប្រាក់លើប្រាក់បញ្ញើ និងកម្ចីពីទីផ្សារប្រាក់ ព្រមទាំងការចំណាយលើប្រាក់ខែ)

**គម្លាតការប្រាក់សុទ្ធ** ៖ វាស់វែងគម្លាតរវាងគម្លាតចំណូលពីការប្រាក់ និងចំណាយលើការប្រាក់។ គោលដៅនេះអាចសម្រេចបានដោយការគ្រប់គ្រងយ៉ាងដិតដល់លើទ្រព្យដែលអាចបង្កើតចំណូលបាន និងការស្វះស្វែងរកប្រភពមូលធនដែលថោក។

**គម្លាតមិនមែនការប្រាក់** ៖ វាស់វែងពីចំណូលដែលទទួលបានពីការយកថ្លៃសេវាកម្មលើប្រាក់បញ្ញើ និងសេវាកម្មផ្សេងៗទៀតរបស់ធនាគារដែលមានទំនាក់ទំនងទៅនឹងការចំណាយមិនមែនការប្រាក់ (រួមមាន បៀវត្ស ការជួសជុល ថៃទាំ និងការចំណាយលើឥណទានបាត់បង់)

### ៤.១.៤.រូបមន្តប្រាក់ចំណេញ

ដើម្បីវិភាគប្រតិបត្តិការរបស់ធនាគារមួយ គេតែងតែវិភាគទៅលើផ្នែកនីមួយៗនៃអនុបាតប្រាក់ចំណេញ ឧទាហរណ៍ ដូចជា ROE និង ROA ដែលជារង្វាស់ដ៏សំខាន់របស់ធនាគារដែលគេប្រើប្រាស់ក្នុងបេលបច្ចុប្បន្ន។ អនុបាតទាំងពីរនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ ហេតុដូច្នេះហើយ យើងប្រើប្រាស់អនុបាតទាំងពីរនេះឱ្យមានទំនាក់ទំនងគ្នាដោយផ្ទាល់។

$$ROE = ROA \times \frac{\text{មូលធនផ្ទាល់សរុប}}{\text{ទ្រព្យសរុប}} \quad (9)$$

ម្យ៉ាងទៀត

$$\frac{\text{ប្រាក់ចំណេញសុទ្ធក្រោយបង់ពន្ធ}}{\text{មូលធនផ្ទាល់សរុប}} = \frac{\text{ចំណូលសុទ្ធក្រោយបង់ពន្ធ}}{\text{ទ្រព្យសរុប}} \times \frac{\text{ទ្រព្យសរុប}}{\text{មូលធនផ្ទាល់សរុប}} \qquad (10)$$

ប៉ុន្តែ ប្រាក់ចំណេញសុទ្ធស្មើនឹងចំណូលសរុបដកនឹងចំណាយប្រតិបត្តិការ និងពន្ធ ដូច្នេះ

$$\text{ចំណូលសរុប} - \text{ចំណាយប្រតិបត្តិការសរុប} - ROE = \frac{\text{ពន្ធ}}{\text{ទ្រព្យសរុប}} \times \frac{\text{ទ្រព្យសរុប}}{\text{មូលធនផ្ទាល់សរុប}} \qquad (11)$$

ទំនាក់ទំនងនៅក្នុងសមីការ (10) និង (11) បានបង្ហាញថា ចំណូលលើភាគហ៊ុនមានទំនាក់ទំនងយ៉ាងជិតស្និតទៅនឹងប្រភពនៃទ្រព្យរបស់ធនាគារ ដែលរួមមានបំណុល និងមូលធនផ្ទាល់។ ទោះបីជាធនាគារមួយមាន ROA ទាបក៏ដោយក៏វាអាចមាន ROE ខ្ពស់បានដែរដោយប្រើប្រាស់បំណុលច្រើន ហើយប្រើប្រាស់មូលធនផ្ទាល់តិច។

## ៤.១.៥.ការវិភាគលើចំណូលធៀបនឹងទុនផ្ទាល់

$$ROE = \frac{\text{ប្រាក់ចំណេញសុទ្ធក្រោយបង់ពន្ធ}}{\text{ចំណាយប្រតិបត្តិការសរុប}} \times \frac{\text{ចំណូលពីប្រតិបត្តិការសរុប}}{\text{ទ្រព្យសរុប}} \times \frac{\text{ទ្រព្យសរុប}}{\text{ទុនផ្ទាល់សរុប}} \qquad (12)$$

ឬក៏

$$ROE = \text{គម្លាតប្រាក់ចំណេញសុទ្ធ} \times \text{អនុបាតប្រើប្រាស់ទ្រព្យ} \times \text{មេគុណរបស់ទុនផ្ទាល់}$$

$$\text{គម្លាតប្រាក់ចំណេញសុទ្ធ} = \frac{\text{ប្រាក់ចំណេញសុទ្ធក្រោយបង់ពន្ធ}}{\text{ចំណូលពីប្រតិបត្តិការសរុប}} \qquad (13)$$

$$\text{អនុបាតប្រើប្រាស់ទ្រព្យ} = \frac{\text{ចំណូលពីប្រតិបត្តិការសរុប}}{\text{ទ្រព្យសរុប}} \qquad (14)$$

$$\text{មេគុណនៃទុនផ្ទាល់} = \frac{\text{ទ្រព្យសរុប}}{\text{ទុនផ្ទាល់សរុប}} \qquad (15)$$

(13) បង្ហាញពីប្រសិទ្ធភាពនៃការគ្រប់គ្រងការចំណាយ និងគោលនយោបាយថ្លៃទំនិញសេវាកម្ម

(14) បង្ហាញពីគោលនយោបាយគ្រប់គ្រងការវិនិយោគចម្រុះ (ជាពិសេសភាពចម្រុះ និងចំណូលលើទ្រព្យរបស់ធនាគារ)

(15) បង្ហាញពីគោលនយោបាយហិរញ្ញប្បទាន: ប្រភពមូលធនដែលជ្រើសរើសដោយធនាគារ (បំណុលឬក៏ទុនផ្ទាល់)

## ៤.១.៦.ការវិនិយោគលើចំណូលធៀបនឹងទ្រព្យ (ROA)

យើងចែកចំណូលនឹងទ្រព្យ (ROA) ជាចំណែកផ្សេងៗដូចខាងក្រោម :

$$\text{គម្លាតការប្រាក់សុទ្ធ} = \frac{(\text{ចំណូលពីការប្រាក់} - \text{ចំណាយការប្រាក់})}{\text{ទ្រព្យសរុប}}$$

បូក

$$\text{គម្លាតមិនមែនការប្រាក់សុទ្ធ} = \frac{(\text{ចំណូលមិនមែនការប្រាក់} - \text{ចំណាយមិនមែនការប្រាក់})}{\text{ទ្រព្យសរុប}}$$

ដក

$$\text{ប្រតិបត្តិការពិសេសដែលជះឥទ្ធពលលើចំណូល} = \frac{\text{ចំណូល និងចំណាយពិសេស } (PLL, Tax)}{\text{ទ្រព្យសរុប}}$$

ស្មើនឹង

$$\text{ផលធៀបនឹងទ្រព្យសកម្ម (ROA)} = \frac{\text{ប្រាក់ចំណេញសុទ្ធក្រោយបង់ពន្ធ}}{\text{ទ្រព្យសរុប}}$$

### ៤.១.៧.វិធានប្រាក់ចំណេញ និងការបកស្រាយ

ការវិភាគដោយផ្នែកៗរបស់ប្រាក់ចំណេញ បានប្រាប់យើងអំពីមូលហេតុនៃការលំបាកក្នុងការរកចំណូលរបស់ធនាគារ និងប្រាប់អ្នកគ្រប់គ្រងពីចំណុចដែលពួកគេត្រូវដោះស្រាយបញ្ហានៃការរកចំណូលផ្សេងៗ។ ការសម្រេចបាននូវប្រាក់ចំណេញខ្ពស់ ផ្អែកទៅលើកត្តាមួយចំនួនដូចខាងក្រោម :

1. ការប្រើប្រាស់យ៉ាងប្រុងប្រយ័ត្ននូវអត្រាបំណុល (Leverage) (ចំនួនបំណុលធៀបទៅនឹងទ្រព្យ និងទុនផ្ទាល់ខ្លួនធៀបនឹងទ្រព្យ)
2. ការប្រើប្រាស់យ៉ាងប្រុងប្រយ័ត្ននៃអត្រាអចលនទ្រព្យ (ចំនួននៃការចំណាយថេរដែលធនាគារប្រើប្រាស់ដើម្បីបង្កើតចំណូលមុនបង់ពន្ធ នៅពេលដែលមានកំណើនប្រតិបត្តិការ)
3. ការគ្រប់គ្រងយ៉ាងប្រុងប្រយ័តន្នពីការចំណាយ ដែលនាំទៅដល់ចំណូលប្រតិបត្តិការ ក្លាយជាប្រាក់ចំណេញសុទ្ធ
4. ការគ្រប់គ្រងយ៉ាងប្រុងប្រយ័តន្នពីទ្រព្យចម្រុះ ដើម្បីឆ្លើយតបនឹងតម្រូវការងាយស្រួល នៅពេលដែលធនាគារស្វែងរកប្រាក់ចំណូលខ្ពស់បំផុតពីទ្រព្យ។
5. ត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ពីហានិភ័យរបស់ធនាគារ ដូច្នេះគេអាចជៀសវាងពីការខាតបង់ដែលគ្របលើចំណូល និងទុបផ្ទាល់របស់ធនាគារ។

## ៤.២.ការជះឥទ្ធិពលនៃទំហំរបស់ធនាគារទៅលើប្រតិបត្តិការ

នៅបេលដែលការប្រព្រឹត្តរបស់ធនាគារមួយ ត្រូវបានគេប្រៀបធៀបនឹងធនាគារមួយទៀត ទំហំរបស់ធនាគារ (ចំនួនទ្រព្យ) គឺជាកត្តាដ៏សំខាន់។ អនុបាតស្ទើតែតាំងអស់ដែលបានបង្ហាញក្នុងមេរៀននេះ គឺមានលក្ខណៈប្រែប្រួលយ៉ាងខ្លាំងទៅតាមក្រុមដែលចាត់ថ្នាក់តាមទំហំ។ ដូចបានបង្ហាញនៅក្នុងតារាង 4-1 ចំណូលសំខាន់ៗ និងរង្វាស់ហានិភ័យបានផ្លាស់ប្តូរយ៉ាងខ្លាំង បើសិនជាយើងប្តូរពីធនាគារ

ដែលតូចបំផុតទៅធនាគារដែលធំបំផុត។ ឧទាហរណ៍ ធនាគារដែលមានប្រាក់ចំណេញច្រើនបំផុតគិតតាម ROA ស្ថិតនៅក្រុមធនាគារដែលមានទំហំមធ្យម។ ចំណែកឯ ក្រុមធនាការដែលធំបំផុតត្រូវបានគេរាយការណ៍ថា មាន ROA ទាបបំផុត។ ប៉ុន្តែ ROE ខ្ពស់បំផុតចំពោះក្រុមធនាគារដែលមានទំហំធំជាងមួយកោដិដុល្លា។

ម្យ៉ាងទៀត ធនាគារដែលមានទំហំកណ្ដាលមានទ្រព្យសកម្មពី $100 លាន ដល់ $10 កោដិ បានបង្ហាញពីការប្រាក់ និងចំណូលប្រតិបត្តិការប្រសើរជាងគេ ព្រមទាំងមានគម្លាតចំណូល និងអនុបាតប្រសិទ្ធភាពប្រតិបត្តិការប្រសើរជាងគេ (ដែលមានអនុបាតចំណាយប្រតិបត្តិការលើចំណូលទាបបំផុត)។ ផ្ទុយមកវិញ ធនាគារដែលធំបំផុតតែងតែមានគម្លាតមិនមែនការប្រាក់ខ្ពស់ជាងគេ ពីព្រោះធនាគារទាំងនោះ តែងតែមានកម្រៃពិសេវាកម្មជាច្រើន។ ធនាគារ ធុនតូច និងមធ្យម តែងតែមានគម្លាតការប្រាក់សុទ្ធធំ ដែលបណ្ដាលមកពីគម្លាតរវាងការប្រាក់ និងចំណាយការប្រាក់ធំ (ប្រាក់បញ្ញើតូចដែលមានការប្រាក់ទាប)។

អនុបាតនៃតារាងតុល្យការ បានបង្ហាញពីហានិភ័យដែលធនាគារប្រឈមមុខ ចំពោះធនាគារតូចតែងតែមានអនុបាតរវាងទុនផ្ទាល់ និងទ្រព្យខ្ពស់ ប៉ុន្តែចំណែកឯធនាគារធំៗវិញ (ច្រើនជាងមួយកោដិដុល្លា) មានអនុបាតនោះទាបជាង។ អ្នកវិភាគខ្លះបានគិតថា ធនាគារធំៗអាចមានអត្រារវាងទុនផ្ទាល់ និងទ្រព្យទាប ពីព្រោះធនាគារនោះអាចពង្រីកវិនិយោគរបស់ខ្លួននៅក្នុងទីផ្សារផ្សេងៗ ហើយមានឧបករណ៍សម្រាប់ការពារហានិភ័យច្រើន ចំណែកេធនាគារតូចៗមានសាច់ប្រាក់ងាយស្រួលច្រើនជាង ពីព្រោះឥណទាន គឺជាទ្រព្យដែលពិបាកប្ដូរជាសាច់ប្រាក់។ ប៉ុន្តែ ធនាគារធំៗមានទ្រព្យជាសាច់ប្រាក់ធំ បើធៀបទៅនឹងទ្រព្យទាំងអស់ បីព្រោះធនាគារទាំងនោះទទួលបញ្ញើរបស់ធនាគារតូចៗផ្សេងទៀត។ ធនាគារធំៗហាក់ដូចជាមានហានិភ័យឥណទានខ្ពស់ ដូចដែលបានបង្ហាញតាមរយៈអត្រាឥណទានបាត់បង់ខ្ពស់។

# មេរៀនទី៥
# ការគ្រប់គ្រងទ្រព្យ និងបំណុល៖ កំណត់ការវាស់វែងអត្រាការប្រាក់ ព្រមទាំងត្រួតពិនិត្យគម្លាតការប្រាក់របស់ធនាគារ

## ៥.១.យុទ្ធសាស្ត្រនៃការគ្រប់គ្រងទ្រព្យ និងបំណុល

### ៥.១.១. យុទ្ធសាស្ត្រនៃការគ្រប់គ្រងទ្រព្យ

ធនាគារពុំមានទស្សនៈគ្រប់ជ្រុងជ្រោយទាំងងស់លើទ្រព្យ និងបំណុរបស់វាទេ។ នៅក្នុងប្រវត្តិសាស្ត្រធនាគារបានទទួលយកប្រភពមូលធនរបស់ខ្លួន (បំណុល និងមូលធនផ្ទាល់) ជាប្រាក់ដែលគេផ្តល់ឱ្យ។ ការព្រប់គ្រងទ្រព្យ ដែលជាចំនួន និងប្រភេទនៃប្រាក់បញ្ញើរបស់ធនាគារនិងចំនួនប្រាក់ដែលខ្ចី ត្រូវបានកំណត់ដោយអតិថិជនរបស់ខ្លួន។ តាមទស្សនៈនេះសាធារណៈជនជាអ្នកកំណត់ប្រាក់បញ្ញើប្រាក់សញ្ច័យ និងប្រភពផ្សេងៗទៀត។ ចំណុចសម្រេចចិត្តគន្លិះនៃការគ្រប់គ្រងធនាគារ គឺមិនមែប្រាក់បញ្ញើឬក៏មូលធនដែលបានខ្ចីទេ តែគឺទ្រព្យ។ ធនាគាររឹកអាចធ្វើលំហាត់លើការត្រួតពិនិត្យ តែទៅលើការចែកចាយមូលធនដោយសម្រេចថា តើនរណាអាចទទួលបាន ឥណទានដ៏ធំនេះហើយមានរយៈពេលប៉ុន្មាន។ វាអាចមានហេតុផលទាក់ទងទៅនឹងរបៀបគ្រប់គ្រងទ្រព្យពីព្រោះមុនពេលនិយ័តកម្មត្រូវលុបបំបាត់ចោលប្រភេទនៃប្រាក់បញ្ញើ អត្រាដែលផ្តល់ឱ្យលើប្រាក់បញ្ញើនិងប្រភពមូលធនផ្សេងៗទៀតដែលមិនមែនជាប្រាក់បញ្ញើត្រូវបានគេធ្វើនិយ័តកម្មយ៉ាងតឹងរឹង។ អ្នកគ្រប់គ្រងធនាគារនៅមានកម្រិតក្នុងការកំណត់ឡើងវិញនូវប្រភពមូលធនរបស់ខ្លួន។

### ៥.១.២.យុទ្ធសាស្ត្រគ្រប់គ្រងបំណុល

ក្នុងទស្សវត្សឆ្នាំ 60 និង70 ដែលជាទស្សវត្សនាំឱ្យមានការផ្លាស់ប្តូរយ៉ាងសំខាន់នៅក្នុងការគ្រប់គ្រងទ្រព្យ និងបំណុល។ ប្រឈមមុខនឹងការកើនឡើងនៃអត្រាការប្រាក់និងការប្រកួតប្រជែងដ៏ម្បីទាក់ទាញមូលធនធនាគារចាប់ផ្តើមយកចិត្តទុកដាក់ទៅលើការទទួលយកប្រភពមូលធនថ្មី និងត្រួតពិនិត្យលើភាពចម្រុះ និងការចំណាយទៅលើប្រាក់បញ្ញើ និងបំណុលមិនមែនប្រាក់បញ្ញើ។ យុទ្ធសាស្ត្រថ្មីនេះហៅថា ការគ្រប់គ្រងបំណុល។ គោលដៅរបស់វាគឺ ដើម្បីគ្រប់គ្រងលើប្រភពមូលធនដែលអាចប្រៀបធៀបទៅនឹងធនាគាររិកធ្វើចំពោះទ្រព្យរបស់ខ្លួន។ ឧបករណ៍ត្រួតពិនិត្យជាគន្លិះគឺ ថ្លៃ។ ថ្លៃគឺជាអត្រាការប្រាក់ និងលក្ខ័ណ្ឌដែលធនាគារផ្តល់ឱ្យចំពោះប្រាក់បញ្ញើ និងការខ្ចីរបស់វាដើម្បីសម្រេចបាននូវចំនួន ភាពចម្រុះ និងការចំណាយដែលខ្លួនចង់បាន។ ធនាគារមួយដែលប្រធមមុខនឹង តម្រូវការលើសលប់ផ្នែកឥណទាននាំទៅដល់ការបង្កើនអត្រាការប្រាក់លើប្រាក់បញ្ញើ និងប្រាក់ដែលគេខ្ចីពីទីផ្សារប្រាក់ហើយមូលធននឹងហូរចូលទៅធនាគារនោះ។ ម៉្យាងទៀត បើធនាគារមួយមានមូលធនលើសលប់ប៉ុន្តែមានចំណែកតិចតួចនៃមូលធននោះអាចបង្កើតប្រាក់ចំណេញ ធនាគារនេះនឹងមិនផ្លស់ប្តូរអត្រាការប្រាក់របស់ខ្លួនឡើយ ហើយអនុញ្ញាតឱ្យគូប្រជែងរបស់ខ្លួនទទួលយកមូលធនដែលមាននៅលើទីផ្សារ។

### ៥.១.៣.យុទ្ធសាស្ត្រគ្រប់គ្រងមូលធន

ការរីកលូតលាស់នៃការគ្រប់គ្រងបំណុល ព្រមជាមួយនិងភាពមិននឹងនរបស់អត្រាការប្រាក់ និងហានិភ័យរបស់ធនាគារដែលធំជាងមុន បានផ្តល់កំណើនដល់ការគ្រប់គ្រងមូលធនដែលត្រូវបានគេប្រើប្រាស់យ៉ាងខ្លាំងនៅក្នុងវិស័យធនាគារបច្ចុប្បន្ន។ នេះជារបៀបដែលមានតុល្យភាពក្នុងការគ្រប់គ្រងទ្រព្យ និងបំណុលដែលបានសង្កត់ធ្ងន់ទៅលើគោលដៅមួយចំនួន :

1- ការគ្រប់គ្រងធនាគារគួរតែអនុវត្តការត្រួតពិនិត្យត្រឹមត្រូវទៅលើ បរិមាណភាពចម្រុះ និងចំណូលឬក៏ចំណាយនៃទ្រព្យ និងបំណុល ដើម្បីសម្រេចឱ្យបាននូវគោលដៅរយៈពេលខ្លីនឹងវែងរបស់ធនាគារ។

2- ការត្រួតពិនិត្យផ្នែកគ្រប់គ្រងទៅលើទ្រព្យ ត្រូវតែសម្របសម្រួលលើការត្រួតពិនិត្យលើបំណុលដែលនាំឱ្យមានចេរភាពនៅក្នុងការគ្រប់គ្រងទ្រព្យ និងបំណុលហើយគ្មានទំនាស់គ្នាទៅវិញទៅមក។ ការសម្របសម្រួលនៅក្នុងការគ្រប់គ្រងទ្រព្យនិងបំណុល នឹងជួយបង្កើតគម្លាតរវាងចំណូល (ពីទ្រព្យ) និងការចំណាយក្នុងការឱ្យមានបំណុលព្រមទាំងការត្រួតពិនិត្យហានិភ័យ។

3- ចំណូលនិងចំណាយកើតមកពី ខ្ទង់ទាំងសងខាងរបស់តារាងតុល្យការរបស់ធនាគារគួរតែត្រូវបានេបង្កើតដើម្បីបង្កើនចំណូលជាៈតិបរមា នឹងបន្ថយចំណាយជាអតិបរមា ពីសេវាកម្មរបស់ធនាគារដែលជាលទ្ធផលគឺទ្រព្យ (ការផ្តល់ឥណទាន) ឬក៏បំណុល (លក់ប្រាក់បញ្ញើ)។

ទស្សនៈបុរាណយល់ថាចំណូលរបស់ធនាគារទាំងអស់ ត្រូវតែបានមកពីឥណទាននិងការវិនិយោគដែលនាំទៅដល់ការយល់ដឹងមួយ ដែលធនាគារលក់សេវាកម្មហិរញ្ញវត្ថុជាចង្កោមដូចជា ឥណទាន ការទូទាត់ ប្រាក់សញ្ញ័យ និងការផ្តល់ដំបូន្មានហិរញ្ញវត្ថុជាដើមហើយសេវាកម្មទាំងនេះគួរតែដាក់ថ្លៃ ដើម្បីអាចសងទៅលើចំណាយនៃការបង្កើតសេវាកម្មនេះ។ ចំណូលពីកម្រៃសេវានៃការគ្រប់គ្រងបំណុលនៃតារាងតុល្យការអាចឱ្យធនាគារសម្រេចគោលដៅផ្នែកប្រាក់ចំណេញរបស់ខ្លួន ដូចនឹងចំណូលដែលទទួលបានពីការគ្រប់គ្រងឥណទាននិងទ្រព្យផ្សេងៗទៀតដែរ។

## ៥.២.ហានិភ័យអត្រាការប្រាក់ : គឺការប្រឹងប្រែងរបស់ធនាគារក្នុងការគ្រប់គ្រងទ្រព្យនិងបំណុល

ដោយមិនទាក់ទងទៅនិងយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងទ្រព្យ និងបំណុល ឬការគ្រប់គ្រងមូលធន ដែលធនាគារបានជ្រើសរើសយក គ្មានធនាគារីកណាមួយអាចគេចផុតពីហានិភ័យទេ។ ហានិភ័យមួយដែលលំបាកបំផុតនិងគ្រោះថ្នាក់បំផុតគឺហានិភ័យអត្រាការប្រាក់ (Interest Rate Risk)។ នៅពេលដែលអត្រាការប្រាក់ផ្លាស់ប្តូរក្នុងទីផ្សារហិរញ្ញវត្ថុ ពួកធនាគារីកដឹងថា ការផ្លាស់ប្តូរនោះមានឥទ្ធិពលទៅលើប្រភពដ៏សំខាន់នៃចំណូលរបស់ធនាគារ គឺចំណូលការប្រាក់ពីឥណទាន និងមូលប័ត្រ

ហើយនឹងប្រភពចំណាយសំខាន់របស់ខ្លួនគឺចំណាយការប្រាក់លើប្រាក់បញ្ញើនឹងកម្ចីពីធនាគារផ្សេងៗ។ ជាងនេះទៅទៀតគឺការផ្លាស់ប្តូរអត្រាការប្រាក់ នឹងនាំទៅដល់ការប្លាស់ប្តូរតម្លៃទ្រព្យនៃធនាគារ និងបំណុលរបស់ធនាគារ ហេតុនេះវានឹងផ្លាស់ប្តូរមូលធនផ្ទាល់របស់ធនាគារ (ដែលជាតម្លៃវិនិយោគរបស់ម្ចាស់ធនាគារ)។ ហេតុនេះហើយការផ្លាស់ប្តូរអត្រាការប្រាក់ជះឥទ្ធិពលដល់តារាងតុល្យការផង និងរបាយការណ៍ចំណូលចំណាយផង។

## ៥.២.១. កម្លាំងដែលកំណត់ពីអត្រាការប្រាក់

ទោះបីជាអត្រាការប្រាក់មានសារៈសំខាន់យ៉ាងណាក៏ដោយក៏ធនាគារមិនអាចគ្រប់គ្រងនូវកម្រិតឬនិន្នាកររបស់អត្រាការប្រាក់នៅលើទីផ្សារបានទេ។ អត្រាការប្រាក់របស់ឥណទាន ឬក៏មូលប័ត្រត្រូវបានកំណត់ដោយទីផ្សារហិរញ្ញវត្ថុ ជាកន្លែងដែលអ្នកមានមូលធន (អាចឱ្យខ្ចីបាន) មានអន្តរកម្មជាមួយអ្នកត្រូវការមូលធន ហើយអត្រាការប្រាក់ (ថ្លៃឥណទាន) ត្រូវបានដោះស្រាយនៅចំណុចមួយដែលបរិមាណមូលធនត្រូវការ និងផ្គត់ផ្គង់ស្មើគ្នា ដូចដែលបានបង្ហាញនៅក្នុងរូបទី 5-1។

នៅក្នុងការផ្តល់ឥណទានធនាគារនៅខាងផ្គត់ផ្គង់មូលធន ប៉ុន្តែធនាគារនីមួយៗជាអ្នកផ្គត់ផ្គង់ឥណទានមួយនៅក្នុងទីផ្សារអន្តរជាតិដែលមានអ្នកឱ្យខ្ចីប្រាក់ច្រើនពាន់នាក់។ ដូចគ្នានេះដែរធនាគាររីកនៅក្នុងទីផ្សារហិរញ្ញវត្ថុក្នុងនាមជាអ្នកត្រូវការមូលធន នៅពេលដែលគេផ្តល់សេវាកម្មប្រាក់បញ្ញើដល់សាធារណៈជន ឬក៏ចេញប័ណ្ណមិនមែនប្រាក់បញ្ញើ IOUs ដើម្បីគៀងគរមូលធនសម្រាប់ឱ្យខ្ចី និងវិនិយោគ។ ប៉ុន្តែជាថ្មីម្តងទៀតធនាគារនូវតែជាអ្នកត្រូវការមូលធននៅក្នុងទីផ្សារដែលមានអ្នកខ្ចីរាប់ពាន់ ទោះបីជាវាមានទំហំប៉ុណ្ណាក៏ដោយ។

ទោះបីជាធនាគាររីកជាអ្នកផ្តល់ ឬក៏ជាអ្នកត្រូវការមូលធនក៏ដោយក៏គេមិនអាចកំណត់បាននូវកម្រិត ឬក៏ដឹងអំពីនិន្នាការនៃអត្រាទីផ្សារ។ ធនាគារនីមួយៗធ្វើសកម្មភាពដើម្បីឱ្យសម្រេចបាននូវគោលដៅរបស់ខ្លួនទៅតាមកំរិត និងនិន្នាការនៃអត្រាការប្រាក់។ និយាយបានម្យ៉ាងទៀតថា ធនាគារគឺជាអ្នកទទួលយកថ្លៃ (Price Taker) មិនមែនជាអ្នកកំណត់ថ្លៃ (Price Maker) ទេ ហើយត្រូវតែទទួលយកនូវកម្រិត និងនិន្នាករនៃអត្រាការប្រាក់ដូចដែលបានផ្តល់ឱ្យ និងគ្រោងទុក។

ដោយអត្រាការប្រាក់ផ្លាស់ប្តូរធនាគារជួបប្រទះនូវហានិភ័យ អត្រាការប្រាក់២ ជាចម្បងគឺហានិភ័យថ្លៃ និងហានិភ័យវិនិយោគជាថ្មី (Price Risk and Reinvestment Risk) ហានិភ័យថ្លៃកើតឡើង នៅពេលដែលអត្រាការប្រាក់តីផ្សារកើនឡើង ដែលបង្កឱ្យតម្លៃនៃសញ្ញាប័ណ្ណ និងឥណទានដែលមានការប្រាក់ថេរស្ទើរតែទាំងអស់ធ្លាក់ចុះ។ បើសិនជាធនាគារចង់លក់ឧបករណ៍ហិរញ្ញវត្ថុទាំងនេះនៅក្នុងរយៈពេលដែលមានអត្រាកើនឡើង ធនាគារត្រូវតែរៀបចំទទួលយកការបាត់បង់មូលធន។ ហានិភ័យវិនិយោគជាថ្មីងើបឡើងនៅពេលដែលអត្រាការប្រាក់ទីផ្សារធ្លាក់ចុះ ដែលបង្ខំធនាគារឱ្យវិនិយោគមូលធនដែលទទួលបានទៅលើសញ្ញាប័ណ្ណឥណទាន ឬទ្រព្យផ្សេងៗទៀតដែលមានចំណូលទាប (អត្រាទាប) ដែលបន្ថយចំណូលទៅអនាគតដែលគេរំពឹងទុក។ ផ្នែកដ៏ធំនៃការគ្រប់គ្រងទ្រព្យ និងបំណុលរបស់

ធនាគារ គឺរួមមានការរកមធ្យោបាយដោះស្រាយដែលមានប្រសិទ្ធភាពជាមួយនិងហានិភ័យទាំងពីដែលក្លាយមកពីការផ្លាស់ប្តូរអត្រាការប្រាក់។

## ៥.២.២.ការវាស់វែងអត្រាការប្រាក់

នៅពេលដែលយើងប្រើពាក្យអត្រាការប្រាក់ តើវាមានន័យជាក់លាក់យ៉ាងណា? ហើយអត្រាការប្រាក់ត្រូវបានគេវាស់យ៉ាងដូចម្តេច?

យើងយល់ថា អ្វីទៅជាអត្រាការប្រាក់ ព្រោះយើងធ្លាប់បានខ្ចីប្រាក់ម្តង ឬច្រើនដងរួចមកហើយ ហើយយើងក៏ដឹងថាអត្រាការប្រាក់គឺជាថ្លៃរបស់ឥណទានដែលត្រូវបានកំណត់ដោយអ្នកឱ្យខ្ចីសម្រាប់ជាថ្នូរនៃការប្រើប្រាស់ប្រាក់កម្ចី។ ងាយជាងនេះទៅទៀត អត្រាការប្រាក់ជាអនុបាតនៃកម្រៃដែលយើងត្រូវតែសង ដើម្បីទទួលយកការប្រើប្រាស់ឥណទានចែកនឹងចំនួនឥណទានដែលទទួល។

មធ្យោបាយវាស់វែងអត្រាការប្រាក់ដែលមានប្រជាប្រិយភាពជាងគេគឺ ទិន្នផលនៅការកំណត់ (Yield to Maturity) គឺអត្រាអប្បហាដែលស្មើនឹងតម្លៃទីផ្សាររបស់ ឥណទានឬមូលប័ត្រជាមួយនឹងចំណូលពីការសងដែលរំពឹងទុកក្នុងពេលអនាគត ដែលនឹងបង្កើតដោយ ឥណទាន ឬមូលប័ត្រនោះ។

ឧទាហរណ៍ :

សញ្ញាប័ណ្ណមួយសន្លឹកត្រូវបានគេទិញថ្លៃ $950 ហើយត្រូវបានគេសន្យាសងការប្រាក់ $100 ក្នុងរយៈពេល 3 ឆ្នាំខាងមុខនៅពេលដែលវាត្រូវបានប្តូរដោយអ្នកចេញសញ្ញាប័ណ្ណនេះគឺ $1000 អត្រាការប្រាក់នៃសញ្ញាប័ណ្ណនេះត្រូវបានគេវាស់ដោយចំណូលនៅកាលវសានត្ត ដូចខាងក្រោម:

$$950 = \frac{100}{(1+YIM)^{1}} + \frac{100}{(1+YIM)^{2}} + \frac{100}{(1+YIM)^{3}} + \frac{100}{(1+YIM)^{3}}$$

តាមការគណនាយើងនឹងបានចំណូលនៅកាលអវសានត្តគឺ 12.10%

ការវាស់វែងដែលគេនិយមមួយទៀតគឺ អត្រាអប្បហាធនាគារដែលគេតែងតែដកស្រង់ពី ឥណទានរយៈពេលខ្លី និងរូបមន្តសម្រាប់គណនា អត្រាអប្បហាគឺ :

$$DR = \frac{(100 - \text{ថ្លៃទិញ ឥណទានឬមូលប័ត្រ})}{100} \times \frac{360}{\text{ចំនួនថ្ងៃផុតកំណត់}} \qquad (2)$$

<u>ឧទាហរណ៍</u> : គេទិញមូលប័ត្រ ឬឥណទានថ្លៃ $96 ដែលមានតម្លៃបោះពុម្ព $100 ត្រូវសងនៅថ្ងៃកំណត់បើសិនជាឥណទាន ឬមូលប័ត្រនេះផុតកំណត់ ក្នុងរយៈពេល 90 ថ្ងៃ។ ដូច្នេះអត្រាការប្រាក់ត្រូវបានវាស់ដោយ អត្រាអប្បហាធនាគារ (DR) ដូចខាងក្រោម :

$$DR = \frac{(100-96)}{100} \times \frac{360}{90} = 0.16 \text{ ឬ } 16\%$$

យើងកត់សម្គាល់ថាការវាស់វែងអត្រាការប្រាក់នេះបានគិតគូរដល់ ឥទ្ធពលនៃបង្គរការប្រាក់ ហើយគណនាផ្អែកលើ 360 ថ្ងៃ ចំណែកការវាស់វែង លើចំណូលនៅកាលអវសានត្ត (YTM) គឺគណនាផ្អែក

លើ 365 ថ្ងៃ ហើយសន្មតថា ចំណូលពីការប្រាក់ត្រូវបង្គរតាមចំណូលនៅកាលអវសាន្ត ដែលប្រហាក់ប្រហែល យើងប្រើប្រាស់រូបមន្តដូចខាងក្រោម :

ចំណូលប្រហាក់ប្រហែលសម្រាប់ឧទាហរណ៍ខាងលើ

$$YTM = \frac{(100 - \text{ថ្លៃទិញ})}{\text{ថ្លៃទិញ}} \times \frac{365}{\text{ចំនួនថ្ងៃអវសាន្ត}} \qquad (3)$$

YTM ប្រហាក់ប្រហែល $= \frac{(100-96)}{96} \times \frac{365}{90} = 0{,}1690$ ឬ16,90%

ការគណនាអត្រាការប្រាក់ពីខាងលើត្រូវបានគេនិយមប្រើប្រាស់តែយើងត្រូវចងចាំថាមានមធ្យោបាយផ្សេងៗទៀតដើម្បីវាស់វែងនូវអត្រាការប្រាក់ផ្សេងទៀត។

## ៥.២.៣.សមាសធាតុនៃអត្រាការប្រាក់

ជាច្រើនឆ្នាំមកហើយ ធនាគារជាច្រើនបានព្យាយាមទោះទាយការផ្លាស់ប្តូរអត្រាការប្រាក់នៅពេលអនាគត ដើម្បីកាត់បន្ថយហានិភ័យអត្រាការប្រាក់ខ្ពស់។ ប៉ុន្តែអត្រាការប្រាក់ត្រូវបានកំណត់ដោយអន្តរកម្មពីអ្នកផ្តល់ឥណទាន និងអ្នកត្រូវការឥណទានរាប់ពាន់អ្នក ដែលបណ្តាលឱ្យភាពជាក់លាក់នៃការព្យាករណ៍មិនអាចធ្វើទៅបាន។ បន្ថែមទៅលើបញ្ហានៃការព្យាករណ៍អត្រាការប្រាក់របស់ឥណទានឬក៏មូលប័ត្រ រួមមាន ជាតុផ្សំជាច្រើន។

អត្រាការប្រាក់ទីផ្សារ ចំពោះឥណទាន និងមូលប័ត្រដែលមានហានិភ័យ អត្រាការប្រាក់ពិតប្រាកដ (ដែលជាចំណូលបន្ទាប់ពី ដកអតិផរណាចំពោះសញ្ញាប័ណ្ណរដ្ឋាភិបាល) + ហានិភ័យបន្ថែមដើម្បីសងទៅអ្នកឱ្យខ្ចីដែល ទទួលយកភាពប្រថុយប្រថានសម្រាប់ការបាត់បង់ហានិភ័យអតិផរណា ហានិភ័យនៃការលក់ និងហានិភ័យផ្សេងៗទៀត (4)

មិនគ្រាន់តែអត្រាការប្រាក់ពិតទេ ដែលប្រែប្រួលទៅតាមការផ្លាស់ប្តូរតម្រូវការ និងផ្គត់ផ្គង់នៃមូលធន ប៉ុន្តែការគិតរបស់អ្នកខ្ចី និងអ្នកឱ្យខ្ចីក៏ប្រែប្រួលដែរទាក់ទងទៅនឹងហានិភ័យបន្ថែម (Risk Premium) ដែលជាផ្នែកមួយនៃអត្រាការប្រាក់ទីផ្សារចំពោះហានិភ័យឥណទាន ហើយផ្នែកនេះក៏បណ្តាលឱ្យមានការឡើងចុះនៃអត្រាការប្រាក់ដែរ។

ផ្នែកសំខាន់មួយទៀតនៃអត្រាការប្រាក់គឺតម្លៃបន្ថែមលើអវសាន្ត (Maturity) ឬក៏ពេលវេលា។ ឥណទានរយៈពេលយូរ និងមូលប័ត្ររយៈពេលយូរ តែងតែមានអត្រាការប្រាក់ខ្ពស់ជាងឥណទានមូលប័ត្ររយៈពេលខ្លី ពីព្រោះហានិភ័យនៃកាលអវសាន្ត។ នៅពេលដែលរយៈពេលកាន់តែវែងឱកាសនៃការបាត់បង់ឥណទានមានកាន់តែច្រើន។ រូបភាពដែលបង្ហាញលើក្រាហ្វិក ពីការប្រែប្រួលនៃអត្រាការប្រាក់ដែលមានកាល អវសាន្តផ្សេងរបស់ឥណទាន ហើយត្រូវបានត្រួតពិនិត្យនៅលើចំណុចពេលតែមួយ (ដោយសន្មតថា គ្រប់កត្តាទាំងអស់មិនប្រែប្រួល ដូចជាហានិភ័យឥណទាន) ត្រូវបានគេហៅថា ខ្សែកោងទិន្នផល (Yield Curve)។

### ៥.២.៤.ការឆ្លើយតបរបស់ធនាគាររីកចំពោះ ហានិភ័យអត្រាការប្រាក់

ដូចដែលយើងបានកត់សម្គាល់ តាំងពីដំបូងម្ល៉ះ ការផ្លាស់ប្តូរ អត្រាការប្រាក់ទីផ្សារជាចធ្វើឱ្យប៉ះពាល់ដល់ភាពចំណេញរបស់ធនាគារបង្កើតការចំណាយលើមូលធននិងបន្ថយប្រាក់ចំណូលពីទ្រព្យដែលផ្តល់ចំណូល ព្រមទាំងបន្ថយនូវតម្លៃវិនិយោគរបស់ម្ចាស់ភាគហ៊ុន។ ជាងនេះទៅទៀត នៅក្នុងទស្សវត្សថ្មីៗនេះបាននាំតៅដល់ពេលមួយនៃអត្រាការប្រាក់មានភាពមិននឹងនរ ធនាគាររីកត្រូវបានបង្ខំឱ្យធ្វើការជាមួយបរិស្ថានមួយដែលថ្មីទាំងស្រុង និងមិនអាចទោះទាយបាន។ ឧទាហរណ៍មួយពីការបាត់បង់ដ៏សម្បើម ដែលបណ្តាលមកពីហានិភ័យអត្រាការប្រាក់។ ការនេះបានកើតឡើងនៅក្នុងរដ្ឋ Minnesota នៅពេលដែល First Bank បានព្យាករណ៍ពីការធ្លាក់ចុះនៃអត្រាការប្រាក់នៅចុងទស្សវត្ស 1980។ ជាអកុសល ថ្លៃរបស់សញ្ញាប័ណ្ណធ្លាក់ចុះនៅពេលដែលអត្រាការប្រាក់កើនឡើង ហើយ First Bank មានការខាតបង់ប្រហែល $500 ហើយត្រូវបង្ខំចិត្ត លក់អាគារកណ្តាល។

ពីរឆ្នាំ មកហើយធនាគាររីកមានការស្វែងរកមធ្យោបាយយ៉ាងខ្លាំក្លា ដើម្បីការបារចង្កោមទ្រព្យនិងបំណុល ព្រមទាំងប្រាក់ចំណេញរបស់គេពីការផ្លាស់ប្តូរអត្រាការប្រាក់ជាមធ្យម។ បច្ចុប្បន្ននេះ ធនាគារ ជាច្រើនកំពុងតែរៀបចំយុទ្ធសាស្ត្រគ្រប់គ្រង ទ្រព្យ និងបំណុលនៅក្រោមការណែនាំរបស់គណកម្មការទ្រព្យ និងបំណុល ហើយគណកម្មការនេះ បានធ្វើការប្រជុំប្រចាំថ្ងៃ។ គណកម្មការនេះមិនគ្រាន់តែជ្រើសរើសយុទ្ធសាស្ត្រសម្រាប់ដោះស្រាយបញ្ហាអត្រាការប្រាក់ប៉ុណ្ណោះទេ ប៉ុន្តែនៅបានចូលរួមក្នុងការធ្វើផែនការរយៈពេលវែង និងខ្លីផងដែរ ដើម្បីរៀបចំយុទ្ធសាស្ត្រ ទប់ទល់នឹងតម្រូវការសាច់ប្រាក់ងាយស្រួលរបស់ធនាគារ ហើយចូលរួមដោះស្រាយជាមួយនឹងបញ្ហាគ្រប់គ្រងផ្សេងៗទៀត។

## ៥.៣.គោលដៅមួយនៃការលប់បំបាត់គ្រោះថ្នាក់នៃអត្រាការប្រាក់

គោលដៅដ៏សំខាន់មួយក្នុងការដោះស្រាយហានិភ័យអត្រាការប្រាក់គឺដើម្បីការពារប្រាក់ចំណេញ (បន្ទាប់ពីការចំណាយលើពន្ធ និងចំណាយទាំងអស់ផ្សេងទៀត) ពីឥទ្ធិពលនៃការឡើងចុះអត្រាការប្រាក់។

ដើម្បីបំពេញឱ្យបាននូវគោលដៅនេះអ្នកគ្រប់គ្រងត្រូវតែប្រមូលការយកចិត្តទុកដាក់ទៅលើធាតុផ្សេងៗនៃចង្កោមទ្រព្យ និងបំណុលរបស់ធនាគារ ដែលប្រែប្រួលខ្លាំងតៅតាមការផ្លាស់ប្តូរអត្រាការប្រាក់។ ចង្កោមទ្រព្យ និងបំណុលនេះរួមមានឥណទានរបស់ធនាគារនិងការវិនិយោគលើផ្នែកទ្រព្យនៃតារាងតុល្យការ (ទ្រព្យដែលបង្កើតប្រាក់ចំណូល) និងប្រាក់បញ្ញើដែលមានការប្រាក់ ព្រមទាំងការខ្ចីពីទីផ្សារប្រាក់នៅខាងបំណុល។ ដើម្បីការពារប្រាក់ចំណេញរបស់ធនាគារទល់នឹងការផ្លាស់ប្តូរការប្រាក់ដូច្នេះហើយធនាគាររក្សាតុល្យភាពថេរនៃគម្លាតសុទ្ធការប្រាក់ (NIM)។

$$NIM = \frac{\text{ចំណូលការប្រាក់ពី} - \text{ចំណាយការប្រាក់លើឥណទាននិងវិនិយោគ ប្រាក់បញ្ញើ និងកម្ចីផ្សេងៗ}}{\text{ទ្រព្យដែលបង្កើតចំណូល}}$$

$$= \frac{\text{ចំណូលការប្រាក់សុទ្ធបន្ទាប់ពីចំណាយ}}{\text{ទ្រព្យសរុបដែលបង្កើតចំណូល}}$$

ឧទាហរណ៍ ធនាគារអន្តរជាតិដ៏ធំមួយ មានចំណូលការប្រាក់ 4 កោដិដុល្លាពីឥណទានរបស់ខ្លួន ហើយ 2,6 កោដិដុល្លាជាការចំណាយលើការប្រាក់ ដើម្បីទទួលយកប្រាក់បញ្ញើ និងកម្ចីផ្សេងៗទៀត។ ប្រសិនបើធនាគារនេះមាន 40 កោដិដុល្លា ជាទ្រព្យដែលបង្កើតចំណូល គម្លាតការប្រាក់សុទ្ធគឺ :

$$NIM = \frac{(4\ \text{កោដិ} - 2{,}6\ \text{កោដិ})}{40\ \text{កោដិ}} \times 100 = 3.5\%$$

ឧទាហរណ៍ យើងឃើញថាគម្លាតការប្រាក់សុទ្ធគឺស្មើនឹង 3.5%។ គួរចងចាំថានេះមិនមែនជាប្រាក់ចំណេញពីការខ្ចីនិងឱ្យមានខ្ចីទេព្រោះយើងពុំទាន់បានគិតពី ការចំណាយផ្សេងៗដែលមិនមែនជាការចំណាយការប្រាក់។ នៅពេលដែលការចំណាយទាំងនោះត្រូវបានគេដក ជាធម្មតាគម្លាតប្រាក់ចំណេញគឺតិចតួចបំផុត សម្រាប់ការពារទប់ទល់នឹងហានិភ័យការប្រាក់។ ប្រសិនបើអ្នកគ្រប់គ្រងធនាគារទទួលយកគម្លាតការប្រាក់សុទ្ធ 3.5% ធនាគារ នេះប្រហែលជាប្រើប្រាស់មធ្យោបាយផ្សេងៗដើម្បីការពារចំណូលសុទ្ធធនាគារមានស្ថិរភាព។

បើសិនការចំណាយលើការប្រាក់កើនឡើង លឿនជាងចំណូលឥណទាន និងវិនិយោគ NIM របស់ធនាគារ និងត្រូវបន្ថយ។ ដូចគ្នានេះដែរប្រសិនបើចំណូលពីឥណទានឬវិនិយោគធ្លាក់ចុះ លឿនជាងចំណាយទៅលើការប្រាក់កម្ចី NIM នឹងត្រូវបន្ថយ។ អ្នកគ្រប់គ្រងត្រូវតែស្វែងរកមធ្យោបាយផ្សេងៗ ដើម្បីកុំឱ្យការចំណាយលើប្រាក់កម្ចីកើនឡើងខ្លាំងពេលធៀបទៅនឹងចំណូលការប្រាក់ដែល គម្រាមកំហែងដល់ គម្លាតចំណេញរបស់ធនាគារ។

## ៥.៣.១.ការគ្រប់គ្រងរំញោចគម្លាតការប្រាក់ (Interest Sensitive Gap Management)

យុទ្ធសាស្ត្រការពារអត្រាការប្រាក់ ដែលមានប្រជាប្រិយជាងគេត្រូវបានធនាគារប្រើប្រាស់គឺ **ការគ្រប់គ្រង រំញោចគម្លាតការប្រាក់**។ វិធីគ្រប់គ្រងគម្លាតនេះតម្រូវឱ្យអ្នកគ្រប់គ្រង ធ្វើការវិនិយោគទៅលើកាលអវសាន្ត និងការអនុវត្តនៃថ្លៃដែលមានទំនាក់ទំនងជាមួយទ្រព្យ ដែលមានការប្រាក់បញ្ញើ ព្រមទាំងប្រាក់កម្ចីពីទីផ្សារប្រាក់។ ប្រសិនបើអ្នកគ្រប់គ្រងគិតថា ស្ថាប័នរបស់ខ្លួនស្ថិតនៅក្នុងហានិភ័យអត្រាការប្រាក់ ពួកគេព្យាយាមផ្គូរផ្គងរវាងបរិមាណនៃទ្រព្យសកម្មរបស់ធនាគារដែលអាចដាក់ថ្លៃជាថ្មីបាន ណៅពេលដែលអត្រាការប្រាក់ផ្លាស់ប្តូរជាមួយបរិមាណនៃប្រាក់បញ្ញើ និងបំណុលផ្សេងៗទៀតដែលអត្រាការប្រាក់ផ្លាស់ប្តូរតាមទិសដៅណាក៏ដោយ។

ចំនួនដុល្លានៃទ្រព្យដែលអាចដាក់ថ្លៃជាថ្មីរបស់ធនាគារ = ចំនួនដុល្លានៃបំណុលដែលអាចដាក់ថ្លៃចាថ្មីបានរបស់ធនាគារ (6)

នៅក្នុងករណីនេះ ចំណូលដែលបានមកពីទ្រព្យ នឹងផ្លាស់ប្តូរតាមទិសដៅដូចគ្នា ហើយមានចំនួនស្មើនឹងការចំណាយការប្រាក់នៃបំណុល។

តើអ្វីទៅដែលជាទ្រព្យដែលអាចដាក់ថ្លៃជាថ្មី? ហើយអ្វីទៅជាបំណុលដែលអាចដាក់ថ្លៃជាថ្មី? ឧទាហរណ៍ដែលគេធ្លាប់ស្គាល់នៃ ទ្រព្យដែលអាចដាក់ថ្លៃជាថ្មីគឺឥណទានដែលជិតដល់អវសាន្ត ឬក៏នឹងត្រូវបានគេផ្តល់ឱ្យលើកដំបូង ធនាគារនឹងផ្តល់ឥណទានជាថ្មីប្រសិនបើគេទទួលបាននូវទិន្នផលដែលគេរំពឹងទុក (ខ្ពស់ជាងផលដែលគេរំពឹងទុកក្នុងពេលបច្ចុប្បន្ន នៃឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតដូចគ្នានេះដែរ ឥណទានដែលដលើកាលអវសាន្តនឹងផ្តល់ឱ្យ)

ឧទាហរណ៍ខ្លះនៃទ្រព្យនិងបំណុលធនាគារដែលអាចដាក់ថ្លៃថ្មី ព្រមទាំង ទ្រព្យនឹងបំណុលដែលមិនអាចដាក់ថ្លៃថ្មី :

**ទ្រព្យដែលអាចដាក់ថ្លៃជាថ្មី**

- មូលប័ត្ររយៈពេលខ្លីដែលបោះពុម្ព ដោយរដ្ឋាភិបាលនិងអ្នកខ្ចីឯកជន
- ឥណទានរយៈពេលខ្លីដែលផ្តល់ឱ្យដោយធនាគារ ទៅឱ្យអតិថិជន (ដែលជិតដល់កាលកំណត់)
- ឥណទាននិងមូលប័ត្រដែលមានអត្រាប្រែប្រួល (អត្រាអណ្តែតឬ អត្រាដែលអាចកែតម្រូវបាន)

**បំណុលដែលអាចដាក់ថ្លៃជាថ្មី**

- កម្ចីបីទីផ្សារប្រាក់ (ដូចជាធនាគារកណ្តាល)
- គណនីបញ្ញើ រយៈពេលខ្លី
- ប្រាក់បញ្ញើទីផ្សារប្រាក់ (ដែលការប្រាក់របស់វាអាចកែតម្រូវក្នុងរយៈពេល ពីរឬបីថ្ងៃ)
- ប្រាក់បញ្ញើ ដែលមានអត្រាប្រែប្រួល (អត្រាអណ្តែត ឬអត្រាដែលអាចកែតម្រូវបាន)

**ទ្រព្យដែលមិនអាចដាក់ថ្លៃជាថ្មី :**

- សាច់ប្រាក់ដែលដាក់ក្នុងឃ្លាំងធនាគារ និងប្រាក់បញ្ញើ នៅឯធនាគារកណ្តាល (ប្រាក់បម្រុងផ្លូវច្បាប់)
- ឥណទានរយៈពេលវែង ដែលអត្រាការប្រាក់ថេរ ផ្តល់ទៅឱ្យ អតិថិជន
- មូលប័ត្ររយៈពេលវែងដែលមានអត្រាថេរ (Coupon)
- អាគាររបស់ធនាគារ និងឧបករណ៍ ព្រមទាំងទ្រព្យដែលមិនបង្កើតចំណូលផ្សេងៗ

**បំណុលដែលមិនអាចដាក់ថ្លៃជាថ្មី**

- គណនី ប្រាក់បញ្ញើតាមតម្រូវការ (ដែលគ្មានការប្រាក់ ឬក៏មានអត្រាការប្រាក់)
- គណនី សញ្ច័យ និងគណនីសោធនិវត្តន៍រយៈពេលវែង
- មូលធនផ្ទាល់ ដែលផ្តល់ដោយ ម្ចាស់ធនាគារ

ធនាគារនូវមូលធន សម្រាប់វិនិយោគថ្មីដែលមានអត្រាការប្រាក់បច្ចុប្បន្ន ដូច្នេះវាក៏ជាទ្រព្យដែលដាក់ថ្លៃជាថ្មីដែរ។ បំណុលដែលមានថ្លៃថ្មីមមាន $CD_5$ដែលជិតដល់ថ្ងៃកំណត់ ឬក៏អាចត្រូវបានគេបន្តជាថ្មីទៀត ដែលធនាគារនិងអតិថិជនត្រូវតែចរចារលើអត្រាការប្រាក់ ដើម្បីឱ្យសមស្របតាមទីផ្សារ

បច្ចុប្បន្ន ប្រាក់បញ្ញើដែលមានអត្រាការប្រាក់អណ្តែតដែលការប្រាក់ផ្លាស់ប្តូរដោយស្វ័យប្រវត្តិទៅតាមអត្រាទីផ្សារ និងកម្ចីទីផ្សារប្រាក់ដែលការប្រាក់ត្រូវបានគេកែតម្រូវជារៀងរាល់ថ្ងៃ ដើម្បីឆ្លើយតបទៅនឹងការអភិវឌ្ឍន៍ថ្មីបំផុតរបស់ទីផ្សារនៅពេលដែលអាចដាក់ថ្លៃជាថ្មី មិនស្មើនឹងចំនួនបំណុលដែលអាចកំណត់ថ្លៃជាថ្មីគឺមានគម្លាតមួយរវាងរំញោចការប្រាក់លើទ្រព្យ និងរំញោចការប្រាក់លើបំណុល។

គម្លាតរំញោចការប្រាក់ = រំញោចការប្រាក់លើទ្រព្យ – រំញោចការប្រាក់លើបំណុល (7)

ប្រសិនបើរំញោចការប្រាក់លើទ្រព្យនៅក្នុងរយៈពេលនីមួយៗ (ថ្ងៃ សប្តាហ៍ ខែ) លើសបរិមាណ រំញោចការប្រាក់លើបំណុលជាកម្មវត្ថុសម្រាប់ដាក់ថ្លៃជាថ្មី ធនាគារនេះត្រូវបានគេនិយាយថាវាមាន គម្លាតវិជ្ជមាន ហើយមានរំញោចលើទ្រព្យ។

គម្លាតវិជ្ជមានលើទ្រព្យ = ទ្រព្យដែលមានរំញោចការប្រាក់ – ដែលមានរំញោចការប្រាក់បំណុល > 0 (8)

<u>ឧទាហរណ៍</u> : ធនាគារមួយមានទ្រព្យដែលមានរំញោចការប្រាក់ $500 លានហើយបំណុលដែលមានរំញោចការប្រាក់ $400 លាន ដូច្នេះរំញោចទ្រព្យមានគម្លាត $100 លាន (វិជ្ជមាន)។ ប្រសិនបើអត្រាការប្រាក់កើនឡើងគម្លាតការប្រាក់ និងកើនឡើងពីព្រោះ ចំណូលការប្រាក់ដែលបង្កើតដោយទ្រព្យកើនឡើងច្រើនជាងការចំណាយ លើប្រាក់កម្ចី ដូច្នេះធនាគារមានការកើនឡើងចំណូលសាច់ប្រាក់សុទ្ធ។ ផ្ទុយមកវិញ បើអត្រាការប្រាក់ធ្លាក់ចុះនៅពេលដែលធនាគារមានរំញោចទ្រព្យ គម្លាតសុទ្ធការប្រាក់ និងធ្លាក់ចុះពីព្រោះ ចំណូលការប្រាក់ពីទ្រព្យត្រូវធ្លាក់ចុះច្រើនជាងការចំណាយលើបំណុល។ ធនាគារដែលមានរំញោចគម្លាតនឹងបាត់បង់ចំណូលការប្រាក់សុទ្ធសងក្នុង ករណីអត្រាការប្រាក់ធ្លាក់ចុះ។

នៅក្នុងស្ថានភាពផ្ទុយពីនេះ ឧបមាថា រំញោចការប្រាក់របស់បំណុលធំជាង រំញោចការប្រាក់របស់ទ្រព្យ ដូច្នេះធនាគារមាន គម្លាតអវិជ្ជមាន ហើយត្រូវបានគេនិយាយថា វាមានរំញោចបំណុល។

គម្លាត (អវិជ្ជមាន) របស់បំណុល = រំញោចការប្រាក់លើទ្រព្យ - រំញោចការប្រាក់របស់បំណុល <0 (9)

ធនាគារមួយមានរំញោចទ្រព្យ $150 លាន ហើយរំញោចការប្រាក់នៃបំណុល $200 លាន ដូច្នេះរំញោចបំណុល ដែលមានគម្លាតអវិជ្ជមាន $50 លាន។ ការកើនឡើងអត្រាការប្រាក់នឹងបន្ទាបគម្លាតការប្រាក់សុទ្ធពីព្រោះ ការកើនឡើងចំណាយដែលទាក់ទងនឹងរំញោចការប្រាក់នៃបំណុលច្រើនជាងការកើនឡើងចំណូលការប្រាក់រំញោចការប្រាក់នៃទ្រព្យ។ ការធ្លាក់ចុះអត្រាការប្រាក់ និងបង្កើតគម្លាតការប្រាក់ខ្ពស់ជាង និងប្រហែលជាមានចំនួនច្រើនជាង ពីព្រោះចំណាយលើកម្ចី និងថយចុះច្រើនជាងចំណូលការប្រាក់។

**មានមធ្យោបាយមួយចំនួនក្នុងការវាស់វែងគម្លាត** រំញោចការប្រាក់ (ISGAP)។ វិធីមួយក្នុងចំណោមវិធីទាំងនោះហៅថា ISGAP ដុល្លា ដូចឧទាហរណ៍ខាងលើ បើរំញោចការប្រាក់នៃទ្រព្យ (ISA) ស្មើនឹង $150 លាន ហើយរំញោចការប្រាក់នៃបំណុល (ISL) ស្មើនឹង $200 លាន ដូច្នេះ

ISGAP = ISA – ISL = 150 – 200 =-50 លាន។ ធនាគារមួយដែលមាន ISGAP ដុល្លាវិជ្ជមាន គឺមានរំញោចទ្រព្យ ចំណែកឯធនាគារដែលមាន ISGAP ដុល្លាអវិជ្ជមាន មានរំញោចបំណុល។
ចំណែកឯអនុបាត ISGAP គេអាចបង្កើតដូចខាងក្រោម :

$$\text{អនុបាត ISGAP} = \frac{ISGAP}{\text{ទំហំធនាគារ}} = \frac{-50\ \text{លាន}}{} = -0.33 \qquad (10)$$

(វាស់វែងដោយ Ex ចំនួនទ្រព្យ)

ចំនួនអនុបាត ISGAP ធំជាងសូន្យ មានន័យថាធនាគារមានរំញោចទ្រព្យចំណែកអនុបាត ISGAP អវិជ្ជមានគឺប្រាប់ពីធនាគារមួយដែលមានរំញោចបំណុល។ ចុងក្រោយយើងអាចប្រៀបធៀបអនុបាតនៃ ISA និង ISL ដែលគេហៅថាអនុបាតរំញោចការប្រាក់ (ISR)។ តាមឧទាហរណ៍ខាងលើគឺ :

$$ISR = \frac{ISA}{ISL} = \frac{150}{200} = 0.75$$

នៅពេលនេះយើងឃើញថា ISR ដែលតូចជាងមួយបានប្រាប់យើងថាកំពុងតែមើលធនាគារមួយដែលមានរំញោចបំណុល ផ្ទុយមកវិញបើរំញោច ISR ធំជាងចំនួនឯកតា (1) មានន័យថាធនាគារមានរំញោចទ្រព្យ។

**ធនាគារមួយដែលមានរំញោចទ្រព្យគឺ :**

- មាន ISGAP ដុល្លាវិជ្ជមាន
- អនុបាត ISGAP វិជ្ជមាន
- អនុបាតរំញោចការប្រាក់ (ISR) ធំជាង 1

**ធនាគារមួយដែលមានរំញោចបំណុលគឺ :**

- មាន ISGAP ដុល្លាវិជ្ជមាន
- មានអនុបាត ISGAP វិជ្ជមាន
- មានអនុបាតរំញោចការប្រាក់តូចជាង 1

ធនាគារមួយគ្មានហានិភ័យការប្រាក់ កាលណាមានរំញោចការប្រាក់នៃទ្រព្យ ស្មើនឹងបម្រែបម្រួលការប្រាក់នៃបំណុល នៅក្នុងករណីនេះចំណូលការប្រាក់ពីទ្រព្យ និងការចំណាយលើមូលធនផ្លាស់ប្តូរក្នុងពេលតែមួយ។ ហើយគម្លាតរបស់ធនាគារស្មើនិងសូន្យ (0) ហើយគម្លាតការប្រាក់សុទ្ធ ត្រូវបានគេការពារទោះបីជាអត្រាការប្រាក់ប្រែប្រួលទៅតាមទិសដៅណាក៏ដោយ។ នៅក្នុងការអនុវត្តទៅបីជាគម្លាតនោះស្មើនឹងសូន្យក៏ដោយ ក៏មិនអាចបំបាត់ចោលទាំងស្រុងនូវហានិភ័យការប្រាក់ដែរ ព្រោះអត្រាការប្រាក់ដែលភ្ជាប់ទៅនឹងទ្រព្យ និងបំណុលនៃធនាគារមិនមានទំនាក់ទំនងឥតខ្ចោះនោះទេ។

ឧទាហរណ៍ អត្រាការប្រាក់ឥណទាន ប្រែប្រួលទៅតាមអត្រាការប្រាក់ទីផ្សារប្រាក់ដែលបានខ្ចី។ ដូច្នេះចំណូលការប្រាក់ នឹងកើនឡើងយឺតជាងការចំណាយក្នុងពេលមានការពង្រីកសេដ្ឋកិច្ច ផ្ទុយទៅវិញ ការចំណាយការប្រាក់ និងថយចុះលឿនជាងចំណូលក្នុងពេលដែលសេដ្ឋកិច្ចធ្លាក់ចុះ។

វិធីគម្លាតនេះប្រើប្រាស់ខុសៗគ្នាទៅតាមទម្រង់ និងភាពស្មុគស្មាញរបស់ធនាគារ ប៉ុន្តែប្រើប្រាស់វិធីទាំងនេះត្រូវបានទាមទារអ្នកគ្រប់គ្រងធនាគារធ្វើការសម្រេចចិត្តដូចខាងក្រោម :

1- អ្នកគ្រប់គ្រងត្រូវតែជ្រើសរើសរយៈពេលត្រឹមត្រូវមួយ ដែលគម្លាតការប្រាក់សុទ្ធ (NIM) ត្រូវបានគេគ្រប់គ្រងក្នុងគោលបំណងសម្រេចនូវតម្លៃដែលគេចង់បាន និងប្រវែងនៃរយៈពេលដែលបានបែងចែកក្នុងផែនការ។
2- អ្នកគ្រប់គ្រងត្រូវតែជ្រើសរើសគំនិតគោលដៅមួយ សម្រាប់គម្លាតការប្រាក់សុទ្ធដែលអាចធ្វើឱ្យវានៅនឹង ឬបង្កើន
3- ប្រសិនបើអ្នកគ្រប់គ្រងចង់បង្កើន NIM ពួកគេត្រូវតែបង្កើតនូវការព្យាករណ៍ អត្រាការប្រាក់ត្រឹមត្រូវមួយ ឬក៏រកមធ្យោបាយដើម្បីបែងចែកទ្រព្យ (បង្កើតចំណូល) នឹងបំណុល ដើម្បីបង្កើតគម្លាតរវាង ចំណូលការប្រាក់ និងចំណាយការប្រាក់។
4- ក្រុមអ្នកគ្រប់គ្រង ត្រូវតែកំណត់ពីចំនួនប្រាក់ដុល្លានៃទ្រព្យដែលមានរំញោចការប្រាក់ និងបំណុលដែលមានរំញោច ដែលធនាគារចង់មាន។

នៅក្នុងតារាងទី 5-2 ខាងក្រោមនេះបានផ្តល់នូវឧទាហរណ៍លម្អិតអំពីការគ្រប់គ្រងគម្លាតដែលបានអនុវត្តអំពីទ្រព្យ និងបំណុលរបស់ធនាគារនីមួយៗ។ ពួកអ្នកគ្រប់គ្រងបានតម្រៀបនូវទ្រព្យ និងបំណុលទៅតាមក្រុមដែលមានកាលអវសាន្តផ្សេងៗគ្នា ឬក៏ការប្រាក់របស់វាត្រូវបានគេកំណត់ជាថ្មី។ គួរកត់សម្គាល់ថាធនាគារនេះមានបម្រែបម្រួលបំណុលក្នុងកំឡុងពេលអាទិត្យក្រោយ និងក្នុង 90 ថ្ងៃក្រោយទៀត។ បន្ទាប់មកវាមានរំញោចទ្រព្យ។ នេះជាប្រភេទធនាគារដែលមានបំណុលរយៈពេលខ្លី ហើយទ្រព្យរយៈពេលវែង។ អ្នកគ្រប់គ្រងបានដាក់ធនាគារបែបនេះឱ្យមានអត្រាការប្រាក់ធ្លាក់ចុះនៅក្នុងរយៈពេល 3 ខែបន្ទាប់ ហើយបន្ទាប់មកអត្រាការប្រាក់កើនឡើងរយៈពេលវែង។

នៅខាងក្រោមបំផុតនៃតារាង 5-2 យើងគណនាចំណូលការប្រាក់សុទ្ធ និងគម្លាតការប្រាក់សុទ្ធ ហើយពិនិត្យមើលថាតើវានឹងមានការផ្លាស់ប្តូរយ៉ាងណាប្រសិនបើការប្រាក់កើនឡើង។ ចំណូលការប្រាក់សុទ្ធរបស់ធនាគារបានមកពីរូបមន្តដូចខាងក្រោម :

ចំណាយការប្រាក់សុទ្ធ =ចំណូលការប្រាក់សរុប – ចំណាយការប្រាក់សរុប =ទិន្នផលការប្រាក់លើទ្រព្យដែលមានរំញោចការប្រាក់ × បរិមាណនៃទ្រព្យដែលមានអត្រារំញោច + ទិន្នផលការប្រាកើលើទ្រព្យ (ដែលមិនមានអត្រាការរំញោច) × បរិមាណទ្រព្យដែលគ្មានអត្រារំញោច – ការប្រាក់លើបំណុលដែលមានអត្រារំញោច × បរិមាណបំណុលដែលមានការប្រាក់រំញោច –ចំណាយការប្រាក់លើបំណុល (ដែលមិនមានអត្រារំញោច) × បរិមាណបំណុលដែលមិនមានអត្រារំញោច

<u>ឧទាហរណ៍</u> : ទិន្នផលនៃអត្រារំញោច និងមិនប្រែប្រួលស្មើនឹង10% នឹង 11%។ ចំណែងបំណុលដែលមានអត្រារំញោច និងមិនរំញោច ស្មើនឹង 8% នឹង 9% ។ ហើយនៅក្នុងសប្តាហ៍ក្រោយធនាគារ និងរក្សាទុកទ្រព្យដែលមានអត្រារំញោច $1.700 លាន (ជាផ្នែកមួយនៃទ្រព្យសរុបនៃ $4.100 លាន) ចំពោះបំណុលដែលមានអត្រារំញោចវិញគឺ $1800 លាន។ ឧបមាថា ការប្រាក់តាំងនេះមិនប្រែប្រួល ដូច្នេះចំណូលការប្រាក់សុទ្ធគឺ :

$$0.12 \times 1700 + 0.11 \times (4100 - 1700) - 0.10 \times 1800 - 0.09 \times [4.100 - 1.800] = \$81\text{លាន}$$

ដូច្នេះធនាគារនឹងខាតបង់ $2 លាននៃចំណូលការប្រាក់សុទ្ធប្រសិនបើអត្រាការប្រាក់កើនឡើងក្នុងអាទិត្យក្រោយ។ អ្នកគ្រប់គ្រងត្រូវតែសម្រេចចិត្ត គួរតែទទួលយក ហានិភ័យនេះឬក៏ទប់ទល់នឹងហានិភ័យនេះឬក៏ទប់ទល់នឹងហានិភ័យនេអដោយប្រើប្រាស់យុទ្ធសាស្រ្តពង្វាង (Hedging)។

**តារាង៥.២** Sample Interest-Sensitivity Analysis (GAP management) for an Individual Bank

វង្វាស់ហានិភ័យការប្រាក់ដ៏មានប្រយោជន៍ គឺជាបង្គរនៃគម្លាត (Accumulative Gap)

# មេរៀនទី៦
# ការផ្តល់ឥណទានដល់ក្រុមហ៊ុនអាជីវកម្ម

ការផ្តល់ឥណទានដល់ក្រុមហ៊ុនអាជីវកម្មរយៈពេលខ្លី ដើម្បីទិញមូលប័ត្រថ្មីៗ និងបន្តរក្សាចង្កោមមូលប័ត្ររបស់ខ្លួនដល់ពេលវាលក់ ឬដល់កាលអវសាន្ត។ ឥណទានប្រភេទនេះត្រូវបានផ្តល់ដោយធនាគារធំៗ ពីព្រោះឥណទាន ទាំងនោះមានគុណភាពខ្ពស់ ដោយប្រើប្រាស់មូលប័ត្ររដ្ឋាភិបាលជាវត្ថុបញ្ចាំ។ ជាងនេះទៅទៀត ឥណទានទៅអោយពាណិជ្ជករមូលប័ត្រមានរយៈពេលខ្លី (មួយថ្ងៃ ឬ ពីរថ្ងៃ)។ ធនាគារអាចប្រមូល ប្រាក់មកវិញបានលឿន ហើយផ្តល់ឥណទានសារជាថ្មី នៅពេលដែលទីផ្សារឥណទានត្រូវបានគេរឹត បន្តឹង។

ប្រភេទឥណទានបែបនេះរបស់ធនាគារ ត្រូវបានពង្រីកទៅដល់ក្រុមហ៊ុន វិនិយោគដើម្បី គាំទ្រដល់ការទិញសញ្ញាប័ណ្ណសាជីវកម្មថ្មី ភាគហ៊ុន និងមូលប័ត្ររដ្ឋាភិបាល។ ការបោះពុម្ពនូវមូលប័ត្រទាំងនេះកើនឡើងនៅពេលដែលធនាគារវិនិយោគជួយអតិថិជនរបស់ខ្លួន ក្នុងការរំលាយបញ្ចូលគ្នា ឬទិញក្រុមហ៊ុនមួយទៀតជួយក្រុមហ៊ុនមួយដើម្បីបោះពុម្ព និងលក់ភាគហ៊ុនរបស់វាឬក៏ជួយបង្កើតក្រុមហ៊ុនថ្មីមួយសុទ្ធសាធ។ នៅពេលដែលធនាគារវិនិយោគអាចលក់នូវមូលប័ត្រទាំងនេះអោយអ្នកវិនិយោគក្នុងទីផ្សារ ចំនួនឥណទាន និងការប្រាក់ត្រូវបានគេសង។

មូលដ្ឋានដែលមាននៅលើទីផ្សារ ឬក៏ Labor។ ក្នុងករណីនេះ ធនាគារអាចមិន អនុវត្តការសន្យា របស់ខ្លួនទៅលើការឲ្យខ្ចីណាដែលមានការផ្លាស់ប្តូរមិនល្អក្នុងស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចីពុំបានបំពេញនូវលក្ខខណ្ឌណាមួយរបស់ធនាគារនៅក្នុងកិច្ចសន្យា។ ទំរង់ទាំងពីរនៃឥណទានបំរុងទុកគឺកំរិត ឥណទានបញ្ជាក់ (Confirmed Credit Line) ដែលធនាគារ បង្ហាញពីការ យល់ព្រមនៃសំណើរសុំ ឥណទានរបស់អតិថិជនពុំមានបំណងយកឥណទានរហូតដល់កំរិតដែលបានកំណត់ទេ ហើយត្រូវ គេ ប្រើប្រាស់វាដើម្បីគាំទ្រដល់ការខ្ចីឥណទានពីធនាគារផ្សេងទៀត។ ឥណទាន បំរុងទុកបែប ផ្តល់ឲ្យតែ ក្រុមហ៊ុនដែលមានកំរិតឥណទានខ្ពស់ៗ ហើយជាធម្មតាមានថ្លៃទាបជាងឥណទានបំរុងទុកផ្លូវការ។

## ៦.១. ហិរញ្ញប្បទានដល់អ្នកលក់រាយ

ធនាគារបានគាំទ្រដល់ការទិញដោយបង់រំលោះនូវឧបករណ៍សង្ហារឹម និងវត្ថុផ្សេងទៀតរបស់អតិថិជននៃក្រុមហ៊ុនលក់រាយ ដោយឲ្យឥណទានទៅលើប្រាក់ដែលអតិថិជនជំពាក់នៅពេលដែលកិច្ចព្រមព្រៀងលើការបង់រំលោះត្រូវបានគេធ្វើ ហើយកិច្ចព្រមព្រៀងនេះត្រូវបានពិនិត្យមើលដោយធនាគារជាមួយនិងពាណិជ្ជករ ដែលនឹងទទួលឥណទាន។ ប្រសិនបើវាឆ្លើយតបនិងបទដ្ឋានឥណទាន កិច្ចព្រមព្រៀងនឹងត្រូវបានទិញដោយធនាគាជាមួយនឹងអត្រាការប្រាក់ខុសៗគ្នាទៅតាមហានិភ័យនៃអ្នកខ្ចី វត្ថុបញ្ចាំ និងលក្ខខណ្ឌ។

ក្នុងករណីពាណិជ្ជករលក់ រថយន្ត ទូរទស្សន៍ គ្រឿងសង្ហារឹមផ្សេងៗ ធនាគារអាចផ្តល់ហិរញ្ញប្បទាន សំរាប់ស្តុកទាំងអស់។ ធនាគារអាចពន្យាឥណទាននេះ ដូច្នេះហើយ ពាណិជ្ជករអាចបញ្ជាទិញជាមួយ នឹងអ្នកផលិត ដើម្បីដឹកទំនិញសំរាប់លក់។ ឥណទានបែបនេះច្រើនតែមានរយៈពេល 90 ថ្ងៃ ហើយត្រូវ បានគេពន្យាពេល 30 ថ្ងៃថែមទៀត។ ដើម្បីផ្តល់ឥណទានធនាគារអោយពាណិជ្ជករចុះកិច្ចសន្យា ដែលផ្តល់សិទ្ធិក្នុងការលក់ទំនិញក្នុងករណីមិនមានការសងវិញ។ ហើយនៅពេល ជាមួយគ្នានេះដែរ អ្នកផលិតអាចផ្ញើរទំនិញទៅឲ្យពាណិជ្ជករ និងផ្ញើរវិក័យប័ត្រទារប្រាក់ទៅឲ្យធនាគារ។ តាមពេលមួយៗ ធនាគារបានបញ្ជូនភ្នាក់ងាររបស់ខ្លួនទៅឃ្លាំងទំនិញដើម្បីពិនិត្យមើលពីអ្វីដែលលក់ និងពីអ្វី ដែលនៅ សល់។ នៅពេលដែលទំនិញបានលក់ពាណិជ្ជករនឹងផ្ញើរមូលប្បទានប័ត្រទៅធនាគារនូវចំនួនទឹកប្រាក់ ស្មើនឹងវិក័យប័ត្ររបស់អ្នកផលិតផ្ញើរមកធនាគារ។

## ៦.២.ហិរញ្ញប្បទានផ្អែកលើទ្រព្យ

ឥណទានប្រភេទនេះត្រូវបានធានាដោយទ្រព្យរយៈពេលខ្លីរបស់ក្រុមហ៊ុន ដែលគេរំពឹង ទុកថានឹង ក្លាយជាសាច់ប្រាក់ក្នុងពេលអនាគត។ ទ្រព្យដែលប្រើសំរាប់ឥណទាននេះគឺ គណនីអតិថិជន និងស្តុកវត្ថុធាតុដើម និងស្តុកផលិតផលសំរេច។ ធនាគារនឹង ឲ្យខ្ចីនូវចំណែក ជាភាគរយជាក់លាក់ នៃ តំលៃក្នុងបញ្ជីនៃគណនីដែលគេជំពាក់ ឬស្តុក។ នៅពេលដែលគណនីអតិថិជនត្រូវបានគេប្រមូល ឬស្តុកត្រូវបានគេលក់ចំណែកខ្លះនៃសាច់ប្រាក់នេះត្រូវបានគេបង្វែរទៅធនាគារដើម្បីសងឥណទាន។ ឥណទានភាគច្រើនដែលប្រើប្រាស់គណនីអតិថិជន និងស្តុកជាវត្ថុបញ្ចាំក្រុមហ៊ុន (ដែលខ្ចី) នៅតែជាម្ចាស់របស់ទ្រព្យទាំងនេះ ប៉ុន្តែពេលខ្លះ កម្មសិទ្ធិ ត្រូវបាន ផ្ទេរទៅឲ្យធនាគារ ហើយ ទ្រព្យខ្លះ មិនត្រូវបានគេសងដូចរំពឹងទុកទេ។ ឧទាហរណ៍ ដែលគេស្គាល់ជាងគេគឺ factoring ដែលធនាគារ ទទួលខុសត្រូវទាំងក្នុងការប្រមូលគណនី អតិថិជន ដោយធនាគារ ត្រូវប្រឈមមុខនឹងការចំណាយ និង ហានិភ័យធនាគារត្រូវវាយតំលៃអត្រាអប្បហាខ្ពស់ ហើយផ្តល់ ឥណទានតែលើផ្នែកតូច លើតំលៃ ក្នុង បញ្ជីតែប៉ុណ្ណោះ។

## ៦.៣. ឥណទានរយៈពេលវែង

### ៦.៣.១.ឥណទានអាជីវកម្មរយៈពេលវែង

ឥណទានរយៈពេលវែងត្រូវបានគេបង្កើតឡើងដើម្បីផ្តល់ហិរញ្ញវត្ថុដល់ការវិនិយោគរយៈពេលវែង និងមធ្យម ដូចជាការទិញឧបករណ៍ ឬក៏ធ្វើសំណង់ ដែលមានរយៈពេលវែងជាងមួយឆ្នាំ។ ជាធម្មតា ក្រុមហ៊ុនដែលខ្ចី សុំឥណទានសរុបផ្អែកលើការចំណាយគ្រោងទុកនៅក្នុងគំរោង ហើយសន្យាសងជា បន្តបន្ទាប់ (ប្រចាំត្រីមាស ឬប្រចាំខែ)។

ឥណទានរយៈពេលវែង ពិនិត្យមើលទៅលើលំហូរនៃចំណូលរបស់ក្រុមហ៊ុនដើម្បីសងឥណទាន។ កាលវិភាគនៃការសងត្រូវបានគេរៀបចំទៅតាមខួបនៃការហូរចូល ឬហូរចេញនៃសាច់ប្រាក់។

ឥណទានខ្លះមិនទាមទារអោយមានការសងជាដំណាក់ៗទេ រហូតទៅដល់កាលអាវសាន្តនៃឥណទានបានផុតកំណត់។

### ៦.៣.២.ឥណទានវិល ( Revolving Credit Financing )

ឥណទានវិលអនុញ្ញាតឲ្យអតិថិជននូវកំរិតមួយកំណត់ សងវិញទាំងអស់ ឬចំណែកខ្លះនៃការខ្ចី ឬ ក៏ខ្ចីបន្ថែមទៀតរហូតដល់កំរិតឥណទានដល់ទីអវសាន្ត។ ឥណទានវិលជា ទំរង់ឥណទាន មួយ ដែល មានលក្ខណៈសំរបសំរួលជាងគេហើយត្រូវបានគេផ្តល់ឲ្យដោយគ្មានវត្ថុបញ្ចាំ ក្នុងរយៈពេលវែង 4 ឬ 5 ឆ្នាំ។ ទំរង់ឥណទាន នេះត្រូវបានគេ និយមនៅពេល ដែលអតិថិជនដឹង ពុំច្បាស់ពីពេលវេលាពិត ប្រាកដនៃឥណទានវិលអាចជួយដល់ការឡើងចុះក្នុងខួបអាជីវកម្ម ដែលអនុញ្ញាត ឲ្យគេអាច ខ្ចីបាន នៅពេលការលក់ថយចុះហើយអាចសងនៅពេលដែលអាជីវកម្មរីកចម្រើនខ្លាំង ហើយមាន សល់សាច់ ប្រាក់ច្រើន។ ជាផ្លូវច្បាប់ ធនាគារមានកាតព្វកិច្ចអនុញ្ញាត ឲ្យអតិថិជនស្នើរ សុំមូលធនរហូតដល់ដែន កំណត់មួយជាធម្មតា ធនាគារយកកំរ៉ៃលើសាច់ប្រាក់បំរុង (Commitment Fee) ទៅលើផ្នែក នៃកំរិតឥណទានដែលមិនបានប្រើប្រាស់ ឬក៏ពេលខ្លះ យកទៅលើ ចំនួនទាំងអស់ នៃ ឥណទាន ដែលបំរុងសំរាប់ការប្រើប្រាស់។

ឥណទានបំរុងទុកមានពីរប្រភេទដែលគេនិយមជាងគេគឺ ឥណទានបំរុងទុកផ្លូវការ (Formal loan Commitment) ដែលជាការសន្យាដោយធនាគារក្នុងការឲ្យខ្ចីទៅអតិថិជននូវចំនួនធំបំផុត ដែលមានអត្រាការប្រាក់កំណត់ជាមុន ឬក៏ការបូកបន្ថែមទៅលើអត្រា។

### ៦.៣.៣.ឥណទានគំរោងរយៈពេលវែង

ឥណទានអាជីវកម្មដែលមានហានិភ័យខ្ពស់ជាងគេបំផុតគឺ ឥណទានគំរោង (Project Loan) ដែលជាឥណទានសំរាប់ផ្តល់ហិរញ្ញវត្ថុដល់ការសាងសង់អចលនទ្រព្យ ដែលសំរាប់ចង្កើត ប្រាក់ចំណូលក្នុងពេលអនាគត។ ឥណទានគំរោងអាចត្រូវបានគេផ្តល់ឲ្យផ្អែកលើការស្វែងរកការសង ដែលអ្នកឲ្យខ្ចីអាចទទួលមូលធនរបស់ខ្លួនពីម្ចាស់គំរោងនៅពេលដែលគំរោងមិនអាចសងប្រាក់ទៅ តាមផែនការ នៅពេលខ្លះឥណទានត្រូវបានគេបន្តដោយមិនផ្អែកលើការសងដែលគ្មានការធានាពី ម្ចាស់គំរោង គំរោងអាចដំណើរការ ឬបរាជ័យដោយខ្លួនឯង។ ក្នុងករណីនេះអ្នកឲ្យខ្ចីអាចប្រឈមមុខ នឹងហានិភ័យ ធ្ងន់ធ្ងរហើយជាធម្មតាទាមទារឲ្យមានអត្រាខ្ពស់ដើម្បីទូរទាត់ទៅនឹងហានិភ័យទាំងនេះ។ ឥណទានបែបនេះទាមទារឲ្យម្ចាស់គំរោងដាក់នូវមូលធនរបស់ខ្លួនឲ្យបានគ្រប់គ្រាន់ដើម្បីធ្វើឲ្យគំរោងទៅដល់ទីបញ្ចប់។

## ៦.៤.ការវិភាគឥណទានអាជីវកម្ម

ប្រភពធនធានដែលគេនិយមប្រើជាងគេសំរាប់សងឥណទានអាជីវកម្មគឺៈ

1.ប្រាក់ចំណេញនិងលំហូរសាច់ប្រាក់របស់អាជីវកម្ម

2.ទ្រព្យដែលបញ្ចាំសំរាប់ឥណទាន

3.ភាពខ្លាំងរបស់តារាងតុល្យការ ដែលមានចំនួនទ្រព្យដែលអាចលក់នៅទីផ្សារច្រើន

4.ការធានាដោយអាជីវកម្មដូចជាការយកទ្រព្យសម្បត្តិផ្ទាល់ខ្លួនសំរាប់ធានាឥណទានអាជីវកម្ម។

ត្រូវចងចាំថា ប្រភេទទាំងនេះទាក់ទងទៅនឹងការវិភាគរបាយការណ៍ហិរញ្ញវត្ថុដែលមានតារាងតុល្យការ និងរបាយការណ៍ប្រាក់ចំណេញ។ ឥឡូវនេះពិនិត្យមើលរបាយការណ៍ហិរញ្ញវត្ថុទាំងពីរនេះ។

## ៦.៤.១.ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ

ការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកខ្ចី ចាប់ផ្តើមនៅពេលនាយកដ្ឋាន វិភាគឥណទានរបស់ ធនាគាររៀបចំការវិភាគទៅលើតួលេខជា គន្លឹះមួយចំនួនលើរបាយការណ៍ហិរញ្ញវត្ថុដែលមានការផ្លាស់ប្តូរក្នុងរយៈពេល 4 ឬ 5ឆ្នាំ។ ឧទាហរណ៍នៃការវិភាគប្រតិបត្តិការពីអតីតកាលរបស់ក្រុមហ៊ុនប្រេងនិងឧស្ម័ន Gas Giant, Inc ត្រូវបានបង្ហាញក្នុងតារាងខាងក្រោម 11-1។

តារាង6.1: Historical Analysis of the Financial Statements of Gas Giant, Inc. (dollar figures in millions)

| Gas Giant's Balance Sheets Arrayed in a Spread Sheet | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | Most recent year | | One Year ago | | Two Years ago | | three Years ago | |
| Balance | Dollar | % value of T | Dollar | % value of T | Dollar | % value of T | Dollar | % value of T |
| Sheet items | | | | | | | | |
| Assets | | | | | | | | |
| Cash | $1.0 | 3.6% | $1.3 | 4.5% | $1.7 | 5.7% | $2.2 | 6.9% |
| Marketable securities | 0.5 | 1.8 | 0.8 | 2.8 | 1.0 | 3.3 | 0.0 | |
| Account receivable | 8.3 | 29.6 | 7.4 | 25.5 | 6.2 | 20.7 | 4.1 | 12.8 |
| Inventories | 5.2 | 18.6 | 4.5 | 15.5 | 3.4 | 11.3 | 2.3 | 7.2 |
| Total Current assets | $15.0 | 53.6 | $14.0 | 48.3 | $12.3 | 41.0 | $8.6 | 26.9 |
| Fixed assets. Gross | 19.4 | 69.3 | 20.2 | 69.7 | 21.5 | 71.7 | 22.4 | 70.0 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| Less: Accumulated Depreciation | 10.3 | 36.8 | 9.2 | 31.7 | 8.0 | 26.7 | 5.1 | 15.9 |
| Fixed assets. Net | 9.3 | 33.2 | 11.0 | 37.9 | 13.5 | 45.0 | 17.3 | 54.1 |
| Other assets | 3.7 | 13.2 | 4.0 | 13.8 | 4.2 | 14.0 | 6.1 | 19.1 |
| Total assets | $28.0 | 100.0% | $29.0 | 100.0% | $30.0 | 100.0% | $32.0 | 100.0% |
| Liability and Equity | | | | | | | | |
| Account payable | $1.3 | 4.6% | $1.2 | 4.1% | $0.8 | 2.7% | $1.0 | 3.1% |
| Note payable | 3.9 | 13.9 | 3.4 | 11.7 | 3.2 | 10.7 | 1.7 | 8.4 |
| Taxes payable | 0.1 | 0.4 | 0.2 | 0.7 | 0.1 | 0.3 | 0.8 | 2.3 |
| Total current liabilities | $5.3 | 18.9 | $4.8 | 16.6 | $4.1 | 13.7 | $4.5 | 14.1 |
| Long-term debt | 12.2 | 43.6 | 13.2 | 45.5 | 12.5 | 41.6 | 11.4 | 35.5 |
| Other liabilities | 0.0 | 0.0 | 0.4 | -1.4 | 3.5 | 11.7 | 1.1 | 1.9 |
| Total liabilities | $17.5 | 62.5% | $18.4 | 63.4% | $20.1 | 67.0% | $22.0 | 68.8% |
| Common stock | 1.0 | 3.6 | 1.0 | 3.4 | 1.0 | 3.3 | 3.1 | 1.0 |
| Paid-in surplus | 3.0 | 10.7 | 3.0 | 10.3 | 3.0 | 10.0 | 3.0 | 9.4 |
| Retained earning | 6.5 | 23.2 | 6.6 | 22.8 | 5.9 | 19.7 | 6.0 | 18.8 |
| Total net worth | 10.5 | 37.5 | 10.6 | 36.6 | 9.9 | 33.0 | 10.0 | 31.3 |

## ៦.៥.ការវិភាគអនុបាតហិរញ្ញវត្ថុ

ពត៌មានពីតារាងតុល្យការ និងរបាយការណ៍ចំណូលត្រូវបានបន្ថែមដោយការវិភាគអនុបាតហិរញ្ញ វត្ថុ។ ដោយជ្រើសរើសយកខ្ទង់មួយចំនួនយ៉ាងប្រុងប្រយ័ត្នពីតារាងតុល្យការ និងរបាយការណ៍ចំណូល មន្ត្រីឥណទានអាចមានពន្លឺលើចំណុចមួយចំនួន (1) សមត្ថភាពគ្រប់គ្រងការចំណាយរបស់អ្នកខ្ចី (2) ប្រសិទ្ធភាពនៃប្រតិបត្តិការក្នុងការប្រើប្រាស់ធនធាន ដើម្បីបង្កើតការលក់ និងសាច់ប្រាក់

(3) លទ្ធភាពលក់លើទីផ្សារនៃផលិតផលរបស់អតិថិជន (4) ចំណូលដើម្បីសងលើការចំណាយផ្នែកហិរញ្ញប្បទាន (5) ស្ថានភាពសាច់ប្រាក់របស់អ្នកខ្ចីដែលបង្ហាញពីភាពមានស្រាប់នៃសាច់ប្រាក់ (6) និន្នាការនៃប្រាក់ចំណាយរបស់អ្នកខ្ចី (7) ចំនួនបំណុលដែលទាក់ទងទៅនឹងទុនផ្ទាល់ (8) បំណុលបំរុងរបស់អ្នកខ្ចីដែលអាចត្រូវបានគេទាមទារនៅពេលអនាគត។

## ៦.៥.១.ការគ្រប់គ្រងលើការចំណាយរបស់អតិថិជន

- អនុបាតហិរញ្ញវត្ថុដែលមន្ត្រីឥណទានប្រើប្រាស់ ដើម្បីត្រួតពិនិត្យការចំណាយមាន៖
- បៀវត្ស/ ចំណូលពីការលក់
- ការចំណាយមិនផ្ទាល់ (Overheads) / ចំណូលពីការលក់
- ការចំណាយលើរំលោះ/ចំណូលពីការលក់
- ចំណាយការប្រាក់/ចំណូលពីការលក់
- ថ្លៃដើមទំនិញ/ចំណូលពីការលក់
- ចំណាយលើការលក់, រដ្ឋបាល និងចំណាយផ្សេងៗ/ ចំណូលពីការលក់
- មន្ត្រីឥណទានប្រឈមមុខនិងវិធានការគ្រប់គ្រងការចំណាយទាំងនេះចំពោះក្រុមហ៊ុន Gas Giant, Inc. អាចមានការសង្ស័យអំពីការគ្រប់គ្រងផ្នែកសាច់ប្រាក់និងចំណូលនៅពេលអនាគត។

## ៦.៥.២.ប្រសិទ្ធភាពនៃប្រតិបត្តិការ

តើការប្រើប្រាស់ទ្រព្យរបស់ក្រុមហ៊ុនមានប្រសិទ្ធភាពយ៉ាងណាដើម្បីបង្កើតចំណូលនិងសាច់ប្រាក់សំរាប់ក្រុមហ៊ុន ហើយប្រសិទ្ធភាពនៃការបំប្លែងចំណូលពីការលក់ទៅជាសាច់ប្រាក់។ ខាងក្រោមនេះជាអនុបាតហិរញ្ញវត្ថុសំខាន់ៗ ៖

- ថ្លៃដើមប្រចាំឆ្នាំ/ មធ្យមភាគស្តុក (ឬអនុបាតនៃការប្រើប្រាស់ស្តុក)
- ចំណូលពីការលក់/ ទ្រព្យសរុប
- ចំណូលពីការលក់/ អចលនទ្រព្យសុទ្ធ
- ចំណូលពីការលក់/ គណនីអតិថិជន
- រយៈពេលប្រមូលសាច់ប្រាក់មធ្យម : គណនីអតិថិជន/ ចំនួនលក់ជំពាក់ប្រចាំឆ្នាំ ($) /360។

## ៦.៥.៣.ភាពលក់ដាច់នៃផលិតផល

ដើម្បីទទួលបាននូវសាច់ប្រាក់សមល្មមក្នុងការសងឥណទាន អាជីវករត្រូវតែអាចលក់ផលិតផល ឬសេវាកម្មរបស់ខ្លួននៅលើទីផ្សារដោយជោគជ័យ។ ធនាគារអាចវាយតម្លៃការទទួលយករបស់ សាធារណៈជននូវអ្វីដែលអាជីវកម្មនេះបានលក់ ឆ្លងតាមការវិភាគនូវកត្តាមួយចំនួនដូចជា អត្រា

កំណើននៃការលក់, ការផ្លាស់ប្តូរចំណែកទីផ្សាររបស់អាជីវកម្ម និងប្រាក់ចំណេញដុលមួយឯកតា (Gross Profit Margin)

$$\text{GPM} = \frac{\text{ចំណូលពីការលក់} - \text{ថ្លៃដើម}}{\text{ចំណូលពីការលក់}}$$

$$\text{NPM} = \frac{\text{ចំណូលសុទ្ធបន្ទាប់ពីពន្ធ}}{\text{ចំណូលពីការលក់}}$$

**តារាង ៦.៤. គលាតប្រាក់ចំណេញដុលនិងសុទ្ធ**

| | ថ្មីៗនេះ | ឆ្នាំទៅ | ពីរឆ្នាំមុន | បីឆ្នាំមុន |
|---|---|---|---|---|
| គំលាតដុល | 43.8% | 46.7% | 46.4% | 54.8% |
| គលាតចំណេញសុទ្ធ | -0.3 | 2.3 | -3.6 | 5.8 |

### ៦.៥.៤.អនុបាតសង

អនុបាតសងដែលគេប្រើប្រាស់ច្រើនជាងគេមានដូចខាងក្រោម៖

អនុបាតសងការប្រាក់ = (ចំណូលមុនការប្រាក់និងពន្ធ) / (ការប្រាក់ត្រូវសង)

$$\text{អនុបាតសងការប្រាក់ និងដើម} = \frac{\text{ចំណេញមុនការសងការប្រាក់និងពន្ធ}}{[\text{ការប្រាក់} + (\text{ឥណទានត្រូវសង}) / (1 - \text{អត្រាពន្ធរបស់ក្រុមហ៊ុន})]}$$

$$\text{អនុបាតសងបំណុល} = \frac{\text{ប្រាក់ចំណេញសុទ្ធ} + \text{រំលោះ} + \text{ការប្រាក់}}{\text{ការប្រាក់} + \text{ភាគខ្លះនៃបំណុលដែលត្រូវសង}}$$

អនុបាតសងលើការ

$$\text{ចំណាយមិនប្រែប្រួល} = \frac{\text{ប្រាក់ចំណេញមុនការប្រាក់, ពន្ធនិងថ្លៃជួល}}{\text{ការប្រាក់} + \text{ថ្លៃឈ្នួល}}$$

**តារាង ៦.៥ : អនុបាតសងក្រុមហ៊ុន Gas Giant, Inc.**

| | ឆ្នាំថ្មីៗ | ឆ្នាំទៅ | ពីរឆ្នាំមុន | បីឆ្នាំមុន |
|---|---|---|---|---|
| អនុបាតសងការប្រាក់ | 1.0 x | 2.0 x | 1.0 x | 2.0 x |
| អនុបាតសងការប្រាក់ និងដើម | 0.29 x | 0.22 x | 0.32 x | 0.43 x |

### ៦.៥.៥.សាច់ប្រាក់របស់អាជីវកម្ម

អនុបាតដែលគេនិយមប្រើមានដូចខាងក្រោម ៖

$$\text{អនុបាតទ្រព្យសកម្ម} = \frac{\text{ទ្រព្យសកម្ម (រយៈពេលខ្លី)}}{\text{បំណុលរយៈពេលខ្លី}}$$

$$\text{Acid} - \text{test ratio} = \frac{\text{ទ្រព្យសកម្ម}\left(\text{រយៈពេលខ្លី}\right) - \text{ស្តុក}}{\text{បំណុលរយៈពេលខ្លី}}$$

$$\text{ទ្រព្យដែលងាយបំប្លែងជាសាច់ប្រាក់} = \text{ទ្រព្យសកម្ម} - \text{ស្តុកវត្ថុធាតុដើម ឬ ទំនិញ} - \text{បំណុលរយៈពេលខ្លី}$$

$$\text{ទុនបង្វិលសុទ្ធ} = \text{ទ្រព្យសកម្ម} - \text{បំណុលរយៈពេលខ្លី}$$

### ៦.៥.៦.ប្រាក់ចំណេញ

លទ្ធផលចុងក្រោយនៃប្រតិបត្តិការក្នុងទីផ្សារសេរី គឺប្រាក់ចំណេញរបស់ម្ចាស់អាជីវកម្មបន្ទាប់ពីការ ចំណាយ។ មន្ត្រីឥណទាននឹងពិនិត្យមើលទៅលើប្រាក់ចំណេញមុនពេលបង់ពន្ធ និងប្រាក់ចំណេញ បន្ទាប់ពីបង់ពន្ធដើម្បីវាស់វែង ការជោគជ័យនិងហានិភ័យនៃអ្នកខ្ចីធៀប ជាមួយនឹងក្រុមហ៊ុនផ្សេង ទៀតនៅក្នុងឧស្សាហកម្មដូចគ្នា។

តម្រុយដែលនិយមប្រើជាងគេគឺ៖

- ប្រាក់ចំណេញមុនពន្ធ ៖ ទ្រព្យសរុប, មូលធនផ្ទាល់ ឬក៏ចំណូលពីការលក់សរុប
- ប្រាក់ចំណេញបន្ទាប់ពីពន្ធ ៖ ទ្រព្យសរុប, មូលធនផ្ទាល់ ឬក៏ចំណូលពីការលក់សរុប

### ៦.៥.៧.អនុបាតបំណុល

គ្រប់ការឲ្យខ្ចីទាំងអស់ តែងតែយកចិត្តទុកដាក់លើបំណុលដែលមានស្រាប់បន្ថែមលើឥណទានដែលគេកំពុងស្នើសុំ។ ពាក្យថាប្រភាគនៃបំណុលមានន័យថា ការប្រើប្រាស់បំណុលដើម្បីបង្កើតចំណូលដែលច្រើនជាងបំណាយលើបំណុលដែលនាំទៅដល់ការកើនឡើងចំណូលដល់ម្ចាស់ អាជីវកម្ម អនុបាតហិរញ្ញវត្ថុ រួមមាន៖

$$\text{អនុបាតបំណុល} = \frac{\text{បំណុលសរុប}}{\text{ទ្រព្យសរុប}}$$

$$\text{អនុបាតមូលធន} = \frac{\text{បំណុលរយៈពេលវែង}}{\text{ផលបូកបំណុលរយៈពេលវែង និងមូលធនផ្ទាល់}}$$

$$\text{អនុបាតបំណុលនៃការលក់} = \frac{\text{បំណុលសរុប}}{\text{ចំណូលពីការលក់}}$$

### ៦.៥.៨.ចំណុលចំរុះ

ជាធម្មតា ប្រភេទបំណុលបែបនេះមិនត្រូវបានបង្ហាញនៅក្នុងតារាងតុល្យការទេ ហើយអាចត្រូវបានគេទាមទារពីអ្នកខ្ចីដែលមន្ត្រីឥណទានត្រូវតែដឹងអំពីបញ្ហានេះ

1. ការធានាអំពីផលិតផលរបស់អាជីវកម្ម
2. ការប្តឹងផ្តល់នៅឯតុលាការទល់នឹងក្រុមហ៊ុន
3. សោធននិវត្តន៍ដែលមិនទាន់បានសងរបស់ក្រុមហ៊ុនចំពោះបុគ្គលិក
4. ពន្ធដែលមិនទាន់បង់
5. និយ័តកម្ម។

បំណុលបែបនេះអាចក្លាយទៅជាការទាមទារពិតប្រាកដទៅលើអ្នកខ្ចីនៅពេលអនាគតដែល អាច បន្ថយមូលធនដែលមានក្នុងការសងបំណុល។ ដើម្បីឆ្លើយតបទៅនឹងបញ្ហានេះមន្ត្រីឥណទាន ដំបូង ត្រូវសាកសួរអតិថិជនអំពីការទាមទារ ដែលអាចកើតមានចំពោះក្រុមហ៊ុនបន្ទាប់មកធ្វើការ ស្រាវជ្រាវ ដោយខ្លួនឯង ឆែកបញ្ជីតុលាការមើលសេចក្តីប្រកាសជាសាធារណៈ។

## ៦.៦.ការគ្រប់គ្រងសេវាឥណទាន (Credit services management)

### ៦.៦.១.ដំណើរការឥណទាន (Credit processing)

ដំណើរការឥណទានមានបីដំណាក់កាល៖

#### ក. ការបង្កើតអាជីវកម្ម និងការវិភាគឥណទាន៖

ការបង្កើតអាជីវកម្ម ជាដំណើរការបង្កើតទីផ្សារសេវាកម្មធនាគារដល់អតិថិជនសក្តានុពល និង អតិថិជនដែលមានស្រាប់។ ចំណុចចាប់ផ្តើមសាមញ្ញនៃការខិតខំប្រឹងប្រែងក្នុងការបង្កើតអាជីវកម្មគឺ ការស្រាវជ្រាវទីផ្សារ និងការគ្រប់គ្រង ដែលដាក់ចេញនូវគោលដៅស្ថានភាពឥណទាន(ផ្តល់កម្ចីត្រឹម ប៉ុន្មាន...អតិថិជនប្រភេទណា...) និងបង្ហាញពីតំបន់អាជីវកម្មមានសក្តានុពល។ ចំណុចសំខាន់ យើង ត្រូវវិភាគហានិភ័យនៃការខកខាន (មិនបានសងត្រឡប់) ហើយផ្តោតជាសំខាន់លើការណែនាំឱ្យមាន ហានិភ័យសំខាន់ៗ ដោយយោងលើការវិភាគលើហ្វាយស៊ីនៃឥណទាន មានដូចខាងក្រោម៖

- ចារឹកលក្ខណ (Character)៖ សំដៅលើភាពស្មោះត្រង់របស់អតិថិជន។ ប្រសិនបើមានការ សង្ស័យខ្លាំងគេមិនផ្តល់ឥណទានទេ។
- ដើមទុន (Capital)៖ សំដៅលើស្ថានភាពទ្រព្យសម្បត្តិរបស់អ្នកខ្ចី។
- សមត្ថភាព (Capacity)៖ ពាក់ព័ន្ធទាំងសិទ្ធិប្តឹងផ្លូវច្បាប់ និងជំនាញគ្រប់គ្រងក្នុងការថែរក្សា ប្រតិបត្តិការ។
- លក្ខខណ្ឌ (Condition)៖ បរិយាកាសសេដ្ឋកិច្ច ឬការផលិតកត្តាបែងចែកដែលជះឥទ្ធិពល លើប្រតិបត្តិការរបស់ក្រុមហ៊ុន។
- វត្ថុបញ្ចាំ (Collateral)៖ គឺជាប្រភពនៃការទូទាត់មកវិញទី២របស់អ្នកឱ្យខ្ចី (បើគេមិនសងគេ រឹបអូស) ក្នុងករណីដែលការខកខាន (មិនសងត្រឡប់មកវិញពីអ្នកខ្ចី)។

**ខ. ការអនុវត្តន៍ឥណទាន និងរដ្ឋបាលៈ**

នៅពេលឥណទានត្រូវបានគេអនុម័តវាជាកិច្ចព្រមព្រៀងរវាងអ្នកឱ្យខ្ចី និងអ្នកខ្ចី ដូចជាតារាងទូទាត់តម្រូវការវត្ថុបញ្ចាំភាពងាយស្រួលឥណទាន។

**គ. ការពិនិត្យមើល(ឡើងវិញ)ឥណទានៈ**

ការខិតខំពិនិត្យឥណទានឡើងវិញត្រូវបានគេធ្វើឡើងក្រោយពីអនុម័តឥណទានរួច វាត្រូវបានគេធ្វើឡើងដោយផ្ទាល់ ដើម្បីកាត់បន្ថយហានិភ័យផងដែរ។ ការត្រួតពិនិត្យការងារឥណទានមានស្រាប់ និងដោះស្រាយឥណទានដែលមានបញ្ហាភាពចាំបាច់នៃការវិភាគឥណទានទាំងអស់ ត្រូវគេតាមដានឈរលើកត្តានៃការផ្តល់ឥណទាន ដូចជាៈ

**គ.១. ចរិតលក្ខណៈៈ**

ធនាគារិកជាច្រើនយល់ស្របថាកត្តាដែលធំបំផុតនៃឥណទានដែលជោគជ័យ គឺភាពស្មោះត្រង់ និងកេរ្តិ៍ឈ្មោះរបស់អ្នកខ្ចី ហើយអ្នកខ្ចីដែលមិនស្មោះត្រង់ជាធម្មតាមិនមានការប្តេជ្ញាក្នុងការបង់បំណុលរបស់គេត្រឡប់មកវិញទេ។

**គ.២. ការប្រើប្រាស់មូលនិធិឥណទានៈ**

វិជ្ជាជីវៈគណនេយ្យរបស់អ្នកវិភាគ និងជំនាញហិរញ្ញវត្ថុ គឺសំខាន់ណាស់នៅក្នុងការកំណត់សមត្ថភាពរបស់អ្នកខ្ចីក្នុងការទូទាត់ឥណទានពីចំណូលសាច់ប្រាក់។

**គ.៣. ប្រភពទី១ នៃការទូទាត់ (សំណង)ៈ**

ជាទូទៅចំណូល (លំហូរ) សាច់ប្រាក់ពីប្រតិបត្តិការអាជីវកម្ម គឺជាប្រភពទូទាត់សំណងឥណទាន។ វត្ថុបញ្ចាំតែងតែត្រូវបានគេមើលឃើញថាជាប្រភពសំណងទី២ជាអ្នកធានា ឬសាក្សី (ផ្តិតមេដៃ) មិនមែនជាប្រភពទី១នៃការទូទាត់សំណងទេ។

## ៦.៦.២.សេវាប្រាក់បញ្ញើអតិថិជន (Customer deposit service)

បញ្ញើជាកិច្ចសន្យាដែលបុគ្គលម្នាក់ហៅថា "អ្នកខ្ចី" យកចលនវត្ថុទៅដាក់ផ្ញើនឹងបុគ្គលម្នាក់ទៀតហៅថា "អ្នកទទួលបញ្ញើ" ដែលយល់ព្រមទទួលទុកអចលនវត្ថុនោះ ហើយសន្យាថានឹងសងប្រគល់ឱ្យអ្នកផ្ញើវិញនៅពេលអ្នកផ្ញើស្នើសុំ។ ទាក់ទងនឹងវិស័យធនាគារចលនវត្ថុទាំងនោះ រួមមានប្រាក់មូលប័ត្រ ឬទ្រព្យដទៃទៀត ដែលមានតម្លៃផ្សេងៗ។ ន័យម្យ៉ាងទៀត ប្រាក់បញ្ញើគឺជាឥណទេយ្យហិរញ្ញវត្ថុរបស់ក្រុមហ៊ុនជំនួញ ក្រុមហ៊ុនគ្រួសារ និងរដ្ឋាភិបាលត្រូវទារពីធនាគារ។ ប្រភេទប្រាក់បញ្ញើ (Types of Deposits) មានបីប្រភេទគឺ ៖

១- ប្រាក់បញ្ញើចរន្ត (Demand Deposit/Current Account)៖ ប្រាក់បញ្ញើចរន្តជាប្រភេទគណនី ដែលអតិថិជនអាចដាក់ផ្ញើប្រាក់ជាប្រាក់រៀល ប្រាក់ដុល្លារ ឬក៏ប្រាក់បាត។ គណនីនេះ អតិថិជនប្រើប្រាស់មូលប្បទានប័ត្រ (Check/Cheque) ជាមធ្យោបាយក្នុងការទូទាត់ទំនិញ ឬសេវាបានដោយមិនចាំបាច់កាន់សាច់ប្រាក់តាមខ្លួន ហើយផ្តល់នូវភាពងាយស្រួល និងរហ័សព្រមទាំងសុវត្ថិភាពខ្ពស់ក្នុងការទូទាត់។ ក្នុងការប្រើប្រាស់គណនីនេះ អតិថិជនពុំទទួលបាននូវការប្រាក់ទេ តែធនាគារបានជួយសម្រួល និងផ្តល់លទ្ធភាពចំណេញដល់អតិថិជនវិញតាមរយៈការប្រើប្រាស់បម្រើសេវាកម្មរបស់ខ្លួនចំពោះអតិថិជន។

២- ប្រាក់បញ្ញើសំចៃ ឬគណនីសន្សំ (Saving Deposit/Saving Account)៖ ជាប្រភេទគណនីបានដាក់ផ្ញើដោយរូបវន្តបុគ្គល និងនីតិបុគ្គល (ក្រុមហ៊ុនសហគ្រាស) ហើយអតិថិជនអាចដាក់ផ្ញើជារូបិយប័ណ្ណផ្សេងៗ ដូចជាបញ្ញើជាប្រាក់រៀល បញ្ញើជាដុល្លារ និងអាចដកប្រាក់ប្រើពេលណាក៏បានទៅតាមតម្រូវការរបស់ខ្លួន។ ចំពោះអតិថិជនបើកគណនីនេះ ធនាគារចេញសៀវភៅសន្សំ (Passbook) ដោយផ្តល់ជូនដោយមិនគិតថ្លៃ ដើម្បីទុកជាឧបករណ៍ក្នុងការដាក់ប្រាក់ និងដកប្រាក់ទៅតាមប្រតិបត្តិការប្រចាំថ្ងៃ និងការបញ្ជាក់ពីកម្មសិទ្ធិចេញច្បាស់លាស់។

៣- ប្រាក់បញ្ញើមានកាលកំណត់ ឬគណនីមានកាលកំណត់ (Term Deposit/Fixed Account)៖ ជាប្រភេទប្រាក់បញ្ញើដែលធនាគារផ្តល់ជម្រើសដ៏ល្អដល់អតិថិជនក្នុងការផ្ញើប្រាក់ ដើម្បីឱ្យទទួលបាននូវអត្រាការប្រាក់ខ្ពស់។ ប្រាក់បញ្ញើនេះមានរយៈពេលផ្សេងគ្នាដូចជា ៣ខែ ៦ខែ ៩ខែ ១២ខែ។ បើកាលវសាន្តនៃប្រាក់បញ្ញើកាន់តែយូរអត្រាការប្រាក់កាន់តែខ្ពស់។ បុគ្គលបើកគណនីមានកាលកំណត់នេះមានក្រុមហ៊ុនរូបវន្តបុគ្គលជាដើម។ ធនាគារចេញវិញ្ញាបនបត្រប្រាក់បញ្ញើ (Certificate Deposit) ជូនអតិថិជន ដើម្បីបញ្ជាក់ពីការផ្ញើប្រាក់នេះ។ វិញ្ញាបនប័ត្រប្រាក់បញ្ញើនេះ ហុចលទ្ធភាពឱ្យអតិថិជនយកទៅដាក់ជាវត្ថុធានាយ៉ាងប្រសើរក្នុងការខ្ចីប្រាក់ ដើម្បីបំពេញនូវតម្រូវការរបស់ខ្លួន។ ប្រសិនបើអតិថិជនមកដកប្រាក់មុនកាលកំណត់នៃការសន្យាផ្ញើប្រាក់ធនាគារធ្វើការពិន័យ តែផ្ទុយទៅវិញ ចំពោះអតិថិជនណាដែលពុំបានដកប្រាក់នៅកាលវសាន្តនៃប្រាក់បញ្ញើរបស់ខ្លួន ធនាគារនឹងគិតការប្រាក់ជូនដល់អតិថិជននោះដោយផ្អែកលើរយៈពេលហួសកំណត់។

### ៦.៦.៣.សេវាប្រាក់កម្ចីធនាគារ (Bank loan services)

មូលហេតុដ៏សំខាន់ក្នុងការបង្កើតធនាគារ គឺឱ្យអតិថិជនខ្ចីប្រាក់។ ភាគច្រើននៃប្រាក់កម្ចីមានចំនួនប្រហែលពាក់កណ្តាល ឬជាងពាក់កណ្តាលនៃទ្រព្យសកម្មសរុប ហើយផ្តល់ប្រាក់ចំណូលប្រហែលពីរភាគបីនៃប្រាក់ចំណូលសរុបរបស់ធនាគារ។ ទោះបីជាយ៉ាងណា ហានិភ័យច្រើនតែកើតឡើងពីប្រតិបត្តិការឥណទាននេះដែរ។ ដូចនេះ ធនាគារគួរតែធ្វើការគ្រប់គ្រងឱ្យបានល្អ។ ឥណទាន គឺជាការផ្តល់ឱ្យ ឬសន្យាផ្តល់ឱ្យនូវមូលនិធិសម្រាប់ជាទុនអាជីវកម្ម ដែលត្រូវសងវិញដោយមានការប្រាក់

ឬការធានាតាមហត្ថលេខា ដើម្បីសងជួសកូនបំណុលចំពោះម្ចាស់បំណុល។ ប្រតិបត្តិការឥណទាន គឺសកម្មភាពមួយដោយគិតកម្រៃដែលបុគ្គលម្នាក់បានដាក់ ឬសន្យាដាក់ទុនឱ្យបុគ្គលម្នាក់ទៀតប្រើប្រាស់ ឬទទួលយកដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ឬដោយមានសន្យាចុះហត្ថលេខា ដូចជាការសន្យាធានាសង ការសងតាមរយៈការលក់វត្ថុធានាជាដើម។ ប្រភេទនៃប្រាក់កម្ចី (Types of Loans) ធនាគារ ឱ្យខ្ចីប្រាក់ច្រើនប្រភេទចំពោះអតិថិជនសម្រាប់គោលបំណងច្រើនប្រភេទ ដូចជាការវិនិយោគ ការទិញរថយន្ត ទិញលំនៅដ្ឋាន សម្រាប់ការសិក្សានៅមហាវិទ្យាល័យ។ ប្រភេទនៃការឱ្យខ្ចីរបស់ធនាគារអាចចាត់ថ្នាក់ដោយផ្អែកទៅតាមគោលបំណងនៃការប្រើប្រាស់ប្រាក់កម្ចីរបស់អតិថិជនដូចជា៖

- ការឱ្យខ្ចីផ្នែកអចលនវត្ថុ (Real estate loans) គឺជាការឱ្យខ្ចីរយៈពេលខ្លីសម្រាប់ការសាងសង់ និងអភិវឌ្ឍដីធ្លី និងការឱ្យខ្ចីរយៈពេលវែង ដើម្បីផ្តល់ទុនសម្រាប់ការទិញដីកសិកម្ម គេហដ្ឋាន សំណង់ពាណិជ្ជកម្ម។
- ការឱ្យខ្ចីចំពោះគ្រឹះស្ថានហិរញ្ញវត្ថុ (Financial Institution Loans) ជាការផ្តល់ឥណទានដល់ធនាគារ ក្រុមហ៊ុនធានារ៉ាប់រង ក្រុមហ៊ុនហិរញ្ញវត្ថុ និងស្ថាប័នហិរញ្ញវត្ថុផ្សេងៗ។
- ការឱ្យខ្ចីផ្នែកពាណិជ្ជកម្ម និងឧស្សាហកម្ម ការឱ្យខ្ចីនេះត្រូវបានផ្តល់ឱ្យក្រុមហ៊ុនជំនួញសម្រាប់ការទូទាត់ការទិញសារពើភ័ណ្ឌ ការបង់ពន្ធ និងសម្រាប់បើកប្រាក់បៀវត្សសម្រាប់ការពង្រីកបន្ថែមនូវអាជីវកម្មរបស់ខ្លួនជាដើម។
- ការឱ្យខ្ចីចំពោះបុគ្គល (Loans to Individual) ជាឥណទានសម្រាប់ការទូទាត់លើការទិញរថយន្ត កែលម្អគេហដ្ឋាន ទូទាត់ថ្លៃថែទាំសុខភាព និងចំណាយផ្ទាល់ខ្លួនផ្សេងៗ។

## ៦.៦.៤.សេវាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (Microfinance institution services)

មីក្រូហិរញ្ញវត្ថុ គឺធនាគារសម្រាប់ជនក្រីក្រមានន័យថាចំនួនឱ្យខ្ចីមានទំហំតូច។ តាមរយៈធនាគារអភិវឌ្ឍន៍ជនបទ ប្រតិបត្តិការមីក្រូហិរញ្ញវត្ថុជាតិ និងអន្តរជាតិបានផ្តល់ជូនសេវាឥណទានគាំទ្រដល់ការអភិវឌ្ឍន៍ជនបទ ដោយឈរលើគោលការណ៍ទីផ្សារសេរី ដើម្បីវឌ្ឍនភាពប្រសិទ្ធភាព និងស្ថិរភាព។ រាជរដ្ឋាភិបាលបានកំណត់ច្បាស់ថាមីក្រូហិរញ្ញវត្ថុ គឺជាយន្តការមួយមិនអាចខ្វះបានក្នុងជួយដល់ការងារអភិវឌ្ឍន៍សហគមកម្ពុជាលើគ្រប់វិស័យ។ ក្នុងនោះការផ្តល់នូវសេវាឥណទានជនបទកំពុងតែមមាញឹក ផ្តល់ទុនជូនប្រជាជនដោយផ្ទាល់នៅទូទាំងប្រទេស។ លើវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាចាប់កំណើតតាំងពីឆ្នាំ ១៩៩២-១៩៩៣។ បច្ចុប្បន្នមានការរីកចម្រើនគួរឱ្យកត់សម្គាល់។

សេវាមីក្រូហិរញ្ញវត្ថុភាគច្រើនសម្រាប់ធនាគារពាណិជ្ជកម្ម បានផ្តល់សេវា និងឥណទាន បានតែទីប្រជុំជន ឬទីក្រុងតែប៉ុណ្ណោះ។ ចំណែកប្រជាជននៅតាមទីជនបទ ពុំអាចមានលទ្ធភាពខ្ចីប្រាក់ពីធនាគារពាណិជ្ជបានឡើយ។ សេវាមីក្រូហិរញ្ញវត្ថុ មានឥណទានទោល ឥណទានជាក្រុម ការសន្សំប្រាក់ ការហ្វឹកហ្វឺន កាចុះតាមដាន និងផ្តល់យោបល់ដល់ប្រជាជនដែលបានខ្ចីប្រាក់។ ការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចែកចេញជាពីរគឺ៖

- ឥណទានទោល៖ ផ្តល់ជូនអតិថិជនជាឯកត្តជន ហើយតម្រូវការឱ្យមានទ្រព្យសម្បត្តិដាក់ធានា ដើម្បីការពារនៅពេលមានការខកខានក្នុងការសងបំណុលត្រឡប់វិញ។ ឥណទានប្រភេទនេះ ត្រូវបានផ្តល់សម្រាប់មុខរបរជំនួញខ្នាតតូច និងមធ្យមពី ១០០ - ៥០០ដុល្លារអាម៉េរិក និងអត្រាការប្រាក់អាស្រ័យលើគោលនយោបាយរបស់ប្រតិបត្តិការនីមួយៗ។
- ឥណទានជាក្រុម ៖ ប្រភេទឥណទានសម្រាប់ប្រជាពលរដ្ឋក្រីក្រ ដែលមានមុខរបរជំនួញ តូចៗ ឬមុខរបរកសិកម្ម ដោយមិនតម្រូវឱ្យមានទ្រព្យសម្បត្តិធានាទេ ប៉ុន្តែអតិថិជនត្រូវចងក្រងគ្នាជាក្រុមពី ៣ ទៅ ១០នាក់ សម្រាប់ធានាគ្នាទៅវិញទៅមក។ ទំហំឥណទានចាប់ពី ២០ ទៅ ១០០ ដុល្លារអាម៉េរិក។ អត្រាការប្រាក់ នៅចន្លោះពី ៣% ទៅ ៥% ក្នុងមួយខែ អាស្រ័យលើគោលនយោបាយរបស់ប្រតិបត្តិការនីមួយៗ។

## ៦.៦.៥.តួនាទីសំខាន់របស់ធនាគារក្នុងសេដ្ឋកិច្ច ( Role of bank for economics )

អន្តរការីរកប្រាក់ចំណេញតាមរយៈភាពខុសគ្នារវាងប្រាក់កម្ចី និងប្រាក់បញ្ញើ។ អន្តរការីបានផ្តល់សេវាកម្ម៤ប្រភេទ ដែលប្រជាជនយល់ព្រមបង់ជូន៖

### ក. ការបង្កើតសាច់ប្រាក់៖

គឺជាទ្រព្យសកម្មសន្ទនីយភាព (ងាយបម្លែងជាសាច់ប្រាក់)។ ទ្រព្យសកម្មនេះ បានមកតាមរយៈអតិថិជនយកមកផ្ញើ ហើយធនាគារប្រើវាជាទុនសម្រាប់ការផ្គត់ផ្គង់រូបិយវត្ថុ។ អន្តរការីធនាគារបង្កើតសាច់ប្រាក់ដោយកម្ចីរយៈពេលខ្លី (ប្រាក់បញ្ញើ) និងផ្តល់កម្ចីរយៈពេលវែង។ កម្ចីរយៈពេលខ្លីមានន័យថា យកប្រាក់បញ្ញើសម្រាប់ដំណើរការចូលត្រៀមខ្លួនជាស្រេច ដើម្បីបង់ជូនអតិថិជនវិញនៅពេលត្រូវការ។ កម្ចីរយៈពេលវែងមានន័យថាអ្នកខ្ចីយកលុយទៅប្រើបានយូរ ដោយគ្រាន់តែបង់ការប្រាក់ប៉ុណ្ណោះជូនកាលរយៈពេលរហូតដល់ ២០-២៥ឆ្នាំ ដូចជាការទិញអគារអាជីវកម្មលំនៅដ្ឋាន។ល។

### ខ. ការបន្ថយចំណាយអប្បបរមានៃការទទួលមូលនិធិ៖

គឺជាមុខងារទី២ដែលអន្តរការីហិរញ្ញវត្ថុត្រូវតែប្រតិបត្តិ។ តាមធម្មតាអ្នកខ្ចីបុលពិតជាលំបាកក្នុងការស្វែងរកកម្ចី ដោយចំណាយពេលវេលា ចំណាយឱកាស ដោយសារតែអន្តរការីធនគារអ្នកមកខ្ចីទទួលបានសេវាកម្មល្អ។ ចំណាយកម្ចីទាប ដោយសារអន្តរការីមានលទ្ធភាពប្រមូលប្រាក់បញ្ញើពីអតិថិជនបានច្រើន ហើយធ្វើការផ្តល់កម្ចី។

### គ. ការបន្ថយចំណាយអប្បបរមានៃការត្រួតពិនិត្យអ្នកខ្ចី៖

គឺជាមុខងាររបស់អន្តរការីរបស់ធនាគារក្នុងការជៀសវាងអ្នកខ្ចីប្រាក់ ដែលមានលទ្ធភាពសងវិញដោយធ្វើយ៉ាងណាប្រើប្រាស់ចំណាយអធិការកិច្ចទាប និងប្រើពេលវេលាតិចបំផុត។

**ឃ. បង្រួមហានិភ័យ៖**

គឺអន្តរការីហិរញ្ញវត្ថុចង់កាត់បន្ថយភាពបាត់បង់ដោយថៃដន្យ។ គេត្រូវកាត់បន្ថយអ្នកខ្ចី ដែលមិនគោរពតាមគោលការណ៍ ព្រោះមិនគ្រាន់តែបាត់បង់ប្រាក់តែប៉ុណ្ណោះទេ។ ប៉ុន្តែថែមទាំងបណ្តាលឱ្យបាត់បង់ជំនឿទុកចិត្តរបស់អ្នកដាក់ប្រាក់បញ្ញើទៀតផង។

និយ័តកម្មធនាគារកណ្តាលប្រើជាមធ្យោបាយគឺ ៖

- ការកំណត់បរិមាណកម្ចីធនាគារ៖

គឺជាការកំណត់របស់ធនាគារកណ្តាល ឬសហព័ន្ធលើការកំណត់លក្ខខណ្ឌ និងទឹកប្រាក់អតិបរមាដែលអតិថិជនអាចឱ្យខ្ចី។ ករណីមួយចំនួនដែលធនាគារកំណត់ចង្អុលទៅលើធនាគារណាដែលខ្ចីបានតាមកម្រិតប្រាក់តម្កល់។ នៅក្នុងពេលចាំបាច់ធនាគារកណ្តាលមានសិទ្ធិផ្អាកអាជីវកម្មបណ្តោះអាសន្នដើម្បីត្រួតពិនិត្យបរិមាណប្រាក់ផ្តល់កម្ចី។

- ការត្រួតពិនិត្យអត្រាការប្រាក់៖

គឺតួនាទីរបស់ធនាគារកណ្តាលនៅក្នុងការត្រួតពិនិត្យអត្រាការប្រាក់បញ្ញើ និងប្រាក់កម្ចី។ ជាទូទៅ ធនាគារកណ្តាលចេញច្បាប់អត្រាការប្រាក់ក្នុងកម្រិតខុសគ្នារវាងកម្ចី និងបញ្ញើ ដើម្បីឱ្យធនាគារពាណិជ្ជទទួលបានផលកម្រៃ។ ប្រសិនបើ ធនាគារណាមួយផ្តល់អត្រាការប្រាក់ខ្ពស់ពេកអាចក្លាយជាធនាគារផ្តាច់មុខ អាចផ្តល់នូវផលវិបាកច្រើនដល់សង្គមសេដ្ឋកិច្ច។

ឧទាហរណ៍៖ ភាគច្រើននៃធនាគារនៅសហរដ្ឋអាម៉េរិកផ្តល់អត្រាការប្រាក់បញ្ញើក្នុងរវាង ៣-៧ ភាគរយ ទន្ទឹមនឹងនេះ កម្រិតអតិផរណា ២-៣ ភាគរយ។ ប្រសិនបើ ធនាគារណាមួយមិនគោរពតាមអត្រាការប្រាក់កំណត់បែបនេះ ដូចជាបង្កើនអត្រាការប្រាក់ខ្ពស់ជាងនេះ នោះតុលាការសភាពាណិជ្ជកម្មនឹងធ្វើការផាកពិន័យ។ សម្រាប់ប្រទេសអូស្ត្រាលីក៏ដូចគ្នាដែរ ហើយប្រតិបត្តិច្បាប់បែបនេះ ដើម្បីធានាការប្រកួតប្រជែងប្រកបដោយសុក្រឹត្យភាព។

ធនាគារកណ្តាលកត់សម្គាល់ថា ប្រសិនបើ គេមិនទប់ស្កាត់ទេអាចឱ្យមានការដួលរលំនៃការវិនិយោគទុន។ ធនាគារតូចៗ និងការបាត់បង់ការងារធ្វើព្រមទាំងផលវិបាកដល់សង្គមដទៃទៀត។ម្យ៉ាងទៀតប្រសិនបើ សេដ្ឋកិច្ចមានការរីកចម្រើនធនាគារទាំងឡាយមិនអាចដំឡើងអត្រាការប្រាក់ ដើម្បីទាក់ទាញអតិថិជនបានទេ។ ព្រោះអតិថិជនដែលផ្ញើប្រាក់ពេលមុនអាចទទួលការខកចិត្ត និងមិនយុត្តិធម៌។

- អត្រាទុនទ្រព្យសាច់ប្រាក់តិចបំផុត៖

គឺជាការកំណត់របស់ធនាគារកណ្តាលទៅលើតម្រូវការបញ្ញើប្រាក់បម្រុងទុក ឬតម្កល់ជារូបិយវត្ថុនៅធនាគារកណ្តាល ឬប័ណ្ណជានា។ ប្រការដែលថាធនាគារកណ្តាល ធ្វើបែបនេះគឺចូលរួមចំណែកដល់ការការពារសំណងអតិថិជនយ៉ាងហោចណាស់ពាក់កណ្តាល។ ប្រសិនបើធនាគារឯកជន ឬធនាគារពាណិជ្ជកម្មណាមួយដួលរលំធនាគារកណ្តាលអាចជួយទប់ស្កាត់ការដួលរលំធនាគារនានាតាមរយៈការផ្តល់កម្ចីបន្ថែម និងកាត់បន្ថយមហិច្ឆិតារបស់ធនាគារពាណិជ្ជកម្ម ដែលផ្តល់កម្ចីដល់ឯកជនច្រើនពេក ឬលួចទៅផ្ញើវិនិយោគក្រៅពីធនាគារ។

# មេរៀនទី៧
# ថ្លៃរបស់ឥណទានអាជីវកម្ម

## ៧.១.វិធីបូកបន្ថែមលើការចំណាយ

ក្នុងការដាក់ថ្លៃឥណទានអ្នកគ្រប់គ្រងធនាគារត្រូវតែពិចារណាលើការចំណាយក្នុងការប្រមូលធនធានសំរាប់ផ្តល់ឥណទាននិងចំណាយប្រតិបត្តិការរបស់ធានាគារទាំងមូល មានន័យថាធនាគារត្រូវតែដឹងពីការចំណាយទាំងអស់របស់ខ្លួនដើម្បីរកប្រាក់ចំណេញឲ្យបានទៀងទាត់និងដាក់ថ្លៃឥណទានរបស់ខ្លួនឲ្យបានត្រឹមត្រូវ។

## ៧.២.គំរូថ្លៃនៃធនាគារធំៗ

ភាពត្រឹមត្រូវរបស់វិធីបូកបន្ថែមលើការចំណាយ គឺការសន្មត់ដែលថា ធនាគារដឹងយ៉ាងពិតប្រាកដពីការចំណាយរបស់ខ្លួន ប៉ុន្តែតាមពិតវាមិនដូចជាការសន្មត់ទេ។ ធនាគារជាឧស្សាហកម្មដែលមានប្រភេទផលិតផលច្រើនដូចឧស្សាហកម្មផ្សេងៗដែរ ធនាគារតែងតែជួបប្រទះនូវការលំបាកធំៗក្នុងការព្យាយាមបែងចែកការចំណាយចំពោះប្រភេទសេវាកម្មផ្សេងៗ។ ជាងនេះទៅទៀត វិធីបូកបន្ថែមលើការចំណាយ មានន័យថា ធនាគារមានការយកចិត្តទុកដាក់តិចតួចទៅលើការប្រកួតប្រជែងពីអ្នកខ្ចីដ៏ទៃទៀត ដែលតាមពិតទៅមិនត្រឹមត្រូវទាល់តែសោះ។ ការប្រកួតប្រជែង និងប៉ះពាល់ទៅដល់គំលាតប្រាក់ចំណេញរបស់ធនាគារ។

ដោយមានភាពអសកម្មបែបនេះ ហើយទើបនាំឲ្យមានគំរូថ្លៃរបស់ធនាគារធំៗ (Price Leadership Model) ដែលមាននៅក្នុងធនាគារដែលជាមជ្ឈមណ្ឌលរូបិយប័ណ្ណជាងកន្លះសតវត្សមកហើយ។ នៅក្នុងកំឡុងពេលវិបត្តិសេដ្ឋកិច្ចធំមួយនៅទសវត្ស 1930 ធនាគារធំៗបានបង្កើតទំរង់រួមមួយផ្អែកទៅលើកំរៃឲ្យខ្ចីដែលត្រូវបានគេស្គាល់ថាជាអត្រាមូលដ្ឋាន (Prime Rate) ជាអត្រាដែលទាបបំផុតដែលគេយកមកពីអតិថិជនដែលមានការជឿជាក់ខ្ពស់បំផុតលើឥណទានទុនបង្វិល។ អត្រាឥណទានត្រូវបានគេកំណត់ដូចខាងក្រោម ៖

**បន្ថែម**

↓

អត្រាការប្រាក់ឥណទាន = អត្រាបន្ថែមលើអត្រាមូលដ្ឋាន (រួមមាន គំលាតហានិភ័យខូចខាត ប្រាក់ចំណេញនិងការចំណាយទាំងអស់) +អត្រាបន្ថែមលើហានិភ័យរយៈពេលដែលត្រូវសងដោយអ្នកខ្ចីរយៈពេលវែង

### ៧.២.១.ការបូកបន្ថែមដោយផ្អែកលើអត្រារបស់ទីផ្សារប្រាក់ (Below-Prime Market Pricing)

ការផ្លាស់ប្តូរបន្ថែមទៀតទៅលើអត្រាមូលដ្ឋាន ឬអត្រា LIBOR ដែលជាមូលធន ចំពោះការដាក់ថ្លៃឥណទានត្រូវបានគេធ្វើនូវទសវត្ស 80 និង 90 ដោយធនាគារធំៗ ធ្វើការប្រកួតប្រជែងយ៉ាងសកម្ម

ជាមួយនឹងការកើនឡើងនៃទីផ្សារមូលប័ត្ររយៈពេលខ្លី ហើយធនាគារបរទេសបានផ្តល់ឥណទានដែលមានថ្លៃជិតស្មើនឹងការចំណាយទៅលើការគៀងគរមូលធន។

អត្រាការប្រាក់ឥណទាន = ចំណាយការប្រាក់នៃការខ្ចីក្នុងទីផ្សារប្រាក់+អត្រាបន្ថែមសំរាប់ហានិភ័យនិងប្រាក់ចំណេញ

### ៧.២.២.ឥណទានដែលមានអត្រាអតិបរមា (Caps)

អត្រាការប្រាក់ផ្សេងមួយទៀតពី Cap Rate គឺជាអត្រាខ្ពស់បំផុតដែលមានព្រមព្រៀងចំពោះអត្រាឥណទាន ដោយមិនគិតពីការប្រែប្រួលនៃអត្រាទីផ្សារទៅអនាគត។ ដូច្នេះ អតិថិជនម្នាក់អាចត្រូវផ្តល់នូវឥណទានដែលមានអត្រាមូលដ្ឋានបូក 2% ជាមួយនឹង Cap 5% បន្ថែមលើអត្រាឥណទានដំបូង។ មានន័យថា បើឥណទានត្រូវបានគេផ្តល់ឲ្យនៅពេលដែលអត្រាមូលដ្ឋាន 10% ដូច្នេះអត្រាដំបូងគឺ 10% + 2% (12%) ប៉ុន្តែអត្រានេះអាចកើនរហូតដល់ 17% (12% + 5%) ដោយមិនទាក់ទងទៅនឹងការកើនឡើងរបស់ទីផ្សារក្នុងជីវិតរបស់ឥណទាននេះ។

Cap គឺជាសេវាកម្មដោយឡែកមួយទៀត ដែលធនាគារផ្តល់ឲ្យទៅអតិថិជនរបស់ខ្លួន ដោយយកកំរៃជាក់លាក់។ អត្រាឥណទាន Cap ផ្តល់ឲ្យអតិថិជននូវការធានាពីការចំណាយធំបំផុត ដែលគេអាចជួបប្រទះ ពីព្រោះគ្រប់ការសងការប្រាក់លើសពី Cap នឹងត្រូវបាន គេសងទៅឲ្យអ្នកខ្ចីវិញជាធម្មតាមួយឆ្នាំម្តង ឬនៅពេលដែលឥណទានគ្រប់អាយុ។ ប៉ុន្តែធនាគារត្រូវតែប្រុងប្រយ័ត្នក្នុងការភ្ជាប់ Cap ជាមួយនឹងឥណទានរបស់ខ្លួនរយៈពេលវែងនៃអត្រាការប្រាក់ខ្ពស់នឹងបញ្ជូនហានិភ័យនៃការឡើងចុះការប្រាក់ពីអ្នកខ្ចីទៅអ្នកឲ្យខ្ចី។

### ៧.២.៣. ការដាក់ថ្លៃឥណទានផ្អែកលើការចំណាយ និងផលប្រយោជន៍ (Cost-Benefit Loan Pricing)

ថ្មីៗនេះធនាគារជាច្រើនបានចង្កើតប្រព័ន្ធនៃការដាក់ថ្លៃឥណទានដ៏ទំនើបមួយ ដែលបង្ហាញថាតើ ធនាគារបានយកកំរៃសមល្មមហើយឬនៅ ចំពោះឥណទានដើម្បីទូទាត់ទៅលើការចំណាយ និងហានិភ័យ។ ប្រព័ន្ធបែបនេះហៅថា ការដាក់ថ្លៃឥណទានផ្អែកលើការចំណាយ និងផលប្រយោជន៍ ដែលមានជំហានងាយៗបី ៖

1) ព្យាករណ៍ពីចំណូលសរុបទាំងអស់ បង្កើតដោយឥណទានផ្សេងៗគ្នា ដែលមានការប្រាក់ និងកំរៃខុសៗគ្នា
2) ព្យាករណ៍ពីមូលធនដែលត្រូវឲ្យខ្ចីទាំងអស់ដែលធនាគារនឹងប្រគល់ឲ្យអ្នកខ្ចី
3) ព្យាករណ៍ទិន្នផល មុនពេលបង់ពន្ធដោយយកចំណូលពីឥណទានទាំងអស់ចែកនឹងចំនួនមូលធនដែលត្រូវឲ្យខ្ចី។

# មេរៀនទី៨
# ប្រព័ន្ធទូទាត់ និងការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិចនៅក្នុងឧស្សាហកម្មធនាគារ

## ៨.១.សេចក្តីផ្តើម

ប្រព័ន្ធទូទាត់អេឡិចត្រូនិក ត្រូវបានគេដាក់ឲ្យប្រើប្រាស់តាំងពីឆ្នាំ ១៩៦០។ ប្រព័ន្ធនេះមានការរីកលូតលាស់យ៉ាងឆាប់រហ័ស។ ក្នុងប្រទេសឧស្សាហកម្មធំៗ បរិមាណសាច់ប្រាក់ប្រតិបត្តិការ និងចំនួនប្រតិបត្តិការដែលត្រូវបានគេទូទាត់តាមប្រព័ន្ធទូទាត់អេឡិចត្រូនិកហើយចំនួនប្រតិបត្តិការត្រូវបានគេទូទាត់អេឡិចត្រូនិកមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ ប្រហែលជា 85-90% នៃចំនួនទឹកប្រាក់ត្រូវបានទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក ហើយចំនួនប្រតិបត្តិការត្រូវបានគេទូទាត់តាមប្រព័ន្ធនេះមានត្រឹមតែ 5-10% តែប៉ុណ្ណោះ។ ភាពមិនសមាមាត្រគ្នាបណ្តាលមកពីកត្តា 4 ៖

1. ខ្សែបណ្តាញធំជិតស្និទ្ធមួយត្រូវបានបង្កើតឡើងដោយសារធនាគារ ដើម្បីការទូទាត់ចំនួនទឹកប្រាក់ធំៗដែលមានលក្ខណៈជាអន្តរជាតិ
2. ចំនួនទឹកប្រាក់នៃការទូទាត់មានទំនាក់ទំនងខ្លាំងឡើងជាមួយ ការប្តូរប្រាក់បរទេស និងប្រតិបត្តិការមូលប័ត្រពិភពលោក
3. ប្រព័ន្ធទូទាត់ដែលមានតម្លៃខ្ពស់ មិនត្រូវបានគេរៀបចំសំរាប់ការទូទាត់ប្រតិបត្តិការដែលមានទឹកប្រាក់តិចតួចឡើយព្រោះប្រសិទ្ធភាពសេដ្ឋកិច្ចវានៅមានកំរិត
4. ប្រព័ន្ធទូទាត់មិនស្វ័យប្រវត្តិនៅតែជាផ្នែកមួយនៃការអនុវត្តន៍ ដែលអាចទទួលយកបាន ដូច្នេះហើយវានៅតែមានសារៈសំខាន់ក្នុងប្រព័ន្ធសេដ្ឋកិច្ច។

Internet កំពុងតែមានការលូតលាស់ខ្លាំង ដែលលំពុងត្រូវបានជំរុញដោយអ្នកប្រើប្រាស់ជាពាណិជ្ជករ ក្រុមហ៊ុនដែលផ្តល់សេវាកម្ម on-Line កំពុងតែពង្រីកយ៉ាងឆាប់រហ័សដូចជា CompuServe. America On-Line និង Prodigy។ Internet និងប្រព័ន្ធ Online Network របស់ពិភពលោកត្រូវបានគេបង្កើតនូវឱកាសពាណិជ្ជកម្មថ្មី សំរាប់ប្រព័ន្ធ Network ពាណិជ្ជកម្ម។ ប៉ុន្តែការអភិវឌ្ឍន៍មកទល់បច្ចុប្បន្នត្រូវបានរាំងដោយការខ្វះខាតនៃហេដ្ឋារចនាសម្ព័ន្ធទូទាត់។ Internet កំពុងតែមានការលូតលាស់ខ្លាំង ដែលលំពុងត្រូវបានជំរុញដោយអ្នកប្រើប្រាស់ជាពាណិជ្ជករ ក្រុមហ៊ុនដែលផ្តល់សេវាកម្ម on-Line កំពុងតែពង្រីកយ៉ាងឆាប់រហ័សដូចជា CompuServe. America On-Line និង Prodigy។ Internet និងប្រព័ន្ធ Online Network របស់ពិភពលោកត្រូវបានគេបង្កើតនូវឱកាសពាណិជ្ជកម្មថ្មី សំរាប់ប្រព័ន្ធ Network ពាណិជ្ជកម្ម។ ប៉ុន្តែការអភិវឌ្ឍន៍មកទល់បច្ចុប្បន្នត្រូវបានរាំងដោយការខ្វះខាតនៃហេដ្ឋារចនាសម្ព័ន្ធទូទាត់។

## ៨.២.សេវាកម្មដែលផ្តល់ឲ្យតាម Internet

សេវាកម្មនេះរួមមានការទូទាត់ (ជាពិសេសការទូទាត់ទឹក និងភ្លើង) ការផ្ទេរសមតុល្យរបស់គណនី ការចរាចរមូលធនពីគណនីមួយទៅគណនីមួយ ហើយអាចប្រើប្រាស់ពាក្យសុំឥណទាន ប្រាក់បញ្ញើរ និងសេវាកម្មផ្សេងៗទៀត។ បច្ចុប្បន្នធនាគារភាគច្រើនប្រើប្រាស់ Internet សំរាប់ផ្សាយពាណិជ្ជកម្មជាជាងផ្តល់សេវាកម្ម។ ប៉ុន្តែវាកំពុងមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ពីព្រោះចំនួន Computer នៅតាមផ្ទះកំពុងតែកើនឡើងហើយចំនួនអ្នកប្រើប្រាស់ Internet កើនឡើងដល់រាប់លាន។ ថ្មីៗនេះក្រុមហ៊ុន Visa និង ក្រុមហ៊ុន Yahoo បានប្រកាសពីអាជីវកម្មចំរុះរបស់ពួកគេ ដើម្បីបង្កើនការលក់ Credit Card ទៅតាម Internet។

អត្ថប្រយោជន៍ Net គឺជាប្រភពពត៌មាន និងការផ្តល់សេវាកម្មដែលមានតំលៃទាប។

- ការបង្កើត និងថែរក្សា Web Site គឺថោកសមរម្យ
- ប្រើប្រាស់ Net អតិថិជនរកធនាគារ ជាជាងធនាគាររកអតិថិជន
- ការប្រើប្រាស់របស់អតិថិជនអាចវាស់វែងបាន ដោយអាចទទួលបាននូវមតិរបស់អតិថិជនទៅលើគុណភាព សេវាកម្ម ថ្លៃ និងបញ្ហាផ្សេងៗ។

គុណវិបត្តិ

បញ្ហាដែលលំបាក គឺការការពារភាពឯកជនរបស់អតិថិជន និងការទប់ស្កាត់បទល្មើស (ដូចជាការភ្ជាប់ជាឯកជន ការបំបែកប្រតិបត្តិការទៅជាផ្នែកតូចៗ ប្រើប្រាស់ទិន្នន័យដែលជាលេខកូដ ដូច្នេះជនល្មើសពិបាកចូលទៅក្នុងប្រព័ន្ធនេះបាន)។

## ៨.៣.លទ្ធភាពប្រើ Internet ដោយធនាគារ

ធនាគារអាចប្រើប្រាស់ប្រព័ន្ធ Internet សំរាប់ផ្សាយពាណិជ្ជកម្មធ្វើការស្ទង់មតិពីអតិថិជនផ្តល់ពត៌មានលំអិតដល់អតិថិជនពីធនាគារ ពិនិត្យមើលប្រតិបត្តិការជំនួសអតិថិជន និងដំណើរការអាជីវកម្ម 24 ម៉ោងក្នុងមួយថ្ងៃផ្តល់នូវសេវារហ័សទាន់ចិត្ត ធ្វើការសន្ទនារវាងអតិថិជន និងធនាគារដើម្បីធ្វើឲ្យប្រសើរនូវសេវាកម្មធនាគារពីព្រោះ Net ងាយស្រួលក្នុងការប្រមូលការតវ៉ារបស់អតិថិជន និងការវាយតំលៃរបស់អតិថិជន ចំពោះសេវាកម្មធនាគារ។ ធនាគារអាចប្រើប្រាស់ប្រព័ន្ធ Internet សំរាប់ផ្សាយពាណិជ្ជកម្មធ្វើការស្ទង់មតិពីអតិថិជនផ្តល់ពត៌មានលំអិតដល់អតិថិជនពីធនាគារ ពិនិត្យមើលប្រតិបត្តិការជំនួសអតិថិជន និងដំណើរការអាជីវកម្ម 24 ម៉ោងក្នុងមួយថ្ងៃផ្តល់នូវសេវារហ័សទាន់ចិត្ត ធ្វើការសន្ទនារវាងអតិថិជន និងធនាគារដើម្បីធ្វើឲ្យប្រសើរនូវសេវាកម្មធនាគារពីព្រោះ Net ងាយស្រួលក្នុងការប្រមូលការតវ៉ារបស់អតិថិជន និងការវាយតំលៃរបស់អតិថិជន ចំពោះសេវាកម្មធនាគារ។

# មេរៀនទី៩
# ទីផ្សារមូលបត្រ
# Securities Markets

## ៩.១.ទិដ្ឋភាពទូទៅនៃទីផ្សារមូលបត្រ ( An Overview of Securities Markets )

វិស័យមូលបត្រជាផ្នែកយ៉ាងសំខាន់មួយក្នុងប្រព័ន្ធហិរញ្ញវត្ថុជាតិ តាមរយៈការផ្តល់យន្តការសម្រាប់គៀគរប្រភពហិរញ្ញវត្ថុ ( Mechanism for Mobilizing all Sorts of Financial Resources ) ផ្សេងៗទាំងខ្នាតតូច និងមធ្យម ព្រមទាំងរយៈពេលខ្លី មធ្យម និងវែងដើម្បីធ្វើហិរញ្ញប្បទាន ( Financing ) គម្រោងវិនិយោគនានា និងធ្វើឲ្យមានភាពសម្បូរបែបនៃប្រភពធនធានក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចឲ្យមានកំណើនខ្ពស់។ វត្តមាននៃទីផ្សារមូលបត្រនឹងផ្តល់ជម្រើសវិនិយោគថ្មីមួយបន្ថែមទៀតសម្រាប់ការវិនិយោគលើវិស័យហិរញ្ញវត្ថុ ក្រៅពីការដាក់ប្រាក់បញ្ញើនៅធនាគារ និងប្រើប្រាស់សាច់ប្រាក់មានប្រសិទ្ធិភាពខ្ពស់។

ទីផ្សារមូលបត្រទាំងមូលអាចដំណើរការទៅបានដោយស្ថិតក្រោមច្បាប់ និងបទប្បញ្ញត្តិនានាដែលរៀបចំ និងអនុម័តដោយអាជ្ញាធរមូលបត្រនៃប្រទេសនីមួយៗ។ ជាទូទៅ ច្បាប់ និងបទប្បញ្ញត្តិនានានៅក្នុងវិស័យមូលបត្រ គឺមានគោលបំណងជួយការពារវិនិយោគិនទាំងអស់ដោយធានាថាប្រព័ន្ធទីផ្សារមូលបត្រទាំងមូលមានភាពត្រឹមត្រូវមានប្រសិទ្ធភាព និងយន្តការគ្រប់គ្រងហានិភ័យ ព្រមទាំងជម្រុញឲ្យមានតម្លាភាព និងគណនេយ្យភាពនៃរបាយការណ៍ហិរញ្ញវត្ថុ និងអភិបាលកិច្ចសាជីវកម្មក្នុងក្រុមហ៊ុន សហគ្រាស។ រាល់ប្រតិបត្តិការទាំងអស់ដែលពាក់ព័ន្ធនៅក្នុងវិស័យមូលបត្រទាំងមូល គឺត្រូវស្ថិតក្រោមបទប្បញ្ញត្តិយ៉ាងពិសេស ដោយតម្រូវឲ្យមានការដាក់បង្ហាញព័ត៌មាននានាជាសាធារណៈ និងមិនមានលក្ខណៈក្លែងបន្លំណាមួយដែលខុសពីច្បាប់ និងបទប្បញ្ញត្តិនានានៃទីផ្សារមូលបត្រ។ ច្បាប់ និងបទប្បញ្ញត្តិមូលបត្រត្រូវបានគេប្រើប្រាស់ដើម្បីគ្រប់គ្រងរាល់ព័ត៌មានទាំងឡាយនៅលើទីផ្សារព្រមទាំងដំណើរការនានាក្នុងការទិញ លក់មូលបត្រ (ដែលគេស្គាល់ថាជាការជួញដូរមូលបត្រ)។ ការធ្វើដូច្នេះ គឺធ្វើឲ្យវិនិយោគិនម្នាក់ៗអាចទទួលបានព័ត៌មានដូចគ្នា នៅក្នុងពេលតែមួយ ហើយមានឱកាសដូចគ្នាក្នុងការជួញដូរមូលបត្រនៅលើទីផ្សារមូលបត្រ ពោលគឺទទួលបានកម្រិតប្រកួតប្រជែងស្មើគ្នា (Level-playing-field)។ កម្រិតប្រកួតប្រជែងស្មើភាពគ្នានេះ គឺជាកត្តាសំខាន់មួយដែលធ្វើឲ្យវិនិយោគិនទាំងអស់មានទំនុកចិត្តទៅលើទីផ្សារមូលបត្រទាំងមូល។ ដើម្បីទទួលបានកម្រិតប្រជែងស្មើគ្នាមួយគឺតម្រូវឲ្យមានការផ្សព្វផ្សាយនូវរាល់ព្រឹត្តិការណ៍សំខាន់ៗទាំងឡាយ (All Material Facts) នៃក្រុមហ៊ុនបោះផ្សាយលក់មូលបត្រនិមួយៗឲ្យបានទូលំទូលាយ ព្រមទាំងទទួលបានព័ត៌មានដែលផ្សព្វផ្សាយនោះដោយស្មើគ្នាចំពោះវិនិយោគិនទាំងអស់ (រួមទាំងវិនិយោគិនមានសក្តានុពលផងដែរ)។ ច្បាប់ និងបទប្បញ្ញត្តិទាំងអស់ក៏ត្រូវកំណត់ និងតាមដានផងដែរពីអាកប្បកិរិយាអ្នកចូលរួមនៅក្នុងទីផ្សារទាំងអស់ ព្រមទាំងដាការផាកពិន័យនានាចំពោះទង្វើទាំងឡាយដែលរំលោភសេចក្តីទុកចិត្តនៅលើទីផ្សារមូលបត្រ និងនិយាមទីផ្សារ (Standard) ដែលបានកំណត់ទុកជាមុខសម្រាប់ការចុះបញ្ជី

(Registration) នៃក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ (Securities Issuers) អន្តរការីមូលបត្រ (Securities Intermediaries) និងមូលបត្របោះផ្សាយទាំងអស់ (Securities)។

## ៩.២.គោលការណ៍សំខាន់ៗនៃច្បាប់ និងបទប្បញ្ញត្តិមូលបត្រ (Principles of Securities Regulations)

ដោយសារមូលបត្រទាំងអស់ត្រូវបានបោះផ្សាយដោយគ្មានកម្រិតចំនួនសន្លឹកមូលបត្រជាក់លាក់ ហើយចំណាយតិចបំផុតក្នុងការបោះផ្សាយមូលបត្រ ព្រោះថាមូលបត្រទាំងអស់មិនមានកម្រិតតំលៃជាក់លាក់ណាមួយនៅលើសន្លឹកមូលបត្រនិមួយៗជាសកល គឺគ្រាន់តែជាតម្លៃតំណាងជាផលប្រយោជន៍ (Interest) នៅក្នុងក្រុមហ៊ុន ឬស្ថាប័នមួយបានបោះផ្សាយមូលបត្រ។ ដូច្នេះហើយ <u>គោលការណ៍សំខាន់ទីមួយ</u> ដែលនិយ័តការមូលបត្រត្រូវយកចិត្តទុកដាក់ គឺជានាថានៅពេលដែលមូលបត្រមួយត្រូវបានបោះផ្សាយ និងដាក់លក់ដល់សាធារណជន វិនិយោគិនទាំងអស់ត្រូវមានការយល់ដឹងឲ្យច្បាស់ថា អ្វីទៅដែលក្រុមហ៊ុន ឬស្ថាប័ននោះមាន ហើយទទួលបានផលប្រយោជន៍ប៉ុន្មាននៅក្នុងមូលបត្រដែលមាន តម្លៃតំណាងទាំងនោះ។

ជាទូទៅ មូលបត្រទាំងអស់មិនត្រូវបានយកមកប្រើប្រាស់ដោយអ្នកទិញមូលបត្រដូចទំនិញនោះទេ ផ្ទុយមកវិញ មូលបត្រ គឺជាប្រភេទរូបិយបណ្ណ (Currency) ដែលត្រូវបានជួញដូរនៅក្នុងទីផ្សារបន្ទាប់ (Secondary Market) ក្នុងតម្លៃប្រែប្រួលមួយ។ សកម្មភាពជួញដូរនៅក្នុងទីផ្សារបន្ទាប់នេះមានចំនួនច្រើនទាំងទំហំ និងបរិមាណ (Number and volume) នៃមូលបត្រដែលបានបោះផ្សាយលក់ថ្មីជាច្រើននៅលើទីផ្សារ។ ដូច្នេះហើយ <u>គោលការណ៍សំខាន់ទីពីរ</u> ដែលនិយ័តករមូលបត្រត្រូវយកចិត្តទុកដាក់គឺត្រូវជានាថា មានលំហូរព័ត៌មានជាប្រចាំ (បន្តបន្ទាប់) អំពីសាជីវកម្ម ឬអង្គភាពនានាដែលមូលបត្ររបស់ពួកគេត្រូវបានការឲ្យជួញដូរនៅលើទីផ្សារ។

ឯកសារផ្តល់ព័ត៌មានបន្ថែម (Additional Disclosure) គឺតម្រូវឲ្យមាន នៅពេលដែលអ្នកកាន់កាប់មូលបត្រត្រូវធ្វើការបោះឆ្នោត ឬក៏ធ្វើការសម្រេចចិត្តនានាដែលពាក់ព័ន្ធទៅនឹងមូលបត្រដែលខ្លួនកាន់កាប់។ វាជាការទទួលខុសត្រូវរបស់ក្រុមហ៊ុនបោះផ្សាយក្នុងការផ្សព្វផ្សាយដោយផ្អែកលើប្រព័ន្ធនិយ័តកម្ម (Regulatory System) ដើម្បីរក្សាឲ្យបច្ចុប្បន្នភាពនៃរាល់ព័ត៌មានពាក់ពន្ធទាំងអស់ព្រមទាំងព័ត៌មានថ្មីៗ ដែលអាចផ្អែកមួយនៃការសម្រេចចិត្តរបស់វិនិយោគិនក្នុងការជួញដូរមូលបត្រ។

ដោយសារឧស្សាហកម្មមូលបត្រ (Securities industry) ផ្តល់កំណើនខ្ពស់ក្នុងការទិញ លក់មូលបត្រដល់វិនិយោគិន និងអ្នកជួញដូរមូលបត្រ ច្បាប់ និងបទប្បញ្ញត្តិមូលបត្រត្រូវគ្រប់គ្រងលើបុគ្គលនិងក្រុមហ៊ុនទាំងឡាយណាដែលពាក់ព័ន្ធនិងការជួញដូរមូលបត្រ ព្រមទាំងបទប្បញ្ញត្តិសម្រាប់មូលបត្រដែលបោះផ្សាយលក់ផងដែរ។ ក្នុងន័យនេះ <u>គោលការណ៍សំខាន់ទីបី</u> ដែលនិយ័តករ មូលបត្រត្រូវយកចិត្តការមូលបត្រតាមរយៈបទពិសោធន៍ជ្រៅជ្រះដែលខ្លួនមាន ព្រមទាំងព័ត៌មាននានាដែលទទួលបានពីអតិថិជនរបស់ខ្លួនក្នុងពេលដែលកម្រិតចំណេះដឹងក្នុងវិស័យមូលបត្ររបស់គាត់នៅមានកម្រិត។

ដោយសារការជួញដូរមូលបត្រនៅលើទីផ្សារ ងាយទទួលរងពីការប្រើឧបាយកលនៅលើទីផ្សារ (Market Manipulation) និងការបោកបញ្ឆោតនានា ដែលការណ៍នេះតម្រូវឲ្យនិយ័តករមូលបត្រត្រូវយកចិត្តទុកដាក់ គោលការណ៍សំខាន់ទីបួន គឺការរៀបចំច្បាប់ និងបទប្បញ្ញត្តិដើម្បីប្រយុទ្ធប្រឆាំងក្លែងបន្លំនានានៅលើទីផ្សារមូលបត្រ។

ជាការពិតច្បាប់ និងបទប្បញ្ញទាំងអស់ គឺមិនត្រឹមតែយកទៅអនុវត្តចំពោះការប្រើឧបាយកលនៅលើទីផ្សារដែលធ្វើឲ្យតម្លៃនៃមូលបត្រ ឬសន្លឹកហ៊ុនប្រែប្រួលប៉ុណ្ណោះទេ ប៉ុន្តែត្រូវទប់ស្កាត់ផងដែរការជួញដូរសន្លឹកហ៊ុនទាំងឡាយណា ដែលប្រើប្រាស់ព័ត៌មានផ្ទៃក្នុងដែលមិនបានផ្សព្វផ្សាយជាសាធារណៈ ឬក៏ធ្វើសេចក្ដីថ្លែងការណ៍មិនត្រឹមត្រូវនានា ដែលធ្វើឡើងដោយគណៈគ្រប់គ្រងរបស់ក្រុមហ៊ុនបោះផ្សាយ ឬក៏ស្ថាប័នពាក់ព័ន្ធដទៃទៀតក្នុងការបំភ័ន្តសាធារណជន ឬវិនិយោគីនក្នុងវិស័យមូលបត្រឲ្យមានការយល់ខុស។

ជាមួយគ្នានេះដែរ ច្បាប់ និងបទប្បញ្ញត្តិមូលបត្រត្រូវចែងលម្អិតពីប្រភេទនានានៃទណ្ឌកម្មរបស់និយ័តករមូលបត្រនៃប្រទេសមួយ ប្រឆាំងនឹងជនទាំងឡាយណា ដែលរំលោភនិងការហាមឃាត់នានាដោយច្បាប់ដែលបានដាក់ចេញ ព្រមទាំងចែងពីសំណងរដ្ឋប្បវេណី (Civil Liability) ចំពោះជនទាំងឡាយណា ដែលទទួលរងផលប៉ះពាល់ដោយសកម្មភាពរំលោភបំពានច្បាប់ទាំងនោះ។ លើសពីនេះទៀត តុលាការអាចបង្កើនចំនួននៃសំណងរដ្ឋប្បវេណីដែលមានចែងដោយច្បាប់ និងបទប្បញ្ញត្តិនៅក្នុងខណៈពេលដែលជនល្មើសមិនរាងចាល ឬក៏ក្នុងករណីប្រព្រឹត្តិបទល្មើសធ្ងន់ធ្ងរ។

## ៩.២.១.ប្រភេទនៃបទប្បញ្ញត្តិមូលបត្រ :

ជាគោលការណ៍ មានប្រភេទបទប្បញ្ញត្តិមូលបត្រចំនួនពីរ ដែលគេនិយមអនុវត្តនៅលើទីផ្សារមូលបត្រគឺ :

១. បទប្បញ្ញត្តិដោយផ្អែកលើការវាយតម្លៃព័ត៌មានជាមូលដ្ឋាន (MERIT-BASED REGULATION)

២. បទប្បញ្ញត្តិដោយផ្អែកលើការបង្ហាញព័ត៌មានជាមូលដ្ឋាន (DISCLOSURE-BASED REGULATION)

### ក. បទប្បញ្ញត្តិដោយផ្អែកលើការវាយតម្លៃព័ត៌មានជាមូលដ្ឋាន (MERIT-BASED REGULATION)

គឺនិយ័តករមូលបត្ររបស់រដ្ឋាភិបាលមានអំណាចឆន្ទានុសិទ្ធិ (Discretion) ក្នុងការអនុម័ត ឬមិនអនុម័តលើបែបបទនានា និងដាក់លក្ខខណ្ឌផ្សេងៗនៅពេលដែលនិយ័តករមូលបត្រយល់ថាមានភាពចាំបាច់ក្នុងការដាក់ចេញ។ លើសពីនេះ និយ័តករមានអំណាចបដិសេធរាល់បញ្ហាទាំងឡាយណាដែលខ្លួនយល់ថាមិនបម្រើផលប្រយោជន៍របស់ក្រុមហ៊ុន ឬសាធារណជន រួមទាំងលទ្ធភាពរបស់និយ័តករមូលបត្រ ក្នុងការកំណត់ថាតើការកំណត់តម្លៃភាគហ៊ុន ឬយ៉ាងណា។ និយ័តករមូលបត្រអាចមាន

លក្ខណៈសមស្របទៅតាមស្ថានភាពរបស់ក្រុមហ៊ុន ឬយ៉ាងណា។ និយ័តករមូលបត្រអាចមានសិទ្ធិពិនិត្យលើកម្រិតនៃប្រាក់ចំណូលរបស់ក្រុមហ៊ុនដែរ។

## ខ. បទប្បញ្ញត្តិដោយផ្អែកលើការបង្ហាញព័ត៌មានជាមូលដ្ឋាន (DISCLOSURE-BASED REGULATION)

គឺនិយ័តករមូលបត្រ ពុំមានសិទ្ធិក្នុងការកំណត់ពីតម្លៃ នៃបែបបទស្នើសុំសម្រាប់ចុះបញ្ជីរបស់ក្រុមហ៊ុនបោះផ្សាយនោះឡើយ ពោលគឺនិយ័តករមូលបត្រពាក់ព័ន្ធតែចំនុច ថាតើបែបបទស្នើសុំចុះបញ្ជីបានបំពេញតាមលក្ខខណ្ឌតម្រូវចាំបាច់ដែរឬទេ? តាមរយៈការបង្ហាញ ឬផ្សព្វផ្សាយព័ត៌មានចាំបាច់នានា។ គោលបំណងក្នុងការតម្រូវឲ្យមានការដាក់បង្ហាញព័ត៌មាន (Disclosure) គឺជាការភ្ជាប់ការទទួលខុសត្រូវក្នុងការទប់ស្កាត់អំពើល្មើសនានាដែលតាមរយៈការបង្ហាញព័ត៌មានពេញលេញ និងត្រឹមត្រូវនឹងផ្តល់ឲ្យវិនិយោគិនក្នុងវិស័យមូលបត្រ ព្រមទាំងទីផ្សារមូលបត្រទាំងជួយជម្រុញឲ្យទីផ្សារមូលធនកាន់តែមានភាពរស់រវើក។

គោលការណ៍នាំនៅក្នុងបទប្បញ្ញត្តិដោយផ្អែកលើការបង្ហាញជាមូលដ្ឋាន គឺមានន័យថា ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ (Issuers) ទទួលខុសត្រូវក្នុងការផ្តល់ព័ត៌មានជាក់លាក់ និងពេញលេញពាក់ព័ន្ធទៅនឹងកិច្ចការជំនួញរបស់ក្រុមហ៊ុន ព័ត៌មានហិរញ្ញវត្ថុ ទិសដៅអនាគត (Future Prospects) របស់ក្រុមហ៊ុន ព្រមទាំងលក្ខខណ្ឌនៃសំណើរលក់មូលបត្រ (Offering)។ ធ្វើដូច្នេះ អាចជួយឲ្យវិនិយោគិនម្នាក់ៗមានព័ត៌មានគ្រប់គ្រាន់ និងដូចៗគ្នាក្នុងពេលតែមួយក្នុងការធ្វើជា មូលដ្ឋានក្នុងការសម្រេចចិត្តវិនិយោគ។ ចំនុចសំខាន់ពិសេសនៅក្នុងបទប្បញ្ញត្តិនៃការដាក់បង្ហាញព័ត៌មាន គឺជាការទទួលខុសត្រូវមួយរបស់ក្រុមហ៊ុនក្នុងការដាក់បង្ហាញព័ត៌មាននានានិង ហានិភ័យ (Risks) ទាំងឡាយដែលពាក់ព័ន្ធដល់ក្រុមហ៊ុនបោះផ្សាយ ឬក៏សំណើរលក់មូលបត្ររបស់ខ្លួន។ លើសពីនេះទៀត ប្រព័ន្ធដាក់បង្ហាញព័ត៌មានតម្រូវឲ្យក្រុមហ៊ុនបោះផ្សាយផ្តល់ព័ត៌មានពាក់ព័ន្ធនានាជាបន្តបន្ទាប់នៅពេលដែលខ្លួនមាន ឬផ្លាស់ប្តូរព័ត៌មានណាមួយដែលខ្លួនបានដាក់បង្ហាញរួចហើយ។

ក្នុងន័យនេះ បទប្បញ្ញត្តិនៃការដាក់បង្ហាញព័ត៌មាន មិនត្រឹមតែទុកដាក់ថាតើការលក់មូលបត្រគឺបម្រើផលប្រយោជន៍ដល់ក្រុមហ៊ុនបោះផ្សាយ និងសាធារណជនប៉ុណ្ណោះទេគឺត្រូវយកចិត្តទុកដាក់ផងដែរទៅលើនិយម (Standards) ទាំងឡាយដែលតម្រូវឲ្យមានការដាក់បង្ហាញព័ត៌មានយ៉ាងពេញលេញ។ និយ័តករមិនត្រឹមតែអនុម័ត (Approved) ទៅលើការវាយតម្លៃនៃការវិនិយោគនោះទេ ពោលគឺត្រូវតាមដានយ៉ាងម៉ឺងម៉ាត់អំពីការគោរពតាមលក្ខខណ្ឌតម្រូវនៃការដាក់បង្ហាញព័ត៌មានរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ដូចមានចែងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិផងដែរ។

ស្ថិតនៅក្រោមប្រព័ន្ធនៃការដាក់បង្ហាញមួយនេះ វិនិយោគិនដែលជាអ្នកពិចារណាថាតើការវិនិយោគទិញមូលបត្រមានផលចំណេញឬទេ? ដោយផ្អែកលើសមត្ថភាពរយៈព័ត៌មានផ្ទាល់របស់គាត់ម្នាក់ៗ អំពីហានិភ័យនានាទល់នឹងផលចំណេញដែលទទួលតាមរយៈព័ត៌មានដែលបានដាក់បង្ហាញដោយក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ។ ដូច្នេះ វិនិយោគម្នាក់ៗ គឺជាមូលដ្ឋាន ដែលចំណុចនេះ គឺ

ផ្ទុយស្រឡះពីប្រព័ន្ធបទប្បញ្ញត្តិដោយផ្អែកលើការវាយតម្លៃព័ត៌មាន។ ជាទូទៅ ប្រព័ន្ធដាក់បង្ហាញព័ត៌មាន មានកាតព្វកិច្ច (បី) ដាក់ទៅលើភ្នាក់ងារចុះបញ្ជីមូលបត្រ (Registrant) ដែលជាល់លក់ជាសាធារណះ :

១. កាត់ព្វកិច្ចក្នុងការដាក់បង្ហាញរាល់ព័ត៌មានសំខាន់ៗ (material Information) : ដើម្បីបង្ហាញការពិនានា ដែលការបង្ហាញនេះ មិនធ្វើឲ្យយល់ខុសដល់វិនិយោគិនដែលមានសក្តានុពលទាំងឡាយ។

២ កាតព្វកិច្ចក្នុងការកែតម្រូវព័ត៌មានទាំងឡាយណាដែលមានលក្ខណះមិនត្រឹមត្រូវ ឬធ្វើយល់ច្រឡំ នៅពេលមានការដាក់បង្ហាញលើកទី១ ក្នុងខណះពេលដែលការសម្រេចក្រោយមកទៀតថាព័ត៌មានទាំងនោះមិនត្រឹមត្រូវ ហើយការបង្ហាញកន្លងមកខុស ឬដែលធ្វើឲ្យយល់ខុស។

៣ កាតព្វកិច្ចក្នុងការធ្វើបច្ចុប្បនភាព (Update) រាល់ព័ត៌មានទាំងឡាយដែលជាព្រឹត្តការណ៍ ឬហេតុការណ៍ថ្មីដែលមានកែប្រែច្រើនទៅលើព័ត៌មានទាំងឡាយដែលចាព្រឹត្តិការណ៍ ឬហេតុការណ៍ថ្មីដែលមានការកែប្រែច្រើនទៅលើព័ត៌មានដែលបានដាក់បង្ហាញកន្លងមក។ នៅក្នុងបរិយោកាសនៃការដាក់បង្ហាញព័ត៌មាននេះ វាជាការទទួលខុសត្រូវនៃភ្នាក់ងារចុះបញ្ជីបត្រ (Registrant) ក្នុងការរក្សាព័ត៌មានទាំងអស់នោះ ត្រូវតែមានលក្ខណះត្រឹមត្រូវតាមដែលភ្នាក់ងារចុះបញ្ជីមូលបត្រអាចធ្វើទៅ ហើយការខកខានណាមួយនៅក្នុងការបំពេញភាកិច្ចនេះត្រូវទទួលទណ្ឌកម្មដូចមានចែងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិ។ ចំពោះការកំណត់ថាតើអ្វីជាព័ត៌មានសំខាន់ អ្វីជាព័ត៌មានដែលមិនត្រឹមត្រូវ ព្រមទាំងលក្ខខណ្ឌតម្រូវនានានឹងត្រូវបានចែងលម្អិតដោយច្បាប់និងបទប្បញ្ញត្តិទៅតាមប្រទេសនិមួយៗហើយ ច្បាប់ និងបទប្បញ្ញត្តិទាំងនោះអាចមានភាពខុសគ្នា។

## ៩.៣.មុខងារនៃទីផ្សារមូលបត្រ (Function of Securities Market)

ពាក្យ "Stock Market" ឬ "Securities Market" ត្រូវបានប្រើប្រាស់ដើម្បីពិពណ៌នាពីសកម្មភាពនៃការជួញដូរ (Trading) ភាគហ៊ុន (Stocks or Shares) និងមូលបត្រពាក់ព័ន្ធផ្សេងទៀតផងដែរ នៅលើទីផ្សារមូលបត្រ (Exchange) ឬនៅលើទីផ្សាររំលងបញ្ជរដែលគេស្គាល់ថា OTC Market (Over-The-Counter)។ ដោយផ្អែកលើទំហំ និង ភាពស្មុគស្មាញនៃទីផ្សារ ជាហេតុធ្វើឲ្យមានទីផ្សារមូលបត្រដាច់ដោយឡែកសម្រាប់ភាគហ៊ុន (Stocks) សញ្ញាបណ្ណ (Bonds) មូលបត្រអនាគត (Futures) ព្រមទាំងមូលបត្រជាក់លក់ផ្សេងទៀត ឬក៏គ្រប់ប្រភេទមូលបត្រទាំងនេះអាចត្រូវបានជួញដូរនៅលើទីផ្សារមូលបត្រតែមួយ។

ទីផ្សារមូលបត្រ មានមុខងារសំខាន់ជាមូលដ្ឋានពីរយ៉ាងគឺ :

១. មុខងារបង្កើតដើមទុន (Capital Formation) : ទីផ្សារមូលបត្រជាកន្លែងប្រជុំវិនិយោគិនទាំងអស់ដែលមានទុនដើម្បីវិនិយោគទៅក្នុងក្រុមហ៊ុនបោះផ្សាយមូលបត្រទាំងឡាយណា ដែលស្វែងរកទុនដើម្បីបង្កើនមូលធនរបស់ខ្លួន។

២. មុខងារសន្ទនីយភាព (Liquidity) : គឺជាលទ្ធភាពក្នុងការលក់ឧបករណ៍វិនិយោគនៅក្នុងទីផ្សារមូលបត្រ។ ទីផ្សារមូលបត្រផ្តល់សន្ទនីយភាពតាមរយៈការផ្តល់ជាទីកន្លែងជួញដូរ (តាំងនៅទីកន្លែង និងប្រព័ន្ធអេឡិចត្រូនិច) ដែលក្នុងនោះអ្នកទិញ និងអ្នកលក់ជួបគ្នាដើម្បីព្រមព្រៀងតម្លៃ និងធ្វើការជួញដូរមូលបត្រ។ សកម្មភាពនេះផ្តល់សន្ទនីយភាពក្នុងការទិញ និងលក់មូលបត្រនៅក្នុងទីផ្សារមូលបត្រ។

## ៩.៤.ប្រសិទ្ធភាពនៃទីផ្សារមូលបត្រ (Efficiency of Securities Markets)

ជាញឹកញាប់គេនិយាយថា ទីផ្សារមូលបត្រជាទីផ្សារដែលមានប្រសិទ្ធភាពខ្ពស់។ តាមរយៈនេះមានន័យថា: ទីផ្សារមូលបត្រជាទីផ្សារដែលពេញលេញ និងមានតម្លាភាព (Transparent) ក្នុងការផ្តល់ព័ត៌មាន ហើយការផ្តល់ព័ត៌មាននេះគឺជាតម្លៃមួយនៃមូលបត្រដែលឆ្លុះបញ្ចាំងដោយព័ត៌មានទាំងអស់ដែលមានជាសាធារណៈ។ នៅក្នុងទីផ្សារដែលមានប្រសិទ្ធិភាពខ្ពស់ ព័ត៌មានធ្វើឲ្យប៉ះពាល់តម្លៃនៅលើទីផ្សារនៃមូលបត្រ ទោះបីជាវិនិយោគិនគ្រប់គ្នាមានព័ត៌មានដូចគ្នានៅក្នុងពេលតែមួយក៏ដោយ។ ព័ត៌មានថ្មីគឺឆ្លុះបញ្ចាំងឲ្យឃើញដោយតម្លៃសម្រាប់មូលបត្រ ទោះបីជាព័ត៌មានថ្មីដែលមាន ធ្វើឲ្យវិនិយោគិនទាំងអស់នៅក្នុងអំឡុងពេលដូចគ្នា។ ជាមួយព័ត៌មានថ្មីដែលមាន ធ្វើឲ្យវិនិយោគិនទាំងអស់ឈានដល់ការព្រមព្រៀងលើតម្លៃថ្មីមួយ។

នៅក្នុងទីផ្សារដែលមានប្រសិទ្ធភាពនោះដែរ គ្មាននរណាម្នាក់ ឬក្រុមណាមួយមានព័ត៌មានច្រើនជាងគ្នា ឬផ្សេងគ្នាពីបុគ្គល ឬក្រុមមនុស្សផ្សេងទៀតឡើយ។ នេះជាគោលបំណងនៃនិយ័តករមូលបត្រទាំងអស់ ដើម្បីចាត់ចែង និងពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិទាំងឡាយដែលនឹងផ្តល់ឲ្យមានបរិយាកាសមួយ ដែលព័ត៌មានទាំងអស់មិនត្រឹមតែត្រូវបានដាក់បង្ហាញយ៉ាងទូលំទូលាយប៉ុណ្ណោះទេ ប៉ុន្តែត្រូវបានដាក់បង្ហាញដល់វិនិយោគិនទាំងអស់ក្នុងពេលតែមួយ។

## ៩.៥.ការកំណត់ប្រភេទនៃមូលបត្រ (Definition of Securities)

មូលបត្រខុសពីទំនិញប្រើប្រាស់ផ្សេងៗដែលយើងទិញប្រើប្រាស់រាល់ថ្ងៃ។ មូលបត្រទាំងអស់មិនមានតម្លៃជាក់លាក់នោះទេ តែវាជាតម្លៃតំណាងនៃសិទ្ធិនៅក្នុងអង្គភាពបោះផ្សាយមួយប៉ុណ្ណោះ។ ចំពោះតម្លៃនៃសញ្ញាណបណ្ណ (Bonds) ឬបណ្ណបំណុលផ្សេងទៀត ត្រូវទូទាត់ដោយផ្អែកលើលក្ខខណ្ឌហិរញ្ញវត្ថុនៃក្រុមហ៊ុនបោះផ្សាយ ជាមួយនឹងលទ្ធភាពរបស់ក្រុមហ៊ុនទាំងនោះក្នុងការសងត្រឡប់មកវិញ នូវបំណុលរបស់ក្រុមហ៊ុន។ ចំពោះតម្លៃនៃភាគហ៊ុនមួយ គឺអាស្រ័យទៅលើកត្តាជាច្រើនក្នុងនោះរួមមានភាពចំណេញ ឬលទ្ធភាពរកប្រាក់ចំណេញនាពេលអនាគតរបស់ក្រុមហ៊ុនសាជីវកម្ម ឬអង្គភាពនានាដែលបានបោះផ្សាយលក់ភាគហ៊ុនផងដែរ។ តម្លៃទីផ្សារមូលបត្រពឹងផ្អែកលើ ថាតើអ្នកទិញមានឆន្ទៈនឹងចំណាយប៉ុន្មានសម្រាប់ភាគហ៊ុន ដោយសំអាងទៅលើការវាយតម្លៃរបស់ពួកគេ ពីអនាគតរបស់ក្រុមហ៊ុនបោះផ្សាយទាំងនោះ។ អ្វីទៅដែលជាមូលបត្រ? ត្រូវបានឲ្យនិយមន័យយ៉ាងជាក់លាក់ដោយច្បាប់ និងបទប្បញ្ញត្តិនៃប្រទេសនិមួយៗ។ ដោយសារតែមានការពិបាកយល់ និងមាន

ការលំបាកក្នុងការឲ្យនិយមន័យថាអ្វីទៅដែលជាមូលបត្រមួយ ទើបច្បាប់ និងបទប្បញ្ញត្តិមូលបត្រភាគច្រើនបានកំណត់មូលបត្រប្រភេទទូទៅ រួមទាំងឧបករណ៍ផ្សេងទៀត ដែលនិយ័តករមូលបត្ររបស់ប្រទេសមួយមានប្រភេទអំណាចបន្ថែមតាមតម្រូវការចាំបាច់។ នៅពេលដែលឧបករណ៍មួយត្រូវបានចាត់ទុកថាជាមូលបត្រមួយ វាត្រូវតែស្ថិតនៅក្រោមច្បាប់ និងបទប្បញ្ញត្តិមូលបត្រ។

ជាទូទៅ មូលបត្រគឺជាប្រភេទវិញ្ញាបនបត្រដែលបញ្ជាក់ពីកម្មសិទ្ធិ ឬបំណុលដែលអាចដោះដូរបាននៅលើទីផ្សារ។ ចំពោះភាគហ៊ុនគឺជាភស្តុតាងនៃកម្មសិទ្ធិករ ចំណែកឯបណ្ណបំណុល (Debentures) ឬក៏សញ្ញាបណ្ណ (Bonds) គឺជាភស្តុតាងនៃឥណទាន (Loan) ឬបំណុល។

ចំពោះប្រទេសមួយចំនួនយល់ថា នៅពេលដែលឧបករណ៍ជួញដូរមួយ ជាប្រភេទមូលបត្រយ៉ាងពិតប្រាកដនោះ វាមិនចាំបាច់មានច្បាប់ និងបទប្បញ្ញត្តិធ្វើការគ្រប់គ្រងនោះទេ។ មូលបត្រទាំងនេះត្រូវបានលើកលែងពីការចុះបញ្ជី និងការដាក់លក្ខខណ្ឌនៃការដាក់បង្ហាញព័ត៌មានដែលច្បាប់ និងបទប្បញ្ញត្តិតម្រូវ តែទោះជាយ៉ាងនេះក្តី មូលបត្រអញ្ញត្តិកម្មតែងតែស្ថិតនៅក្រោមការហាមឃាត់មិនឲ្យមានការក្លែងបន្លំ ព្រមទាំងការទទួលខុសត្រូវខាងរដ្ឋប្បវេណីផ្សេងទៀត (Civil Liability Provisions)។ នៅក្នុងប្រទេសខ្លះ សញ្ញាបណ្ណរបស់រដ្ឋាភិបាល (Government Bonds) ត្រូវបានលើកលែងពីការចុះបញ្ជី ឬក៏មិនស្ថិតនៅក្រោមលក្ខខណ្ឌនៃការចុះបញ្ជីដែលមានលក្ខណៈតឹងរឹង ដូចដែលបានតម្រូវចំពោះមូលបត្រកម្មសិទ្ធិ (Equity) ឬសញ្ញាបណ្ណក្រុមហ៊ុនឯកជន (Corporate Bonds) នោះទេ។ នៅក្នុងប្រទេសឥណ្ឌូនេស៊ី ឧបករណ៍ជួញដូរទាំងឡាយនៅលើទីផ្សាររូបិយវត្ថុ (Money Market) មិនត្រូវបានចាត់ទុកជាមូលបត្រទេ។

## ៩.៥.១.ប្រភេទភាគហ៊ុន (Stocks/Shares)

ពាក្យ "Stock" តែងមានន័យថា កម្មសិទ្ធិករ ឬដើមទុននៅក្នុងសាជីវកម្មមួយ។ ជាធម្មតា "Stock" ត្រូវបានគេបោះផ្សាយក្នុងទម្រង់ជាភាគហ៊ុន។ ផ្នែក ឬភាគនៃកម្មសិទ្ធិករគឺជាអ្វីដែលត្រូវបានសំដៅដោយពាក្យ "Stock ឬ Share"។

### ក.ផលចំណេញមូលធន (Capital Gains)

ផលចំណេញមូលធន គឺជាប្រាក់ចំណេញដែលកើតចេញពីការវិនិយោគនៅលើភាគហ៊ុនឬសញ្ញាបណ្ណ។ ផលចំណេញមូលធន ជាភាពខុសគ្នារវាងតម្លៃលក់ និងតម្លៃទិញ ពោលគឺតម្លៃលក់ខ្ពស់ជាងតម្លៃទិញ ដែលភាពលើសហិរញ្ញវត្ថុ (Financial Gains) នេះត្រូវវិនិយោគិនទទួលបាន។

### ខ.ភាគលាភ (Dividends)

ក្រៅពីផលចំណេញមូលធន វិនិយោគិនមូលបត្រនិងទទួលបានភាគលាភ។ ភាគលាភ គឺជាប្រាក់ចំណូលពីការវិនិយោគទិញភាគហ៊ុន ដែលត្រូវបានប្រកាសដោយក្រុមប្រឹក្សាភិបាលរបស់ក្រុម

ហ៊ុន ហើយជាធម្មតាត្រូវទូទាត់ក្នុងទម្រង់ជាសាច់ប្រាក់ (Cash) ឬក៏ទទួលបានភាគហ៊ុនបន្ថែម។ ខ្ញុំសូមបរិយាយចំណុចនេះលម្អិតនៅក្នុងមេរៀន២ បន្ថែម។

### ៩.៥.២.ប្រភេទសញ្ញាប័ណ្ណ (Bonds)

មានមូលបត្រជាច្រើនដែលមិនមែនជាភាគហ៊ុន (Stock)។ ជាទូទៅគេស្គាល់មូលបត្រទាំងនោះថាជាសញ្ញាបណ្ណ (Bonds)។ ជាធម្មតា មូលបត្រទាំងនោះជាបណ្ណបញ្ជាក់ពីបំណុល (Debts) ឬឥណទាន (Loan) ហើយជួនកាលអាចបោះផ្សាយដោយរដ្ឋាភិបាលនៃប្រទេសមួយ ភ្នាក់ងារនានារបស់រដ្ឋាភិបាលមួយ ឬក៏ក្រុមហ៊ុនសាជីវកម្មមួយ។ ក្នុងករណីខ្លះមានការខុសគ្នាយ៉ាងទូលំទូលាយរវាងបណ្ណភាគហ៊ុន និងសញ្ញាបណ្ណ។ មូលបត្រកម្មសិទ្ធិ (Equity Securities) និងមូលបត្របំណុល (Debt Securities) មិនមានលក្ខណៈដាច់ស្រឡះពីគ្នានោះទេ។

#### កការប្រាក់. (Interest)

សញ្ញាបណ្ណ ឬបណ្ណបំណុលត្រូវបានវាស់វែងដោយការប្រាក់ដែលត្រូវបង់ដោយសញ្ញាបណ្ណដែលបានបោះផ្សាយ។ ការប្រាក់ គឺជាតម្លៃដែលបង់សម្រាប់ការទទួលបានប្រាក់ (Money) នាពេលបច្ចុប្បន្ន ជាជាងរង់ចាំនៅខណៈពេលមួយ ដែលគំនិតនេះ (Concept) ត្រូវបានគេស្គាល់ថា "តម្លៃពេលវេលានៃសាច់ប្រាក់" (Time Value of Money)។ និយាយឲ្យសាមញ្ញ អត្រាការប្រាក់រយៈពេលខ្លី ទាបជាងអត្រាការប្រាក់រយៈពេលវែង ដោយសារតែហានិភ័យដែលធ្វើឲ្យស្ថានភាពមានការប្រែប្រួលអវិជ្ជមានចំពោះវិនិយោគិន និងកើនឡើងនៅពេលវេលាកាន់តែវែង។ម្យ៉ាងទៀត មានកាលានុវត្តភាពវិនិយោគ (Investment Opportunities) ដែលនឹងអាចទទួលបានប្រាក់ចំណេញច្រើនទៀតនិងលេចចេញឡើងផងដែរនៅក្នុងអំឡុងពេលវេលាដ៏វែងមួយ។ ការវិនិយោគសាច់ប្រាក់នៅខណៈពេលមួយ ហើយសាច់ប្រាក់នេះមិននៅទំនេរក្នុងពេលបច្ចុប្បន្នត្រូវបានគេហៅថា "តម្លៃកាលានុវត្តភាព" (Opportunity Cost) ហើយវាជាផ្នែកមួយនៃថ្លៃដើមដែលវិនិយោគិនត្រូវរាប់បញ្ចូលក្នុងការគណនាថ្លៃដើមនៃការវិនិយោគ និងចំណូលពីការវិនិយោគនេះ។

#### ខ.ទិន្នផល (Yields)

| Moody's | Standard & Poor's | (Interpretation) |
|---|---|---|
| Aaa | AAA | កម្រិតខ្ពស់បំផុត |
| Aa1 | AA+ | - |
| Aa2 | AA | កម្រិតខ្ពស់ |

| | | |
|---|---|---|
| Aa3 | AA - | - |
| A1 | A+ | - |
| A2 | A- | កម្រិតមធ្យម |
| A3 | A- | - |
| : | : | - |

គឺជាចំណូល (Returns) ពីការវិនិយោគមួយដែលជាញឹកញយត្រូវបានប្រើប្រាស់ដើម្បីពិពណ៌នាពីអត្រាការប្រាក់នៃសញ្ញាបណ្ណមួយ។ ខ្សែកោងទិន្នផល (yield Curve) គឺជាក្រាហ្វិក (Graph) មួយដែលបង្ហាញពីទំនាក់ទំនងរវាងទិន្នផល និងឥណប្រតិទាន (Maturity)

(ដកស្រង់ចេញពី ADB-Module 1, Self Study on Capital Market)

ការផ្តល់សេវាកម្មនេះ គឺធ្វើយ៉ាងណាមិនឲ្យលក្ខណៈលំអៀង ពីព្រោះថាការធ្វើបុរេវិនិច្ឆ័យអាចនឹងធ្វើឲ្យខូចដល់កេរ្តិ៍ឈ្មោះ និងអត្ថប្រយោជន៍នៃកិច្ចការជំនួញរបស់ក្រុមហ៊ុនពួកគេ។ នៅពេលមានការបោះផ្សាយសញ្ញាបណ្ណបត្រត្រូវបានផ្តល់ការវាយតម្លៃ និងផ្តល់ចំណាត់ថ្នាក់ទៅតាមអក្ខរក្រម (Alphabetical) ខាងលើនេះ។ ការវាយតម្លៃសញ្ញាបណ្ណរបស់គ្រប់ភ្នាក់ងារវាយតម្លៃទាំងអស់ គឺធ្វើឡើងដោយប្រើប្រាស់ព័ត៌មាន។ ពេលព័ត៌មានត្រូវបានផ្សព្វផ្សាយ ការបកស្រាយពីព័ត៌មាន និងសេចក្តីសន្និដ្ឋានត្រូវបានធ្វើឡើង ដែលការសន្និដ្ឋានទាំងនោះអាចមានភាពខុសគ្នា ពីភ្នាក់ងារវាយតម្លៃមួយទៅភ្នាក់ងារវាយតម្លៃមួយទៀត តែទោះជាយ៉ាងណា ការវាយតម្លៃនេះមាននិន្នាការស្រដៀងគ្នា ប៉ុន្តែមិនដូចគ្នាទាំងស្រុងនោះទេ។

ការវាយតម្លៃនៃសញ្ញាបណ្ណមួយគឺមានសារសំខាន់ណាស់ ពីព្រោះវាជាកត្តាសំខាន់មួយក្នុងការកំណត់អត្រាការប្រាក់ ចំពោះសញ្ញាបណ្ណដែលត្រូវបោះផ្សាយ។ សញ្ញាបណ្ណត្រូវបានវាយតម្លៃទៅតាមចំណាត់ថ្នាក់និមួយៗដែលជាទូទៅកម្រិតពី A ដល់ B ត្រូវបានគេហៅថា កម្រិតវិនិយោគមូលបត្រ "Investment Grade Securities"។ ចំពោះវិនិយោគិនជាស្ថាប័នខ្លះមិនអនុញ្ញាតឲ្យវិនិយោគលើមូលបត្រ ឬសញ្ញាបណ្ណទាំងឡាយណាដែលបានវាយតម្លៃក្រោមកម្រិតវិនិយោគមូលបត្រឡើង។ ការហាមឃាត់នេះ ជួនកាលមានចែងនៅក្នុងបទប្បញ្ញត្តិ បទបញ្ជាលផ្ទៃក្នុង ឬការអនុវត្តជាក់ស្តែងរបស់ក្រុមហ៊ុនតែម្តង។

ភាគហ៊ុនមួយចំនួនក៏ត្រូវបានវាយតម្លៃដោយភ្នាក់ងារផ្សេងៗផងដែរ ប៉ុន្តែវិនិយោគិន និងទីផ្សារមូលបត្រមានការយកចិត្តទុកដាក់តិចតួចចំពោះការវាយតម្លៃរបស់ភ្នាក់ងារទាំងនោះ។ ការវាយតម្លៃសំខាន់បំផុតរបស់ភាគហ៊ុនមួយ គឺធ្វើឡើងដោយទីផ្សារខ្លួនឯងតាមរយៈការឆ្លុះបញ្ចាំងនៃតម្លៃភាគហ៊ុននិមួយៗស្រាប់ ដែលស្ថានភាពនេះកើតឡើងនៅពេលដែលទីផ្សារមានភាពចាស់ទុំ ពោលគឺទីផ្សារមានប្រសិទ្ធិភាពខ្ពស់។

**គ.ហានិភ័យ (Risks)**

ហានិភ័យគឺជាលទ្ធភាពដែលអាចធ្វើមានការខាតបង់។ រាល់ការវិនិយោគទាំងអស់គឺមានហានិភ័យជាប់ជាមួយ។ ហានិភ័យមួយ អាចខ្ពស់ជាងហានិភ័យមួយផ្សេងទៀត។ ជាធម្មតាហានិភ័យកាន់តែ

ខ្ពស់ កម្រិតប្រាក់ចំណេញកាន់តែច្រើន ដើម្បីទាក់ទាញវិនិយោគិនឲ្យហ៊ានប្រថុយប្រថានទិញមូលបត្រ។ ហានិភ័យគឺជាការខកខានទទួលបានប្រាក់ចំណូលតាមការរំពឹងទុកទៅលើមូលបត្រមួយ ឬក៏ការវិនិយោគមួយ។ ហានិភ័យត្រូវបានវាស់វែងដោយគម្លាតនៃតម្លៃរំពឹងទុកដោយប្រើរូបមន្តមួយឈ្មោះថា "និយាមគម្លាត" (Standard Deviation)។ (ពាក់ព័ន្ធនឹងនិយាមគម្លាត (Standard Deviation) សូមអានសៀវភៅ: David P. Doane & Lori E. Seward, (2007) . Applied Statistics in Business and Economics)។

បណ្តុំនៃហានិភ័យ (Total Risks) គឺជាចំនួនសរុបនៃហានិភ័យជាប្រព័ន្ធ និងមិនមែនជាប្រព័ន្ធ (Systemic and Non-systemic Risk)។ ចំពោះហានិភ័យដែលមិនមែនជាប្រព័ន្ធ ត្រូវបានគេហៅផងដែរថាជាហានិភ័យនៅសល់ផ្សេងៗទៀត (Residual Risk)។ ហានិភ័យនៅក្នុងទីផ្សារមូលបត្រចែកចេញជាពីរប្រភេទគឺ :

- ហានិភ័យជាប្រព័ន្ធ (**Systemic Risk**) : គឺជាហានិភ័យដែលពាក់ព័ន្ធទៅនឹងប្រព័ន្ធទាំងមូលរបស់វិស័យណាមួយ។ គ្រប់ប្រព័ន្ធទាំងអស់ត្រូវតែមានហានិភ័យជាប្រព័ន្ធ។ សម្រាប់ទីផ្សារមូលបត្រ ហានិភ័យជាប្រព័ន្ធ គឺជាហានិភ័យដែលកើតឡើងដោយសារកត្តានានាដែលធ្វើឲ្យប៉ះពាល់ចំណូលនៃមូលបត្រទាំងអស់។ ហានិភ័យជាប្រព័ន្ធ មិនអាចត្រូវបានការពារទប់ទល់ដោយការធ្វើពិពិធកម្ម (**Diversification**) នៃសំណុំវិនិយោគ (**Portfolio**) បានទេ។ មានទំនុកចិត្ត ឬខ្វះទំនុកចិត្តមកលើទីផ្សារមូលបត្រគឺជាហានិភ័យជាប្រព័ន្ធមួយ។
- ហានិភ័យមិនមែនជាប្រព័ន្ធ (**Non-Systemic Risk**) : គឺជាបុព្វហេតុដែលកើតឡើងដោយកត្តទូទៅមួយចំនួន។ ហានិភ័យមិនមែនជាប្រព័ន្ធ ធ្វើឲ្យប៉ះពាល់តែវិស័យឧស្សាហកម្ម ឬ ភាគហ៊ុនតែម្តង។

ភាគហ៊ុនមួយចំនួនក៏ត្រូវបានវាយតម្លៃដោយភ្នាក់ងារផ្សេងផងដែរ ប៉ុន្តែវិនិយោគិន និងទីផ្សារមូលបត្រមានការយកចិត្តទុកដាក់តិចតួចចំពោះការវាយតម្លៃរបស់ភ្នាក់ងារទាំងនោះ។ ការវាយតម្លៃសំខាន់បំផុតរបស់ភាគហ៊ុនមួយ គឺធ្វើឡើងដោយទីផ្សារខ្លួនឯងតាមរយៈការឆ្លុះបញ្ចាំងនៃតម្លៃភាគហ៊ុននិមួយៗស្រាប់ ដែលស្ថានភាពនេះកើតឡើងនៅពេលដែលទីផ្សារមានភាពចាស់ទុំ ពោលគឺទីផ្សារមានប្រសិទ្ធិភាពខ្ពស់។

ទីផ្សារមូលបត្រ អាចមានសន្ទនីយ (Liquid) ឬគ្មានសន្ទនីយ (Illiquid)។ ទីផ្សារមានសន្ទនិយភាពគឺជាទីផ្សារមួយដែលវិនិយោគិនអាចទិញ លក់មូលបត្ររបស់គេបានភ្លាមៗតាមតម្លៃទីផ្សារ។ ចំពោះទីផ្សារគ្មានសន្ទនីយភាពវិញ គឺមានគុណវិបត្តិខ្លះ ពោលគឺ ការទិញ លក់មូលបត្រនៅលើទីផ្សារមានលក្ខណៈយឺតយ៉ាវ ហើយគ្មានការប្រកួតប្រជែងតម្លៃនៅលើទីផ្សារតែម្តង។ ក្នុងន័យនេះ ហានិភ័យសន្ទនីយភាព (Liquidity Risks) គឺជាលទ្ធភាពដែលវិនិយោគិនទាំងឡាយមិនអាចផ្លាស់ប្តូរ (លក់) ទ្រព្យវិនិយោគរបស់ខ្លួនទៅជាប្រាក់ភ្លាមៗ ដោយមិនមានការខាតបង់តម្លៃណាមួយ។ ហានិភ័យសន្ទនីយភាព (Liquidity Risks) គឺជាហានិភ័យជាប្រព័ន្ធមួយនៅក្នុងទីផ្សារមូលបត្រ។

### ៩.៦. អ្នកចូលរួមសំខាន់ៗនៅក្នុងទីផ្សារមូលបត្រ (participants in Securities Markets)

ជាទូទៅ នៅក្នុងទីផ្សារមូលបត្ររីកចម្រើន មានអ្នកចូលរួមនៅក្នុងទីផ្សារមូលបត្រ ៣ប្រភេទសំខាន់ៗគឺ :

#### ៩.៦.១. ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ (issuers)

គឺជាអង្គភាពដែលបោះផ្សាយ (លក់) មូលបត្រដែលមានតម្លៃតំណាងឲ្យអត្រាភាពរយនៃភាពហ៊ុននៅក្នុងអង្គភាពនោះ ឬជាការសន្យាមួយថានឹងបង់ត្រឡប់មកវិញនៃប្រាប់កម្ចី (Loan) ជាមួយការប្រាក់ (សម្រាប់សញ្ញាបណ្ណ) នឹងបង់ភាគលាភសម្រាប់បណ្ណភាគហ៊ុន)។ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ អាចជាស្ថាប័នសាធារណៈ ឬក្រុមហ៊ុនឯកជនដែលស្វែងរកទុននៅលើទីផ្សារមូលបត្រតាមរយៈការលក់ភាគហ៊ុនរបស់ខ្លួន។

#### ៩.៦.២. វិនិយោគិនមូលបត្រ (Investors)

គឺជាអ្នកទិញ និងអ្នកលក់ (អ្នកជួញដូរ) មូលបត្រដែលស្វែងរកប្រាក់ចំណេញ (ហៅថាចំណូល) ទៅលើការវិនិយោគរបស់ខ្លួន។ ជាទូទៅវិនិយោគិននៅលើទីផ្សារមូលបត្រ ចែកចេញជាពីរប្រភេទគឺ វិនិយោគិនជាបុគ្គល (Individual Investors) និងវិនិយោគិនជាស្ថាប័ន (Individual Investors)។

#### ៩.៦.៣. អន្តរការីទីផ្សារមូលបត្រ (Securities Intermediaries)

គឺជាអង្គភាព (Organization) ឬបុគ្គលទាំងឡាយដែលប្រមូលផ្តុំវិនិយោគិន ហើយបង្ហាញឬណែនាំក្រុមហ៊ុនបោះផ្សាយទៅកាន់ទីផ្សារមូលបត្រ។ អន្តរការីទីផ្សារមូលបត្រមាន ចំនួនច្រើនហើយដើរតួនាទីច្រើននៅក្នុងទីផ្សារ ដូចជា: ធ្វើជាពាណិជ្ជករមូលបត្រ (Securities Dealers) ឈ្មួញជើងសាមូលបត្រ (Securities Brokers) ទីប្រឹក្សាវិនិយោគ (Investment Advisors) អ្នកធានាទិញមូលបត្រ (Underwriter)។ ល។

### ៩.៧. ទីផ្សារមូលធន និងទីផ្សាររូបិយវត្ថុ (Capital and Money Markets)

#### ៩.៧.១. ទីផ្សារមូលធន (Capital Market)

គឺជាទីផ្សារហិរញ្ញវត្ថុដែលជួញដូរមូលបត្រកម្មសិទ្ធិ (Equity Securities) និងឧបករណ៍បំណុលរយៈពេលវែងមួយចំនួនទៀត។ ជាទូទៅ ឧបករណ៍បំណុលរយៈពេលវែងត្រូវបានគេកំណត់ថាជាឧបករណ៍ទាំងឡាយណាដែលមានឥណប្រតិទានរយៈពេលមួយឆ្នាំ ឬច្រើនជាងមួយឆ្នាំ។

### ៩.៧.២. ទីផ្សាររូបិយវត្ថុ ( Money Market )

គឺជាទីផ្សារហិរញ្ញវត្ថុដែលជួញដូរតែឧបករណ៍បំណុលរយៈពេលខ្លី និងប្រាក់កម្ចី (Loan)។ ឧបករណ៍បំណុលរយៈពេលខ្លី ត្រូវបានគេកំណត់ថាជាឧបករណ៍ទាំងឡាយណាដែលមានឥណប្រតិទានរយៈពេលតិចជាងមួយឆ្នាំ។

## ៩.៨. ទីផ្សារដំបូង និងទីផ្សារបន្ទាប់ ( Primary and Secondary Markets )

### ៩.៨.១. ទីផ្សារដំបូង ( Primary market )

ការដាក់លក់មូលបត្រជាលើកដំបូងដោយក្រុមហ៊ុនបោះផ្សាយទៅឲ្យវិនិយោគិន ត្រូវបានហៅថាជាការលក់ចែកចាយជាលើកដំបូង។ ទីផ្សារដំបូងគឺជាទីកន្លែងដែល មូលបត្រត្រូវបានលក់ជាលើកទីមួយឲ្យសាធារណជន ហើយអ្នកទិញបានទិញមូលបត្រដោយផ្ទាល់ពីក្រុមហ៊ុនបោះផ្សាយដែលអាចជាក្រុមហ៊ុនសាជីវកម្ម (Corporation) ឬអង្គភាពរដ្ឋាភិបាល (Government Entity) មួយដែលបានបោះផ្សាយលក់មូលបត្រ។ សាច់ប្រាក់សម្រាប់ទូទាត់មូលបត្រត្រូវបង់ទៅក្រុមហ៊ុនបោះផ្សាយ ហើយអ្នកទិញភាគហ៊ុនទាំងនោះក្លាយជាអ្នកកាន់កាប់ (ម្ចាស់) ភាគហ៊ុនដំបូងគេ។ ភាគហ៊ុនិកដំបូងគេអាចកាន់កាប់ភាគហ៊ុនទាំងនេះ ឬក៏លក់ភាគហ៊ុនទាំងអស់ទៅឲ្យអ្នកផ្សេងទៀត។ ដំណើរការលក់ភាគហ៊ុនទៅឲ្យសាធារណជនជាលើកដំបូង ត្រូវគេស្គាល់ថាជា "ការនាំក្រុមហ៊ុនទៅកាន់សាធារណៈ" (Taking the Company Public)។ នេះមានន័យថា ក្រុមហ៊ុនលែងកាន់កាប់ដោយវិនិយោគិនដំបូង ឬស្ថាបនិក (Founder) ទៀតហើយ។ ក្រុមហ៊ុនដែលលក់ភាគហ៊ុនរបស់ខ្លួនទៅកាន់សាធារណជនត្រូវបានគេសន្មតថា "សំណើរលក់មូលបត្រជាសាធារណៈ" (Going Public) កើតមានឡើង។ នៅក្នុងប្រទេសមួយចំនួនដែលធ្លាប់ជាអតីតរដ្ឋរបស់សហភាពសូវៀត និងប្រទេសកុម្មុយនីស្តមួយចំនួនគេប្រើពាក្យ Taking the Company Private ជំនួសពាក្យ "Taking the Company Public"។ ចំពោះដំណើរការនៃការលក់ភាគហ៊ុនជាលើកដំបូងរបស់ក្រុមហ៊ុនមួយត្រូវបានគេហៅថា "សំណើរបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង" ( Initial Public Offering ) ឬ "IPO"។




រូបភាពទី១៖ ការជួញដូរសញ្ញាប័ណ្ណក្នុងទីផ្សារបឋម

### ៩.៨.២. ទីផ្សារបន្ទាប់ (Secondary Market)

ដោយសារវិនិយោគិនមួយចំនួនយល់ថា ការប្រើប្រាស់មូលធន (Tie up Funds) របស់ពួកគេមិនមានការកំណត់ជាក់លាក់ ដូចនេះហើយភាគច្រើននៃមូលបត្រអាចចរចាទិញ លក់បាន។ នេះមានន័យថាភាគហ៊ុនអាចផ្លាស់ប្តូរបានដោយសេរីពីអ្នកលក់ម្នាក់ទៅអ្នកទិញម្នាក់ទៀតដោយតម្លៃកំណត់មួយដែលមានការព្រមព្រៀង និងពេញចិត្តដោយភាគីទាំងពីតាមរយៈការផ្តល់ភាគហ៊ុនឲ្យទៅអ្នកទិញ។ បណ្ណកម្មសិទ្ធិស្របច្បាប់របស់ភាគហ៊ុន និងត្រូវបានផ្ទេរឲ្យអ្នកទិញនៅពេលដែលភាគហ៊ុនផ្តល់មកឲ្យភាគីអ្នកទិញ។ ការកំណត់តម្លៃ និងការផ្តល់កម្មសិទ្ធិលើមូលបត្រកើតឡើងនៅកន្លែងមួយដែលគេស្គាល់លល់ថាជាទីផ្សារបន្ទាប់ (Secondary Market)។ ទីផ្សារបន្ទាប់គឺជាកន្លែងដែលការជួញដូរមូលបត្រត្រូវបានកើតឡើងជាប្រចាំរវាងអ្នកលក់ និងអ្នកទិញមូលបត្រ។ ទឹកប្រាក់ដែលកើតចេញពីកម្មភាពជួញដូរនេះ ត្រូវបង់ទៅឲ្យភាគហ៊ុនិកដែលលក់ មិនមែនឲ្យទៅក្រុមហ៊ុនបោះផ្សាយដំបូងនោះទេ។ ក្រុមហ៊ុនបោះផ្សាយមូលបត្រមិនទទួលបានផលចំណេញជាហិរញ្ញវត្ថុពីការជួញដូរមូលបត្រកើតឡើងនៅលើទីផ្សារបន្ទាប់ទេ ហើយមូលបត្រទាំងអស់ដែលជួញដូរនៅលើទីផ្សារបន្ទាប់អាចត្រូវបានជួញដូរនៅក្នុងទីផ្សារមូលបត្រឬនៅក្រៅទីផ្សារមូលបត្រ ដែលគេហៅថា "Over The Counter" (ទីផ្សាររំលងបញ្ជរ)។

វាជាមុខងារនៃទីផ្សារមូលបត្រ (Securities Exchanges) និងទីផ្សាររំលងបញ្ជរ (Over The Counter) ក្នុងការផ្តល់ទីកន្លែងមួយក្នុង ការកំណត់តម្លៃភាគហ៊ុន ព្រមទាំងផ្តល់មូលបត្រទៅអ្នកទិញ។




រូបភាពទី២៖ការជួញដូរសញ្ញាប័ណ្ណក្នុងទីផ្សារបន្ទាប់

### ៩.៩. ទីផ្សារមូលបត្រ និងទីផ្សាររំលងបញ្ជរ (Exchanges and Over The Counter Market)

ទីផ្សារបន្ទាប់សម្រាប់ជួញដូរមូលបត្រ ត្រូវដំណើរការទៅទាំងនៅក្នុងទីផ្សារមូលបត្រ (Exchanges) ដែលត្រូវបានគេស្គាល់ថា ជាទីផ្សារសម្រាប់ដេញថ្លៃ (Auction Market) ព្រមទាំងនៅក្នុងទីផ្សាររំលងបញ្ជរ (Over The Counter) ដែលត្រូវបានគេស្គាល់ថាជាពាណិជ្ជករមូលបត្រ ឬក៏ជាការព្រមព្រៀងគ្នារវាងអ្នកទិញ និងអ្នកលក់។

ភាពខុសគ្នារវាងទីផ្សារមូលបត្រ (Exchange) និង ទីផ្សាររំលងបញ្ជរ (OTC) គឺត្រង់ថាទីផ្សារមូលបត្រមានទីកន្លែងជាក់លាក់សម្រាប់ឲ្យពាណិជ្ជករមូលបត្រ (Securities Dealers) ឬឈ្មួញជើងសាមូលបត្រ (Securities Brokers) ជួបទល់មុខគ្នាក្នុងការជួញដូរមូលបត្រ ចំណែកឯទីផ្សាររំលងបញ្ជរ (OTC) វិញ ពាណិជ្ជករមូលបត្រ ឬឈ្មួញជើងសាមូលបត្រធ្វើការជួញដូរភាគហ៊ុនតាមរយៈការភ្ជាប់ប្រព័ន្ធទីផ្សារមូលបត្រទេ។ ដោយសារបច្ចេកវិទ្យារីកចំរើន ភាពខុសគ្នារវាងទីផ្សារទាំងពីរនេះមានលក្ខណៈមិនច្បាស់លាស់ នៅពេលដែលទីផ្សារមូលបត្រនាពេលបច្ចុប្បន្ន ពឹងផ្អែកកាន់តែច្រើនឡើងទៅលើបណ្តាញប្រព័ន្ធកុំព្យូទ័រ ជាជាងប្រើប្រាស់ទីកន្លែងនៅលើទីផ្សារមូលបត្រសម្រាប់ជួញដូរភាគហ៊ុន។ ឧទាហរណ៍ ទីផ្សារភាគហ៊ុនទីក្រុង Toronto (The Toronto Stock Exchange) បានលុបចោលទីកន្លែងជួញដូរ (Exchange Floor) របស់ខ្លួន។

ក្នុងន័យទូទៅការជួញដូរមូលបត្រមួយកើតឡើងទាំងនៅលើទីផ្សារមូលបត្រ និងនៅក្រៅទីផ្សារមូលបត្រ។ ចំពោះការជួញដូរភាគហ៊ុនទាំងឡាយណា ដែលមិនកើតឡើងនៅលើទីផ្សារមូលបត្រត្រូវបានគេសំដៅទៅទីផ្សាររំលងបញ្ជរក្នុងន័យទូលាយមួយ។ នៅលើទីផ្សាររំលងបញ្ជរជាប្រពៃណី មិនមានរចនាសម្ព័ន្ធទីផ្សារច្បាស់លាស់ ព្រមទាំងមិនមានទីកន្លែងជាក់លាក់សម្រាប់ធ្វើការជួញដូរមូលបត្រ អាចចូលរួមក្នុងការជួញដូរមូលបត្រដោយសេរី រួមទាំងសកម្មភាពនានាដែលពាក់ព័ន្ធនៅក្នុងវិស័យមូលបត្រផងដែរ។

នៅក្នុងទីផ្សាររំលងបញ្ជរ (Over The Counter Market) ជាធម្មតា អ្នកជួញដូរមូលបត្រដើរតួនាទីជាពាណិករមូលបត្រ ព្រមទាំងបង្កើតទីផ្សារមួយ (Make a Market) ដោយខ្លួនឯងក្នុងការជួញដូរប្រភេទមូលបត្រជាច្រើន។ ហេតុដូចនេះហើយអ្នកជួញដូរមូលបត្រទាំងអស់នេះ ត្រូវបានគេស្គាល់ថាជាអ្នកបង្កើតទីផ្សារ (Market Markers)។ អ្នកបង្កើតទីផ្សារ ធ្វើឲ្យមានទីផ្សារដែលចែកចេញជាពីរផ្នែក (ផ្នែកទិញ និងផ្នែកលក់ Bid-offer) តាមរយៈការដាក់តម្លៃ (Quoting a Price) មួយដែលអ្នកបង្កើតទីផ្សារអាចទូទាត់ឲ្យអ្នកលក់ (Bidding Price) ឬក៏ក្នុងតម្លៃមួយដែលពួកគេអាចលក់ទៅឲ្យអ្នកទិញ (Asking Price)។ ភាពខុសគ្នារវាងតម្លៃលក់ និងតម្លៃទិញ (Bid និង Ask) ត្រូវបានហៅថា "គម្លាត" (Spread)។ ប្រសិនបើពាណិជ្ជករមូលបត្រមួយទទួលបានការបញ្ជាទិញមួយលើភាគហ៊ុនណាមួយ ដែលក្នុងតម្លៃបញ្ជាទិញនោះ ពាណិជ្ជករមូលបត្រមិនអាចបង្កើតទីផ្សារដោយខ្លួនឯងបាន ត្រូវបញ្ជូនការបញ្ជាទិញនោះ ហើយបន្ទាប់មកធ្វើការប្រៀបធៀបការដាក់តម្លៃ។ ពាណិជ្ជករមូលបត្រ មិនទទួលបានកម្រៃជើងសារទេពីព្រោះតម្លៃដែលដាក់ (Quoted) រួមបញ្ចូលតម្លៃបន្ថែម (Mark Up) លើភាគីខាងទិញ និងការបញ្ចុះតម្លៃ (Mark Down) លើភាគីខាងលក់ជាស្រេច។ តម្លៃគម្លាតរវាងការបន្ថែម និងការបញ្ចុះតម្លៃ គឺជាប្រាក់ចំណេញរបស់ពាណិជ្ជករមូលបត្រ។ ជាធម្មតា អ្នកបង្កើតទីផ្សារមិនទាក់ទង ឬជួញដូរមូលបត្រដោយផ្ទាល់ជាមួយសាធារណជនដែលជាវិនិយោគិនមូលបត្រនោះទេ គឺពួកដូរមូលបត្រ ជាមួយពាណិជ្ជករមូលបត្រផ្សេងទៀត ឬក៏ជាមួយឈ្មួញជើងសាមូលបត្រដែលវិនិយោគមូលបត្រក្នុងនាមអតិថិជនមួយ។ សកម្មភាពជួញដូរនេះមានលក្ខណៈដូចជាទីផ្សារបោះដុំមួយ

(A Wholesales Market) ខណៈពេលនេះឈ្មួញជើងសារមូលបត្រជើរត្តនាទីជាអ្នកលក់ (Retail Market)។

មុខងារសំខាន់ៗនៃទីផ្សារមូលបត្រ ឬទីផ្សារវិលងបញ្ជរ គឺត្រូវផ្តល់ទីផ្សារ (Market Place) ឲ្យក្រុមហ៊ុនទាំងឡាយណា ដែលជាសមាជិករបស់ទីផ្សារ (ក្រុមហ៊ុនជើរត្តនាទីជាឈ្មួញជើងសារមូលបត្រអាចទិញ និងលក់មូលបត្រសម្រាប់គណនីទាំងឡាយដែលជារបស់អតិថិជនរបស់ខ្លួន។

## ៩.១០. សន្ទនីយភាព (Liquidity)

មូលបត្រទាំងឡាយអាចផ្លាស់ប្តូរជាសាច់ប្រាក់បាន។ អ្នកទិញ និងអ្នកលក់ពិភាក្សាគ្នាលើតម្លៃភាគហ៊ុនឥតឈប់ឈរ (Continually Bargain) ក្នុងអំឡុងពេលជាក់លាក់មួយ។ ការបង្កើតឲ្យទីផ្សារមានភាពរស់រវើក និងអាចដោះដូរជាសាច់ប្រាក់បានងាយស្រួល (Liquid) គឺជាមុខងារដ៏សំខាន់មួយក្នុងចំណោមមុខងារសំខាន់ៗទាំងឡាយនៃទីផ្សារមូលបត្រ និងទីផ្សារវិលងបញ្ជរ។ ស្ថានភាពនេះ អាចនិយាយបានថា ទីផ្សារមានសន្ទនីយភាព (Liquidity) ពោលគឺធ្វើឲ្យមានភាពងាយស្រួល និងមានកាលានុវត្តភាព (Opportunities) ភ្លាមៗដើម្បីទិញ និងលក់មូលបត្រ ហើយដែលធ្វើឲ្យមូលបត្រអាចជួញដូរបាននៅលើទីផ្សារមូលបត្រ ឬទីផ្សារវិលងបញ្ជរប្រកបដោយប្រសិទ្ធភាពខ្ពស់។ មានលក្ខខណ្ឌ៤យ៉ាង ដែលបង្ហាញថា សន្ទនីយភាពមាននៅក្នុងទីផ្សារមូលបត្រមួយចំពោះភាគហ៊ុនទាំងឡាយ:

១. ភាពញឹកញាប់នៃការលក់មូលបត្រ (Frequency of Sales)
២. គម្លាតតូចរវាងតម្លៃទិញ និងតម្លៃលក់ (Narrow Spread Between Bids and Offers)
៣. ការធ្វើប្រតិបត្តិការនៃការបញ្ជាទិញភ្លាមៗ (Prompt Execution of Order)
៤.បម្រែបម្រួលថ្លៃអប្បបរមារវាងប្រតិបត្តិការមួយទៅប្រតិបត្តិការមួយ (Minimum Price Changes Between Transactions)

## ៩.១១. ការកំណត់តម្លៃ (Fair Price Determination)

ជាការពិត ទាំងទីផ្សារមូលបត្រ ទាំងទីផ្សារវិលងបញ្ជរ គឺមិនមានគោលការណ៍កំណត់តម្លៃសម្រាប់ជួញដូរមូលបត្រនៅលើទីផ្សារទាំងនេះទេ។ ផ្ទុយមកវិញ អ្នកទិញ និងអ្នកលក់មូលបត្រ គឺជាអ្នកកំណត់តម្លៃនៅលើទីផ្សារតាមរយៈការព្រមព្រៀងតម្លៃគ្នា ដែលយន្តការនេះត្រូវបានគេស្គាល់ថាជាការកំណត់តម្លៃ (Fair Price Determination) ឬតម្លៃរកឃើញ (Price Discovery)។ សកម្មភាពទិញ លក់ទៅវិញទៅមក និងជាបន្តបន្ទាប់រវាងអ្នកទិញ និងអ្នកលក់នេះហើយ ដែលអាចកំណត់បានតម្លៃនេះអ្នកទិញមូលបត្រមានបំណងនឹងបង់ប្រាក់ និងអ្នកលក់មានបំណងនឹងទទួលយកតម្លៃទូទាត់ក្នុងការដោះដូរមូលបត្រ។

ប្រព័ន្ធជួញដូររបៀបនេះអាចងាយទទួលរងការប្រើប្រាស់ល្បិចកលផ្សេងៗ ក្នុងការធ្វើឲ្យតម្លៃមូលបត្រមានការប្រែប្រួល ប្រសិនបើភាគីមួយមានព័ត៌មានច្រើនជាង ឬព័ត៌មានផ្សេងពីគ្នាពីភាគីមួយទៀត។ វាជាទិសដៅនៃច្បាប់ និងបទប្បញ្ញត្តិទាំងឡាយក្នុងការដាក់បញ្ញត្តិ និងជាការទទួលខុសត្រូវ

របស់និយ័តករ ក្នុងការការពារកុំឲ្យមានស្ថានភាពដូចនេះកើតឡើងនៅលើទីផ្សារមូលបត្រ។ នៅក្នុងទីផ្សារជឿនលឿនមួយចំនួន មានប្រព័ន្ធត្រួតពិនិត្យមួយក្នុងការត្រួតពិនិត្យសកម្មភាពជួញដូរនៃភាគហ៊ុននីមួយៗ ហើយផ្តល់សញ្ញាប្រាប់អ្នកត្រួតពិនិត្យទីផ្សារនៅពេលដែលមានសកម្មភាព មិនប្រក្រតីកើតឡើងនៅលើទីផ្សារ ហើយអាចឈានទៅដល់ការសើបអង្កេតជាក់លាក់មួយ ក្នុងករណីមិនប្រក្រតីធ្ងន់ធ្ងរ។ ជាប្រពៃណី ទីផ្សារមូលបត្រដំណើរការដោយមានរចនាសម្ព័ន្ធច្បាស់លាស់ និងមានបទប្បញ្ញត្តិតឹងរឹងពាក់ព័ន្ធនឹងចំនួន និងគុណវុឌ្ឍ (Qualification) នៃសមាជិកទីផ្សារ មុខងាររបស់សមាជិកនៅក្នុងទីផ្សារ និងប្រភេទឧបករណ៍នានាដែលអាចជួញដូរបាននៅលើទីផ្សារ។ នៅក្នុងទីផ្សារមូលបត្រធំៗខ្លះ ពួកគេធ្វើការបែងចែករវាងទីផ្សារមូលបត្រសម្រាប់មូលបត្រកម្មសិទ្ធិ (Equities) សម្រាប់ទំនិញ (Commodities) សម្រាប់កិច្ចសន្យាអនាគត (Future Contracts)។ ល។ ឧទាហរណ៍ ទីផ្សារអនាគតរបស់ប្រទេសសិង្ហបុរី (Singapore Future Exchange) គឺធ្វើការជួញដូរតែប្រភេទកិច្ចសន្យាអនាគតប៉ុណ្ណោះ។

### ៩.១២.សន្ទស្សន៍ថ្លៃ indexes និង សន្ទស្សន៍ថ្លៃ Averages

សន្ទស្សន៍ថ្លៃ **Index** គឺជារង្វាស់មួយដែលផ្អែកលើការប្រៀបធៀបជាមួយឆ្នាំមូលដ្ឋានមួយ (**Based Year**) ដែលជាធម្មតាគេកំណត់យក ១០០ជាគោល។ សន្ទស្សន៍ថ្លៃ **Indexes** ទាំងអស់ប្រើប្រាស់រយះពេលគោល ប៉ុន្តែឆ្នាំគោលនេះខុសៗគ្នាពីសន្ទស្សន៍ថ្លៃ **Indexes** មួយទៅសន្ទស្សន៍ថ្លៃ **Index** មួយទៀត។ ជាធម្មតា សន្ទស្សន៍ថ្លៃភាគហ៊ុន **Index** មានចំនួនភាគហ៊ុនច្រើនជាងសន្ទស្សន៍ថ្លៃភាគហ៊ុន **Average** ហើយជួនកាលមានគ្រប់ប្រភេទនៃភាគហ៊ុនទាំងអស់ដែលធ្វើការជួញដូរនៅក្នុងទីផ្សារមូលបត្រមួយ។

ភាគច្រើននៃសន្ទស្សន៍ថ្លៃភាគហ៊ុន Average សំខាន់ៗមានទម្ងន់ (Weight) ទៅតាមទំហំនៃទីផ្សារមូលបត្រដែលស្មើនឹងតម្លៃទីផ្សារនៃភាគហ៊ុន គុណនឹងចំនួនភាគហ៊ុនដែលបោះផ្សាយលក់នៅលើទីផ្សារ។ សន្ទស្សន៍ថ្លៃភាគហ៊ុន Average នេះផ្តល់សារៈសំខាន់ច្រើនដល់ក្រុមហ៊ុនទាំងឡាយដែលមានចំណែកទីផ្សារធំ ជាជាងក្រុមហ៊ុនទាំងឡាយណាដែលមានតម្លៃភាគហ៊ុនខ្ពស់។ ប្រសិនបើសន្ទស្សន៍ថ្លៃភាគហ៊ុន Average មិនមានទម្ងន់ នោះការគណនាតម្លៃមានលក្ខណះសាមញ្ញ ដោយយកតម្លៃមធ្យមនៅពេលបិទទ្វារនៃភាគហ៊ុនទាំងអស់ក្នុងសន្ទស្សន៍ថ្លៃ Index។ ជាទូទៅ មានសន្ទស្សន៍ថ្លៃ Index នឹងសន្ទស្សន៍ថ្លៃ Average សម្រាប់គ្រប់ទីផ្សារទាំងអស់ ហើយសន្ទស្សថ្លៃនេះ គឺជាការប្រៀបធៀប (Benchmark) ដោយយកសម្ថភាពការវិនិយោគមកធ្វើការវិនិច្ឆ័យ។ រាល់សំណុំវិនិយោគ (Portfolio) គឺត្រូវបានធ្វើការប្រៀបធៀបជាមួយសន្ទស្សន៍ថ្លៃ Index ឬសន្ទស្សន៍ថ្លៃ Average ដោយផ្អែកលើប្រភេទនៃការវិនិយោគទាំងឡាយដែលកាន់កាប់ដោយវិនិយោគិន។ សំណុំវិនិយោគ (Portfolio) ដែលកាន់កាប់ដោយក្រុមហ៊ុនធំៗ ត្រូវបានយកមកប្រៀបធៀបជាមួយតារាងសន្ទស្សន៍ថ្លៃ Index សម្រាប់ទីផ្សារមូលបត្រដែលធ្វើការជួញដូរភាគហ៊ុនដែលមានចំនួនច្រើន ពោលគឺសំណុំដែល

កាន់កាប់ភាគហ៊ុននៃក្រុមហ៊ុនបច្ចេកវិទ្យាខ្ពស់ៗ (High Technology Stocks) ត្រូវធ្វើការប្រៀបធៀបជាមួយសន្ទស្សន៍ថ្លៃ Index នៅក្នុងទីផ្សារមូលបត្ររបស់ក្រុមហ៊ុនទាំងនោះ។

ចំពោះសញ្ញាបណ្ណ បញ្ហាមួយដែលលំបាកក្នុងការរៀបចំសន្ទស្សន៍ថ្លៃ Index ឬសន្ទស្សន៍ថ្លៃ Average គឺអាយុកាលនៃសញ្ញាបណ្ណមានកាលកំណត់។ ខុសពីភាគហ៊ុនដែលអាយុកាលរបស់វាមានរយៈពេលយូរអង្វែង ភាគច្រើនអាយុកាលនៃសញ្ញាបណ្ណបំណុល ត្រូវបានគេដឹង និងស្គាល់នៅពេលបោះផ្សាយ។ បន្ថែមពីលើនេះទៅទៀត ជាទូទៅការបោះផ្សាយសញ្ញាបណ្ណឋកជន (Corporate Bonds) មិនមានឥណប្រតិទានច្បាស់លាស់ មានសញ្ញាបណ្ណឋកជនខ្លះត្រូវបានគេទិញត្រឡប់វិញនៅមុនកាលបរិច្ឆេទឥណប្រតិទានជាក់លាក់របស់សញ្ញាបណ្ណ ដែលបានបោះផ្សាយ។ សញ្ញាបណ្ណប្រភេទនេះត្រូវបានគេឲ្យឈ្មោះថា Callable Bonds)។

បញ្ហាស្មុគស្មាញមួយសំខាន់ជាងនេះទៅទៀតគឺថា សន្ទនស្សន៍ថ្លៃ Index និងសន្ទស្សន៍ថ្លៃ Average របស់សញ្ញាបណ្ណអាចត្រូវបានដាក់តម្លៃផងដែរទាំងនៅលើតម្លៃជាមូលដ្ឋានមួយ ឬកម្រិតទិន្នផលជាមូលដ្ឋាន (Yield Basis) មួយ។ ក្នុងអតីតកាល សន្ទស្សន៍ថ្លៃនៃសញ្ញាបណ្ណត្រូវបានពឹងផ្អែកលើតម្លៃនៃមូលបត្រខណៈពេលក្រោយមកទៀតគឺត្រូវផ្អែកលើចំណូលនៃមូលបត្រដែលនឹងត្រូវលក់នៅលើទីផ្សារ។

សន្ទស្សន៍ថ្លៃ Index នៃសញ្ញាបណ្ណ ជាធម្មតាត្រូវបានយកប្រើប្រាស់ដោយវិនិយោគិនប្រកបដោយវិជ្ជាជីវៈ (Professional Investors) ប៉ុណ្ណោះ ហើយបន្ទាប់មកដោយវិនិយោគិនដែលមានឋកទេសក្នុងមូលបត្រ ដែលមានចំណូលថេរ (Fixed income) តែប៉ុណ្ណោះ៕

# មេរៀនទី ១០
# ប្រភេទផ្សេងៗ នៃមូលបត្រ
## Types of Securities

មានប្រភេទខុសៗគ្នានៃមូលបត្រ ដែលត្រូវបានគេធ្វើការជួញដូរនៅលើទីផ្សារមូលបត។ ប្រភេទមូលបតទាំងនេះ អាចត្រូវបានគេជួញដូរនៅលើទីផ្សារមូលបត្រផ្សេងៗគ្នា ឬទីផ្សាររំលង បញ្ជរខុសៗគ្នា។ មូលបតចែកចេញជាពីរប្រភេទធំៗគឺៈ

១. ប្រភេទមូលបត្របំណុលសញ្ញាបណ្ណ″ (Bonds)

២. ប្រភេទមូលបត្រកម្មសិទ្ធិ ″ភាគហ៊ុន‶ (Equities Securities)

### ១០.១.ប្រភេទសញ្ញាបណ្ណ (Bonds)

មូលបត្រប្រភេទនេះ ធ្វើការជួញដូរក្នុងទម្រង់ជាឧបករណ៍បំណុល ដែលបានបោះផ្សាយដោយរដ្ឋាភិបាល ភ្នាក់ងាររដ្ឋាភិបាលផ្សេងៗដូចជាៈ សាលាក្រុង (Municipalities) និងក្រុមហ៊ុនសាជីវកម្ម (Corporations) ជាធម្មតា ទីផ្សារសញ្ញាបណ្ណទាក់ទាញការចាប់អារម្មណ៍ខ្លាំងពី សំណាក់វិនិយោគិនវិជ្ជាជីវៈ (Professional Investors) និងវិនិយោគិនជាស្ថាប័ន (Institutional Investors ជាងពីសាធារណជនទូទៅ វិនិយោគិនជាស្ថាប័នរួមមានមូលនិធិសោធននិវត្តន៍ ក្រុមហ៊ុនធានារ៉ាប់រង ធនាគារវិនិយោគ ព្រមទាំងគម្រោងវិនិយោគរួម (Collective Investment Scheme - CIS) សញ្ញាបណ្ណ គឺជាកម្ចីរយៈពេលវែងមួយដែលបោះផ្សាយក្នុងទម្រង់ជាមូលបតដែលអាច ចរចារបាន ដោយក្រុមហ៊ុនសាជីវកម្មមួយ រដ្ឋាភិបាល ឬភ្នាក់ងាររបស់រដ្ឋាភិបាលមួយ។ សញ្ញ បណ្ណទាំងអស់គឺជាកម្ចីដែលផ្តល់ដោយអ្នកកាន់កាប់សញ្ញាបណ្ណ (អ្នកទិញ) ទៅឲ្យក្រុមហ៊ុនបោះ ផ្សាយសញ្ញាបណ្ណ (អ្នកលក់)។ សញ្ញាបណ្ណមួយ គឺជាការសន្យាមួយរបស់ក្រុមហ៊ុនបោះផ្សាយថា នឹងសងត្រលប់មកវិញនូវចំនួនដែលបានឲ្យខ្ចីដល់អ្នកទិញសញ្ញាបណ្ណ (ហៅថាប្រាក់ដើម) រួម ជាមួយការប្រាក់ដែលបានព្រមព្រៀងនៅពេល ឬមុនពេលបោះផ្សាយសញ្ញាបណ្ណ ការប្រាក់ អាចត្រូវបង់ជាដំណាក់កាលនៅក្នុងអំឡុងពេលនៃការឲ្យខ្ចី ឬក៏មិនអញ្ចឹងទេ បង់ផ្តាច់តែមួយដង នៅពេលដែលប្រាក់កម្ចីត្រូវសងត្រឡប់ទៅម្ចាស់បំណុលវិញ។ សញ្ញាបណ្ណ ត្រូវបានហៅម្យ៉ាង ទៀតថា ឧបករណ៍វិនិយោគហិរញ្ញវត្ថុដែលមានចំណូល ពីព្រោះថាបរិមាណនៃចំណូលមូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រដែលសញ្ញាបណ្ណនឹងផ្តល់ឲ្យគឺថេរ ដោយបញ្ជាក់ពីអត្រាការប្រាក់នៃសញ្ញាបណ្ណនោះរួចជា ស្រេច។ កាលបរិច្ឆេទនៅពេលដែលកម្ចីនោះត្រូវសងត្រឡប់វិញ ត្រូវបានហៅថា‶ ឥណប្រតិទាន" (Maturity) នៃសញ្ញាបណ្ណ។ ប្រាក់កម្ចីត្រូវបានតំណាងដោយឯកសារមួយសន្លឹក និងត្រូវបង់ការប្រាក់ជាតំណាក់កាល នៅអំឡុងពេលនៃការសុំខ្ចី។ បណ្ណបញ្ជាក់នេះ អាចមានជាខ័ណ្ឌបណ្ណ (Coupon) ដែលអាចបោក ចេញបានពីវិញ្ញាបនបតសញ្ញាបណ្ណ និងត្រូវបង្ហាញ (Present) ទៅភ្នាក់ងារទូទាត់ (Paying Agent) នៃក្រុមហ៊ុនបោះផ្សាយដែលជាទូទៅគឺជាធនាគារពាណិជ្ជសម្រាប់ទូទាត់សាច់ប្រាក់។ ដោយ ហេតុផលនេះហើយ ទើបពួកគេហៅថា ខ័ណ្ឌបណ្ណ

សញ្ញាបណ្ណ (Coupon Bonds)។ ទោះបីជា ខ័ណ្ឌបណ្ណលែងត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយក៏ដោយ ក៏ការប្រាក់ដែលសញ្ញាបណ្ណ មួយទូទាត់នៅតែត្រូវបានគេហៅថាជាអត្រាខ័ណ្ឌបណ្ណសញ្ញាបណ្ណ (Coupon Rate) និងសញ្ញ បណ្ណនៅតែត្រូវបានគេហៅថា ខ័ណ្ឌបណ្ណសញ្ញាបណ្ណ។ អ្នកកាន់កាប់សញ្ញាបណ្ណនេះ ត្រូវបានគេសម្គាល់ដោយបុគ្គលដែលកាន់វានៅក្នុងដៃ។ សញ្ញាបណ្ណគាហក (Bearer Bonds) គឺជាកម្មសិទ្ធិរបស់បុគ្គលដែលកាន់វានៅក្នុង និងភាពជា ម្ចាស់នៃសញ្ញាបណ្ណនេះពុំមានកត់ត្រាទុកទេ។ ទម្រង់នៃភាពជាម្ចាស់បែបនេះមានហានិភ័យនៅ ពេលបាត់បង់ ដោយសារការកត់ត្រាកម្មសិទ្ធិក នៃសញ្ញាបណ្ណមានលក្ខណៈអាណាមិក (Anonymity) - កម្រិតខ្ពស់ ដែលជាហេតុធ្វើឲ្យនៅក្នុងប្រទេសខ្លះគេលែងអនុញ្ញាតឲ្យចេញលិខិត បញ្ជាក់កម្មសិទ្ធិករនេះទៀតហើយ តួយ៉ាងដូចជានៅក្នុងសហរដ្ឋអាមេរិកជាដើម។ ប្រភេទសាមញ្ញផ្សេងទៀតនៃទម្រង់សញ្ញាបណ្ណ គឺជាសញ្ញាបណ្ណដែលចុះបញ្ជីពេញ លេញ ទាំងក្នុងទម្រង់លិខិតបញ្ជាក់ ទាំងក្នុងការកត់ត្រា (Book Entry)។ ឈ្មោះម្ចាស់សញ្ញាបណ្ណ ត្រូវបានកត់ត្រាទុកជាមួយនឹងភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ (Transfer Agents) ហើយការទូទាត់ ការប្រាក់ត្រូវបានធ្វើឡើងដោយមូលប្បទានបត្រ (Checks) ឬក៏តាមប្រព័ន្ធអេឡិចត្រូនិក (Electronic System)។ វិធីសាស្ត្រការកត់ត្រា (Book Entry) ដោយមិនមានបណ្ណបញ្ជាក់ណាមួយត្រូវបានបោះ ផ្សាយដោយកម្មសិទ្ធិករ គឺគ្រាន់តែកត់ត្រានៅក្នុងសៀវភៅធំមួយ (Ledger) ដែលកំពុងតែពេញ និយម ដោយសារតែវាជួយកាត់បន្ថយតម្លៃនៃការផ្ទេរកម្មសិទ្ធិ វាមានលក្ខណៈសាមញ្ញ និងបន្ថយ លទ្ធភាពនៃការបាត់បង់ ឬការលួចជាដើម។ ហេតុផលដែលសញ្ញាបណ្ណមួយ ត្រូវបានគេហៅថាឧបករណ៍បំណុលមួយគឺដោយសារ សញ្ញាបណ្ណមិនមានសិទ្ធិលើកម្មសិទ្ធិណាមួយ (Ownership Right) នៅក្នុងក្រុមហ៊ុនដែលបានបោះ ផ្សាយនោះទេ។ ការសន្យាសងបំណុលគឺជាចំណុចខុសគ្នា (Distinguishes) រវាងសញ្ញាបណ្ណនិង ភាគហ៊ុន (Stocks)។ អ្នកកាន់កាប់សញ្ញាបណ្ណ គឺជាម្ចាស់បំណុល (Creditor) ចំណែកឯអ្នកកាន់ កាប់ភាគហ៊ុន គឺជាម្ចាស់របស់ក្រុមហ៊ុន។ ទោះជាយ៉ាងណាអ្នកកាន់កាប់សញ្ញាបណ្ណឯកជន មិនមានសិទ្ធិបោះឆ្នោត និងចូលរួមក្នុងការបែងចែកប្រាក់ចំណេញសុទ្ធនោះទេ តែពួកគេអាច ទាមទារការទូទាត់ពេញលេញនៃសញ្ញាបណ្ណរបស់ពួកគេ ទោះបីជាក្រុមហ៊ុនបោះផ្សាយកំពុង ប្រឈមមុខនឹងការក្ស័យធន (Bankruptcy) ក៏ដោយ។ ផ្ទុយមកវិញ ភាគហ៊ុនិកមិនមានសិទ្ធិយ៉ាង នោះទេ ក្នុងករណីមានការជម្រះបញ្ជី (Liquidation) ឬការក្ស័យធននៃក្រុមហ៊ុនបោះផ្សាយនោះអ្នកកាន់កាប់សញ្ញាបណ្ណត្រូវបានទូទាត់មុនភាគហ៊ុនិ (Shareholders) របស់ក្រុមហ៊ុន។ អ្នកកាន់ កាប់សញ្ញាបណ្ណត្រូវបានគេនិយាយថា មានសិទ្ធិជាអាទិភាព (Superior Claim) ទៅលើទ្រព្យសកម្ម នៃក្រុមហ៊ុនបោះផ្សាយ។ អ្នកកាន់កាប់សញ្ញាបណ្ណ គឺជាម្ចាស់បំណុលសំខាន់បំផុតនៅក្នុងការ ការពារដោយនិយ័តករ ព្រមទាំងច្បាប់ និងបទប្បញ្ញត្តិមូលបត្រនៃប្រទេសនិមួយៗ។ ជាទូទៅ គេចែកសញ្ញាបណ្ណជាច្រើនប្រភេទដូចខាងក្រោម៖

### ១០.១.១. សញ្ញាបណ្ណបំណុលទូទៅ និងសញ្ញាបណ្ណប្រាក់ចំណូល (General Obligation and Revenue Bonds)

សញ្ញាបណ្ណបំណុលទូទៅ និងសញ្ញាបណ្ណប្រាក់ចំណូល (General Obligation and Revenue Bonds) ទូទៅសំដៅទៅលើសញ្ញាបណ្ណរបស់រដ្ឋាភិបាល និងពោរពេញទៅដោយការជឿជាក់ និងធានាដោយអំណាចនសារពើពន្ធ (Taxing Power) ដើម្បីបោះផ្សាយសញ្ញាបណ្ណបំណុលទាំង នេះ។ ភ្នាក់ងារដែលមានសិទ្ធិបោះផ្សាយសញ្ញាបណ្ណបំណុលនេះបានគឺមានតែភ្នាក់ងាររបស់ប្រទេសមួយ ឬសាលាក្រុងមួយ។ ល។
ចំពោះសញ្ញាបណ្ណប្រាក់ចំណូល (Revenue : Bonds) វិញគឺជាសញ្ញាបណ្ណដែលអាចធ្វើការ ទូទាត់បានតែពីប្រភពជាក់លាក់មួយចំនួននៃចំណូលពន្ធនានាដូចជា កម្រៃប្រើប្រាស់ផ្លូវ Highways វិក្កយបត្រប្រើប្រាស់ទឹក ភ្លើងជាដើម។ សញ្ញាបណ្ណបំណុលទាំងនេះ មិនស្ថិតនៅក្រោមអំណាច សារពើពន្ធទូទៅ នៃភ្នាក់ងារបោះផ្សាយសញ្ញាបណ្ណនោះទេ។

### ១០.១.២. សញ្ញាបណ្ណរតនាគារ ឬរដ្ឋាភិបាល (Treasury/Government Bonds)

តម្រូវការហិរញ្ញប្បទានរយៈពេលវែងរបស់ប្រទេសមួយ ត្រូវបានបំពេញបន្ថែមតាមរយៈ ការបោះផ្សាយសញ្ញាបណ្ណដែលមានឥណប្រតិទានលើសពីមួយឆ្នាំ រហូតដល់រយៈពេលចាំបាច់ របស់ប្រទេសនោះ ព្រមទាំងស្របតាមសាធារណជនដែលមានបំណង ឬឆន្ទៈក្នុងការវិនិយោគ សាច់ប្រាក់របស់ពួកគេ។ រយៈពេលជាមធ្យមរបស់សញ្ញាបណ្ណរបស់រតនាគារជាតិ ឬរបស់មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្ររដ្ឋាភិបាល រហូតដល់២០ឆ្នាំ ទៅ៣០ឆ្នាំ ហើយដែលគេហៅថា សញ្ញាបណ្ណរយៈពេលវែង។ សញ្ញាបណ្ណរយៈពេលវែងទាំងនេះ ត្រូវបានតាមដានយ៉ាងយកចិត្តទុកដាក់ដោយទីផ្សារតាម រយៈតារាងសូចនាករ (Indicator) អំពីបម្រែបម្រួលនៃអត្រាការប្រាក់រយៈពេលវែង។ មានសញ្ញាបណ្ណរយៈពេលវែងខ្លះអាចទិញត្រឡប់មកវិញ (Callable Bonds) មុនពេល ឥណប្រតិទានរបស់សញ្ញាបណ្ណមកដល់ នេះមានន័យថា ក្រុមហ៊ុនបោះផ្សាយសញ្ញាបណ្ណមាន សិទ្ធិបង់ផ្តាច់ (ទិញវិញ) លើតម្លៃសញ្ញាបណ្ណមុនកាលបរិច្ឆេទឥណប្រតិទានរបស់សញ្ញាបណ្ណមក ដល់។ ប្រសិនបើ សញ្ញាបណ្ណមួយដែលផ្តល់សិទ្ធិឲ្យក្រុមហ៊ុនបោះផ្សាយមានសិទ្ធិបង់ផ្តាច់ (Pay Off) តម្លៃសញ្ញាបណ្ណមុនកាលបរិច្ឆេទឥណប្រតិទានមកដល់ សញ្ញាបណ្ណនេះត្រូវមានបញ្ជាក់ពី កាលបរិច្ឆេទទាំងពីរនៅពេលចុះបញ្ជីរបស់សញ្ញាបណ្ណ។ ឧទាហរណ៍៖ សញ្ញាបណ្ណមួយមានការ ប្រាក់ ៥ %និងមានកាលបរិច្ឆេទឥណប្រតិទានក្នុងខែមិថុនា ឆ្នាំ ២០១០ ប៉ុន្តែសញ្ញាបណ្ណនេះអាច បង់ផ្តាច់បានបន្ទាប់ពីខែមិថុនា ឆ្នាំ២០០៥ នេះតទៅ ដូចនេះសញ្ញាបណ្ណនេះ ត្រូវសរសេរថា " អត្រាការប្រាក់ ៥ %កាលបរិច្ឆេទឥណប្រតិទានគឺខែមិថុនា ឆ្នាំ ២០០៥ ដល់ ២០១០។ ជាធម្មតា ភ្នាក់ងារបោះផ្សាយសញ្ញាបណ្ណរដ្ឋាភិបាល បោះផ្សាយសញ្ញាបណ្ណដែលអាចទិញត្រឡប់មកវិញ បានក្នុងអំឡុងពេលដែលអត្រាការប្រាក់នៅលើទីផ្សារមានកម្រិតខ្ពស់ ធ្វើដូច្នេះ ដើម្បីឲ្យ មានឱកាសក្នុងការទិញត្រឡប់មកវិញ បានឆាប់មុនពេលការប្រាក់ធ្លាក់

ចុះ។ បន្ទាប់ពីទិញ សញ្ញាបណ្ណវិញ រដ្ឋាភិបាលអាចបោះផ្សាយសញ្ញាបណ្ណថ្មីក្នុងកម្រិតអត្រាការប្រាក់មួយទាប។

### ១០.១.៣. បណ្ណរតនាគារ ឬរដ្ឋាភិបាល (Treasury/Government Notes)

ជាទូទៅ បណ្ណរតនាគារ ឬបណ្ណរដ្ឋាភិបាលមានឥណប្រតិទានពី ២ឆ្នាំ ទៅ ១០ឆ្នាំ យ៉ាង យូរ ហើយត្រូវបានគេស្គាល់ថាជាឧបករណ៍វិនិយោគ (Investment Instruments) ដែលមានរយៈ ពេលមធ្យម (Intermediate Term)។ បណ្ណរតនាគារ មិនអាចទិញត្រឡប់វិញមុនកាលបរិច្ឆេទឥណ ប្រតិទានរបស់វា ហើយបណ្ណរតនាគារទាំងអស់ ជាធម្មតាត្រូវបង់ការប្រាក់រៀងរាល់ ៦ខែម្តង (Semi-annually)

### ១០.១.៤. បណ្ណបំណុលរតនាគារ ឬរដ្ឋាភិបាល (Treasury/Government Bills)

បណ្ណបំណុលរតនាគារ ឬបណ្ណបំណុលរដ្ឋាភិបាល (T-Bills/Government Bills) គឺជាមូលបត្របំណុលរយៈពេលខ្លីបំផុត ដែលជាធម្មតា ឥណប្រតិទានរបស់មូលបត្រនេះ មានចាប់ពី ៣, ៦, ៩, ឬ១២ ខែ។ T-Bills មិនមានខ័ណ្ឌបណ្ណ (Coupon) ឬអត្រាការប្រាក់ទេ ប៉ុន្តែត្រូវលក់ក្នុងតម្លៃមួយដែលស្មើនឹងតម្លៃចារឹក (Par) ដកតម្លៃអប្បហា (Discount) តម្លៃចារឹកគឺជាតម្ល នៃសញ្ញាបណ្ណ នេះមានន័យថា តម្លៃបង់សម្រាប់ T-Bills មួយគឺតិចជាងតម្លៃនៅឥណប្រតិទាន។ សម្រាប់បណ្ណបំណុល T-Bills ដែលមានរយៈពេលឥណប្រតិទាន១២ខែ និងមានការប្រាក់ ៥ %នឹងត្រូវលក់ក្នុងតម្លៃមួយដែលមានអត្រាអប្បហារ ៥% (5% Discount) នៃតម្លៃចារឹក (Face Value) សញ្ញាបណ្ណ។

### ១០.១.៥. សញ្ញាបណ្ណចែករំលែកប្រាក់ចំណេញ (Participating Bonds)

សញ្ញាបណ្ណប្រភេទនេះ មិនត្រឹមតែផ្តល់អត្រាការប្រាក់ក្នុងកម្រិតថេរមួយនេះទេ ប៉ុន្តែថែមទាំងមានការចែករំលែកប្រាក់ចំណេញ (Profit) ផងដែរ ចំពោះវិនិយោគិនវិនិយោគលើសញ្ញ បណ្ណប្រភេទនេះ។ អ្នកកាន់កាប់សញ្ញាបណ្ណនេះ មានសិទ្ធិចូលរួមជាមួយភាគហ៊ុនិកដ៏ទទៀត (Shareholders) ក្នុងការចែកប្រាក់ចំណេញរបស់សាជីវកម្មដែលទទួលបាននៅក្នុងទំហំមួយ ដូច មានចែងនៅក្នុងកិច្ចសន្យាទិញសញ្ញាបណ្ណ។ សញ្ញាបណ្ណប្រភេទនេះ ត្រូវបានបោះផ្សាយ និង ជួញដូរយ៉ាងទូលំ ទូលាយនៅក្នុងប្រទេសមួយចំនួននៅអឺរ៉ុប ហើយជាធម្មតាត្រូវបានបោះផ្សាយ ដោយក្រុមហ៊ុនទន់ខ្សោយមួយចំនួន ដែលជួយទាក់ទាញឲ្យមានការទិញច្រើនតាមរយៈការផ្តល់ អត្ថប្រយោជន៍បន្ថែមលើការទិញសញ្ញាបណ្ណ។

### ១០.១.៦. សញ្ញាបណ្ណដែលអាចប្តូរបាន (Convertible Bonds)

ជាទូទៅ វិនិយោគិនទាំងអស់ដែលកាន់កាប់សញ្ញាបណ្ណ គឺសង្ឃឹមថានឹងទទួលបានប្រាក់ដើមព្រមទាំងការប្រាក់នៅពេលដែលគេវិនិយោគទិញសញ្ញាបណ្ណ។ ប៉ុន្តែ មានការលើកលែងខ្លះ ចំពោះស

ញ្ញបណ្ណ ក្នុងករណីដែលវិនិយោគលើសញ្ញាបណ្ណដែលអាចប្តូរបាន (Convertible Bonds)។ សញ្ញាបណ្ណដែលអាចប្តូរបាន គឺជាសញ្ញាបណ្ណមួយដែលនៅឥណប្រតិទាន ឬនៅក្នុង កាលបរិច្ឆេទដែលបានបញ្ជាក់ណាមួយនោះ សញ្ញាបណ្ណអាចត្រូវបានគេប្តូរទៅជាចំនួនណា មួយនៃភាគហ៊ុនដែលអាចបោះឆ្នោតបាន (Common - Shares) នៅក្នុងសាជីវកម្មមួយ។ ក្រុមហ៊ុន សាជីវកម្មថ្មីមួយដែលមិនមានសាច់ប្រាក់ច្រើន ឬមិនធ្លាប់មានលទ្ធភាពទូទាត់ សងផ្តាច់ (Pay Off) សញ្ញាបណ្ណដែលបានបោះផ្សាយ ឬក៏ក្រុមហ៊ុនសាជីវកម្មទាំងឡាយណាដែលមានកម្រិតលទ្ធភាព សងបំណុលទាប (Low Credit Rating) ក្រុមហ៊ុននោះអាចមានជម្រើសបោះផ្សាយសញ្ញាបណ្ណដែលមូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រអាចប្តូរបាន ពីព្រោះថាចំណាយសម្រាប់ការបោះផ្សាយសញ្ញាបណ្ណគឺមានទំហំធំពេក។ សញ្ញបណ្ណដែលអាចប្តូរបាន មានសិទ្ធិអាទិភាពនៅក្រោយសញ្ញាបណ្ណធំៗផ្សេងទៀត ប៉ុន្តែទទួលបាន មុនមូលបត្រកម្មសិទ្ធិនានាក្នុងការទាមទារទ្រព្យសកម្មរបស់ក្រុមហ៊ុននៅពេលទូទាត់បំណុល។

### ១០.១.៧. សញ្ញាបណ្ណដែលមានខ័ណ្ឌបណ្ណសូន្យ (Zero Coupon Bonds)

ជាធម្មតា សញ្ញាបណ្ណមានខណ្ឌបណ្ណសូន្យ សំដៅលើសញ្ញាបណ្ណដែលបោះផ្សាយ លក់ក្នុងថ្លៃអប្បហា (Discount នៃតម្លៃចារឹករបស់សញ្ញាបណ្ណ។ មិនដូចសញ្ញាបណ្ណនានាទ សញ្ញាបណ្ណដែលមានខ័ណ្ឌបណ្ណស្មើសូន្យ គឺមិនបង់ការប្រាក់ និងការសងរំលោះ (Redemption) សញ្ញាបណ្ណទេ ក្នុងអំឡុងបោះផ្សាយ ប៉ុន្តែលើកលែងតែនៅឥណប្រតិទាននៃសញ្ញាបណ្ណ។ ទោះ បីជាអ្នកកាន់កាប់សញ្ញាបណ្ណនោះមិនទទួលបានចំណូលពីការវិនិយោគលើសញ្ញាបណ្ណក៏ដោយ ក៏ទិន្នផលសញ្ញាបណ្ណនៅឥណប្រតិទានត្រូវបានគណនាក្នុងការសន្មតថា ខ័ណ្ឌបណ្ណ (Coupon) ត្រូវយកទៅវិនិយោគជាថ្មីនៅកម្រិតអត្រាដំបូង (Prevailing Rate) នៅពេលដែលបានទទួលដំបូង។ ជាលទ្ធផល ខណៈអត្រាការប្រាក់ធ្លាក់ចុះ ការវិនិយោគឡើងវិញរបស់សញ្ញាបណ្ណត្រូវបន្តក្នុង កម្រិតអត្រាការប្រាក់ដែលទាប តម្លៃសញ្ញាបណ្ណនឹងធ្លាក់ចុះ ក៏ប៉ុន្តែខ័ណ្ឌបណ្ណ (Coupon) ត្រូវបាន វិនិយោគជាថ្មីឡើងវិញនៅកម្រិតអត្រាមួយខ្ពស់ ដែលធ្វើឲ្យកើនឡើងនូវទិន្នផលនៅឥណប្រតិ ទាននៃសញ្ញាបណ្ណ។ ដោយមិនមានចលនាសាច់ប្រាក់ (CashFlow) កើតចេញពីការទូទាត់ខ័ណ្ឌ បណ្ណ ហើយដែលការណ៍នេះ ក្លាយទៅជាបន្ទុកមួយក្នុងការវិនិយោគ។ តម្លៃសញ្ញាបណ្ណនេះ មានការកើនឡើង ឬធ្លាក់ចុះយ៉ាងលឿនស្របទៅតាមការប្រែប្រួលបន្តិចបន្តួចនៃអត្រាការប្រាក់។ ក្នុងពេលដែលអត្រាការប្រាក់កើនឡើងខ្ពស់ សញ្ញាបណ្ណដែលមានខ័ណ្ឌបណ្ណស្មើសូន្យ ទទួល បានការពេញនិយមពីសំណាក់វិនិយោគិន ដើម្បីទប់មិនឲ្យមានការប្រែប្រួលក្នុងអត្រាការប្រាក់ ឡើងខ្ពស់ទាំងនោះ។

### ១០.១.៨. សញ្ញាបណ្ណមានអត្រាទិន្នផលខ្ពស់ (High Yield "Junk" Bonds)

ចំណាត់ថ្នាក់វាយតម្លៃខ្ពស់បំផុតចំនួនបួន (Top Four Ranking) របស់រាល់ភ្នាក់ងារវាយ តម្លទាំងអស់ ត្រូវបានគេស្គាល់ថាជា" កម្រិតវិនិយោគ" (Investment Grades)។ សញ្ញាបណ្ណទាំងឡាយណាដែលស្ថិតក្នុងចំណាត់ថ្នាក់នេះ ជាទូទៅត្រូវបានគេទិញសម្រាប់គណនីនៃកិច្ចសន្យា ជានា

(Fiduciary Accounts) លើកលែងតែសញ្ញាបណ្ណខ្លះដែលមានការហាមឃាត់ពិសេសណាមួយ។ គណនីនៃកិច្ចសន្យាជានា រួមមានទាំងផែនការប្រាក់សោធននិវត្តន៍ (Pension Plans) ព្រមទាំងគណនីធនាគារមួយចំនួនដែលគេឲ្យឈ្មោះថា Bank Trust Accounts។ សញ្ញាបណ្ណទាំង ឡាយណាដែលត្រូវបានវាយតម្លៃនៅក្រោមកម្រិតវិនិយោគ ត្រូវបានគេហៅថា Junk Bonds ប៉ុន្តែ នៅក្នុងទីផ្សារមូលបត វាត្រូវបានគេហៅថា សញ្ញាបណ្ណដែលមានទិន្នផលខ្ពស់ (High-yield Bond)។ វាត្រូវបានគេហៅថា" unk" ពីព្រោះគេពិពណ៌នាអំពីគុណភាព (Quality) នៃសញ្ញាបណ្ណនេះ។ ឈ្មួញជើងសារមូលបត និងពាណិជ្ជករមូលបត (Brokers and Dealers) ពេញចិត្តនឹងហៅថា High-yield. Bond ពីព្រោះវាមានលក្ខណៈល្អប្រសើរ និងដោយសារវាបង្ហាញទិន្នផលមកជាមួយ។ ទិន្នផល (Yield) គឺជាតម្លៃដែលសញ្ញាបណ្ណមួយត្រូវបង់ឲ្យវិនិយោគិន ឬក៏ជាអត្រាការប្រាក់ន សញ្ញាបណ្ណ។ សញ្ញាបណ្ណនេះត្រូវបង់ការប្រាក់មួយក្នុងកម្រិតខ្ពស់ ពីព្រោះវាមានកម្រិតវាយតម្ល ទាប ដូច្នេះហើយកម្រិតហានិភ័យដែលក្រុមហ៊ុនបោះផ្សាយមិនអាចមានលទ្ធភាពសងបំណុល នៃសញ្ញាបណ្ណគឺមានកម្រិតខ្ពស់។ ក្នុងន័យនេះ លទ្ធភាពទទួលបានចំណេញចំពោះវិនិយោគិន ទាំងឡាយត្រូវតែមានកម្រិតខ្ពស់ដែរ ដើម្បីឲ្យមានសមាមាត្រនឹងការប្រថុយប្រថានក្នុងការទទួល ហានិភ័យលើការវិនិយោគរបស់ពួកគេ។ កម្រិតវាយតម្លៃទាប (Low Rating) គឺជាលទ្ធផលដែល ភ្នាក់ងារវាយតម្លធ្វើការរកឃើញថា ក្រុមហ៊ុនបោះផ្សាយមិនមានស្ថានភាពហិរញ្ញវត្ថុរឹងមាំ ( Not in Sound Financial Shape) នឹងមិនអាចសងបំណុលនៃសញ្ញាបណ្ណតាមការសន្យារបស់ខ្លួន។

### ១០.១.៩. សញ្ញាបណ្ណធានា (Warrant Bonds/Bonds with Warrants)

សញ្ញាបណ្ណទាំងនេះផ្តល់សិទ្ធិ (ការធានា) ដើម្បីទិញភាគហ៊ុននភាគហ៊ុនដែលមានសិទ្ធិ បោះឆ្នោត (Common Stock) ក្នុងតម្លជាក់លាក់មួយ។ ជាទូទៅ តម្លជានាខ្ពស់ជាងតម្លៃដែលមាន នៅលើទីផ្សារ។

### ១០.១.១០. សញ្ញាបណ្ណសន្ទស្សន៍ថ្លៃ (Indexed Bonds)

សញ្ញាបណ្ណទាំងនេះ ត្រូវបានប្រើប្រាស់ក្នុងរយៈពេលដែលមានអតិផរណាខ្ពស់ (High Inflation)។ ការទូទាត់ការប្រាក់នៃសញ្ញាបណ្ណនេះ ត្រូវបានធ្វើជាតារាងរៀងទៅតាមអតអតិផរណា (Inflation)។

### ១០.១.១១. ផលបតពាណិជ្ជកម្ម (Commercial Paper)

ផលបតពាណិជ្ជកម្ម (Commercial Paper) គឺជាបណ្ណបំណុលរយៈពេលខ្លី ដែលចេញផ្សាយដោយក្រុមហ៊ុនសាជីវកម្មមួយ។ ផលបត្រពាណិជ្ជកម្មមានកាលបរិច្ឆេទតំណប្រតិទានមួយច្បាស់លាស់ដែលមិនលើសពីមួយឆ្នាំ ហើយជួនកាលមានអាយុកាលតែមួយទៅពីរខែប៉ុណ្ណោះ។ ផលបតពាណិជ្ជកម្ម គឺជាបណ្ណមួយដែលមានតម្លៃប្រែប្រួលខ្លាំង (An Unsecured Promissory Note)

ព្រមទាំងអាចបោះផ្សាយលក់ក្នុងកម្រិតតម្លៃអប្បហារមួយលើតម្លចារឹក (Par_Value) ការប្រាក់ លើផលបត្រពាណិជ្ជកម្ម ជាធម្មតាត្រូវបង់តែនៅពេលកាលបរិច្ឆេទឥណប្រតិទាន។

### ១០.១.១២. មូលបត្រដាក់បញ្ចាំ (Mortgage Backed Securities)

ការដាក់បញ្ចាំ (Mortgage) គឺជាការផ្ទេរឈ្មោះនៃសិទ្ធិកាន់កាប់នៅលើទ្រព្យសម្បត្តិមួយដែលបានដាក់ជាវត្ថុធានាសម្រាប់ការទូទាត់នៃបំណុលមួយ។ នៅពេលដែលបុគ្គលមួយទទួល បានការដាក់បញ្ចាំទៅលើផ្ទះមួយ គាត់ចុះហត្ថលេខាទៅលើឯកសារពីរច្បាប់។ ឯកសារទី១ គឺជា បណ្ណដែលមានការសន្យាថាត្រូវទូទាត់សងបំណុល ហើយឯកសារនេះក៏ដូចទៅនឹងឯកសារមួយ ទៀតដែរ។ ឯកសារបញ្ចាំគឺជាឯកសារដែលផ្លាស់ប្តូរសិទ្ធិកាន់កាប់នៃផ្ទះមួយនោះទៅឲ្យឈ្មោះន ស្ថាប័ន ឬបុគ្គលដែលឲ្យខ្ចីលុយដែលជាមូលបត្រ។ ផ្ទះដាក់បញ្ចាំនោះ គឺដាក់ជាការធានាដើម្បីឲ្យ អ្នកខ្ចីមានទ្រព្យសកម្មធានាលើសញ្ញាបណ្ណ ក្នុងករណីដែលកូនបំណុលមិនអាចមានលទ្ធភាព ទូទាត់បំណុលបាន។ ប្រសិនបើកូនបំណុលមិនអាចសងបំណុលបានទេ នោះម្ចាស់បំណុលមាន សិទ្ធិលក់ផ្ទះដើម្បីទូទាត់បំណុលដែលមាន។ ការដាក់បញ្ចាំត្រូវបានធ្វើរួមគ្នាជាមួយការដាក់បញ្ចាំផ្សេងទៀតដើម្បីបង្កើតបានជាអ្វីមួយ ដែលត្រូវបានគេហៅថាជាមូលបត្រដាក់បញ្ចាំ (Mortgage Backed Securities)។ មូលបតទាំងនេះ ត្រូវបានធានាដោយការដាក់បញ្ចាំភ្ជាប់ជាមួយ ការទូទាត់ត្រូវបានធ្វើឡើងតាមរយៈអ្នកជំពាក់ បំណុល (Debtor) ឬហៅម្យ៉ាងទៀតថា" កូនបំណុល "ជាមួយវិនិយោគិនមូលបត្រ។ ការដាក់បញ្ចាំ នេះអាចត្រូវបានលក់នៅលើទីផ្សារ ហើយមិនចាំបាច់កាន់កាប់មូលបត្ររហូតទាល់តែបំណុល ត្រូវបានទូទាត់នោះទេ។ ដំណើរការនៃការដោះដូរទ្រព្យសកម្ម ទៅជាមូលបត្រដែលអាចជួញដូរបានសម្រាប់លក់ បន្តនៅក្នុងទីផ្សារហិរញ្ញវត្ថុយ៉ាងដូចនេះ ត្រូវបានគេស្គាល់ថាជា មូលបត្រនីយកម្ម (Securitizing) នៃទ្រព្យសកម្ម។ មូលបត្រដាក់បញ្ចាំអាចត្រូវបានលក់នៅតម្លៃប្រាក់ដើម និងការប្រាក់ (Principal and Interest) ឬលក់នៅតម្លៃប្រាក់ដើម (Principal) ឬនៅតម្លការប្រាក់ប៉ុណ្ណោះដែលត្រូវបានផ្តល់ទៅឲ្យអ្នកទិញ។

## ១០.២. ប្រភេទមូលបត្រកម្មសិទ្ធិ (Securities Equities)

ការយកចិត្តទុកដាក់ជាចម្បងរបស់និយ័តករមូលប ...គឺទៅលើទីផ្សារមូលបត្រកម្មសិទ្ធិ ពីព្រោះមូលបត្រកម្មសិទ្ធិទាក់ទាញចំណាប់អារម្មណ៍ខ្លាំងពីសំណាក់សាធារណជន ដែលជា ទូទៅមិនសូវមានជំនាញដូចវិនិយោគិនអាជីព ឬវិនិយោគិនជាស្ថាប័នផ្សេងៗ។ នៅលើទីផ្សារនេះ គេច្រើនជួញដូរប្រភេទមូលបត ឬភាគហ៊ុនមានសិទ្ធិបោះឆ្នោត (Common Stocks) ដែលត្រូវបាន បោះផ្សាយដោយក្រុមហ៊ុនសាជីវកម្មនានា។

### ១០.២.១. ភាគហ៊ុនមានសិទ្ធិបោះឆ្នោត (Common Stock)

ក្រុមហ៊ុនសាជីវកម្មទាំងអស់ ធ្វើការបោះផ្សាយភាគហ៊ុនមួយដែលមានសិទ្ធិទទួលការ ទូទាត់ភាគលាភ ឬកម្រៃផ្សេងៗចុងក្រោយគេនៅលើទ្រព្យសកម្មរបស់ក្រុមហ៊ុនសាជីវកម្មដែល បោះផ្សាយភាគហ៊ុនប្រភេទនេះ ក្នុងករណីក្រុមហ៊ុនក្ស័យធន (Bankrupt)។ ភាគហ៊ុនប្រភេទនេះ ត្រូវបានគេដាក់ឈ្មោះថាជាភាគហ៊ុនមានសិទ្ធិបោះឆ្នោត (Common Stock)។ ប៉ុន្តែភាគហ៊ុនមាន សិទ្ធិបោះឆ្នោត ត្រូវបានគេហៅផ្សេងទៀតថា" ភាគហ៊ុនធម្មតា "នៅក្នុងប្រទេសអង់គ្លេស និង អូស្ត្រាលី។ ភាគហ៊ុនធម្មតាគឺជាប្រភេទមូលបត្រទីមួយ ដែលក្រុមហ៊ុនបោះផ្សាយលក់ ហើយក៏ជា ប្រភេទមូលបត្រដែលទទួលបានសិទ្ធិទូទាត់ចុងក្រោយគេ។ ភាគហ៊ុនមានសិទ្ធិបោះឆ្នោត តំណាង ឲ្យកម្មសិទ្ធិករធំៗនៃក្រុមហ៊ុនសាជីវកម្មមួយ ហើយជាទូទៅភាគហ៊ុននេះមានសិទ្ធិបោះឆ្នោតនៅ ក្នុងការចាត់ចែងគ្រប់គ្រងក្រុមហ៊ុន។ នៅពេលដែលក្រុមហ៊ុនមួយក្ស័យធន (Bankrupt) អ្នកកាន់ កាប់មូលបត្រផ្សេងៗរបស់ក្រុមហ៊ុនដូចជាសញ្ញាបណ្ណ និងភាគហ៊ុនបុរិមា (Preferred Stock) នឹង ទទួលបានការទូទាត់មុនភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត។ ដូច្នេះហើយ ភាគហ៊ុនិកមានសិទ្ធិ បោះឆ្នោតអាចមិនទទួលបានអ្វីទាំងអស់សម្រាប់ភាគហ៊ុនរបស់ពួកគ នៅក្នុងពេលដែល ក្រុមហ៊ុនបោះផ្សាយមានជួបបញ្ហាក្ស័យធន (Bankrupt) ឬក៏ត្រូវបានបង្ខំឲ្យធ្វើការជម្រះបញ្ជី (Liquidation)។ ភាគហ៊ុនមានសិទ្ធិបោះឆ្នោត ជាទូទៅ គឺជាភាគហ៊ុនទាំងឡាយណាដែលអាចបោះ ឆ្នោតក្នុងនាមជាសមាជិកក្រុមប្រឹក្សាភិបាល (Board of Directors) នៃក្រុមហ៊ុន ប៉ុន្តែមានការលើក លែងខ្លះចំពោះភាគហ៊ុនបុរិមាមួយចំនួន។

### ១០.២.២. ភាគហ៊ុនបរិមា (Preferred Stock)

ការប្រើពាក្យ" ភាគហ៊ុនបុរិមា "គឺហាក់ដូចជាដាក់ឈ្មោះមិនសមរម្យមួយ។ ប្រភេទន ភាគហ៊ុននេះ ជាទូទៅមិនមានសិទ្ធិបោះឆ្នោតនៅក្នុងក្រុមហ៊ុនទេ ហើយអាយុកាលនៃភាគហ៊ុន នេះមានកម្រិតដូចភាគហ៊ុនមានសិទ្ធិបោះឆ្នោតដែរ។ ពាក្យថា" បុរិមា" (Preferred) គឺសង្កត់ន័យ ថា ភាគហ៊ុននេះមានសិទ្ធិទទួលការបែងចែកភាគលាភ ឬក៏ទាមទារសិទ្ធិទទួលផលលើទ្រព្យ សកម្មទាំងឡាយរបស់ក្រុមហ៊ុនក្នុងករណីក្រុមហ៊ុនជួបប្រទះស្ថានភាពក្ស័យធន មុនពេលធ្វើការ ទូទាត់ទៅឲ្យភាគហ៊ុនិកដែលជាភាគហ៊ុនមានសិទ្ធិបោះឆ្នោត (Common Stock) ប៉ុន្តែនៅត ក្រោយម្ចាស់បំណុលដែលកាន់កាប់សញ្ញាបណ្ណ (Bonds) ដែលបោះផ្សាយដោយក្រុមហ៊ុន។ ភាគលាភរបស់ក្រុមហ៊ុន ជាធម្មតាគេបង្គរទុក ប៉ុន្តែស្ថានការនេះមិនកើតឡើងគ្រប់ពេលនោះទេ។ ភាគលាភត្រូវបែងចែកទៅឲ្យអ្នកកាន់កាប់ភាគហ៊ុនទាំងអស់ ដែលត្រូវបានប្រកាសដោយក្រុម ប្រឹក្សាភិបាលនៃក្រុមហ៊ុនបោះផ្សាយ ដោយផ្អែកទៅលើផលចំណេញដែលទទួលបានរបស់ ក្រុមហ៊ុន។ ភាគលាភ អាចត្រូវបានប្រកាសផ្តល់ឲ្យក្នុងទម្រង់ជា"ប្រាក់ "ឬក៏ភាគហ៊ុនបន្ថែម។ ភាគហ៊ុនបុរិមា អាចត្រូវបានបោះផ្សាយក្នុងទម្រង់មួយដែលគេស្គាល់ថាជាភាគហ៊ុនបុរិមា ដែលអាចប្តូរបាន (Convertible Preferred Stock)។ នេះមានន័យថា ភាគហ៊ុនបរិមាអាចត្រូវបានគ ប្តូរទៅជាភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត (ដែលការណ៍នេះដូចទៅ

នឹងសញ្ញាបណ្ណដែលអាច ប្តូរបាន" Convertible | Bonds")។ នៅពេលដែលភាគហ៊ុនបុរិមាមួយដែលអាចប្តូរបានត្រូវបានគ បោះផ្សាយ ជាទូទៅវាមានសិទ្ធិបោះឆ្នោតដូចគ្នា។

### ១០.២.៣. តម្លៃចារឹកនៃភាគហ៊ុន (Par Value)

ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត ត្រូវបានបោះផ្សាយជាមួយតម្លចារឹកមួយដែលចុះនៅ លើភាគហ៊ុននោះ។ តម្លៃចារឹកនៃភាគហ៊ុន ពាក់ព័ន្ធច្រើនជាមួយគណនេយ្យករ ជាងជាមួយ វិនិយោគិនលើភាគហ៊ុន។ តម្លចារឹកនៃភាគហ៊ុន ត្រូវបានកំណត់ជាក់លាក់ ដោយផ្អែកលើ លក្ខខណ្ឌហិរញ្ញវត្ថុ ឬពន្ធ។ តម្លៃចារឹក តែងតែកំណត់ក្នុងកម្រិតទាបមួយ ដែលជួនកាលមាន ភាគហ៊ុនខ្លះមិនមានតម្លចារឹកនៅលើភាគហ៊ុនតែម្តង។ ប្រសិនបើមានការចុះបញ្ជីនៃតម្លចារឹក នៃភាគហ៊ុនមួយ សារៈសំខាន់តែមួយគត់សម្រាប់វិនិយោគិនគឺថា ភាគហ៊ុននោះមិនអាចត្រូវបាន បោះផ្សាយដោយមានតម្លភាគហ៊ុនទាបជាងតម្លចារឹកនៃភាគហ៊ុននោះទេ។ ភាគហ៊ុនទាំងឡាយណាដែលបោះផ្សាយមានតម្លៃទាបជាងតម្លចារឹករបស់ភាគហ៊ុននោះ ត្រូវបានគេហៅថា ជា" ភាគហ៊ុនមានតម្លៃនៅក្រោមតម្រៃចារឹក" (Watered Stock)។ អាស្រ័យទៅលើច្បាប់ និងបទប្បញ្ញត្តិ នៃបណ្តាប្រទេសនិមួយៗ វិនិយោគិនម្នាក់អាច ទិញភាគហ៊ុន មានតម្លៃនៅក្រោមតម្លៃចារឹក (Watered Stock) ដោយជំពាក់ក្រុមហ៊ុនបោះផ្សាយ ភាគហ៊ុន នូវគម្លាតរវាងតម្លចារឹកនៃភាគហ៊ុន និងតម្លៃដែលវិនិយោគិននោះបង់ជាក់ស្តែង។ តម្ល ចារឹកនៃភាគហ៊ុន គឺពាក់ព័ន្ធតនឹងតម្លៃដើមដែលត្រូវបានបោះផ្សាយដោយក្រុមហ៊ុន។ ភាគហ៊ុន បោះផ្សាយអាចលក់ក្នុងតម្លៃមួយដែលខ្ពស់ ឬទាបជាងតម្លៃចារឹកនៃភាគហ៊ុនដែលជាលទ្ធផលន ការជួញដូរមូលបត ឬភាគហ៊ុននៅលើទីផ្សារបន្ទាប់។ ផ្ទុយពីភាគហ៊ុន តម្លចារឹកនៃសញ្ញាបណ្ណ គឺជាតម្លៃជាក់ស្តែង (Face Amount) នៃសញ្ញាបណ្ណ។

### ១០.២.៤. តម្លៃកត់ត្រា (Book Value)

តម្លៃកត់ត្រា គឺជាតម្លៃជាក់ស្តែងនៃទ្រព្យសកម្មរបស់ក្រុមហ៊ុននៃភាគហ៊ុននិមួយៗ ដែលមានសិទ្ធិបោះឆ្នោតរបស់ក្រុមហ៊ុន។ វាត្រូវបានគណនាដោយបូកតម្លចារឹកជាមួយ ចំនួនលើសនៃមូលធន (Capital Surplus) និងប្រាក់ចំណេញរបស់ក្រុមហ៊ុន (Retained Earnings) ហើយដកចេញនូវទ្រព្យសកម្មអរូបិយ (Intangible Assets) និងចែកឲ្យចំនួន ភាគហ៊ុនដែលលក់នៅលើទីផ្សារ (Outstanding Share) សារៈសំខាន់នៃតម្លកត់ត ជាទូទៅមិនត្រូវបានគេយល់ស្របទាំងស្រុងនោះទេ។ ប្រសិនបើតម្លៃទីផ្សារ (តម្លៃដែល ភាគហ៊ុនត្រូវបានលក់នៅលើទីផ្សារ ទាបជាងតម្លកត់ត្រា ធ្វើឲ្យឈ្មួញ (Speculators) យល់ថា មានវិនិយោគិនខ្លះទិញក្រុមហ៊ុន ហើយលក់ក្រុមហ៊ុនជាផ្នែកតូចៗ (Pieces)។ តម្លៃនៃផ្នែកតូចៗនិមួយៗ ត្រូវបានគេស្គាល់ថា" តម្លៃបំបែក "| Break up Value) របស់ក្រុមហ៊ុន ហើយក្នុងករណីនេះ តម្លៃបំបែក នឹងមានកម្រិតខ្ពស់ជាងតម្លកត់ត្រា។ មានអ្នក ខ្លះទៀតយល់ថា តម្លកត់តនៃភាគហ៊ុនមួយ មិនមានតម្លៃជាក់លាក់ (Inaccurate Value) នោះទេ។ ពួកគេយល់ថា ដោយសារទ្រព្យសកម្មរបស់ក្រុមហ៊ុនត្រូវបានចុះបញ្ជីនៅក្នុង សៀវភៅដែលទ្រព្យសកម្មទាំង

នោះត្រូវបានដកតម្លៃរំលោះចេញ ពេលគឺតម្លចុះបញ្ជី គឺ ជាតម្លៃជាក់ស្តែងនៃទ្រព្យសកម្មទាំងអស់ ឬក៏ តម្លៃលក់ទ្រព្យសកម្មរបស់ក្រុមហ៊ុន ដែលតម្លទាំងនោះមិនមានលក្ខណៈជាក់លាក់ ហើយត្រូវបាន បង្ហាញនៅលើបញ្ជីរបស់ ក្រុមហ៊ុន។

## ១០.២.៥. ប្រភេទនានានៃភាគហ៊ុន ( Classes of Stock )

ជួនកាល ក្រុមហ៊ុនមួយបោះផ្សាយភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត (Common Stock) ច្រើនប្រភេទផ្សេងៗគ្នា។ ភាពខុសគ្នារវាងប្រភេទផ្សេងៗនៃភាគហ៊ុននេះគឺជាទូទៅផ្អែកទៅលើ សិទ្ធិបោះឆ្នោតនៃភាគហ៊ុនទាំងនោះ។ ប្រភេទភាគហ៊ុនខ្លះមានភាពលប់ (Superior) ដែលគេហៅ ថាមានទម្ងន់ (Weighted) ទៅលើសិទ្ធិបោះឆ្នោត។ ប្រភេទភាគហ៊ុនខ្លះទៀត មិនមានសិទ្ធិបោះ ឆ្នោតទាល់តែសោះ។ ជាទូទៅ ប្រភេទផ្សេងៗនៃភាគហ៊ុនត្រូវបានដាក់សញ្ញា (Labelled) ដោយ អក្សរដូចជា ប្រភេទអក្សរ A ឬ B។

## ១០.២.៦. ភាគហ៊ុនបំបែក ( Stock Splits )

ភាគហ៊ុនបំបែកមួយកើតឡើង នៅពេលក្រុមហ៊ុនមួយមានបំណងធ្វើការបែងចែកភាគ ហ៊ុនរបស់ខ្លួន។ ការបំបែកនេះ មិនជះឥទ្ធិពលទៅលើតម្លសុទ្ធ (Net Worth) នៃក្រុមហ៊ុន ឬតម្ល នៃការវិនិយោគរបស់ភាគហ៊ុនិកនោះទេ។ ការបំបែកភាគហ៊ុនគឺគ្រាន់តែបង្កើនការវិនិយោគតាម រយៈការបោះផ្សាយភាគហ៊ុនឲ្យច្រើនឡើង។ ឧទាហរណ៍ ប្រសិនបើក្រុមហ៊ុនមួយមានភាគ ហ៊ុនចំនួន ១លានសន្លឹក ដែលលក់នៅលើទីផ្សារមូលបត ហើយបង្កើនចំនួននេះដល់ ២លាន សន្លឹក។ ក្នុងស្ថានភាពនេះ គេនិយាយថា ក្រុមហ៊ុនបំបែកភាគហ៊ុនមួយជាពីរភាគហ៊ុន ហើយតម្ល នៃភាគហ៊ុនត្រូវបានចែកជាពីរផងដែរ។ ដូច្នេះ អ្នកកាន់កាប់ភាគហ៊ុនចំនួន ១០០សន្លឹកនៃក្រុមហ៊ុននេះ ដែលមានតម្លៃ ១០ដុល្លារ បន្ទាប់ពីការបំបែកភាគហ៊ុនមក ភាគហ៊ុនិកនឹងទទួលបានភាគហ៊ុនចំនួន ២០០សន្លឹកក្នុងតម្ល ដដែល។ ជាទូទៅក្រុមហ៊ុនបំបែកភាគហ៊ុនដើម្បីបន្ទាបតម្លៃរបស់សន្លឹកហ៊ុន និងបង្កើនចំនួន ភាគហ៊ុនដែលមានសក្តានុពល តាមរយៈការធ្វើឲ្យតម្លៃភាគហ៊ុនមានកម្រិតសមរម្យ។ ក្រុមហ៊ុន មួយជាទូទៅ មានបំណងបង្កើនកម្មសិទ្ធិករក្រុមហ៊ុន (Ownership) ដើម្បីឆ្លើយតបនឹងបទប្បញ្ញត្តិ មួយចំនួនរបស់ទីផ្សារមូលបត្រ ឬក៏ធ្វើឲ្យតម្លៃភាគហ៊ុនអាចទាក់ទាញវិនិយោគិនបន្ថែមទៀត។ ដោយសារ វាមានការកាន់កាប់ដោយវិនិយោគិនជាច្រើន និងមានតម្លៃសមរម្យ វាធ្វើឲ្យមានភាព ងាយស្រួលសម្រាប់ឈ្មួញជើងសាមូលបត (Brokers) លក់ភាគហ៊ុនទាំងនោះទៅវិនិយោគិនផ្សេង ទៀត។

ផ្ទុយមកវិញ ក្រុមហ៊ុនអាចបង្រួមចំនួនភាគហ៊ុន តាមរយៈការកាត់បន្ថយភាគហ៊ុនឲ្យនៅ តិច និងបង្កើនតម្លៃនៃភាគហ៊ុន។ ទីផ្សារមូលបត្រខ្លះ តម្រូវឲ្យមានតម្លៃភាគហ៊ុនអប្បបរមាមួយ ដើម្បីចុះបញ្ជីនៅលើទីផ្សារមូលបត្រ ក្នុងករណីនេះការបង្រួមចំនួនភាគហ៊ុន ត្រូវធ្វើឡើងដើម្បី ឆ្លើយតបទៅនឹងតម្រូវការនេះ ភាគហ៊ុនដែលមានតម្លៃទាប ជាធម្មតាត្រូវបានគេហៅថាជា ភាគហ៊ុនតូចតាច "Penny_Stocks" ទោះបីជាភាគហ៊ុនទាំងនោះលក់ក្នុងតម្លៃខ្ពស់ជាងនេះក៏ដោយ ក៏មិនត្រូវបានទទួល

ការចាប់អារម្មណ៍ខ្លាំងពីសំណាក់វិនិយោគិនមូលបតទូទៅឡើយ។ ការ បង្កើមភាគហ៊ុនអាចធ្វើឲ្យកើន តម្លៃភាគហ៊ុន ហើយប្រហែលជាសារតារបស់ក្រុមហ៊ុននៅក្នុងទី ផ្សារមូលបត្រត្រូវបានទាក់ទាញការ ចាប់អារម្មណ៍ផងដែរ។ ការបង្កើមភាគហ៊ុនអាចជាសញ្ញាមួយ បង្ហាញថាក្រុមហ៊ុនមួយនេះមានស្ថាន ភាពហិរញ្ញវត្ថុមិនល្អ។

### ១០.២.៧. ភាគលាភ (Dividends)

ភាគលាភ គឺជាប្រាក់ចំណូលពីការវិនិយោគទិញភាគហ៊ុន ដែលត្រូវបានប្រកាសដោយ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ហើយជាធម្មតាត្រូវទូទាត់ក្នុងទម្រង់ជាសាច់ប្រាក់ (Cash) ឬក៏ ទទួលបានភាគហ៊ុនបន្ថែម។ គោលនយោបាយបែងចែកភាគលាភរបស់ក្រុមហ៊ុនមួយ គឺអាស្រ័យ ទៅលើកត្តាមួយចំនួនដូចជា ស្ថានភាពសាច់ប្រាក់របស់ក្រុមហ៊ុន ទិដ្ឋភាពកំនើនរបស់ក្រុមហ៊ុន ស្ថេរភាពនៃប្រាក់ចំណូល សេចក្តីត្រូវការចំណាយមូលធន និងកេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុនជាដើម។ វិនិយោគិនភាគច្រើន ទិញភាគហ៊ុនដោយសារតែប្រវត្តិនៃការបែងចែកភាគលាភរបស់ក្រុមហ៊ុន ព្រមទាំងអាស្រ័យលើការបែងចែកសាច់ប្រាក់ចំណូលរបស់ក្រុមហ៊ុន។ ជាទូទៅ ក្រុមហ៊ុនចាស់ ហើយធំៗ បង់ភាគលាភជាសាច់ប្រាក់សុទ្ធ រីឯក្រុមហ៊ុនថ្មីហើយតូចៗ ច្រើនតែបង់ភាគលាភជា ភាគហ៊ុនបន្ថែម។ ដោយសារភាគលាភជាសាច់ប្រាក់ត្រូវបង់ ដោយយកចេញពីប្រាក់ចំណេញចរន្ត (Current Earning) នៃក្រុមហ៊ុន ដូចនេះក្រុមហ៊ុនដែលថ្មីហើយតូចៗ ពួកគេចាំបាច់ត្រូវរក្សាសាច់ ប្រាក់សុទ្ធសម្រាប់ធ្វើឲ្យមានកំណើនបន្ថែមទៀតនាពេលអនាគត ដូច្នេះហើយពួកគេមិនអាចបង់ ភាគលាភជាសាច់ប្រាក់បានទេ។ ភាគលាភ អាចត្រូវបានទូទាត់ក្នុងទម្រង់ជាទ្រព្យសម្បត្តិផ្សេងៗ ទៀតផងដែរដូចជាភាគហ៊ុននៅក្នុងក្រុមហ៊ុនមួយផ្សេងទៀត ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនមេ (Subsidiary)។

**ក .ភាគលាភចាស់ ឬបុព្វលាភ (Ex-dividends)** គេអាចនិយាយបានថាភាគហ៊ុនមួយ គឺជាការលក់ភាគលាភចាស់ (Ex-dividend) របស់ខ្លួននៅពេលដែលក្រុមហ៊ុនប្រកាសថា មិនមានភាគលាភចំពោះអ្នកទិញភាគហ៊ុន។ ជា ធម្មតា អ្នកទិញភាគហ៊ុនមិនទទួលបានភាគលាភដោយសារភាគហ៊ុននោះត្រូវបានទិញហួស កាលបរិច្ឆេទដែលត្រូវទទួលបានភាគលាភ។ នៅពេលភាគហ៊ុនមួយត្រូវបានជួញដូរនៅកាល បរិច្ឆេទដែលមិនអាចទទួលបានការទូទាត់ភាគលាភចាស់ ថ្ងៃទីផ្សាររបស់មូលបត្រនោះនឹងធ្លាក់ ចុះស្មើនឹងចំនួនភាគលាភនោះ។ អ្នកទិញភាគហ៊ុននឹងទិញក្នុងតម្លៃភាគហ៊ុនកនឹងចំនួន ភាគលាភចាស់ ដែលត្រូវទទួលបាន។

**ខផែនការវិនិយោគភាគលាភជាថ្មី .** (Dividend Re-investment Plans) DRIPS គឺជាផែនការដែលទទួលបានការគាំទ្រដោយក្រុមហ៊ុនធំៗជាច្រើន។ ផែនការទាំងនេះ អនុញ្ញាតឲ្យ ភាគហ៊ុនិកធ្វើការវិនិយោគឡើងវិញនូវភាគលាភជាសាច់ប្រាក់ទាំងអស់ ដោយផ្ទាល់នៅក្នុងការ ទិញភាគហ៊ុនរបស់ក្រុមហ៊ុនបន្ថែមទៀត។ ភាគហ៊ុនទាំងអស់ ត្រូវទិញដោយផ្ទាល់ពីក្រុមហ៊ុននៅ ក្នុងទីផ្សារដំបូង។ សកម្មភាពវិនិយោគឡើងវិញនេះ គឺត្រូវបានចាត់ចែងដោយក្រុមហ៊ុន។ ពុំមាន វិញ្ញាបនបត្រភាគហ៊ុន (Share Certificates) ណាមួយត្រូវបានបោះផ្សាយឡើយ។ ភាគហ៊ុនទាំងអស់ ត្រូវបានចុះបញ្ជី

សម្រាប់អ្នកកាន់កាប់ភាគហ៊ុន ដែលជាទូទៅ មានភាគហ៊ុនជាផ្នែក (Fractional Shares) ដែលមិនអាចទិញបាននៅក្នុងទីផ្សារបន្ទាប់។

### ១០.២.៨. ភាគហ៊ុនក្រុមហ៊ុន (Treasury Stock)

ភាគហ៊ុនក្រុមហ៊ុន គឺជាភាគហ៊ុនដែលត្រូវបានបោះផ្សាយលក់ទៅឲ្យសាធារណជននៅ ក្នុងទីផ្សារដំបូង ហើយបន្ទាប់មកត្រូវបានទិញត្រឡប់មកវិញដោយក្រុមហ៊ុន ពីភាគហ៊ុនិកដោយ ផ្ទាល់ ក្នុងទីផ្សារបន្ទាប់។ ភាគហ៊ុនប្រភេទនេះ ត្រូវបានគេស្គាល់ថាជាភាគហ៊ុនក្រុមហ៊ុន (Treasury Stock) ពីព្រោះថា ភាគហ៊ុនទាំងអស់ត្រូវបានត្រឡប់ចូលទៅក្នុងបេឡារបស់ក្រុមហ៊ុនវិញ។ ភាគ ហ៊ុនទាំងអស់នេះពុំមានសិទ្ធិបោះឆ្នោតទេ ហើយពុំទទួលបានភាគលាភដែរ។ ភាគហ៊ុនទាំងនេះ មិនត្រូវបានគេយកមកធ្វើការគណនារកចំណូលទទួលបាន ក្នុងមួយភាគហ៊ុននៅក្នុងរបាយ ការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ ក្រុមហ៊ុន អាចប្រើប្រាស់ភាគហ៊ុនក្រុមហ៊ុនសម្រាប់ផែនការទិញ ភាគហ៊ុនរបស់បុគ្គលិកក្រុមហ៊ុន (Employee Stock Purchase Plans) ដើម្បីផ្តល់មូលនិធិសម្រាប់ បុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុន (Executive Stock Options) ឬក៏ផ្តល់ប្រាក់លើកទឹកចិត្ត (Bonuses) ដែលជាមធ្យោបាយមួយក្នុងការទិញទ្រព្យសកម្មរបស់ក្រុមហ៊ុនមួយផ្សេងទៀត តាមរយៈការ ផ្លាស់ប្តូរភាគហ៊ុនដោយការដាក់ដេញថ្លៃរបៀបនេះ។ នេះក៏ជាឧបករណ៍វិនិយោគមួយដោយ សារតែក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនយល់ថា ភាគហ៊ុនមានតម្លៃទាប (Under Priced) ពក ហើយអាចស្ថិតក្រោមតម្លៃចុះបញ្ជីរបស់ភាគហ៊ុន (Book Value)។ ភាគហ៊ុនក្រុមហ៊ុន ឬការទិញ (Acquisition) នៃភាគហ៊ុនក្រុមហ៊ុន អាចត្រូវបានគេប្រើប្រាស់ ដើម្បីការពារប្រឆាំងទប់ទល់នឹងការប៉ុនប៉ងកាន់កាប់ក្រុមហ៊ុន ដោយភាគហ៊ុនចំនួនច្រើនមកលើ ក្រុមហ៊ុន តាមរយៈការកាន់កាប់ភាគហ៊ុនចំនួនច្រើននៅលើទីផ្សារ , ការគ្រប់គ្រងក្រុមហ៊ុនគួរមានការត្រួតពិនិត្យកាន់តែតឹងរ៉ឹងជាងមុន ដោយសារតែភាគហ៊ុនក្រុមហ៊ុនមិនអាចបោះឆ្នោត ប្រឆាំងជាមួយនឹងការគ្រប់គ្រងរបស់ក្រុមហ៊ុនទៀតទេ។

### ១០.២.៩. បណ្ណទទួលតម្កល់ភាគហ៊ុន (Depository Receipts)

បណ្ណទទួលតម្កល់ភាគហ៊ុន គឺជាភស្តុតាងបង្ហាញពី ភាគហ៊ុននៃក្រុមហ៊ុនមួយដែលធ្វើ អាជីវកម្មនៅក្រៅប្រទេស ហើយបណ្ណតម្កល់ភាគហ៊ុនរបស់ក្រុមហ៊ុនត្រូវបានគេជួញដូរ។ ឧទាហរណ៍៖ ក្រុមហ៊ុនមួយតាំងនៅក្នុងប្រទេសជប៉ុន (Sony) អាចចុះបញ្ជីលក់ភាគហ៊ុន របស់ខ្លួននៅក្នុងប្រទេសឥណ្ឌូនេស៊ីនៃទីផ្សារ Jakarta Stock Exchange តាមរយៈការប្រើប្រាស់បណ្ណ ទទួលតម្កល់ភាគហ៊ុននៃប្រទេសឥណ្ឌូនេស៊ី ហើយធ្វើការជួញដូរនៅលើទីផ្សារមូលបត្រនៃទីក្រុង Jakarta បណ្ណទទួលតម្កល់ភាគហ៊ុន ជាទូទៅត្រូវបានគេដាក់ឈ្មោះបន្ទាប់ពីឈ្មោះប្រទេសដែល ពួកគេធ្វើការលក់ភាគហ៊ុនប្រភេទនេះ ហើយជាធម្មតា ត្រូវបានគេសម្គាល់ដោយពាក្យកាត់មួយ (Acronym ដែលបង្កើតឡើងដោយអក្សរដំបូងនៃឈ្មោះប្រទេសដែលលក់ភាគហ៊ុនប្រភេទនេះ ភ្ជាប់ដោយអក្សរ" DR" សម្រាប់បណ្ណទទួលតម្កល់ភាគហ៊ុន។ ដូច្នេះ តាមរយៈឧទាហរណ៍នេះ ការ ទិញភាគហ៊ុននៅក្នុងទីផ្សារមូលបត្រ

របស់ឥណ្ឌូនេស៊ីគឺ Sony IDRs។ ប្រតិបត្តិការក្នុងការជួញដូរបណ្ណតម្កល់ភាគហ៊ុន ត្រូវបានធ្វើឡើងជំនួសការធ្វើការជួញដូរ ក្នុងទម្រង់ជាមូលបត្រផ្ទាល់។ ជាទូទៅ បណ្ណតម្កល់ភាគហ៊ុនត្រូវបានចេញផ្សាយដោយសាខា បរទេសនៃធនាគារក្នុងស្រុកមួយសម្រាប់ភាគហ៊ុននៃក្រុមហ៊ុនមេ ដែលកាន់កាប់ និងគ្រប់គ្រងនៅ ក្នុងប្រទេសដែលក្រុមហ៊ុននោះតាំងនៅ។ ប្រសិនបើ អនុញ្ញាតដោយច្បាប់ បណ្ណតម្កល់ភាគហ៊ុន អាចត្រូវបានបោះផ្សាយផងដែរ ដោយផ្អែកលើការដាក់តម្កល់នៅក្នុងភ្នាក់ងារទទួលតម្កល់មជ្ឈឹម (Central Depository) នៅក្នុងស្រុកនៃប្រទេសដែលក្រុមហ៊ុនតាំងនៅ។ ជាធម្មតា បណ្ណតម្កល់ ភាគហ៊ុនត្រូវបានចុះបញ្ជី និងជួញដូរស្របទៅតាមបទប្បញ្ញត្តិនៃទីផ្សារមូលបត្រដែលបានដាក់ ចេញ។ ការចុះបញ្ជីនៃបណ្ណតម្កល់ភាគហ៊ុន ត្រូវមាននីតិវិធីក្នុងការទូទាត់ និងផ្ទេរពីប្រទេស ក្រៅដែលមានលក្ខណៈសាមញ្ញ ព្រមទាំងអនុញ្ញាតឲ្យវិនិយោគិនក្នុងស្រុកទទួលបានភាគលាភ ជារូបិយបណ្ណជាតិរបស់គ និងរបាយការណ៍ហិរញ្ញវត្ថុក្នុងទម្រង់ជាភាសាក្នុងស្រុករបស់ពួកគេ។

## ១០.៣. កិច្ចសន្យាទិញលក់ទំនិញ- (Commodities)

ជាលក្ខណៈបច្ចេកទេស កិច្ចសន្យាទិញ-លក់ទំនិញ មិនមែនជាប្រភេទមូលបត្រទេ ប៉ុន្ត ជាកិច្ចសន្យាទិញ ឬលក់ទំនិញ។ ដោយសារវាជាកិច្ចសន្យាទិញ-លក់នៅពេលអនាគត ដូចនេះ វិនិយោគិនទាំងអស់ត្រូវជួញដូរមូលបត្រ (កិច្ចសន្យា) ទាំងនេះ ដោយមិនបានឃើញទំនិញជាមុន ដែលមាននៅក្នុងកិច្ចសន្យា។ កិច្ចសន្យាទិញ-លក់ទំនិញ ត្រូវបានគេពិពណ៌នាឬសរសេរនៅក្នុង កិច្ចសន្យា ឯការពិនិត្យទំនិញមិនចាំបាច់មានឡើយ។ ទីផ្សាររូបិយបណ្ណ (Currency Markets) បានក្លាយជាទីផ្សារនៃកិច្ចសន្យាទិញ-លក់ទំនិញ ចុងក្រោយដែលជះឥទ្ធិពលនៅទូទាំងពិភពលោក។ អត្រាការប្រាក់ និងតារាងសន្ទស្សន៍ថ្លៃភាគ ហ៊ុនជាឧបករណ៍ពីរផ្សេងទៀត ដែលត្រូវបានដាក់បង្ហាញនៅលើទីផ្សារនាពេលថ្មីៗនេះ ហើយ ដែលស្ថិតនៅក្រោមកិច្ចសន្យាទិញ-លក់ទំនិញ។ ដោយសារកិច្ចសន្យាទិញ-លក់ទំនិញខ្លះមិនអាចត្រូវបានផ្តល់អត្រាការប្រាក់ និងភាគ ច្រើនអ្នកជួញដូរកិច្ចសន្យាទិញ-លក់ទំនិញមិនត្រូវការផ្តល់ទំនិញឲ្យនោះទេ។ កិច្ចសន្យាទិញ លក់ទំនិញអាចត្រូវបានទូទាត់ផងដែរជាសាច់ប្រាក់ ជាជាងទំនិញទូទៅដែលមាននៅក្នុងកិច្ច សន្យា។ តម្លៃដែលត្រូវទូទាត់ត្រូវបានកំណត់ដោយភាពខុសគ្នារវាងតម្លៃនៃទំនិញនៅពេលដែល ទិញ ឬក៏លក់ ជាមួយនឹងតម្លៃនៃទំនិញនៅពេលវេលាផុតកំណត់កិច្ចសន្យា។ កិច្ចសន្យាទិញ-លក់ទំនិញ អាចត្រូវបានបញ្ចប់ផងដែរតាមរយៈការទិញកិច្ចសន្យាទិញ លក់ទំនិញមួយផ្សេងទៀត ជាជាងទទួលយកទំនិញ ឬប្រាក់សុទ្ធ។ ឧទាហរណ៍៖ ប្រសិនបើអ្នក ជួញដូរម្នាក់បានទិញកិច្ចសន្យាទិញ-លក់ទំនិញមួយ គាត់នឹងទិញចំនួនស្មើគ្នានៃកិច្ចសន្យាទិញ លក់ទំនិញដូចគ្នា មុនពេលដែលកិច្ចសន្យានៅផុតកំណត់។ ដូចគ្នាដែរ អ្នកលក់កិច្ចសន្យាម្នាក់នឹង ទិញត្រឡប់មកវិញនូវកិច្ចសន្យាទិញ-លក់ទំនិញ ដើម្បីជៀសវាងដល់កាលកំណត់ផ្តល់ទំនិញ។ អ្នកជួញដូរទាំងពីរនេះគឺជាអ្នកកេងយកចំណេញ (Speculators) ដែលជាការពិត ពួកគេនឹង ទទួលបានប្រាក់ចំណេញរវាងប្រតិបត្តិការទិញ-លក់កិច្ចសន្យា៕

# មេរៀនទី១១
# ការជួញដូរ ការជាត់ទាត់ និងការទូទាត់មូលបត្រ
# ( Trading, Clearing and Settling Securities )

## ១១.១. ប្រភេទនានានៃការជួញដូរមូលបត្រ ( Types of Securities Trades )

### ១១.១.១. ការបញ្ជាតាមថ្លៃ ( Price Orders )

#### ក. ការបញ្ជាទិញលក់មូលបត្រ ( Buy and Sell orders )

ការបញ្ជាទិញមូលបត្របង្កើតឲ្យមាន ឬបង្កើតការកាន់កាប់មូលបត្រជាក់លាក់មួយៗ វិនិយោគដែលកាន់កាប់មូលបត្រមួយ មានន័យថាពួកគេមានកម្មសិទ្ធិលើមូលបត្ររយៈពេលវែង នៃមូលបត្រនោះ។ ផ្ទុយមកវិញការបញ្ជាទិញមូលបត្រធ្វើឲ្យអស់សិទ្ធ ឬកាត់បន្ថយការកាន់កាប់មូលបត្រ។ វិនិយោគគិនដែលលក់មូលបត្រដែលពួកគាត់ពុំមានក្នុងដៃបានន័យថាពួកគេខ្ចីមូលបត្ររបស់អ្នកដទៃលក់ក្នុងរយៈពេលខ្លី ( Short Selling ) ឬមានកម្មសិទ្ធិរយៈពេលខ្លី ( Short Position ) លើមូលបត្រនោះ។ ជាទូទៅ ការខ្ចីមូលបត្រលក់រយៈពេលខ្លី ( Short Sales ) អាចត្រូវបានហាមឃាត់នៅក្នុងប្រទេសមួយ។

វិនិយោគគិននឹងធ្វើការលក់មូលបត្ររយៈពេលខ្លី ( Short Sales ) នៅពេលដែលខ្លួនជឿថាមូលបត្រនោះនឹងធ្លាក់ថ្លៃ ពួកគេនឹងទិញយកមូលបត្រនៅដើម្បីសងមូលបត្រទៅម្ចាស់ដើមវិញក្នុងតម្លៃទាបហើយពួកគេនឹងទទួលបានប្រាក់ចំណេញពីគម្លាតថ្លៃទាំងពីរ។ ការធ្វើដូចនេះត្រូវបានគេហៅថា ការទូទាត់លើការខ្ចីមូលបត្រមកលក់ ឬការទិញមូលបត្រចូល ( Buying In )។

#### ខ.ការបញ្ជាតាមទីផ្សារ ( Market Orders )

ការបញ្ជាតាមទីផ្សារ គឺជាប្រភេទនៃការបញ្ជាទិញលក់ដែលសាមញ្ញបំផុត-។ ការបញ្ជាទិញ-លក់មូលបត្រនេះត្រូវបានធ្វើឡើងដោយមិនដាក់ថ្លៃ ហើយការជួញដូរត្រូវបានប្រតិបត្តិជាមួយនឹងថ្លៃប្រសើរជាងគេបំផុតមួយ ( Best Price ) នៅក្នុងទីផ្សារក្នុងខណៈពេលការបញ្ជាត្រូវប្រតិបត្តិ ឧទាហរណ៍ គឺនៅពេលដែលថ្លៃខ្ពស់បំផុតសម្រាប់ការលក់នឹងថ្លៃទាបបំផុតសម្រាប់ការទិញ។ ការជួញដូរប្រភេទនេះត្រូវបានធ្វើឡើងភ្លាមៗហើយវិនិយោគគិនចាំបាច់ត្រូវបញ្ជាក់ ( Confirm ) ការបញ្ជារបស់ខ្លួនភ្លាមៗដោយផ្ទាល់មាត់តាមរយទូរស័ព្ទ ឬតាម:Online ចំពោះការបញ្ជាតាមប្រព័ន្ធអ៊ីនធើណេត ( Internet )។ ប្រសិនបើ មូលបត្រមិនត្រូវបានជួញដូរញឹកណាប់ទេ គេអាចពន្យារពេលបានខ្លះក្នុងការបញ្ជាក់។

ដើម្បីជួញដូរឈ្មួញជើងសារមូលបត្រ ( Securities Brokers ) អាចធ្វើតាមការបញ្ជាទៅកាន់ទីផ្សារ ( Exchange Floor ) ឬបញ្ជូនការបញ្ជាតាមបណ្តាញកំព្យូទ័រណាមួយ។ បញ្ជារដែលមាននៅលើទីផ្សារត្រូវបានទិញ នឹងលក់ដោយសមាជិករបស់ទីផ្សារ ដែលជាឈ្មួញជើងសារមូលបត្រ ឬពាណិជ្ជករមូលបត្រ ( Securities Dealer )។ ឯបញ្ជាដែលលក់នៅលើទីផ្សារកំព្យូទ័រ នឹងត្រូវផ្គូផ្គងដោយប្រព័ន្ធ

ជួញដូរដោយស្វែងរកបញ្ជាពីរដែលត្រូវគ្នាដើម្បីផ្គូរផ្គង បញ្ជាមួយ បញ្ជាពីរ បីដែលត្រូវគ្នា (គេច្រើននិយមហៅការផ្គូផ្គងនេះ ថាជាការបន្សុីការបញ្ជា)។ ឧបករណ៍ :ការបញ្ជាមួយមានចំនួន ១,០០០ ហ៊ុននៃក្រុមហ៊ុន ATC (និមិត្តសញ្ញាATC) អាចត្រូវបានផ្គូផ្គងជាមួយការបញ្ជាលក់តែមួយដែលមានចំនួនស្មើរ ១,០០០ ហ៊ុនដូចគ្នា ឬការបញ្ជាពីរដែលសត្វចូលគ្នាមានចំនួនស្មើរ ១,០០០ ហ៊ុន។

ឈ្មួញជើងសារមូលបត្រ ចង់ឲ្យវិនិយោគគិនធ្វើការបញ្ជារតាមទីផ្សារ (Marking Sales) ពីព្រោះធ្វើដូចនេះពួកគេនឹងទទួលបានកម្រៃជើងសារភ្លាមៗ។ ម្យ៉ាងទៀត ឈ្មួញជើងសារមូលបត្រក៏មិនចាំបាច់ទិកការបញ្ជាក្នុងកុំព្យូទ័ររបស់ពួកគេ ហើយដោយសារប្រទេសភាគច្រើនតម្រូវឲ្យមានរយៈពេលជាក់លាក់ក្នុងការបញ្ជាក់ (Periodic Confirmation) ជាមួយវិនិយោគិនមិនពេលបញ្ជាទិញ ដូចនេះឈ្មួញជើងសារមូលបត្រមិនចាំបាច់ ធ្វើការបញ្ជាក់ឡើយ។ ឈ្មួញជើងសារមូលបត្រ នឹងត្រូវឧស្សាហ៍សួរបញ្ជាក់វិនិយោគិនរបស់ខ្លួនពីភាគហ៊ុនដែលត្រូវទិញលក់នៅលើទីផ្សារ-។

### ១១.១.២.ការបញ្ជាមានកំណត់ (Limit Orders)

ការបញ្ជាមានការកំណត់គឺមានបញ្ជាកើតពីថ្លៃអតិបរមាដែលវិនិយោគិនមានបំណងលក់ (ការកំណត់ថ្លៃខ្ពស់បំផុត ដែលខ្លួនហ៊ានទិញ នឹងថ្លៃទាបបំផុតដែលខ្លួនអាចលក់បាន)។ ការបញ្ជាមានកំណត់ ធ្វើឡើងដើម្បីបានថ្លៃដែលប្រសើរមួយ ពោលគឺប្រសិនបើមូលបត្រអាចជួញដូរនៅថ្ងៃដែលប្រសើរជាងថ្លៃអតិបរមារ ឬអប្បបរមាដែលបានកំណត់ នោះមូលបត្រត្រូវជួញដូរនឹងស្ថិតនៅថ្ងៃដែលប្រសើរជាងនោះ។ ដូចនេះចំពោះបញ្ជាទិញមួយដែលកំណត់ថ្លៃអតិបរមា ១០ ដុល្លារ អាចត្រូវបានទិញនៅត្រង់ថ្លៃ ៩ដុល្លារ ដោយសារវាថោកជាង ១០ដុល្លារ ប៉ុន្តែមិនអាចទិញនៅត្រង់ថ្លៃ ១១ ដុល្លារទេ។។ ផ្ទុយមកវិញបញ្ជាលក់មួយដែលកំណត់ថ្លៃអប្បបរមា ១០ ដុល្លារ អាចត្រូវបានលក់នៅត្រង់ថ្លៃ ១១ ដុល្លារ ជាថ្លៃប្រសើរជាង ១០ ដុល្លារ សម្រាប់ភាគីអ្នកលក់ ឯថ្លៃ ៩ដុល្លារវិញ គឺមិនមែនជាថ្លៃប្រសើរជាងសម្រាប់គាត់ទេ។ ឈ្មួញជើងសារមូលបត្រ ដែលមិនបានបញ្ជាដោយការកំណត់ថ្លៃ ឬថ្លៃប្រសើរជាង ត្រូវបានចាត់ទុកថា ខកខានក្នុងការចូលរួមទីផ្សារ (Missing the Market) ហើយជាទូទៅត្រូវទទួលខុសត្រូវចំពោះការខាតបង់ដែលកើតមានចំពោះវិនិយោគគិន ដែលទៅតាមច្បាប់ និងបទបញ្ញត្តិរបស់ប្រទេសនីមួយៗ។

ការបញ្ជាមានការកំណត់ អាចលុបបានគ្រប់ពេល នៅមុនពេលការបញ្ជាត្រូវបានប្រតិបត្តិ (Executed)។ ដូច្នេះប្រសិនបើបុគ្គលម្នាក់ដាក់ការបញ្ជាទិញកំណត់ត្រឹម ៥ដុល្លារ ហើយមូលបត្រនោះមានតម្លៃ ៦ដុល្លារ និងបានកើនឡើងដល់ ១០ដុល្លារ នៅប៉ុន្មានខែក្រោយ នោះវិនិយោគិនត្រូវរក្សាការបញ្ជានៅក្នុងបញ្ជីកករហូត ដោយសង្ឃឹមថាវានឹងធ្លាក់ថ្លៃមកវិញ វិនិយោគិនត្រូវលុបចោលការបញ្ជានោះ។

ការបញ្ជាមានការកំណត់អនុញ្ញាតឲ្យវិនិយោគិនជួញដូរដោយមិនចាំបាច់តាមដានឥតឈប់ឈរពីតម្លៃមូលបត្រដើម្បីដឹងច្បាស់ថាពេលណាត្រូវបញ្ជាទិញលក់មូលបត្រ-។ ទីបីជាវិនិយោគិនបានបញ្ជាទិញលក់មូលបត្រភ្លាមៗនៅលើទីផ្សារ នៅពេលដែលតម្លៃមូលបត្រឈានដល់តម្លៃដែលពួកគេចង់-

បាន ប៉ុន្តែពេលវេលាដែលត្រូវចំណាយនៅមូលបត្រនៅឈ្មួញជើងសារមូលបត្រដើម្បីធ្វើប្រតិបត្តិបញ្ជា (Exact Orders) គឺយូរល្មមគ្រប់គ្រាន់ដែលអាចឲ្យថ្លៃនោះប្រែប្រួលបន្តទៀត នៅក្នុងទីផ្សារដែលមានភាពមមាញឹក (Active Market)។

ចំពោះមូលបត្រដែលពេញនិយម និងនៅទីផ្សារធំៗការបញ្ជាមានកំណត់មិនត្រូវបានប្រតិបត្តិឡើយ។ ដោយសារតែវិនិយោគិនតែងតែដាក់ការបញ្ជាមានកំណត់ជាតួរលេខខាងចុងជាលេខ០ ឬលេខ៥ ដូចនេះអាចមានការបញ្ជាដ៏ច្រើនដែលដាក់តម្លៃដូចជា ១០ឬ ១៥ ដុល្លារ។ ការបញ្ជាចូលទៅក្នុងទីផ្សារអាចមានអាទិភាពទៅលើថ្លៃ បន្ទាប់មកការបរិច្ឆេទការបញ្ជាត្រូវ បានប្រតិបត្តិ តាមគោលការណ៍បញ្ជាទិញលក់ណាដែលមានមុនគេ-។ ប្រសិនបើមូលបត្រណាដែលត្រូវលក់ក្នុងតម្លៃ ៦ដុល្លារ ហើយស្រាប់តែធ្លាក់ថ្លៃទៅ ៥ដុល្លារវាអាចនឹងមានបញ្ជាទិញជាច្រើនដែលអាចនាំឲ្យមូលបត្រនោះកើនថ្លៃទៅ ៦ដុល្លារវិញមុនពេលការបញ្ជាក្នុងតម្លៃ ៥ដុល្លារ ទងអស់ត្រូវបានប្រតិបត្តិ។ មូលបត្រនោះក៏អាចធ្លាក់ថ្លៃទៅ ៥ដុល្លារវិញដែរ ប៉ុន្តែវិនិយោគិននោះប្រហែលមិនអាចផ្គូរផ្គងបញ្ជាមានកំណត់របស់ខ្លួនឲ្យបានទាំងអស់ឡើយ។ របាយការណ៍ស្តីពី សកម្មភាពរបស់មូលបត្រអាចបង្ហាញឲ្យវិនិយោគិនដឹងថាមានការបញ្ជាជាច្រើនទៅលើមូលបត្រនោះ ដែលកំពុងរង់ការផ្គូផ្គង។ ការបញ្ជាទាំងនោះ ប្រហែលជាមិនអាចផ្គូផ្គងបានរហូត ប្រសិនបើ មូលបត្រនោះមិនព្រមធ្លាក់ថ្លៃទៅ ៥ដុល្លារ ក្នុងរយៈពេលយូរល្មមដើម្បីឲ្យការបញ្ជាមុនៗត្រូវបានផ្គូរផ្គងអស់។

ដូច្នេះ បញ្ហាចោទឡើងសម្រាប់ការបញ្ជាមានកំណត់គឺ វិនិយោគិនម្នាក់ខកខានការជួញដូររបស់ខ្លួននៅពេលដែលថ្លៃខ្សែគ្នាតែបន្តិចជាមួយថ្លៃដែលខ្លួនបានកំណត់។

### ក.ការបញ្ជាបញ្ឈប់ (Stop Orders)

ការបញ្ជាបញ្ឈប់ មានសុពលភាពនៅពេលដែលទីផ្សារ ឈានទៅដល់ ឬឆ្លងកាត់ថ្លៃដាក់លាក់មួយ។ ពេលឈានទៅដល់ថ្លៃនោះ ការបញ្ជានិងមានសុពលភាព (Triggered) ហើយការបញ្ជានោះនឹងក្លាយទៅជាការបញ្ជាតាមទីផ្សារ Market Orders) ដែលនឹងត្រូវប្រតិបត្តិភ្លាមៗ។

ការបញ្ជាបញ្ឈប់ ត្រូវប្រើតែនៅទីផ្សារភាគហ៊ុន (Exchange) ប៉ុណ្ណោះ។ ទីផ្សាររំលងបញ្ជា (Over- The-Counter Market) ស្ទើរទាំងអស់មិនទទួលការបញ្ជាបែបនេះទេ ដោយសរតែភាពខុសគ្នាក្នុងការប្រតិបត្តិការបញ្ជា រវាងទីផ្សារភាគហ៊ុនដេញថ្លៃ (Exchange Auction Price) នឹងទីផ្សាររំលងបញ្ជាលក់ដុំ (Over-The- Counter Dealer Market)។

ការបញ្ជាបញ្ឈប់លក់ គឺធ្វើឡើងដោយកំណត់ថ្លៃមួយដែលស្ថិតនៅក្រោមថ្លៃទីផ្សារ ( Market Price) ឧទាហរណ៍សន្មតថាភាគហ៊ុនមួយកំពុងឡើងថ្លៃជាបន្តបន្ទាប់ក្នុងកំឡុងពីរ បីសប្តាហ៍ចុង : ក្រោយ។ វិនិយោគិនម្នាក់ទិញភាគហ៊ុននៅត្រង់ថ្លៃ ៣ដុល្លារ ហើយបីសប្តាហ៍ក្រោយមក ភាគហ៊ុននៅកើនថ្លៃដល់ ១២ដុល្លារ។ វិនិយោគិននរំពឹងយ៉ាងមុះមុតថាមូលបត្រនឹងឡើងថ្លៃដល់ ១៥ដុល្លារ ប៉ុន្តែគេនៅតែមានគំនិតចង់ការពារប្រាក់ចំណេញដែលបានគ្រោងទុក។ វិនិយោគនិងនោះបានដាក់ការបញ្ជាបញ្ឈប់នៅត្រង់ ១១ ដុល្លារ។ ប្រសិនបើមូលបត្រនៅបន្តកើនឡើងដល់ ១៥ ដុល្លារ វិនិយោគមិន

និងលក់នៅថ្លៃ ១៥ ដុល្លារ ហើយនឹងលុបការបញ្ជាបញ្ឈប់ភ្លាមផងដែរ។ តែប្រសិនបើភាគហ៊ុនធ្លាក់ថ្លៃវិញនោះការបញ្ជាលក់នឹងធ្វើឡើងដោយស្វ័យប្រវត្តិនៅពេលថ្លៃធ្លាក់ដល់ ១១ ដុល្លារ ឬនៅក្រោមថ្លៃនេះ (Stop Orders) ប៉ុន្តែវាប្រហែលវាមិនត្រូវបានលក់នៅត្រង់ថ្លៃ ១១ ដុល្លារទេ គឺលក់នៅថ្លៃទីផ្សារជាក់ស្តែងនៅពេលការបញ្ជាត្រូវបានប្រតិបត្តិ នៅពេលការបញ្ជាបញ្ឈប់មានសុពលភាព (Triggers) នៅត្រង់ថ្លៃដែលបានកំណត់ (១១ ដុល្លារ)។ ប្រសិនបើភាគហ៊ុនកើនឡើងដល់ថ្លៃ ១១ ដុល្លារ ហើយវិនិយោគិននៅតែគិតថាវានឹងកើនឡើងបន្តទៀត គាត់នឹងលុបការចោលការបញ្ជាបញ្ឈប់នៅត្រង់ថ្លៃ ១១ ដុល្លារ ហើយដាក់ថ្លៃផ្សេងមួយទៀត (ឧបករណ៍ ថ្លៃ ១៤ដុល្លារ ហើយបន្តរក្សាប្រាក់ចំណេញស្របពេលដែលថ្លៃកំពុងកើនឡើង)។ បញ្ជាបញ្ឈប់ជាបន្តបន្ទាប់ទាំងនេះ ត្រូវបានគេហៅថា បញ្ជាបញ្ឈប់ឥតឈប់ឈរ ( Tralling Stops )។ ការប្រើវិធីសាស្ត្របែបនេះ អាចបង្កឲ្យមានការប្រែប្រួលកាន់តែខ្លាំងឡើងទៅលើមូលបត្រដែលកំពុងប្រែប្រួលតម្លៃជាញឹកញាប់ ( Volatile ) ស្រាប់។ ប្រសិនបើមូលបត្រចាប់ផ្តើមធ្លាក់ថ្លៃបញ្ជាបញ្ឈប់ជាបន្តបន្ទាប់បន្តធ្វើឲ្យបញ្ជាលក់ជាច្រើនមានសុពលភាពជាលទ្ធផលបណ្តាលឲ្យមូលបត្រធ្លាក់ថ្លៃយ៉ាងងាយ។

បញ្ជាបញ្ឈប់អាចត្រូវបាននៅក្នុងការខ្ចីមូលបត្រលក់រយពេលខ្លីៈ ( Short Sales )។ ឧទាហរណ៍ដុល្លារ គឺជាកម្រិតទ្រទ្រង់ ១០ អ្នកវិភាគឯកទេសរំពឹងថា ថ្លៃ : (Support Levell)។ មានន័យថា ពួកគេរំពឹងថាមូលបត្រនៅអាចធ្លាក់ថ្លៃទៅដល់ ១០ដុល្លារ ប៉ុន្តែវានឹងកើនឡើងវិញ។ ប្រសិនបើមូលបត្រធ្លាក់ក្រោមថ្លៃ ១០ដុល្លារ មានន័យថា មូលបត្រនោះបានបំបែកកម្រិតទ្រទ្រង់ ហើយវាជាសញ្ញាបង្ហាញពីការធ្លាក់ចុះនាពេលអនាគត។ ប្រសិនបើមូលបត្រកំពុងលក់នៅត្រង់ថ្លៃ ១២ ដុល្លារ វិនិយោគិននិងនឹងមិនមានបំណងខ្ចីមូលបត្រលក់រយៈពេលខ្លីទេព្រោះវាស្ថិតនៅលើកម្រិតទ្រទ្រង់ ដែលអាចនឹងបន្តកើនតម្លៃដែលវិនិយោគិនមិនទទួលបានប្រាក់ចំណេញពីប្រតិបត្តិការនោះ។ ប្រសិនបើវាបំបែកកម្រិតទ្រទ្រង់វិនិយោគិននឹងមានបំណងខ្ចីមូលបត្រលក់រយពេលខ្លី ដោយជឿជាក់វានឹងធ្លាក់ថ្លៃៈនៅពេលខាងមុខ។ វិនិយោគិននឹងអាចដាក់ការបញ្ជាលក់ដោយខ្ចីមូលបត្ររយពេលខ្លីៈ (Sell Short) នៅពេលថ្លៃលក់ឈប់ត្រង់ចំណុច ៩,៧៥ ដុល្លារ។ បញ្ជានេះ អាចមានសុពលភាពលើទីផ្សារកម្រិតថ្លៃ ៩,៧៥ ដុល្លារ។

បញ្ជាបញ្ឈប់ទិញមួយ អាចត្រូវបានប្រើដើម្បីការពារការខ្ចីមូលបត្រលក់នៅរយៈពេលខ្លី។ ឧបមាថា មូលបត្រមួយបានធ្លាក់ថ្លៃទៅ ៩,៧៥ ដុល្លារ ហើយការបញ្ជាលក់មូលបត្រដែលបានខ្ចី (Short Sales) ស្ថិតនៅត្រង់ ៩,៧៥ ដុល្លារ របស់វិនិយោគិននៅក្នុងឧទាហរណ៍ ខាងលើត្រូវបានប្រតិបត្តិ។ ឯការបញ្ជាមួយទៀតនៅពេលដែលថ្លៃឈប់នៅត្រង់ថ្លៃ ១០,៥០ដុល្លារ អាចការពារវិនិយោគិនពីការខាតបង់នាពេលអនាគតបាន។ ដោយសារវិនិយោគិនបានខ្ចីមូលបត្រលក់ក្នុងរយៈពេលខ្លីពោល គឺបានលក់មូលបត្រដែលមិនមែនជាកម្មសិទ្ធិរបស់គាត់នៅត្រង់កម្រិតថ្លៃណាមួយ ការខ្ចីត្រូវបានទូទាត់ទៅឲ្យម្ចាស់ដើមវិញនៅពេលឈានដល់កាលវសានណាមួយ។ ដរាបណាមូលបត្រនៅតែបន្តធ្លាក់ចុះ វិនយោគិនកំពុងបង្កើនប្រាក់ចំណេញ ពីព្រោះគាត់អាចទិញមូលបត្រសងត្រឡប់វិញនៅក្នុងតម្លៃកាន់តែទាប។ ប្រសិនបើ មូលបត្រធ្លាក់ថ្លៃវិញ វិនិយោគិននឹងចាប់ផ្តើមខាតបង់ នៅពេលដែលថ្លៃ

កើនឡើងលើសថ្លៃដែលគាត់បានខ្ចីមូលបត្រមកលក់ ដោយសារគាត់ត្រូវចំណាយខ្ពស់ជាងមុនដើម្បីទិញមូលបត្រសងត្រឡប់ទៅគេវិញ។ ក្រោយពេលការដាក់បញ្ជាទិញ មូលបត្រនឹងត្រូវបានទិញហើយមូលបត្រដែលត្រូវបានខ្ចីនឹងត្រូវបានសងត្រឡប់ទៅវិញនៅថ្ងៃមួយដែលគេស្គាល់ ដូចនេះ ហានិភ័យនៃការខាតបង់ត្រូវបានកំណត់។ ប្រសិនបើ មូលបត្រនៅតែបន្តធ្លាក់ថ្លៃ វិនិយោគិនអាតលុបការបញ្ជា នៅពេលថ្លៃឈប់នៅត្រង់ ១០,៥០ដុល្លារ ហើយដាក់ការបញ្ជាមួយទៀតនៅត្រង់ថ្លៃកំណត់ដែលទាបជាងមុនដើម្បីរក្សាប្រាក់ចំណេញ។ ការបញ្ជាអាចឈប់ឈរនេះត្រូវបានគេហៅថា បញ្ជាបញ្ឈប់ទិញឥតឈប់ឈរ (Tralling Buys)។

ប្រសិនបើ បញ្ជាបញ្ឈប់មួយដាក់ថ្លៃក្នុងទំហំមួយខិតជិតទៅរកនឹងថ្លៃទីផ្សារពេកការបញ្ជានោះនឹងត្រូវបានប្រតិបត្តិយ៉ាងឆាប់រហ័ស ហើយឱកាសក្នុងការទូទាត់ប្រាក់ចំណេញច្រើនក៏នឹងត្រូវបាត់បង់ផងដែរ។ ប្រសិនបើថ្លៃទីផ្សារធ្លាក់ចុះច្រើន មិននឹងបញ្ជាបញ្ឈប់មានសុពលភាព ហើយបន្ទាប់មកកើនឡើងវិញ គេថាវិនិយោគិន (គួរកែសម្រួលជាភាសាខ្មែរ) Stopped out។ ប្រសិនបើបញ្ជាបញ្ឈប់ត្រូវបានដាក់ថ្លៃដែលស្ថិតនៅឆ្ងាយពីថ្លៃទីផ្សារពេក ការការពារពីការខាតបង់នឹងត្រូវបានកាត់បន្ថយ។ ប្រសិនបើ មានរូបមន្តយ៉ាងសុក្រិតមួយក្នុងការកំណត់ថាតើត្រូវដាក់ថ្លៃបញ្ជាបញ្ឈប់ឃ្លាតពីថ្លៃទីផ្សារប៉ុន្មាន យើងប្រាកដជាអាចជិះនាវាលំហែកម្សាន្តនៅជុំវិញពិភពលោកដ៏ស្រស់បំព្រងដោយគ្មានការខ្វល់ខ្វាយអ្វីឡើយ ហើយយើងគ្រាន់តែរង់ចាំទទួលប្រាក់ចំណេញដ៏ច្រើនសន្ធឹកសន្ធាប់ប៉ុណ្ណោះ។

**ខការបញ្ជាបញ្ឈប់មានកំណត់. (Stop-limit Orders)**

ដូចទៅនឹងបញ្ជាបញ្ឈប់ដែល បញ្ជាបញ្ឈប់មានកំណត់នឹងមានសុពលភាពនៅថ្លៃដែលបានកំណត់។ នៅពេលមានបញ្ជាមានសុពលភាព វានឹងក្លាយទៅជាការបញ្ជាមានកំណត់។ ឧទាហរណ៍ : ភាគហ៊ុននៃក្រុមហ៊ុនជួញដូរអាសុ៊ី ១០០ វិនិយោគិនបានបញ្ជាលក់ (និមិត្តសញ្ញា ATC) នៅថ្លៃបញ្ឈប់ ១២ដុល្លារ ដូចបញ្ជាបញ្ឈប់ដែរ វានឹងមានសុពលភាពពេលថ្លៃឈ"ប់នៅត្រង់ ១២ដុល្លារ ហើយវានឹងក្លាយទៅជាបញ្ជាមានកំណត់នៅថ្លៃ ១២ដុល្លារ ឬ ថ្លៃប្រសើរជាងនេះ។ ប្រសិនបើ ថ្លៃធ្លាក់ចុះយ៉ាងលឿន ការបញ្ជាមានកំណត់នឹងអាចខកខាន ហើយមូលបត្រមិនត្រូវបានលក់នោះទេ។ ប្រសិនបើ ជាការបញ្ជាបញ្ឈប់មមានកំណត់ (Buy Stop-limit Orders) ហើយថ្លៃកើនឡើងយ៉ាងលឿនការបញ្ជាមានកំណត់អាចខកខានហើយមូលបត្រមិនត្រូវបានទិញទេ។

អ្នកជួញដូរខ្លះបំបែកថ្លៃដែលត្រូវបញ្ឈប់ (Stop Price) ពីថ្លៃមានកំណត់ (Umit Price) ដើម្បីកាត់បន្ថយបញ្ហាជាមួយនឹងប្រតិបត្តិមានកំណត់។ ដូច្នេះវិនិយោគិននោះអាចបញ្ជាទិញភាគហ៊ុន ATC ចំនួន ១០០ ដោយដាក់ថ្លៃមានកំណត់ចំនួន ១៤ដុល្លារហើយឲ្យបញ្ជានេះមានសុពលភាពនៅពេលដែលថ្លៃឈប់ត្រង់ ១២ដុល្លារ។ ដូចនេះ នៅពេលដែលមូលបត្រធ្លាក់ថ្លៃដល់ ១២ដុល្លារ ការបញ្ជានឹងត្រូវបានប្រតិបត្តិនៅត្រង់កម្រិតថ្លៃ ទីផ្សារបន្ទាប់ គឺនៅថ្លៃ ១៤ដុល្លារ ឬទាបជាងនេះ (១៤ ជាថ្លៃអតិបរមាដែលបានកំណត់)។

នៅក្នុងទីផ្សារដែលបានអនុវត្ត មូលធនដែលជួញដូរសរុបនៅក្នុងទីផ្សារមានទំហំតូច ដូចនេះការបញ្ជាប្រភេទនេះអាចមិនត្រូវបានអនុញ្ញាត។ ទីផ្សារមូលបត្រភាគច្រើនអនុញ្ញាតការជួញដូរបែបនេះ នឹងរក្សាសិទ្ធក្នុងការហាមជាតើពួកគេប្រសិនបើពួកគេបង្កឲ្យមានការប្រែប្រួល (Volatility) ខ្ពស់នៅលើទីផ្សារ។

## ១១.១.៣.ការបញ្ជាតាមពេលវេលា (Time Orders)

ការបញ្ជាតាមពេលវេលាមិនដូចជាការបញ្ជាមួយទេ ប៉ុន្តែហាក់ដូចជាការណែនាំមួយថាតើការបញ្ជាមួយមានការល្អប្រសើរមានរយៈពេលប៉ុន្មាន:។

### ក.បញ្ជាក្នុងថ្ងៃឬបញ្ជាបើក (Day Order or Open Orders)

បញ្ជាក្នុងថ្ងៃមានសុពលភាពពេញមួយថ្ងៃនៃថ្ងៃជួញដូរ។ ប្រសិនបើ បញ្ជានេះមិនត្រូវបានប្រតិបត្តិក្នុងថ្ងៃនេះទេ វានឹងត្រូវបានលុបចោល។ បញ្ជាតាមទីផ្សារ (Market Orders) ជាទូទៅគឺជាការបញ្ជាក្នុងថ្ងៃ។ ប្រសិនបើ ការជួញដូរត្រូវបានលុបចោល ការបញ្ជាថ្មី នឹងត្រូវបានធ្វើឡើងនៅថ្ងៃជួញដូរបន្ទាប់។

បញ្ជាបើកមានសុពលភាពរហូត ទាល់តែការបញ្ជាត្រូវបានលុបចោល ហើយជាបញ្ជាដែលសាមញ្ញបំផុត។ ការបញ្ជាទាំងនេះ តែងតែត្រូវបានវាយតម្លៃដោយឈ្មួញជើងសារមូលបត្រ (Brokers) មិនពេលទទួលការបញ្ជា។ ឧទាហរណ៍ បញ្ជាទិញភាគហ៊ុន :ATC១០០ នៅថ្លៃ ១២ដុល្លារ នៅពេលមូលបត្រកំពុងលក់ក្នុងតម្លៃ ១៤ដុល្លារ អាចសមហេតុផលទទួលយកបាន ប៉ុន្តែ បញ្ជាទិញ ភាគហ៊ុន ATC ១០០ នៅថ្លៃ ១០ ដុល្លារ មិនអាចទទួលយកបានទេចំពោះឈ្មួញជើងសារមូលបត្រ។

បញ្ជាបើក ជាទូទៅ តម្រូវឲ្យច្បាប់ នឹងបទប្បញ្ញត្តិ ឬក្រុមហ៊ុនផ្ទាល់ឲ្យមានការបញ្ជាក់ (Confirmation) នៅពេលជាក់លាក់ដោយឈ្មួញជើងសារមូលបត្រ។

### ខការបញ្ជាឲ្យបិទឬបើកការជួញដូរ . (On the Open or Close)

បញ្ជាប្រភេទនេះ តែងត្រូវបានប្រើនៅពេលទីផ្សាររំលងអធ្រាត្រ (Overnight Market) បង្ហាញពីការប្រែប្រួលនៅក្នុងទីផ្សារក្នុងស្រុក។ ការបញ្ជាឲ្យបិទការជួញដូរ គឺជាបញ្ជាតាមទីផ្សារ (Market Orders) ប៉ុន្តែការបញ្ជាឲ្យមានការជួញដូរ អាចជាការបញ្ជាតាមទីផ្សារ (Market Orders) ឬការបញ្ជាមានកំណត់ (Limit Orders)។ ការបញ្ជាឲ្យបើកឬបិទការជួញដូរភាគច្រើនត្រូវបានប្រើដោយអ្នកជួញដូរប្រកបដោយវិជ្ជាជីវៈ (Professional Traders)។ ឧទាហរណ៍អ្នកជួញដូរក្នុងថ្ងៃ : តែងតែបញ្ជាឲ្យបិទការជួញដូរទាំងអស់នៅចុងបញ្ចប់នៅថ្ងៃជួញដូរនីមួយៗ។

### គ. បញ្ជា Fill or Kill និងបញ្ជា All or None

បញ្ជា Fill or Kill orders គឺជាការបញ្ជាភ្លាមៗសម្រាប់បញ្ជាទាំងមូល។ ឧទាហរណ៍វិនិយោគ : កនបញ្ជាទិញភាគហ៊ុនATC ២,០០០ នៅថ្លៃ ១៤ដុល្លារ។ មានន័យថាឈ្មួញជើងសារមូលបត្រត្រូវ

ស្វែងរកមូលបត្រទង ២,០០០ នៅថ្លៃ ១៤ដុល្លារ ឲ្យបានភ្លាមៗ បើមិនបានទេមានន័យថា ការផ្គូផ្គង មិនបានសម្រេច នឹងមិនត្រូវបានប្រតិបត្តិឡើយ។

បញ្ជា All or None orders គឺជាការបញ្ជាដូចគ្នាប៉ុន្តែមានពេលច្រើនជាង។ ប្រសិនបើ ការបញ្ជាមិនអាចផ្គូផ្គងបានភ្លាមៗពីអ្នកម្នាក់ ឈ្មួញជើងសារមូលបត្រមានពេលវេលាបន្ថែមដើម្បីព្យាយាមផ្គូផ្គងបញ្ជាទាំងអស់ជាមួយអ្នកលក់ ពីរ ឬបីនាក់ ឬអ្នកលក់ដទៃទៀត។

### ឃ.ការបញ្ជាទំហំធំ (Sale Orders)

ការបញ្ជាទំហំធំ ជាធម្មតាត្រូវបានប្រើប្រាស់ដោយវិនិយោគិនជាស្ថាប័នដើម្បីទិញនៅលើទីផ្សារដែលកំពុងធ្លាក់ថ្លៃខ្លាំង ឬដើម្បីលក់នៅក្នុងទីផ្សារដែលកំពុងឡើងថ្លៃខ្លាំង។ ការបញ្ជានេះជួយឲ្យគេមិនចាប់អារម្មណ៍ទៅលើការជួញដូររបស់ពួកគេ។ វិនិយោគិននិងអាចបញ្ជាភាគហ៊ុន ATC ចំនួន ៣,០០០ នៅថ្លៃ ១៤ដុល្លារ នឹង ចំនួន ១,០០០ នៅរាល់ ១១២ដុល្លារ នៃថ្លៃ ៤/ (Each % to 12)។ ប្រសិនបើវាត្រូវបានប្រតិបត្តិទាំងអស់ មានន័យថាការបញ្ជាសរុបមានចំនួន ១១,០០០ ភាគហ៊ុន ព្រោះរាល់ការបញ្ជាដំបូងមាន ៣,០០០ បូក ១,០០០ ប្រាំបីដង ព្រោះនៅរាល់ ១ មាន ១៤ រហូតដល់ ១២ នៃថ្លៃ ៤/ ១២, ១២, ២៥១២ .,៥០១២ .,៧៥១៣ .,២៥១៣ .,៥០១៣ .,៧៥.។ ប្រសិនបើ មូលបត្រមិនធ្លាក់ថ្លៃដល់ ១៣ដុល្លារទេ ការបញ្ជាដែលនៅសល់មិនត្រូវបានប្រតិបត្តិទេ។

ការបញ្ជាទំហំធំ ត្រូវបានប្រើចំពោះការបញ្ជាដែលមានទឹកប្រាក់ច្រើនសន្ធឹកសន្ធាប់ ឬនៅក្នុងទីផ្សារតូចតាច ដើម្បីកឲ្យជះឥទ្ធិពលធ្ងន់ធ្ងរដល់មូលបត្រ ក៏ដូចជាយុទ្ធសាស្ត្រវិនិយោគមួយរបស់អ្នកជួញដូរ ដើម្បីបញ្ចៀសការរកឃើញរបស់វិនិយោគិនដទៃទៀតដែលអាចធ្វើឲ្យប៉ះពាល់ទៅដល់ថ្លៃមូលបត្រ។

### ង.ការបញ្ជាមានជម្រើស (Alternative Orders)

ការបញ្ជានេះជាទូទៅមានការពេញនិយមចំពោះអ្នកជួញដូរ Futures នឹង Options ដោយសារតែភាពប្រែប្រួលឆាប់រហ័សនៅក្នុងទីផ្សារនេះ។ ការបញ្ជាមានជម្រើសត្រូវបានគេហៅថា បញ្ជាតែមួយក្នុងចំណោមពីរ (Elther/ or Orders) ឬមួយលុបចោលមួយ (One Cancel the other-OCOs)។

ឧទាហរណ៍ វិនិយោគិនបានខ្ចីភាគហ៊ុន :ATC ១,០០០ លក់នៅថ្លៃ ១០ដុល្លារ ហើយថ្លៃនៅលើទីផ្សារបច្ចុប្បន្នគឺ ៩ដុល្លារ។ វិនិយោគិនបានកំណត់ថ្លៃគោលដៅគឺ ៨ដុល្លារ។ វាគឺជាថ្លៃដែលគាត់រំពឹងថានឹងធ្លាក់ចុះ ហើយគាត់នឹងទិញនៅថ្លៃនោះដើម្បីសងភាគហ៊ុនត្រឡប់ទៅវិញ។ វិនិយោគិនដាក់ជម្រើសការបញ្ជាដោយបញ្ជាទិញភាគហ៊ុន ATC ចំនួន ១០០ នៅថ្លៃកំណត់ ៨ដុល្លារ ឬបញ្ជាទិញភាគហ៊ុន ATC ចំនួន ១០០ ដដែលនៅពេលដែលឈប់ថ្លៃត្រង់ ១០០ ដុល្លារ។ វិនិយោគិនបានកំណត់ចន្លោះថ្លៃទីផ្សារបច្ចុប្បន្នជាងមួយនឹងការបញ្ជាពីរ គឺការបញ្ជាទិញមានកំណត់និងការបញ្ជាបញ្ឈប់ទិញ។ ប្រសិន បើថ្លៃភាគហ៊ុនATC ធ្លាក់ដល់៨ដុល្លា នោះបញ្ជាមានកំណត់នឹងត្រូវបានប្រតិបត្តិដោយ

ពេញលេញឯបញ្ជាបញ្ឈប់ទិញនិងត្រូវលុបចោល។ ផ្ទុយមកវិញប្រសិនបើថ្លៃភាគហ៊ុន ATC កើនដល់ ១០ដុល្លា នោះបញ្ជាបញ្ឈប់នឹងមានសុពលភាព ឯបញ្ជាមានកំណត់នឹងត្រូវលុបចោល។

**គ. ការបញ្ជាធន្ទានុសិទ្ធិ** (Discretionary Orders)

ជាទូទៅ ការបញ្ជាធន្ទានុសិទ្ធិមិនត្រូវបានប្រើប្រាស់ដោយវិនិយោគិនជាបុគ្គលឬអ្នកលក់រាយនោះទេ។ ការបញ្ជាប្រភេទនេះផ្តល់សិទ្ធិទូលំទូលាយដល់ឈ្មួញជើងសាមូលបត្រក្នុងការផ្គូផ្គងការបញ្ជា។ ការបញ្ជាប្រភេទនេះផ្តល់សិទ្ធិទូលំទូលាយដល់ឈ្មួញជើងសាមូលបត្រក្នុងការផ្គូផ្គងការបញ្ជា។ ចំពោះការបញ្ជាដែលផ្តល់ធន្ទានុសិទ្ធិពេញលេញ (Completely Discretionary Orders) ឈ្មួញជើងសាមូលបត្រអាចអនុញ្ញាតឲ្យជ្រើសរើសមូលបត្រ បរិមាណនិងថ្លៃដែលត្រូវបញ្ជាទិញ។ ចំពោះការបញ្ជាដែលដាក់កម្រិតជាងនេះ គឺវិនិយោគិននឹងកំណត់មូលបត្រ និងបរិមាណដោយខ្លួនឯង ហើយឲ្យឈ្មួញជើងសាមូលបត្រត្រូវសម្រេចចិត្តលើថ្លៃល្អបំផុតដែលត្រូវដាក់។ ក្នុងករណីវិនិយោគិនមិនយល់ស្របជាមួយជម្រើសរបស់ឈ្មួញជើងសាមូលបត្រ ពុំមានសិទ្ធិស្របច្បាប់ណាមួយដើម្បីទាមទារការទូទាត់សងការខាតបង់ឡើយ។

## ១១.២. ការជួញដូរតាម Margin (Margin Trading)

ការជួញដូរ Margin គឺជាការខ្ចីទ្រព្យ (សាច់ប្រាក់ ឬមូលបត្រ) ដើម្បីទទួលបានមូលបត្រ។ នៅក្នុងគណនីកម្ចីដើម្បីទិញ (Coming Margin Account) សាច់ប្រាក់ត្រូវបានខ្ចី។ នៅក្នុងគណនីដើម្បីលក់ (Short Margin Account) មូលបត្រត្រូវបានខ្ចី។ អ្នកខ្ចីត្រូវបានគេនិយាយថាប្រើប្រាស់បំណុល (Leverage) ដោយសាមូលធន ឬមូលបត្រផ្ទាល់ដែលអ្នកខ្ចីមានគឺគ្រាន់តែជាផ្នែកតូចមួយនៃចំនួនដែលត្រូវការពិតប្រាកដ។

ទឹកប្រាក់ប៉ុន្មានដែលវិនិយោគិនត្រូវមាន និងលក្ខខណ្ឌផ្សេងទៀតដើម្បីអាចខ្ចីបាន ត្រូវបានគ្រប់គ្រងដោយច្បាប់ និងបទប្បញ្ញត្តិនៅក្នុងប្រទេសនីមួយៗ ឬទីផ្សារមូលបត្រផ្ទាល់។ លក្ខខណ្ឌតម្រូវទាំងនោះរួមបញ្ចូលផងដែរនូវទ្រព្យសកម្មសុទ្ធអប្បបរមា (Minimum Net Worth Asset) និងកម្រិតសន្ទនីយភាព (Liquidity Level) របស់វិនិយោគិន។ គោលបំណងជាចម្បង នៃលក្ខខណ្ឌតម្រូវសម្រាប់ការជួញដូរតាមរយៈការខ្ចីនេះ គឺដើម្បីដាក់កំហិតទៅលើការកេងយកចំណេញ (Speculation) ជាជាងដើម្បីការពារវិនិយោគិន។

### ១១.២.១. ការទិញ (purchases)

កម្ចីសម្រាប់ទិញ គឺស្រដៀងទៅនឹងកម្ចីទិញរថយន្ត ឬទិញគេហដ្ឋានដែរ។ ការខ្ចីនេះអាចធ្វើឲ្យវិនិយោគិនអាចទិញមូលបត្របានច្រើន ប្រសិនបើគេតម្រូវឲ្យទូទាត់ជាសាច់ប្រាក់ទាំងអស់។ មិនដូចជាការខ្ចីមូលបត្រទេ ការប្រាក់ត្រូវបានគិតលើគណនីកម្ចីសម្រាប់ទិញ ហើយកម្រៃជើងសា ត្រូវបានបង់ទៅតាមតម្លៃពេញនៃការបញ្ជា។ វិនិយោគិនដាក់មូលបត្រជាវត្ថុតំកល់ធានាសម្រាប់ទូទាត់ប្រាក់កម្ចីវាដូចជាអ្នកទិញដាក់រថយន្ត ឬគេហដ្ឋានជាវត្ថុតំកល់ធានាដែរ។

ប្រសិនបើយើងសន្មតថា ច្បាប់កំណត់ឲ្យមានទឹកប្រាក់ផ្ទាល់ខ្លួនត្រឹមតែ៥០នៃថ្លៃជួញដូរ% សរុប (50% Margin) ដូច្នេះ វិនិយោគិនម្នាក់ អាចទិញមូលបត្របានស្មើនឹងចំនួនពីរដងនៃទឹកប្រាក់ដែរខ្លួនមាន ក្នុងករណីតម្រូវឲ្យទូទាត់ជាសាច់ប្រាក់ទាំងអស់។ ប្រសិនបើ វិនិយោគិនគិតបានត្រឹមត្រូវ ហើយមូលបត្រនោះឡើងថ្លៃ វិនិយោគិននិងទទួលបានប្រាក់ចំណេញទ្វេដង។ ប៉ុន្តែ ប្រសិនបើវិនិយោគិនគិតខុសគាត់នឹងខាតបង់ទ្វេដងផងដែរ។ ប្រសិនបើ មូលបត្រត្រូវបានទិញរយៈពេល Margin ចាប់ផ្តើមធ្លាក់ថ្លៃ វិនិយោគិនអាចត្រូវបានតម្រូវឲ្យអនុវត្ត Margin Call។ វាមានន័យថា តម្លៃរបស់មូលបត្រដែលបានដាក់ជាវត្ថុតំកល់ធានាបានធ្លាក់ថ្លៃក្រោមកម្រិត Margin។ ក្នុងឧទាហរណ៍ខាងលើ នៅពេលដែលកម្រិត Margin លើសពី ៥០% (ឬក៏តម្លៃមូលបត្រធ្លាក់ចុះទាបជាង ៥០%) គណនីនោះមិនអាចធានាបានទៀតទេ ហើយវិនិយោគិននឹងត្រូវបានតម្រូវឲ្យបន្ថែមសាច់ប្រាក់ដើម្បីធ្វើឲ្យគណនីនោះត្រឡប់ស្ថិតនៅក្នុង Margin វិញ។ នៅពេលដែលវិនិយោគិនមិនអាចបំពេញ Margin Call បានដោយសារខ្វះសាច់ប្រាក់ មូលបត្រនឹងត្រូវលក់ដើម្បីទូទាត់កម្ចី។

### ១១.២.២. ការខ្ចីមូលបត្រលក់ក្នុងរយៈពេលខ្លី (Short Sales)

ដូចដែលបានលើកឡើងខាងលើ ការខ្ចីមូលបត្រលក់រយៈពេលខ្លី គឺជាការលក់មូលបត្រដែលមិនមាននៅក្នុងដៃរបស់អ្នកលក់នៅពេលមានអ្នកទិញ។ អ្នកលក់នឹងខ្ចីមូលបត្រ ពីអ្នកដ៏ទៃដើម្បីលក់បន្ត ការធ្វើបែបនេះ ជាអំពើល្មើសនឹងច្បាប់នៅក្នុងប្រទេសមួយចំនួន។ អ្នកខ្ចីមូលបត្រលក់រយៈពេលខ្លីសង្ឃឹមថាថ្លៃនៃមូលបត្រទាំងនេះនឹងធ្លាក់ចុះ ដូច្នេះ មូលបត្រអាចត្រូវបានទិញវិញក្នុងតម្លៃទាបជាងដើម្បីសងត្រឡប់ទៅវិញ។ ការខ្ចីមូលបត្រលក់រយៈពេលខ្លី ជារឿយៗ ត្រូវបានប្រើដោយវិនិយោគិនប្រកបដោយវិជ្ជាជីវៈខ្ពស់ព្រោះទាមទារនៅការវិភាគ និងការព្យាករណ៍យ៉ាងសុក្រឹតមួយ។ ការខ្ចីមូលបត្រលក់រយៈពេលខ្លីក៏ត្រូវបានប្រើផងដែរ នៅពេលដែលវិនិយោគិនជាបុគ្គលជួញដូរដោយប្រើប្រាស់គណនី Margin ដោយសាមូលបត្រទាំងនេះមិនមែនជាកម្មសិទ្ធិរបស់វិនិយោគិន ប៉ុន្តែត្រូវខ្ចីពីក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ។ គណនី Margin ជាទូទៅ ត្រូវបានតម្រូវឲ្យបើកសម្រាប់ការខ្ចីមូលបត្រលក់រយៈពេលខ្លី។ មូលបត្រត្រូវបានខ្ចីពីក្រុមហ៊ុនឈ្មួញជើងសាមូលបត្រខ្លួនឯងផ្ទាល់ ឬពីអតិថិជនរបស់ឈ្មួញជើងសាមូលបត្រដែលយល់ព្រមឲ្យខ្ចីមូលបត្រក្នុងគណនីរបស់ពួកគេ។ វិនិយោគិនមួយ ខ្ចីមូលបត្រលក់រយៈពេលខ្លី ត្រូវតែបំពេញលក្ខខណ្ឌតម្រូវ Margin ដូចក្នុងករណីពេលមូលបត្រត្រូវបានទិញដែរ។ ប្រាក់តម្កល់នេះបូកនឹងសាច់ប្រាក់ទទួលបានពីការលក់បង្កើតឲ្យមានសមតុល្យវិជ្ជមាន (Credit Balance) នៅក្នុងគណនីខ្ចីមូលបត្រលក់រយៈពេលខ្លី (Short Margin Account) ប្រាសមកវិញមានសមតុយ្យអវិជ្ជមាន (Credit Balance) នៅក្នុងគណនីកម្ចីទិញមូលបត្រ (Long Margin Account)។ ដោយសារគ្មានសាច់ប្រាក់ត្រូវខ្ចី ដូចនេះគ្មានការគិតការប្រាក់ឡើយ។ ការខ្ចីមូលបត្រលក់រយៈពេលខ្លី (Short Position) មានហានិភ័យខ្ពស់ជាងកម្ចីទិញមូលបត្រ (Long Position)។ ចំពោះកម្ចីទិញមូលបត្រ ការខាតបង់អតិបរមាគឺត្រឹមតែតម្លៃនៃមូលបត្រដែលបានប្រែប្រួលតែប៉ុណ្ណោះ។ ដូចដែលបានលើកឡើង ខាងដើម ការខាតបង់អតិបរមាអាចមិនកើតមានឡើង ដោយសារការតម្រូវឲ្យបង្គ្រប់

Margin ដែលខ្វះ (A Missed Margin Call) អាចនឹងធ្វើឲ្យកើតមានសន្ទនីយភាពនៃការកាន់កាប់មូលបត្រ និងការបង់ប្រាក់ដើម្បីបង្គ្រប់ Margin Call។ ក្នុងការខ្ចីមូលបត្រលក់រយៈពេលខ្លី វិនិយោគិនជំពាក់មូលបត្រ មិនមែនសាច់ប្រាក់ទេហើយកម្រិតនៃការខាតបង់នេះគឺជាថ្លៃនៃមូលបត្រដែលត្រូវទិញសងត្រឡប់ទៅវិញ។ ក្នុងន័យនេះ គណនីកម្ចី មូលបត្រលក់រយៈពេលខ្លី (Short Margin Accounts) តែងតែមានកម្រិតប្រាក់ចំណេញ (Margin Limit) ទាបជាងគណនីកម្ចីសម្រាប់ទិញមូលបត្រ។

### ១១.២.៣. មូលបត្រអនាគត (Futures)

រាល់ការជួញដូរមូលបត្រអនាគត (Futures) ត្រូវធ្វើឡើងតាមរយៈ Margin ហើយកម្រិតនៃ Margin (ទឹកប្រាក់ដែលត្រូវមានដើម្បីអាចជួញដូរបាន) មានទំហំទាប (ប្រមាណតែ៥ប៉ុណ្ណោះ%)។ គ្មានទឹកប្រាក់ត្រូវបានខ្ចីទេ ហើយក៏គ្មានម្ចាស់បំណុល និងកូនបំណុលដែរ គឺអាស្រ័យលើបទប្បញ្ញត្តិនៃប្រទេសនីមួយៗ ប៉ុន្តែអាចមានកំណត់ពីដំណោះស្រាយតាមផ្លូវច្បាប់ ក្នុងការប្រមូលប្រាក់ទូទាត់លើកិច្ចសន្យាអនាគត។ ប្រសិនបើមានម្ចាស់បំណុល និងកូនបំណុលទេបទប្បញ្ញត្តិស្តីពីការប្រមូលប្រាក់ទូទាត់ក៏មិនត្រូវបានអនុវត្តដែរ។ ការដាក់ប្រាក់តម្កល់អាចជាសាច់ប្រាក់ ឬមូលបត្រដែលមានការប្រាក់ (Interest Bearing Securities) ដូចជា បណ្ណរតនាគារ (T-Bills) ជាដើម។

នៅពេលបិទទីផ្សារនៅរៀងរាល់ថ្ងៃជួញដូរ គ្រប់គណនីទាំងអស់ត្រូវបានកែតម្រូវទៅតាមទីផ្សារ (Marked to the Market) មានន័យថាសមតុល្យនៅក្នុងគណនីនីមួយៗត្រូវបានដាក់តម្លៃ (Priced) ដោយថ្លៃទីផ្សារ (Market Value)។ គណនីកម្ចីសម្រាប់ទិញមូលបត្រ និងគណនីខ្ចីមូលបត្រលក់មានទំនាក់ទំនងផ្ទុយគ្នាជាមួយថ្លៃទីផ្សារគឺមានន័យថាប្រសិនបើមូលបត្រឡើងថ្លៃគណនីកម្ចីសម្រាប់ទំនិញមូលបត្រនឹងកើនវិជ្ជមាន (Credited) ឯគណនីខ្ចីមូលបត្រលក់នឹងត្រូវបានកាត់បន្ថយ (Debited)។

លក្ខខណ្ឌតម្រូវទឹកប្រាក់ដែលត្រូវមានក្នុងការជួញដូរទាប (Low Margin Requirement) គឺជាកត្តាទាក់ទាញបំផុតសម្រាប់ទីផ្សារមូលបត្រអនាគត ពីព្រោះពួកគេផ្តល់កម្រិតនៃការផ្តល់កម្ចីខ្ពស់បំផុត (Highest Leverage) ទៅឲ្យមូលបត្រទាំងឡាយ។ ហានិភ័យជាប់ជាមួយ (Inherent Risk) នៃគណនីMargin និង លក្ខខណ្ឌតម្រូវទឹកប្រាក់ដែលត្រូវមាន ក្នុងការជួញដូរទាប (Low Margin Requirement) សម្រាប់ពេលអនាគត គឺជាហេតុផលពីរដែលធ្វើឲ្យការវិនិយោគិនលើមូលបត្រអនាគត មានហានិភ័យខ្ពស់។ ឧទាហរណ៍៖ សន្មតថាទឹកប្រាក់ដែលមានក្នុងដៃសម្រាប់ជួញដូរមូលបត្រអនាគតនៃសញ្ញាបណ្ណគឺ៥,០០០ដុល្លារ ប្រសិនបើ ទឹកប្រាក់នេះអាចជួញដូរជាក់ស្តែងបានសញ្ញាបណ្ណស្មើនឹង១០០,០០០ដុល្លារនោះថ្លៃ១ចំណុច ឬ១នៃតម្លៃចារឹក% (១០០,០០០) គឺស្មើនឹង ១,០០០ដុល្លា (១,០០០,០០០ដុល្លា១១០០/)។ ប្រសិនបើ ថ្លៃទីផ្សារធ្លាក់១ចំណុចអ្នកជួញដូរនឹងខាតបង់១,០០០ដុល្លា នៃទឹកប្រាក់៥,០០០ ដុល្លារ ដែលបានវិនិយោគ ឬស្មើនឹង២០នៃទឹកប្រាក់វិនិ% យោគសរុបចំពោះការធ្លាក់ថ្លៃ១%នៃតម្លៃចារឹករបស់មូលបត្រ។

## ១១.៣.ការឲ្យខ្ចីមូលបត្រ (Securities Lending)

ការឲ្យខ្ចីមូលបត្រ មិនមែនជាការជួញដូរតាមលក្ខណៈបច្ចេកទេសនោះទេ។ ភាគហ៊ុនអាចត្រូវបានខ្ចីពីវិនិយោគិនផ្សេងទៀតជាជាង ឈ្មួញជើងសាមូលបត្រ។ កិច្ចព្រមព្រៀងឲ្យខ្ចីត្រូវបានចុះហត្ថលេខាដោយវិនិយោគិនដែលបានអនុញ្ញាតឲ្យឈ្មួញជើងសាមូលបត្រខ្ចីភាគហ៊ុនពីគណនីរបស់ខ្លួន ទៅឲ្យវិនិយោគិនផ្សេងទៀតខ្ចីបន្ត។ ការឲ្យខ្ចីមូលបត្រ គឺជាវិធីមួយដែលអាចស្វែងរកប្រាក់ចំណេញពីមូលបត្រ ហើយដែលតែងតែធ្វើឡើងដោយវិនិយោគិនជាស្ថាប័នដែលមានភាគហ៊ុនយ៉ាងច្រើនតែមិនសូវធ្វើការជួញដូរ។ ការឲ្យខ្ចីមូលបត្រក៏ផ្តល់ប្រាក់ចំណេញទៅឲ្យឈ្មួញជើងសាមូលបត្រដែរ។ កម្ចីនេះ តម្រូវឲ្យដាក់សាច់ប្រាក់តម្កល់ស្មើនឹងថ្លៃទីផ្សារមូលបត្រដែលបានខ្ចី។ កម្ចីនេះត្រូវបានកែតម្រូវជាមួយថ្លៃទីផ្សារ (Marked-to-Market) (តម្លៃនៃកម្ចីត្រូវធៀបទៅនឹងតម្លៃនៃភាគហ៊ុននៅលើទីផ្សារ)។ ប្រសិនបើថ្លៃភាគហ៊ុនកើនឡើង អ្នកខ្ចីត្រូវតែដាក់ប្រាក់បន្ថែមឲ្យស្មើគ្នាវិញ។ ប្រសិនបើថ្លៃភាគហ៊ុនធ្លាក់ចុះវិញ សាច់ប្រាក់នឹងត្រូវដកយកទៅដាក់នៅក្នុងគណនីអ្នកខ្ចីវិញ។ សាច់ប្រាក់នេះ បង្ហាញថាវាជាកម្ចីដែលមានការប្រាក់សម្រាប់ឈ្មួញជើងសាមូលបត្រដែលវិនិយោគលើមូលបត្ររយៈពេលខ្លីក្នុងរយៈពេលនៃកម្ចី។

វិនិយោគិនមិនត្រូវបានគិតការប្រាក់ទៅលើកម្ចីនេះទេ ហើយវិនិយោគិនក៏មានត្រូវបានចំណេញពីការវិនិយោគរយៈពេលខ្លីដែរ។ ឈ្មួញជើងសាមូលបត្រជាអ្នកទទួលបានប្រាក់ចំណេញ។ វិនិយោគិនជាស្ថាប័នធំៗដែលយល់ច្បាស់ពីកិច្ចព្រមព្រៀងនេះ ចាប់ផ្តើមស្នើសុំឲ្យមានការបែងចែកប្រាក់ចំណេញនេះជាមួលឈ្មួញជើងសាមូលបត្រ តាមរយៈការចរចា ឬការព្រមព្រៀងបែបណាមួយ។ ភាគលាភសម្រាប់ភាគហ៊ុនដែលបានខ្ចី ត្រូវបានគិតទៅឲ្យអ្នកខ្ចីយកទៅលក់ (Short Seller) បន្ទាប់មកផ្ទេរទៅឲ្យម្ចាស់ដើមវិញ គឺអ្នកដែលបានឲ្យខ្ចី (Lenders)។ អ្នកឲ្យខ្ចីអាទាមទាររកសិទ្ធិក្នុងការបោះឆ្នោតរបស់មូលបត្រដែលបានឲ្យខ្ចី។ ប្រសិនបើវាកើតឡើង ដោយយោងទៅតាមទ្រឹស្តី ឈ្មួញជើងសាមូលបត្រត្រូវទាមទារមូលបត្រពីអ្នកខ្ចីត្រឡប់មកវិញ ហើយការខ្ចីនោះក៏ត្រូវបានបញ្ចប់។ ក្នុងការអនុវត្តជាក់ស្តែង អ្នកសុំខ្ចីគ្រាន់តែប្តូរមូលបត្រនោះជាមួយមូលបត្ររបស់អ្នកឲ្យខ្ចីណាដែលមិនទាមទារសិទ្ធិក្នុងការបោះឆ្នោត ឬផ្តល់សិទ្ធិប្រទាន (Prow) ក្នុងការបោះឆ្នោត។ សិទ្ធិប្រទាន (Proxy) គឺជាឯកសារមួយដែលផ្តល់សិទ្ធិឲ្យអ្នកដែលកាន់កាប់ឯកសារនេះបោះឆ្នោះក្នុងនាមជាម្ចាស់កម្មសិទ្ធិលើមូលបត្រនោះ។

## ១១.៤. ការកេងយកចំណេញ (Arbitrage)

ការកេងយកចំណេញ គឺជាការទិញហើយលក់វិញភ្លាមៗ ឬក្រោយមួយរយៈពេលខ្លីនូវមូលបត្រដែលដូចគ្នា ឬប្រហាក់ប្រហែលគ្នាដើម្បីទាញយកចំណេញពីតម្លៃលម្អៀងគ្នា (Price Discrepancies) នៃការទិញនិងលក់ដែលគេរំពឹងថាមិនអាចទៅរួច ហើយជាទូទៅវាពាក់ព័ន្ធទៅនឹងភាពខុសគ្នារវាងមូលបត្រ និងឧបករណ៍និស្សន្ទនៃមូលបត្រ (Derivative of Securities)។ ការកេងយកចំណេញភាគច្រើនធ្វើឡើងដោយវិនិយោគិនប្រកបដោយវិជ្ជាជីវៈ និងវិនិយោគិនជាស្ថាប័ន។ មាន

វិធីសាស្ត្រជាច្រើនក្នុងការកេងចំណេញពីមូលបត្រ ដែលវិធីសាស្ត្រទាំងអស់នេះមិនបានលាតត្រដាងនៅក្នុងសៀវភៅនេះទេ។ យើងនឹងបង្ហាញតែវិធីសាស្ត្រមួយចំនួនដែលសាមញ្ញនិងមានលក្ខណៈទូទៅបំផុត។

### ១១.៤.១. ការកេងយកចំណេញលើមូលបត្រ (Securities Arbitrage)

មូលបត្រដែលអាចប្តូរទៅជាភាគហ៊ុនបាន (Convertible Securities), Options, និង Warrants ផ្តល់ឱកាសឲ្យអ្នកកេងយកចំណេញបានតាមរយៈការខ្ចីមូលបត្រលក់រយៈពេលខ្លី។ តួយ៉ាងសញ្ញាបណ្ណដែលអាចប្តូរទៅជាភាគហ៊ុនបាន (Convertible Bands) អាចនឹងលក់នៅក្នុងតម្លៃថោកជាតម្លៃភាគហ៊ុនសរុបដែលវាប្តូរបាននោះ។ បើដូច្នេះមែន អ្នកកេងយកចំណេញ (Arbitrageur) នឹងខ្ចីភាគហ៊ុននោះមកលក់ (Short Sales) ហើយទិញយកសញ្ញាបណ្ណ បន្ទាប់មកប្តូរវាទៅជាភាគហ៊ុនដើម្បីសងត្រឡប់ទៅវិញ។ គម្លាតរវាងថ្លៃសញ្ញាបណ្ណ និងថ្លៃភាគហ៊ុនដែលបានខ្ចីគឺជាប្រាក់ចំណេញ។

### ១១.៤.២. ការកេងយកចំណេញលើសន្ទស្សន៍ (Index Arbitrage)

នៅពេលដែលអ្នកកេងយកចំណេញជឿថា កិច្ចសន្យាអនាគតលើសន្ទស្សន៍ (Index) មួយមានតម្លៃថោកដោយសារតែតម្លៃនៃភាគហ៊ុននៅលើសន្ទស្សន៍នោះ អ្នកកេងយកចំណេញនឹងខ្ចីមូលបត្រនោះលក់ ហើយទិញកិច្ចសន្យាអនាគតលើសន្ទស្សន៍នោះ។ នៅថ្ងៃផុតកំណត់នៃកិច្ចសន្យាអនាគត គម្លាតថ្លៃរវាងតម្លៃភាគហ៊ុន និងតម្លៃសន្ទស្សន៍នឹងលេចចេញ។ ប្រសិនបើថ្ងៃកើនឡើង មូលបត្រអនាគតនឹងកើនឡើងលឿនជាងភាគហ៊ុនពិតប្រាកដ ប៉ុន្តែបើធ្លាក់ចុះ ភាគហ៊ុននឹងធ្លាក់ចុះលឿនជាងឧបករណ៍អនាគត។ ក្នុងករណីណាក៏ដោយ ក៏វិនិយោគិនអាចធានាបាននូវប្រាក់ចំណេញដែរ។

### ១១.៤.៣. ការកេងយកចំណេញពីហានិភ័យ (Risk Arbitrage)

វិធីសាស្ត្រនេះត្រូវបានគេប្រើនៅពេលគេប្រកាសដាក់ឲ្យដេញថ្លៃ។ ក្នុងការដាក់ឲ្យដេញថ្លៃភាគច្រើន ថ្លៃភាគហ៊ុននៃក្រុមហ៊ុនគោលដៅ នឹងកើនឡើងតាមរយៈការដេញថ្លៃ (ត្រូវចងចាំថាជាការដាក់ឲ្យដេញថ្លៃមួយធ្វើឡើងនៅថ្លៃខ្ពស់ជាងថ្លៃទីផ្សារបច្ចុប្បន្ន ដើម្បីឲ្យការដេញថ្លៃមានការទាក់ទាញ)។ ស្របពេលជាមួយគ្នានេះដែរ មូលបត្ររបស់អ្នកដែលដេញថ្លៃបាន អាចនឹងធ្លាក់ថ្លៃមកវិញដោយសារចំណោាយកើនឡើង (Cost) ឬការបញ្ចុះតម្លៃហ៊ុន (Stock Dilution)។ អ្នកកេងយកចំណេញអាចនឹងទិញភាគហ៊ុននៃក្រុមហ៊ុនគោលដៅ ហើយខ្ចីមូលបត្ររបស់ក្រុមហ៊ុនដែលនឹងអាចដេញថ្លៃបានលក់ថយៈពេលខ្លី។

## ១១.៥.ការផាត់ទាត់ (Clearing)

ការផាត់ទាត់ គឺជាដំណើរការនៃការប្រៀបធៀប (Comparing) ការជួញដូរមុនពេលទូទាត់ (Settlement)។ នៅពេលដែលការជួញដូរចប់សព្វគ្រប់នៅទីផ្សារមូលបត្រ ឬទីផ្សាររំលងបញ្ជា (OTC) ព័ត៌មានលម្អិតនៃការជួញដូរនឹងត្រូវបានរាយការណ៍ទៅផ្នែកទិញលក់នៃ ឈ្មួញជើងសាមូល-បត្រ (សម្រាប់ការទិញលក់-)។ ជាទូទៅ ផ្នែកលក់នៃក្រុមហ៊ុនមូលបត្រនីមួយៗ នឹងប្រៀបធៀប ឬផ្ទៀងផ្ទាត់ការបញ្ជាដោយកុំព្យូទ័រ។ ក្រោយពេលការផ្ទៀងផ្ទាត់ត្រូវបានបញ្ជាក់ (Confirmed) ឈ្មួញជើងសាមូលបត្រនីមួយៗនឹងត្រូវចេញលិខិតបញ្ជាក់នៃការបញ្ជាក់ទៅវិនិយោគិន។ លិខិតបញ្ជាក់ក៏បានបង្ហាញពីកាលបរិច្ឆេទទូទាត់ និងបរិមាណទឹកប្រាក់ដែលត្រូវទូទាត់ទៅកាន់វិនិយោគិន (ចំពោះការលក់) ឬឈ្មួញជើងសាមូលបត្រ (ចំពោះការទិញ)។ ការខកខានមិនបានទទួលលិខិតបញ្ជាក់ទាន់ពេលដើម្បីធ្វើការទូទាត់នៅកាលបរិច្ឆេទកំណត់មួយមិនអាចយកធ្វើជាហេតុផលក្នុងការខកខានមិនបានទូទាត់ នៅកាលបរិច្ឆេទកំណត់នោះឡើយ។ លើសពីនេះទៅទៀត ចំពោះការបញ្ជាតាមទីផ្សារ (Market orders) ការបញ្ជាភ្លាមៗផ្សេងៗទៀតដែលមិនអាចលក្ខណៈស្មុកស្មាញ (Immediate Non-complicated orders) ឈ្មួញជើងសាមូលបត្រអាចបញ្ជាក់ការប្រតិបត្តិ (Execution) នៃការជួញដូរពេលដែលវិនិយោគិនកំពុងនិយាយទូរស័ព្ទ ឬកំពុង Online ជាមួយភ្លាមៗ ឬ ឈ្មួញជើងសាមូលបត្រអាចទូរស័ព្ទត្រឡប់ទៅវិញដើម្បីបញ្ជាក់ក្រោយពេលការបញ្ជាត្រូវបានប្រតិបត្តិក៏បាន។ មានតែសមតុល្យសុរុបត្រូវ ឬទទួល ឈ្មួញជើងសាមូលបត្រនៅចុងបញ្ចប់នៃជួញដូរ។ ដូចនេះ បរិមាណទិញ និងលក់មូលបត្រសរុបនឹងត្រូវនឹងត្រូវបានដកចេញពីគ្នា ហើយសមតុល្យទឹកប្រាក់ដែលត្រូវទទួលបាន ឬត្រូវជំពាក់នឹងត្រូវបានកាត់កង (Netted)។ ដំណើរការនៃការកាត់កងនេះ ត្រូវបានហៅថា ការផាត់ទាត់ (Clearing)។ ប្រសិនបើមិនមានការផាត់ទាត់ទេ ការជួញដូរនីមួយៗនឹងត្រូវកាត់កងដាច់ដោយឡែកពីគ្នា។ ឧទាហរណ៍៖ បើគ្មានប្រព័ន្ធផាត់ទាត់ នៅពេលឈ្មួញជើងសាមូលបត្រតំណាងឲ្យអ្នកលក់បញ្ជូនមូលបត្រទៅឲ្យឈ្មួញជើងសាមូលបត្រ តំណាងឲ្យអ្នកទិញ អ្នកបញ្ជូលមូលបត្រនឹងទាមទារការទូទាត់ជាសាច់ប្រាក់ភ្លាមៗ ព្រោះកម្មសិទ្ធិនៃមូលបត្រត្រូវបានផ្ទេរនៅពេលបញ្ចូល ឬចែកចាយមូលបត្រ (Deliver)។ ក្នុងករណី ឈ្មួញជើងសាមូលបត្រដែលមានការជួញដូររាប់សិបពាន់ប្រតិបត្តិការក្នុងមួយថ្ងៃ នោះប្រហែលជាត្រូវទាមទារឲ្យមានឯកសារ ទឹកប្រាក់ និងអ្នកបញ្ជូលមូលបត្រគរដូចភ្នំហើយបើឈ្មួញជើងសាមូលបត្រទាំងនោះស្ថិតនៅឆ្ងាយពីគ្នាទៀត តើវានឹងទៅជាយ៉ាងណា វាប្រាកដជាមិនអាចធ្វើទៅរួចទេចំពោះទីតាំងឆ្ងាយពីគ្នា នឹងឆ្លងប្រទេសនោះ។

ដូច្នេះហើយទើបគេបង្កើតប្រព័ន្ធផាត់ទាត់នេះឡើងដែលធ្វើប្រតិបត្តិការ (Operated) ដោយប្រតិបត្តិករផាត់ទាត់ (Clearing Houses)។ បទប្បញ្ញត្តិស្ដីពីការផាត់ទាត់ និងប្រតិបត្តិករផាត់ទាត់។ ឧទាហរណ៍៖ ប្រទេសហ្វីលីពីន មានប្រតិបត្តិករផាត់ទាត់កណ្តាល (Central Clearing House) ចំនួនពីរ ដែលប្រតិបត្តិករមួយសម្រាប់ផាត់ទាត់មូលបត្រ និងប្រតិបត្តិករមួយទៀតសម្រាប់ផាត់ទាត់សាច់ប្រាក់។ ប្រទេសភាគច្រើនមានប្រតិបត្តិករតែមួយទេ ដែលធ្វើប្រតិបត្តិការផាត់ទាត់ទាំងមូលបត្រ និងទាំងសាច់ប្រាក់។ ទោះបីជាយ៉ាងណាក៏ដោយ វាមានសុវត្ថិភាព ប្រសិនបើច្បាប់ទាំងអស់តម្រូវឲ្យ

ប្រតិបត្តិករផាត់ទាត់ត្រូវចុះបញ្ជី ហើយត្រូវមានមូលធនដែលត្រូវបង់ (Paid-in Capital)។ ច្បាប់របស់ប្រទេសចិនចែងថា ប្រតិបត្តិករផាត់ទាត់ត្រូវតែជាអង្គភាពមិនស្វែងរកប្រាក់ទៅក្នុងមូលនិធិផាត់ទាត់ (Clearing fund) ដើម្បីកាត់បន្ថយហានិភ័យនៃភាពមិនអាចទូទាត់ (Default Risk) របស់សមាជិក (ករណីនៅក្នុងប្រទេសមួយចំនួន)។

## ១១.៦. ការទូទាត់ (Settlement)

ការទូទាត់គឺជាដំណាក់កាលចុងបញ្ចប់នៃការជួញដូរដោយមូលបត្រ មូលនិធិ រឺទឹកប្រាក់ (Funds) ត្រូវបានបញ្ចូលរួច។ កាលបរិច្ឆេទូទៅគឺជាការបរិច្ឆេដែលមូលបត្រដែលបានលក់ត្រូវតែបានបញ្ចូលឬ មូលបត្រដែលបានទិញត្រូវបានបង់ប្រាក់រួចរាល់។ ការបញ្ចូល (Deliver) គឺជាការបំពេញឲ្យការជួញដូរ ឬប្រតិបត្តិការ (Transaction) ចប់សព្វគ្រប់ដោយមិនចាំបាច់ទាល់តែឃើញមូលបត្តឬសាច់ប្រាក់ត្រូវបានគណនាសមតុល្យដោយធ្វើឥណទានកម្ម (បូកបន្ថែម -Crediting) ឬការធ្វើឥណពន្ធកម្ម (ដកចេញ -Debiting) ពីគណនី។

ការលក់មូលបត្រដែលបានចុះបញ្ជីត្រូវចប់សព្វគ្រប់នៅកាលបរិច្ឆេតទទូទាត់ដោយធ្វើការផ្ទេរសិទ្ធិលើមូលបត្តពីអ្នកលក់ទៅអ្នកទិញនៅពេញបង់ប្រាក់។ ចន្លោះពេលរវាងការបរិច្ឆេតជួញដូរនិងកាលបរិច្ឆេតទូទាត់ត្រូវបានកំណត់ដោយច្បាប់និងបងប្បញត្តិនៅក្នុងប្រទេសនិមួយៗហើយអាស្រ័យទៅលើបច្ចេកវិទ្យានិងទំហំនៃមូលបត្រដែលបានជួញដូរ។ ការទូទាត់តែងត្រូវបានធ្វើឡើងនៅចន្លោះពី៣ទៅ៥ថ្ងៃបន្ទាប់ពីថ្ងៃជួញដូរ (T+ ឬ 3T+s)។ គេជឿថាចន្លោះពេលរវាងកាលបរិច្ឆេទជួញដូរនិងកាលបរិច្ឆេទទូទាត់កាន់តែខ្ពស់ (High liquidity) និងកម្រិតហានិភ័យទាបហេតុនេះហើយទើបគោលដៅរបស់សហគមន៍វិនិយោគអន្តរជាតិ (International Investing Community) គឺចង់ប្តូរទៅT+1 សម្រាប់ការទូទាត់គ្រប់ប្រតិបត្តិការជួញដូរទាំងអស់។

កាលបរិច្ឆេទទូទាត់ជាធម្មតាតំណាងដោយT+ រយះពេលរង់ចាំការទូទាត់។ ដូចនេះការទូទាត់នៅរយះពេលបីថ្ងៃក្រោយថ្ងៃជួញដូរត្រូវតំណាងដោយ T+ 3ដោយT មានន័យថាTrade Day˝ ថ្ងៃជួញដូរ˝។ កាលបរិច្ឆេទនេះសំដៅតែទៅលើថ្ងៃដែលទីផ្សារបើកឲ្យធ្វើអាជីវកម្មតែប៉ុណ្ណេះ។ ប្រសិនបើមានថ្ងៃឈប់សម្រាប់នៅចន្លោះថ្ងៃជួញដូរនិងថ្ងៃទូទាត់នោះមានថ្ងៃដែលទីផ្សារបើកទេដែលត្រូវបានរាប់បញ្ចូល។ ដូនច្នេះប្រសិនបើការជួញដូរកើតឡើងនៅថ្ងៃច័ន្ទហើយកាលបរិច្ឆេទទូទាត់គឺ T+មានន័នថា 4 កាលបរិច្ឆេទដែលត្រូវទូទាត់ថ្ងៃសុក្រ្។ តែប្រសិនបើមានថ្ងៃឈប់សម្រាក១ថ្ងៃនៅចន្លោះពេលនោះហើយទីផ្សារត្រូវបិទកាលបរិច្ឆេទដែលត្រូវទូទាត់ពិតប្រាកដគឺធ្វេ ីឡេ ីងនៅថ្ងៃច័ន្ទក្រោយ។ កាលបរិច្ឆេទជញដូរកេ ីតឡេ ីងនៅថ្ងៃច័ន្ទប៉ុន្តែដោយមានថ្ងៃឈប់សម្រាកនាំឲ្យការបរិច្ឆេទទូទាត់ទៅ T+ 4 ត្រូវរំកិលទៅថ្ងៃសោរ៏តែដោយទីផ្សារត្រូវបិទនៅថ្ងៃសោរ៏និងថ្ងៃអាទិត្យដូចនេះថ្ងៃបន្ទាប់ដែលទីផ្សារបើកគឺថ្ងៃច័ន្ទក្រោយ។

នីតិវិធីការទូទាត់ត្រូវបានកំណត់ដោយច្បាប់និងមានភាពខុសគ្នាទៅតាមប្រទេសនីមួយៗ ឧទាហរណ៍នៅក្នុងប្រទេសហ្វីលីពីន ប្រសិនប :េីមូលបត្រមិនបានបញ្ចូល (ចំពោះការលក់) ឬទឹកប្រាក់មិនត្រូវបានបង់ (ចំពោះការទិញ) នៅថ្ងៃទូទាត់ទេឈ្មួញជើងសារមូលបត្តនិងត្រូវទទួលខុសត្រូវ

ក្នុងការទូទាត់ការជួញដូររបស់ពួកគេនៅកាលបរិច្ឆេទកំណត់កម្រិតរកបានឈ្មួញជើងសាមូលបត្រដើម្បីប្រតិបត្តិការជួញដូរគេណាស់ហើយព័ត៌មានប្រភេទនេះផ្សព្វផ្សាយយ៉ាងលឿនពីក្រុមហ៊ុនមួយទៅក្រុមហ៊ុន។ ប្រទេសម៉ាឡេស៊ីមានបញ្ជីឈ្មោះអ្នកមិនទាន់ទូទាត់ការជួញដូរ (Defaulter's list) ដែលរក្សាទុកដោយឈ្មួញជើងសាមូលបត្រ។ ទៅក្នុងប្រទេសខ្លះមានការហាមឃាត់គណនីដែលមិនបានទូទាត់ពេលវេលា មិនឲ្យជួញដូរបានក្នុងរយៈពេលកំណត់មួយ។ ការកំណត់នេះអាចត្រូវបានដាក់ដោយ ឈ្មួញជើងសាមូលបត្រ ទីផ្សារមូលបត្រឬ ទីផ្សារក្រៅផ្លូវការឬដោយច្បាប់។

ប្រសិនបើអ្នកលក់មានសន្លឹកមូលបត្រ (Physical Securities) ពួកគេត្រូវបញ្ជូនវាទៅឲ្យឈ្មួញជើងសាមូលបត្រនៅកាលបរិច្ឆេទទូទាត់។ ទោះបីអ្នកទិញមិនមានសមតុល្យសាច់ប្រាក់ទៅក្នុងគណនីគ្រប់គ្រាន់ដើម្បីទូទាត់ការទិញក៏ទឹកប្រាក់ត្រូវតែបញ្ចូលទៅឈ្មួញជើងសាមូលបត្រឲ្យបាននៅកាលបរិច្ឆេទទូទាត់។ ប្រសិនបើអតិថិជនមានមូលបត្រ ឬសាច់ប្រាក់នៅក្នុងគណនីរបស់គាត់នៅកាលបរិច្ឆេទទូទាត់ជាធម្មតាឈ្មួញជើងមូលបត្រ និងធ្វើការដក ឬបូកបន្ថែមលើគណនីនោះ។ បញ្ហាក្នុងការបញ្ជូនវិញ្ញាបនបត្រនៅកាលបរិច្ឆេទទូទាត់គឺថាហេតុផលមួយទៀតដែលបង្ហាញថាហេតុអ្វីបានជាវាមានភាពងាយស្រួលជាងចំពោះឈ្មួញជើងសាមូលបត្រនិងអតិថិជនក្នុងការរក្សាសមតុល្យសាច់ប្រាក់នៅក្នុងគណនីហើយអនុញ្ញាតឲ្យឈ្មួញជើងសាមូលបត្ររក្សាទុកមូលបត្រជាជាងបញ្ជូនវិញមូលបត្រ (Certificates) ឬសន្លឹកមូលបត្រ (Script) ទៅឲ្យអ្នកទិញ។ មានទីតាំងដាក់ដោយឡែកៗក្រុមហ៊ុនខ្លះមិនធ្វើប្រតិបត្តិទូទាត់ដោយខ្លួនឯងទេគឺពួកគេជួលក្រុមហ៊ុនផ្សេងមួយទៀតដែលមានជំនាញក្នុងការទូទាត់ការជួញដូរនេះឲ្យធ្វើវាជំនួសពួកគេ។ ក្រុមហ៊ុនទាំងនេះជួនកាលគឺជាប្រតិបត្តិការទូទាត់ (Settlement Houses) ឬស្ថាប័នហិរញ្ញវត្ថុផ្សេងៗ។

ការជួញដូរត្រូវបានទូទាត់ដោយប្តូរឈ្មោះអ្នកលក់ចេញពីសៀវភៅ និងកំណត់ត្រារបស់ក្រុមហ៊ុនបោះផ្សេងលក់មូលបត្រជំនួសដោយឈ្មោះរបស់អ្នកទិញដែលជាកម្មសិទ្ធិករថ្មីៗ ប្រសិនបើអ្នកទិញចង់បានវិញ្ញាបនបត្រ វិញ្ញាបនបត្រថ្មីនិងត្រូវបោះពុម្ពឡើងដោយដាក់ឈ្មោះរបស់អ្នកទិញ។ នេះជាប្រតិបត្តិការរក្សាកំណត់ត្រាដែលគេឲ្យឈ្មោះថាការចុះបញ្ជីក្នុងសៀវភៅ (Book Entry) ព្រោះភស្តុតាងតែមួយគត់ដែលបង្ហាញពីកម្មសិទ្ធិករគឺការចុះបញ្ជីកម្មសិទ្ធិករថ្មីនៅក្នុងសៀវភៅវិញ្ញាបនបត្រមិនត្រូវបានបោះផ្សាយនោះទេ។

## ១១.៧. ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ (Transfer Agent)

ការចុះបញ្ជីផ្ទេរមូលបត្រ គឺជាដំណើរការដែលឈ្មោះកម្មសិទ្ធិករនៃមូលបត្រត្រូវប្តូរអ្នកលក់ទៅអ្នកទិញនិងត្រូវបានកត់ត្រាទុកត្រឹមត្រូវនៅក្នុងសៀវភៅបញ្ជីក្រុមហ៊ុន។ ដំណើរការអាចធ្វើឡើងដោយក្រុមហ៊ុនបោះផ្សាយលក់មូលបត្រដោយផ្ទាល់ឬ ដោយក្រុមហ៊ុនឬដោយភ្នាក់ងារដាច់ដោយឡែកដែលក្រុមហ៊ុនបោះផ្សាយលក់មូលបត្របានជួលដែលក្រុមហ៊ុននេះត្រូវបានគេហៅថាភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ (Transfer Agent)។

ក្នុងការបញ្ជូន ឬចែកចាយសន្លឹកមូលបត្រត្រូវបានការខ្នងដោយអ្នកលក់ (ដូចគ្នាទៅនឹងមូលទានបត្រដែរ) ហើយបន្ទាប់មកត្រូវបានបញ្ជូនទៅឲ្យឈ្នួញជើងសារមូលបត្ររបស់ភាគីអ្នកលក់ដែលត្រូវបញ្ជូនបន្តទៅឲ្យឈ្នួញជើងសារមូលបត្ររបស់ភាគីអ្នកទិញដែលនិងត្រូវបញ្ជូនបន្តទៅឲ្យភាគីអ្នកទិញ។

នៅផ្នែកខាងក្រោយនៃគ្រប់វិញ្ញាបនបត្រមូលបត្រដែលបានចុះបញ្ជីទាំងអស់មានសំណេរអក្សរពុម្ពមួយ (A Printed) ដែលគេឲ្យឈ្មោះថាការប្រគល់សិទ្ធិនិងអំណាចជំនួសទោះបីជមូលបត្រត្រូវបានបញ្ជូន ឬទឹកប្រាក់ត្រូវបានបង់មុនការបរិច្ឆេទទូទាត់ក៏ដោយក៏កាលបរិច្ឆេទទូទាត់ទៅតែជាT+កាលបរិច្ឆេទមួយៗប្រសិនបើអ្នកលក់មានមូលបត្រនៅក្នុងគណនីរបស់គាត់ហើយអ្នកទិញមានសាច់ប្រាក់នៅក្នុងគណនីមុនកាលបរិច្ឆេទទូទាត់ ការជួញដូរនៅតែត្រូវទូទាត់នៅកាលបរិច្ឆេទទូទាត់មិនមែននៅកាលបរិច្ឆេទជួញដូរទេ។

បណ្តាលប្រទេសនៅតែបោះពុម្ពជាសន្លឹកមូលបត្រអ្នកទិញមូលបត្រមានជម្រើសក្នុងការទូទាត់យកសន្លឹកមូលបត្រដោយទុកមូលបត្រនៅជាមួយឈ្នួញជើងសាមូលបត្រដោយដាក់ឈ្មោះខ្លួនឯង ឬមួយទុកមូលបត្រ។ ប្រសិនបើបុគ្គលម្នាក់ជួញដូរជាញឹកញាប់ ឬមិនចង់ទទួលខុសត្រូវលើការរក្សាទុកមូលបត្រដោយខ្លួនឯង ការទទួលយកជាសន្លឹកមូលបត្រមិនមែនជាជម្រើសល្អទេ។ ក្រៅពីអាចបាត់ ឬក៏ត្រូវចំណាយលើថ្លៃសេវារក្សាទុកមូលបត្រ (Depository) អ្នកជួញដូរនិងត្រូវរវល់ជាមួយការបញ្ជូននិងទទួលមូលបត្រចុះឡើងទៅ ឯឈ្នួញជើងសាមូលបត្រ។ ប្រសិនបើអ្នកទិញចង់ធ្វើដូច្នេះ ឈ្នួញជើងសាមូលបត្រនិងកត់ត្រាមូលបត្រនៅក្នុងសៀវភៅរបស់ក្រុមហ៊ុន (Books of Company) ដោយដាក់ឈ្មោះឈ្នួញជើងសាមូលបត្រហើយបញ្ជូនមូលបត្រទាំងនោះនៅក្នុងគណនីរបស់អ្នកទិញ នៅក្នុងកំណត់ត្រារបស់វា។ អ្នកទិញអាចមានបំណងធ្វើដូច្នេះដោយសាមូលហេតុជាច្រើនដូចជាមានភាពងាយស្រួលក្នុងការជួញដូរ និងការប្រើឈ្មោះអានាមិក។ ទម្រង់នៃភាពជាកម្មសិទ្ធិបែបនេះសម្រួលនូវការជួញដូរដោយសារមូលបត្រដែលបានចុះបញ្ជីដោយចាក់ឈ្មោះអ្នកទិញទោះបីជានៅទីណាក៏ដោយត្រូវតែការខ្នង (Endorsed) នៅពេលលក់ ដូចនេះឈ្នួញជើងសាមូលបត្រត្រូវតែកាន់វាយកទៅជាមួយ។ នៅពេលនោះឈ្នួញជើងសាមូលបត្រ និងកាត់មូលបត្ររបស់អតិថិជនកាន់តែច្រើនឡើងដោយប្រើឈ្មោះឈ្នួញជើងសាមូលបត្រ ហើយប្រទេសជាច្រើនដែលនៅប្រេ◌ីមូលបត្រក៏កំពុងព្យាយាមធ្វើការលុបបំបាត់ការអនុវត្តដូចនេះដែរ។

ការងារដាក់ស្តែងក្នុងការទទូត់ចំពោះការជួញដូរ គឺធ្វើឡើងដោយការិយាល័យប្រតិបត្តិការនៃឈ្នួញជើងសាមូលបត្រដែលជាទូទៅ គឺជាការិយាល័យខាងក្រោយ (Back office) ដោយសាវាមានទីតាំងនៅខាងក្រោយអគារដែលជាកន្លែងអតិថិជនមិនទៅទីនោះទេ។ ចំពោះក្រុមហ៊ុនធំៗដែលប្រើបច្ចេកវិទ្យាអេឡិចត្រូនិចគ្រប់ទីកន្លែង (Fully Automated) ការិយាល័យខាងរបាយការណ៍គណនេយ្យ គឺជាកំណតកត្រាកម្មសិទ្ធិតែមួយគត់ វិធីសាស្រ្តកត់ត្រចូលក្នុងសៀវភៅ គឺកាត់បន្ថយថ្លៃផ្ទេរ និងធ្វើឲ្យការបញ្ជូន និងការរក្សាទុកកាន់តែមានភាពងាតស្រួល និងសាមញ្ញ។

## ១១.៨.មូលបត្រដែលត្រូវបានលួច បាត់ឬ ខូចខាត

ប្រទេសដែលប្រើសន្លឹកមូលបត្រធ្វើការផ្តល់មូលបតហារសម្រាប់មូលបត្រដែលត្រូវបានលួចបាត់ ឬខូចខាត។ មូលបត្រណាដែលខូចខាតសញ្ញាណ អាចក្លាយទៅជាមូលបត្រមិនអាចជួញដូរបានហើយត្រូវប្តូថ្មី ដូចជានៅពេលដែលអ្នកទិញព្យាយាមកែអក្ខរាវិរុទ្ធឈ្មោះដែលបានសរសេរខុសនៅលើវិញ្ញាបនបត្រ ឬកែព័ត៍មានផ្សេងៗទៀត។ រាល់ការកែប្រែអត្តសញ្ញាណទៅលើវិញ្ញាបនបត្រ និងធ្វើឲ្យវិញ្ញាបនបត្រនោញមិនអាចជួញដូរដោយស្វ័យប្រវត្ត។

## ១១.៩.ភ្នាក់ងារបញ្ជីការមូលបត្រ

ក្រោយពេលភ្នាក់ងារចុះបញ្ជីការផ្ទេរមូលបត្រផ្ទេរកម្មសិទ្ធិនៃវិញ្ញាបនបត្រទៅឲ្យម្ចាស់ថ្មីគេនិងធ្វើវិញ្ញាបនបត្រចុះបញ្ជីនៃការផ្ទេរមូលបត្រ។ ភ្នាក់ងារបញ្ជីការមូលបត្រត្រូវពិនិត្យកំណត់ត្រារបស់ខ្លួនដើម្បីធានាថាចំនួនភាគហ៊ុនដែលសរសេរនៅក្នុងវិញ្ញាបនបត្រដូចគ្នាទីនឹងចំនួនភាគហ៊ុនដែលសរសេរនៅក្នុងវិញ្ញាបនបត្រចាសដែលបានលុបចោរនៅពេលវិញ្ញាបនបត្រមួយបានការខ្ទងត្រឹមត្រូវ និងត្រូវបានបញ្ជូនទៅបញ្ជីម្ចាស់ថ្មី ប៉ុន្តែការផ្ទេរមិនទាន់ត្រូវបានកត់ត្រានៅក្នុងសៀវភៅក្រុមហ៊ុនបោះផ្សាយលក់មូលបត្រទេ។

ចំពោះការផ្ទេរសិទ្ធិប្រទេសនេះ គ្មានវិញ្ញាបនបត្រត្រូវបានផ្ទេរពីអ្នកលក់ទៅអ្នកទិញនោះទេ។ ការផ្លាស់ប្តូរកម្មសិទ្ធិការត្រូវបានកតកត្រមូលបត្រក្នុងសៀវភៅក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាទូទៅដោយភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។ ការកត់ត្រ រួមមាន ឈ្មោះ និងអាសង្ហាយអចិន្ត្រៃយរបស់កម្មសិទ្ធិករ ចំនួនភាគហ៊ុន និងព័ត៍មានបញ្ជាក់អត្តសញ្ញាផ្សេងៗទៀតដូចជាលេខរបបសន្តិសុខសង្គម។ល។

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ អាចធ្វើជាភ្នាក់ងាររបញ្ជីការមូលបត្រដោយខ្លួនឯង ឬជួលក្រុមហ៊ុនពីខាងក្រៅឲ្យធ្វើការនេះឲ្យក៏បាន។ ជាធម្មតា ភ្នាក់ងារបញ្ជីការមូលបត្របំពេញការងារជូនក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ តាមរយៈកិច្ចសន្យាដែលបានរៀបចំរវាងក្រុមហ៊ុន និងភ្នាក់ងារ។

## ១១.១០. ប្រតិបត្តិការរក្សាមូលបត្រ

យើងធ្លាប់បាននិយាយថាឈ្មួញជើងសាមូលបត្រអាចកាន់មូបត្រដោយដាក់ឈ្មោះអតិថិជន ឬឈ្មោះរបស់ក្រុមហ៊ុនផ្ទាល់។ ប៉ុន្តែឈ្មួញជើងសាមូលបត្រជាធម្មតមិនរក្សាទុកមូលបត្រទាំងនេះនៅក្នុងក្រុមហ៊ុនឡើយ គឺពួកគេជួលសេវ ឬប្រតិបត្តិការរក្សាទុកមូលបត្រដើម្បីរក្សាទុកមូលបត្រទាំងនោះវិញ។

ប្រតិបត្តិការរក្សាទុកមូលបត្រកណ្តាល គឺជាកន្លែង ឬប្រព័ន្ធរក្សាទុករក្សាសុវត្ថភាព និងផ្ទៀងផ្ទាត់គណនីរបស់សមាជិក ប្រសិនបើវិញ្ញាបនបត្រ ឬកំណត់ត្រាត្រូវបានច្រើន។ ប្រតិបត្តិការរក្សាទុកមូលបត្រកណ្តាលរក្សាទុកមូលបត្រដែលខ្លួនកាន់កាប់នៅក្នុងឈ្មោះខ្លួនហើយមិនបញ្ជូនទៅអតិថិជនជាសន្លឹកមូលបត្រទេ។ ប្រសិនបើមូលប្រត្រូវបោះពុម្ពហើយកត់ត្រទុកនៅក្នុងសៀវភៅប្រតិបត្តិការរក្សា

ទុកមូលបត្រកណ្តាល គឺជាប្រព័ន្ធកុំព្យូទ័រដែលរក្សាទុកនូវការគណនាសមតុល្យក្នុងគណនីនីមួយៗរបស់ក្រុមហ៊ុនដែលជាសមាជិក។

នៅពេលភ្នាក់ងារផាត់ទាត់ធ្វើការផាត់ទាត់ការជួញដូរហើយគណនាសមតុល្យរបស់គណនីក្រុមហ៊ុនដែលជាសមាជិកនៅចុងបញ្ចប់នៃថ្ងៃជួញដូរមូលបត្រតែបានបញ្ជូនរួចរាល់ដូចនេះគណនីទាំងអស់មានសមតុល្យៗ ដូច្នេះនៅចុងបញ្ចប់នៃថ្ងៃជួញដូរភ្នាក់ងារផាត់ទាត់ និងជូនដំណឹងទៅប្រតិបត្តិការរក្សាទុកមូលបត្រកណ្តាលអំពីការប្រែប្រួលសមតុល្យគណនីរបស់សមាជិក ហើយប្រតិបត្តិកររក្សាទុកមូលបត្រកណ្តាលកែតម្រូវកំណត់ត្រាសមតុល្យគណីរបស់ពួកគេទៅតាមនោះ។ គណនីរបស់សមាជិកដែលជាក្រុមហ៊ុនមូលបត្រត្រូវបានកែតម្រូវស្របទៅតាមការជួញដូរប្រចាំថ្ងៃហើយគ្មាននណាម្នាក់បានប៉ះពាល់វិញ្ញាបនបត្តដោយផ្ទាល់ឡើយ។ ដំណើរទាំងមូលនៃការបញ្ជូនវិញ្ញាបនបត្រត្រូវធ្វើឡើងតាមរយះការធ្វើសមតុគណនីដោយអេឡិត្រូនិច។ ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រភ្នាក់ងារផាត់ទាត់មូលបត្រ និងទទួល ឬទាក់ទងកត់ត្រា និងធ្វើសមតុល្យគ្រប់ពេលវេលា នៃការជួញដូរទាំងមូល។

ជាប្រពៃណីមានតែសមាជិកដែលជាឈ្មួញជើងសាមូលបត្រ ឬពាណិជ្ជករមូលបត្រប៉ុណ្ណោះដែលអនុញ្ញាតប្រើគណនីនៅក្នុងប្រតិបត្តិការរក្សាទុកមូលបត្រកណ្តាល។ ដោយការប្រើប្រាស់កំណត់ត្រាបានបាត់ពីដំណើរការវិនិយោគគិតជាបុគ្គលត្រូវតែបើកគណនីឬគណនីរងនៅក្នុងប្រតិបត្តិការរក្សាទុកមូលបត្រកណ្តាលដែរ។

តាមការរំពឹងទុកបទប្បញ្ញាត្តិជាក់ស្តែងទាក់ទងនឹងការចុះបញ្ជីការផ្តល់អាជ្ញាប័ណ្ណលក្ខខណ្ឌតម្រូវមូលធន វិធានប្រតិបត្តិការ វិធានសមាជិកភាព។ ល។ នៃប្រតិបត្តិកររក្សាទុកមូលបត្រកណ្តាលនឹងត្រូវបានកំណត់ដោយច្បាប់ នៃប្រទេសនីមួយៗហើយអាចនិងមានភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយផ្សេងទៀត។

# បណ្ណាល័យសាស្ត្រ


Adam. J. 1985, Longman Concise Dictionary of Business English, Longman York Press. London.

Chhuon. C & Keo. S. 1996, Dictionary of Modern Economy English-Khmer. Phnom Penh.

Crede. A. 1995, Electronic Commerce and Banking Industry, Journal of Computer-mediated Communication. Vol 1. Issue 3.

David W. Pearce, 1986, The MIT Dictionary of Modern Economics, 3rd Edition, The MIT Press, Cambridge, Massachausetts.

Eiteman. K. 1995, Multinational Business Finance, 7th edition, Addison Wesley, New York.

http://corporate.visa.com/me/facts/corporate/transactions.shtml

http://www.asiaweek.com/asiaweek/features/financial500.2000/banks1-50.html

http://www.swift.com/index.html

MacCrimmon. K. 1998, Taking Risks: The Management of Uncertainly, 1st edition, Free Press, New York.

Rose. S. 1999. Commercial Bank Management, 4th edition. McGraw Hill. Boston

Sinkey. J. 1998, Commercial Bank Financial Management, 5th edition. Prentice Hall, Upper Saddle River. New Jersey.